
គុកនយោបាយ
ប៊ុណ្ណចន្ទ-ម៉ុល
បដិវត្តន៍ឆ្នាំ ២៤៨៥/១៩៤២
• គុកភ្នំពេញ
• គុកព្រៃនគរ
• គុកកោះត្រឡាច



រូបថតកាលនៅគុកធំភ្នំពេញ

ថតដោយមន្ទីរក្រុមព្រះនគរបាល ( ថ្ងៃទី ៦ សីហា ១៩៤២ )

# គុកនយោបាយ

អ្នកនិពន្ធ

**ប៊ុណ្ណចន្ទ ម៉ុល**

*ប្រធានពុទ្ធិកសមាគម សំណាក់ការវត្តឧណ្ណាលោម*
*វរសេនីយត្រីយ៍ឧត្តមមេបញ្ជាការជូនក្បួននឹងអភិបាល*

ផ្សាយចេញពីលំនៅលេខ៧៩

**វិថីអាចារ្យហែម ចៀវ**
(អតីតវិថីត្រសក់ផ្អែម)

**ភ្នំពេញ**

លំនៅ ២.៥៧៤៨
ទូរស័ព្ទ : {
ស្នាក់ការ ២.២៦០៥

**ព.ស.២៥១៤ គ.ស.១៩៧១**

រក្សាសិទ្ធិ

# អារម្ភកថា

រឿង **«តុភនយោបាយ»** ដែលអស់លោកអ្នកកំពុងកាន់អាននៅពេលនេះ នឹងថាជារឿង ផ្ទាល់ខ្លួនរបស់ខ្ញុំក៏ថាបាន ព្រោះខ្ញុំបានរាយរាប់ពីព្រឹត្តិការណ៍ទាំងឡាយដែលមានខ្ញុំនេះឯងជាអ្នកប្រឡូកផ្ទាល់ក្នុងព្រឹត្តិការណ៍ទាំងនោះផង ។

ប៉ុន្តែការសំខាន់បំផុត គឺត្រង់ការដែលអស់លោកអ្នកនឹងបានជ្រាបអំពីកិច្ចការរបស់វរជនយើងមួយក្រុមនោះទេវិញទេ ដែលផ្ដើមធ្វើការតស៊ូឡើងតាំងពីឆ្នាំ១៩៣៦ និងផ្ដើមបដិវត្តន៍ឡើងនៅឆ្នាំ៤៧មកទៀត ។ ពេលនោះយើងទាំងអស់គ្នាខិតខំធ្វើការតស៊ូដើម្បីរំដោះខ្លួនពីព្រ្យាណានិគមបារាំងយ៉ាងស្វិតស្វាញ ។

ហេតុដែលយើងរំលឹកឡើងវិញនូវអតីតកាលរបស់យើង ដែលស្ថិតនៅក្រោមការជិះជាន់របស់បរទេស ដ៏ពោរពេញដោយការឈឺចាប់ខ្លោចផ្សាទាំងផ្លូវចិត្ត ផ្លូវកាយមកលាតត្រដាងនៅគ្រានេះ គឺប្រយោជន៍ដើម្បីនឹងទាញសតិស្មារតីយុវជនយើងសម័យនេះ និងតទៅអនាគតឱ្យចេះមានចិត្តគិតរឿង**ជាតិ**គ្រប់ៗគ្នា ។ ឱ្យមានចិត្តគំនិតជាតិនិយមសតិសម្បជញ្ញៈជាតិ ស្រឡាញ់ទឹកដីខ្មែរ ,ពូជពង្សខ្មែរ,ប្រពៃណីខ្មែរ ,ឱ្យដួញចិត្តគិតពីរឿង**ជាតិខ្មែរ**នេះឱ្យបានស្មើៗគ្នាទាំងអស់ កុំឱ្យមួយប្រចាំមួយផ្ដេកវេរគ្នាឱ្យសោះ ។ ឱ្យមានចិត្តមុះមុត ក្លៀវក្លា រឹងប៉ឹង ស្វាហាប់ ,កុំឱ្យទន់ខ្សូរ ម្ងូរមុខ ញញាប់ញ័រ សស្លន់សស្លោឱ្យសោះ ! ត្រូវមានឯកភាពសាមគ្គីភាពរឹងប៉ឹងដូច ផ្ទាំងសិលា វេញត្របាញ់ស្អិតល្មួតចូលសាច់ឈាមគ្នា ជាសាច់ឈាមតែមួយ ទើបអាចនឹងរក្សាបូរណភាពទឹកដី បានដោយប្រសើររុងរឿងគ្មានជាតិណាប្រមាថបាន ។

យើងរាល់គ្នាជាខ្មែរ គប្បីដឹងឱ្យច្បាស់ថា យើងជាជាតិច្បងគេ នៅចុងអាស៊ីអាគ្នេយ៍នេះ។ យើងមានជាតិ,មានអម្បូរ , មានប្រទេស , មានវប្បធម៌ អរិយធម៌ឧត្ដុងឧត្ដមណាស់ , សឹងមាន

ប្រាសាទនគរវត្តជាតឹកតាងស្រាប់ ។ យើងត្រូវយល់ឱ្យច្បាស់ថា វឌ្ឍន៍ភាពរបស់យើងពីបុរាណ កាលនោះមិនមែនកើតឡើងដោយទេពនិម្មិតបង្កក់ប្រសិទ្ធិទេ គឺប្រាកដជាកើតឡើងដោយសារវីរៈភាពនៃដូនតាយើងយ៉ាងជាក់ស្តែង ដែលលោកខិតខំធ្វើ ខិតខំកសាង រចនាប្រកបដោយវិរិយភាពខ្ពស់បំផុត ។

យល់ដំណើរយ៉ាងនេះហើយ ត្រូវតែខ្មែរយើងរាល់គ្នា ខិតខំថែរក្សាតម្លៃនៃកេរ្តិ៍ឈ្មោះពីរោះល្បីរបស់យើងនេះឱ្យស្ថិតនៅជរាបតទៅផង ។

គ្រប់សម័យទាំងអស់ ត្រូវតែខ្មែរ យើងបណ្តុះបណ្តាលចិត្តស្នេហាជាតិឱ្យបានមុតមាំ ។

សម័យនេះទំព័រនៃប្រវត្តិសាស្ត្របានបើកហើយ របបរាជានិយម ,លទ្ធិផ្តាច់ការ រលុបរលាយហើយយើងចូលមកជារបប**សាធារណរដ្ឋ** ដែលខ្មែរយើងមិនដែលមានម្តងណាឡើយ នាំឱ្យបងប្អូនរួមឈាមខ្មែរទាំងអស់ បានសប្បាយចិត្តនឹងជោគវាសនាដ៏ឧត្តុងឧត្តមនេះណាស់ ។

ដូច្នេះយើងរាល់គ្នាត្រូវតែថែរក្សាទ្រទ្រង់របបថ្មីនេះឱ្យមានជំហរស្ថិរភាពតទៅ ហើយនឹងជួយរក្សាផែនដីយើង«ដីតូច»នេះឱ្យបានគង់វង្ស នៅក្នុងផែនទីសកលលោកតទៅកុំឱ្យសាបសូន្យឱ្យសោះ !

ចំពោះរឿងទឹកដីស្ងួមជ្រាបថា ៖ តាំងតែពីសតវត្សទី១៣រៀងមក ប្រទេសយើងចេះតែរេរ៉ូញរហូតសព្វថ្ងៃដោយសារតែយើងចេះតែ ជឿនិងផ្ញើវាសនាតែទៅលើបុគ្គលម្នាក់បណ្តោយឱ្យបុគ្គលនោះដឹកនាំ,ចង់ដឹកនាំយើងនិង ប្រទេសឱ្យទៅរកផ្លូវមរណៈក៏ចេះតែនៅស្ងៀមផ្សងសំណាងគ្មានគិតភ្ញាក់រលើករឿទាំងអស់ គឺដូចជាស្លាប់ទាំងជំហរតែម្តង ។ ការណ៍នោះហើយដែលជាហេតុនាំឱ្យសត្រូវបានចិត្តរឹតតែប្រមាថ មើលងាយបានដៃលើកគ្នាចូលមកលុកលុយដណ្តើមយកផ្ទៃដីយើងបន្តិចម្តងៗរហូតបក នៅសល់«ប៉ុនបាតដៃ»សព្វថ្ងៃនេះ ។

យើងត្រូវចងចាំឡើងវិញថា កាលពីមុននេះឆ្នាំ១៩៤១ សៀមប្រវ័ញ្ចយកដីបាត់ដំបង ។ **សៀមនិ**យាយប្រាប់ខ្មែរនៅស្រុកសៀមថា ឱ្យពួកខ្មែរដែលរស់នៅនឹងស្រុកសៀមទាំងប៉ុន្មានជួយ



ចេញមុខវាយបារាំង ដើម្បីរំដោះជាតិខ្មែរឱ្យរួចពីការជិះជាន់របស់បារាំង ស្រេចទៅសៀមយកដីបាត់ដំបងធ្វើក្រអេះ ។ ងាកទៅខាងខ្មែរកម្ពុជាក្រោមវិញពួកយួនយៀកមិញបានបោកប្រាស់ដែរថា ឱ្យខ្មែរកម្ពុជាជួយយួនក្នុងការដេញបារាំងឱ្យផុតស្រឡះពីកម្ពុជាក្រោមទៅយួននឹងឱ្យកម្ពុជាក្រោម គឺក្លួសាំងស៊ីនទាំងមូលមកខ្មែរកាន់កាប់ថែរក្សាតទៅ ។ សម្រេចទៅមានឯណា ? យួនមានឱ្យមកខ្មែរឯណា ?

គិតទៅយើងចាញ់បោកគេសៀម យួន នេះច្រើនលើកច្រើនគ្រាណាស់មកហើយគួរឈឺចាប់ណាស់ ។

រហូតដល់បច្ចុប្បន្នកាលនេះទៀត យួនយៀកកុងយៀកណាមខាងជើង បាននិយាយឃោសនាប្រាប់អ្នកស្រុកយើងថា ឱ្យជួយវាវាយទ័ពអាមេរិកកាំងឱ្យចេញទីប្រទេសខ្មែរ ហើយវាថាវាមកជួយរំដោះស្រុកខ្មែរពីក្រញាំចក្រពត្តិអាមេរិកាំង យកទៅឱ្យស្តេចសីហនុវិញ ។ ខ្មែរល្ងង់ខ្លៅខ្លះតាំងជឿវាជួយវាវាយទ័ពជាតិខ្មែរគ្នាឯងគ្មានពិចារណាអ្វីបន្តិចសោះ ។

យើងត្រូវពិចារណាថា សីហនុនេះពីដើមជាស្តេចជាតិយួនឬស្តេចជាតិខ្មែរ ? ឆ្លើយថាគាត់ជាស្តេចរបស់ខ្មែរទេ ! ចុះបើស្តេចនេះជារបស់ខ្មែរទេហើយខ្មែរលែងត្រូវការឱ្យកាន់ចង្កូតផែនដីតទៅទៀត ម្តេចក៏យួននោះជួយយកចិត្តទុកដាក់ឧត្តុង្គស្តេចនេះខ្លាំងម្ល៉េះ ? ចំណែកស្តេចយួនឈ្មោះបាវដាយដែលធ្លាប់សោយរាជនៅអណ្ណាមនោះម្តេចក៏យួនមិននាំគ្នាតំកើងផង ? ម្តេចក៏ជាតិយួននាំគ្នារំលំចោលចេញ ? រំលំស្តេចឯងហើយក៏តំកើងស្តេចគេនោះយួនវាមិនឆ្កួតទៅហើយឬ ?

ការណ៍នេះ យួនយៀកកុងយៀកណាមខាងជើង វាពុំឆ្កួតទេគឺវាពិតជាមានគំនិតគ្រប់គ្រាន់ ។ វាធ្វើជាកាន់ជើងស្តេចសីហនុ យកឈ្មោះស្តេចសីហនុមកដាក់ពីមុខ គឺប្រយោជន៍ដើម្បីនឹងវាយដណ្តើមទឹកដីខ្មែរ បំផ្លាញជាតិខ្មែរយ៉ាងច្បាស់ពិតប្រាកដតែម្តង ។

យើងមិនត្រូវជឿពាក្យសំដីជាតិនេះទេ ! វាមានពុតណាស់ វាជាសត្រូវនឹងយើងតាំងពី៣០០ឆ្នាំមកហើយ !

ម្យ៉ាងទៀត, ខ្ញុំសូមបងប្អូនរួមជាតិពិចារណាគិតនូវរឿងមួយ ។ សព្វថ្ងៃនេះប្រទេសខ្មែរយើងស្ថិតនៅចំកណ្ដាលប្រទេសទាំងពីរ គឺយួននៅខាងកើត និងសៀមនៅខាងលិច ។ ប្រទេសយើងមានទំហំតូចជាងគេ មានមនុស្សតិចជាងគេថែមទៀត ។ យួនមានចំនួនប្រជាជនដល់ទៅ៤០លាននាក់ ឯសៀមវិញមានមនុស្សដល់ទៅ៣០លាននាក់ ចំណែកខ្មែរយើងវិញមានតែ៧លាននាក់ប៉ុណ្ណោះ ។ ក្នុងសលកលោកទាំងមូល មនុស្សលោកចេះតែកើតឡើងកើនចំនួនជាលំដាប់ ។ ក្នុងរយៈកាល៣០តទៅមុខទៀត យួនត្រូវកើនឡើងយ៉ាងតិច៨០លាននាក់ ហើយសៀមយ៉ាងតិច៧០លាននាក់ ចំណែកខ្មែរវិញកើនឡើងយ៉ាងច្រើនត្រឹម១៥លាននាក់ប៉ុណ្ណោះ ។

យើងគិតមើល, ដល់មានហេតុកើតឡើងតើយើង១៥លាននាក់បានអ្វីទប់ទល់ចំពោះគេដែលមានមនុស្សដល់ទៅ១៥០លាននាក់ ហើយដែលនៅកៀបយើងទាំងសងខាងនោះ ?

នេះជារឿងមួយ ដែលត្រូវបងប្អូនរួមឈាមត្រិះរិះគិតឱ្យបានឃើញជាមុនឱ្យហើយផង ។ បើឧបមាថា មនុស្ស១៥០លាននាក់រំលោភប្រុងរំលាយមនុស្ស ១៥លាននាក់នោះតើមនុស្ស១៥លាននាក់នោះត្រូវគិតយ៉ាងណា ត្រូវមានវិធីណានឹងទប់ទល់ ? ការណ៍នេះត្រូវយើងភ្ញាក់រលឹកគន់គិតឱ្យបានម៉ដ្ឋចត់ ហើយត្រូវគិតតាំងពីព.ស.២៥១៤ គ.ស.១៩៧១ នេះតទៅទើបបាន ។

តាមយោបល់ខ្ញុំ ខ្ញុំយល់ថា ត្រូវរកពិធីពន្យល់កូនចៅខ្មែរយើងទាំងអស់ឱ្យយល់ពីរឿងជាតិរឿងប្រទេសនេះឱ្យបានច្បាស់ អប់រំបំផុសទឹកចិត្តស្នេហាជាតិឱ្យកើតឡើងតាំងពីនេះតរៀងទៅ ។ ក្នុងវត្ត ក្នុងសាលារៀនគ្រប់ទិសទីត្រូវរៀបចំកម្មវិធីសិក្សា ឱ្យមានរឿងជាតិនិយមគ្រប់ពេល ឱ្យក្មេងចេះចាប់តាំងពីថ្នាក់ទី១២ឡើងទៅឱ្យចេះស្រឡាញ់ជាតិស៊ូប្ដូរស្លាប់នឹងជាតិធ្វើការដើម្បីឱ្យជាតិបានចម្រើនគ្រប់វិស័យ ។

សរុបសេចក្ដីទៅ យើងគិតអប់រំកូនចៅយើងធ្វើម៉េចឱ្យតែយល់ច្បាស់ថា ខ្លួនអញជាខ្មែរធ្លាប់មានឈ្មោះរាប់ពាន់ឆ្នាំ មានអរិយធម៌រុងរោចន៍អស្ចារ្យមានឈាមជ័រជាអ្នកច្បាំងយ៉ាងរហ័ស... កាលបើយើងរាល់គ្នាបំផុសស្មារតីជាតិនិយមតាំងពីឥឡូវនេះទៅ រហូតដល់គ.ស.២០០០ និងតៗ



ទៅទៀតនោះយើងប្រាដកជានឹងរាចការរាយុជីវិតប្រទេសជាតិយើងបានរង់រាច ។ ព្រោះការតាំអាន់ស្ថិតនៅលើចិត្តគំនិតមិនមែនស្ថិតនៅលើចំនួនប្រជាជននោះឡើយ ។

កាលបើយើងរាល់គ្នា យល់នូវតម្លៃនៃពូជពង្សខ្មែរដូច្នេះគ្រប់គ្នាហើយ ហើយជួយអប់រំពន្យល់កូនចៅខ្មែរឱ្យយល់តៗគ្នាគ្រប់ជំនាន់ហើយ នោះពូជពង្សខ្មែរប្រពៃណីខ្មែរនឹងគង់វង្សជាដរាបហើយ**សាធារណរដ្ឋខ្មែរ**ក៏នឹងបានរីកចម្រើនសាយភាយទូលំទូលាយទៅ សមតាមសេចក្ដីសង្ឃឹមរបស់យើងគ្រប់គ្នាពុំខាន ។

សរសេររឿងនេះ គឺខ្ញុំពោនគោលបំណងចង់បញ្ជាក់នូវសន្ដានចិត្តខ្ញុំ ដែលចង់តែពោលនូវពាក្យទាំងប៉ុន្មានឃ្លានេះឯង ។ ហើយគឺព្រោះតែចង់ពោលបញ្ជាក់នូវន័យទាំងនេះហើយ ទើបសៀវភៅ**គុកនយោបាយ**ត្រូវដាក់តម្លៃជាវចុះមកយ៉ាងតិចបំផុត (គឺគ្រាន់តែឱ្យរួចចំណាយក្នុងការបោះពុម្ពប៉ុណ្ណោះគ្មានចំណេញអ្វីកើងរស់) ដើម្បីអនុគ្រោះចំពោះអ្នកអានដែលពុំសូវមានប្រាក់កាសនោះ ឱ្យអាចពិញសៀវភៅនេះមួយបានដែរ យកទៅអានផ្សព្វផ្សាយ បន្តៗគ្នាទៅទៀត ជាកិច្ចដាស់សតិស្មារតីយើងខ្មែរទាំងអស់គ្នាឱ្យយល់រឿង**ជាតិមាតុភូមិ**នេះកាន់តែទូលំទូលាយឡើង ។

សូមមិត្តអ្នកអានគ្រប់បណ្ដាដ្ឋាន ទទួលនូវសេចក្ដីគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

២៥១៤
*ភ្នំពេញ ថ្ងៃទី១ ខែមិនា ឆ្នាំ* ——
១៩៧១

**ប៊ុណ្ណចន្ទ ម៉ុល**

ប្រធានពុទ្ធិកសមាគម សំណាក់ការវត្តឧណ្ណាលោម

វរសេនិយត្រី ឧត្ដមបញ្ជាការដ្ឋាន

ជូនក្បួន និងអភិបាល

# ការខំប្រឹងតស៊ូយកឥស្សរភាព
# នៃ
# ពួកខ្មែរស្នេហាជាតិមួយក្រុម

## កាលជំនាន់ឆ្នាំ១៩៣៦-១៩៤២

## (បារាំងចាប់ក្នុងឆ្នាំ១៩៤២-១៩៤៥)

កាលជំនាន់អាណានិគមនិយមបារាំង ត្រួតត្រាស្រុកយើងនៅឡើយ ,វាសង្កត់សង្កិន, ជិះជាន់ប្រជារាស្ត្រខ្មែរ ឱ្យរងទុក្ខវេទនាកាន់តែខ្លាំងឡើងៗស្ទើរតែលេបភ្នែកគ្រប់ គ្នា,ធ្វើឱ្យយើងឈឺចាប់ រអាមកគ្រប់គ្នា ក្នុងនឹមដែករបស់វា,រើខ្លួនមិនរួច,រលាស់នឹមចោលក៏មិនរួចស្ទើតែសម្រក់ទឹកភ្នែកគ្រប់គ្នា ពុំដឹងគិតយ៉ាងណា ។ ប្រជាពលរដ្ឋខ្មែរគ្មានសិទ្ធិសេរីភាពអ្វីបន្តិចសោះ, វាបិទសិទ្ធិគ្រប់យ៉ាងមិនឱ្យយើងមាន,មិនឱ្យយើងតវ៉ាអ្វីឡើយ ។ ពន្ធដារសព្វសារពើចេះតែឡើងធ្ងន់ឡើងៗស្ទើរតែទ្រាំពុំបាន ។

ជំនាន់នោះ ,ឥតមានវីរជនណាម្នាក់មានមធ្យោបាយគិតនាំគ្នា រើខ្លួនឱ្យរួចពីខ្ញុំកញ្ជះបារាំងឡើយ គឺថាគំនិតងាប់ស្លក ដោយរអារាងចាល ខ្លាចវាចោទថានាំបះបោរក្បត់ជាតិ(ក្បត់វា) ដូចជាពោរកំបោរ, អាចារ្យស្វា,ក្រឡាហោមគង់,ឧកញ៉ាឈូក ។ល។ ដែលត្រូវទោសធ្ងន់ដល់ជីវិតដោយហេតុមកពីនាំគ្នាតស៊ូប្រឆាំងនឹងវា កាលដែលវាទើបនឹងចូលមកកាន់កាប់ទឹកដីខ្មែរកាលពីក្នុងឆ្នាំ១៨៨៦និងឆ្នាំតមកទៀត ។

ព្រមជាមួយនេះមានខ្មែរយើងពួកខ្លះ,គេចូលចិត្តធ្វើខ្ញុំបារាំគេខំផ្គាប់ផ្គុនបារាំងយកមានបាន

យកបុណ្យសក្ដិឱ្យខ្ពស់មុខ ចំពោះតែគ្រួសារគេ ,ឥតគិតដល់សេចក្ដីទុក្ខវេទនានៃជនរួមជាតិឡើយ ។ គេក៏តាំងសង្កត់សង្កិនជិះជាន់តែខ្មែរគ្នាឯង មានការចាប់ចងវាយទាត់ធាក់ កៀបយកលុយកាក់ ព្រមទាំងឱ្យការណ៍ទៅបារាំងឱ្យធ្វើទោសជាតិឯង ជាហេតុនាំឱ្យបានប្រាក់កាសផង, នាំឱ្យបារាំងទុកចិត្តស្រឡាញ់ថាស្មោះត្រង់នឹងវាផង, ក៏បានឡើងបុណ្យឡើងសក្ដិដោយអំពើជិះ-ជាន់ជាតិឯងនេះទៅ ។

ពួកទាំងនេះឯងហើយ ដែលជាឧបសគ្គធំបំផុតស្ទាក់ដំណើរការបដិវត្តន៍របស់យើងមិនឱ្យដើរទៅមុខបានស្រួលសោះ ។

***

# អំពីសេចក្ដីក្រខ្សត់អត់ឃ្លានរបស់ខ្មែរ

នៅក្នុងដង្កាប់ដែក នៃអាណានិគមនិយមនេះ ខ្មែរពុំគ្រាន់តែត្រូវរងទុក្ខឈឺចាប់ក្នុងចិត្តដោយសារគេជិះជាន់បំបិទសិទ្ធិសេរីភាពប៉ុណ្ណោះទេ ខ្មែរត្រូវរងទុក្ខដ៏ធ្ងន់មួយចំណែកទៀត គឺការខ្វះខាតនូវគ្រឿងឧបភោគបរិភោគ ។ ការនេះគួរកត់សម្គាល់តទៅអនាគត ។

សង្គ្រាមលោកលើកទីពីរ(១៩៣៩-១៩៤៥) ផ្ទុះឡើង,ផ្លូវគមនាគមន៍តាមសមុទ្រក៏ដាច់ អស់រលីងដោយមានការត្រួតត្រាតាមសមុទ្រយ៉ាងតឹងតែងបំផុត ។ ការដឹកនាំទំនិញចេញ-ចូលតាមសមុទ្រក៏ត្រូវបិទឈឹង ។ កាលណាកប៉ាល់ជំនួញណាហ៊ានដឹកនាំទំនិញមកម្ដងម្កាល ត្រូវពួកខ្មាំងស្ទាក់ចាប់យកទំនិញអស់ ឬក៏បាញ់ពន្លិចចោលតែម្ដង ។ ប៉្លោះហើយស្រុកយើងកាន់តែក្រី-ក្រទៅៗ,រកតែកន្ទបនឹងវ័ណ្ឌស្ទើរពុំបាន ។ ផ្ទះខ្លះមានសំពត់អាវតែមួយសម្រាប់ក្នុងគ្នាពីរនាក់បីនាក់ ។ បើចង់ចេញក្រៅ(ទៅផ្សារឬទៅបុណ្យទានអ្វីៗ) តោងតែទៅម្ដងម្នាក់,ព្រោះសម្លៀក



បំពាក់ពុំគ្រប់គ្នា ។ ឯអ្នកនៅផ្ទះពុំហ៊ានចេញទៅក្រៅទេ,ត្រូវវ័ណ្ឌកន្ទបរយីររយ៉ៃឬត្រូវវ័ណ្ឌមេយមានកំណាត់ ប៉ុងកញ្ចាស់ខ្មៅពភ្លក់ ឬកំណាត់កន្ទេលជាដើម ឱ្យតែបានបិទបាំងកេរ្តិ៍ខ្មាសទៅ ។ បើមានញាតិមិត្ត ណោមកសួរក,គ្រាន់តែឆ្លើយពីក្នុងផ្ទះមក,ឥតហ៊ានចេញមកទទួលភ្ញៀវឡើយព្រោះសម្លៀក-បំពាក់ខ្លួនពុំគួរគប្បី ។ នេះនិយាយចំពោះតែអ្នកក្រ ។ ឯចំណែកអ្នកមានវិញ,គេមិនសូវខ្វះខាតទេព្រោះគេបានប្រាក់ទិញសំពត់អាវទុក ។

ដប់ក្រសំពត់អាវពេកទៅ,ខាងខេត្តស្វាយរៀង ទើបអ្នកស្រុកបែកប្រាជ្ញាយកចចូតដែលសម្រាប់ត្បាញធ្វើកន្ទេលមកត្បាញធ្វើជាខោខ្លីចេញផ្សាយលក់ពាសពេញ ។

ម៉េចក៏ខ្មែរយើងបណ្ដោយឱ្យខ្វះខាតសម្លៀកបំពាក់ដូច្នេះ ? ម្ដេចក៏មិនដាំកប្បាសរវៃធ្វើសម្លៀកបំពាក់ទៅ ? បញ្ហានេះ,អស់លោកនឹង ជ្រាបដូចតតទៅ :

និយាយពីបារាំងវិញ ,ក្នុងពេលនោះ,ដោយពុំអាចធ្វើជំនួញចេញចូលបាន ,វាក៏តាំងប្រមូលយកផលិតផលរបស់ខ្មែរយើងធ្វើជាជំនួញវា គឺថាផលិតផលក្នុងស្រុកខ្មែរអ្វីក៏ដោយត្រូវតែយកទៅលក់ថោកឱ្យវាសិន ,វាបោះត្រាហាងវារួចហើយទើបវាបញ្ចេញលក់ឱ្យយើងវិញយ៉ាងថ្លៃៗ ។ បើឃើញយើងដឹកនាំឬកាន់វត្ថុអ្វីបន្តិចបន្តួច ដូចជាត្រីងៀត ត្រីឆ្អើរមួយគីឡូ ខ្លាញ់ត្រីមួយក្អម ,ក្រប្ដូនឃ្មុំប្លួយចានជាដើម ក៏វាចាប់ដកហូតហើយធ្វើទោសម្ចាស់របស់ទៀត ។ ដាំកប្បាសក៏ពុំ បានត្បាញរវៃធ្វើសំពត់អាវខ្លួ នឯងក៏ពុំបាន ។

អ្នកខ្លះលបលួចត្បាញសំពត់ដោយភិតភ័យភ្នែកចាប ភ្នែកព្រាបនៅគុម្ពចេក,ក្នុងព្រៃ,ទើបបានស្លៀកពាក់ខ្លះ ។ តាំងពីបារាំងចូលមកនៅស្រុកយើង ស្រីខ្មែរដែលពីដើមពូកែខាងតម្បាញក៏បានបោះបង់ ចោលវិជ្ជានេះអស់,នៅសល់ចេះត្បាញរវៃតិចគ្នាណាស់ ព្រោះបារាំងវាយកសំពត់អឺរ៉ុបមកលក់ឱ្យយើង មានសាច់ល្អសឬខ្មៅស្អាតជាងសំពត់ត្បាញអាយ ដែលយើងឱ្យឈ្មោះថា«អឺរ៉ុបឯក»គឺជាសំពត់មកពីបរទេសសាច់ល្អឯក ។

ជាន់នោះ,អំបិលក៏គ្មានទទួលទានដែរ ត្បិតគ្មានលក់ អ្នកនៅក្បែរមាត់សមុទ្រ,ខំទៅដងទឹកសមុទ្រមកដាំរម្ងាស់យកអំបិលបានបន្តិចបន្តួចគ្រាន់ប្រើដោយលួចលាក់ កុំឱ្យបារាំងវាដឹង ខ្លាចត្រូវទោសទណ្ឌកម្ម ។ ឯអ្នកក្រដែលនៅឆ្ងាយពីសមុទ្រខ្លះក៏ទទួលទានសាបទៅជាហើមខ្លួនក៏មាន ។ ខ្លះយកត្រីសាច់ទៅត្រាំទឹកផេះឱ្យចេញប្រៃជាប់បន្តិចៗក៏មាន ។ល។

នេះជានយោបាយអ្នកជិះជាន់ បារាំងក៏ដូចអង់គ្លេសនៅឥណ្ឌាដែរ ។

ចំណែកអ្នកមានទ្រព្យគេមិនអត់ទេ ,គេឃើញស្រុកទេសមិនស្រួលដូច្នេះ គេទិញសំពត់ទុកប្រើ រកទិញអំបិលទុកបរិភោគសម្រាប់តែគ្រួសារគេ ប៉ុណ្ណោះ ។

***

# -១-

# ការតស៊ូចាប់ផ្ដើមដំបូងតាមផ្លូវសារពត៌មាន

ជាន់នោះប្រជារាស្ត្រយើងមានសេចក្ដីលំបាកវេទនាកាន់តែខ្លាំងឡើងៗ ដោយបារាំងធ្វើបាបហើយជាឱកាសល្អហុចឱ្យផង ត្បិតពេលនោះបារាំងវាកំពុងជាប់ដៃធ្វើសឹកសង្គ្រាមជាមួយអាល្លឺម៉ង់ផង ហើយតមកវាច្បាំងនឹងសៀមទៀតពុំអាចដឹកនាំគ្រឿងអាវុធយុទ្ធភ័ណ្ឌមកបង្ក្រាបយើងបានឡើយ នៅស្រុកយើងវាប្រើតែអាវុធចាស់តាំងពី១៩១៤មក ហួសសម័យទៅ



ហើយ ។ ហេតុនេះហើយបានជាវាច្បាំងចាញ់សៀម[១] ។ ដឹកពីពេលនោះ ឬវាបន្តឃ្លេអ្នកស្រុកដើម្បីបំភ័ន្តខ្មែរថា បារាំងខ្លាំងពូកែ ដឹកតែទ័ពកាំភ្លើងចុះឡើងបន្លាចខ្មែរកុំឱ្យហ៊ានតនឹងបារាំង ។

គ្រានោះទើបមានវីរជនអ្នកស្នេហាជាតិមុតមាំមួយចំនួន ឥតខ្លាចគុកច្រវ៉ាក់ ឥតខ្លាចចោលស្រុក ឥតខ្លាចស្លាប់,មុនដំបូងបានលបលោក់ដឹកនាំបបួលគ្នីគ្នាឱ្យធ្វើការតស៊ូប្រឆាំងនឹងបារាំងយកឥស្សរភាពពីវាមកវិញ ក្នុងពេលដែលបារាំងកំពុងមានអំណាចនៅឡើយ គឺថាចង្កូមឬធ្មេញវានៅពេញមាត់ស្រួចវែលមនៅឡើយ វាចង់ធ្វើអ្វីយើងក៏បានតាមចិត្តវា ឥតអ្វីទបបាំងបានឡើយ ។ ក្នុងបណ្ដាវីរជនទាំងនោះ មានលោក*ស៊ឺង ង៉ុកថាញ់*[២] ជាមេដឹកនាំបាននាំគ្នាតស៊ូធ្វើបដិវត្តន៍ឡើង ។

ការតស៊ូនេះចាប់ផ្ដើមដំបូងក្នុងឆ្នាំ១៩៣៦ តាមផ្លូវសារពត៌មានមួយឈ្មោះថា«*សារ-ពត៌មាននគរវត្ត*» ។ សារពត៌មាននេះបានពន្យល់,ណែនាំ,ដាស់ស្មារតីបងប្អូនខ្មែរយើងដែលដេកលក់,ដែល រងកម្មវេទនា,ដែលបាក់ស្បាតធ្លាប់ខ្លាចបារាំងដាក់គុកឬសម្លាប់, ឱ្យភ្ញាក់ស្មារតីឡើង, ឱ្យចេះស្នេហាជាតិ,ឱ្យចេះតស៊ូឥតខ្លាចស្លាប់ ដើម្បីយកឥស្សរភាពពីបារាំងមកវិញ ដែលវា

---

១.កាលចម្បាំងបារាំង-សៀម,ជនជាតិខ្មែរនៅស្រុកសៀម ត្រូវចាញ់បោកសៀម ដែលវាបោកឱ្យច្បាំងនឹងបារាំងថាឱ្យមករំដោះជាតិខ្មែរឱ្យរួចពីនឹមបារាំង ។ ឯខ្មែរនៅស្រុកខ្មែរក៏ ត្រូវបារាំងបោកដូចគ្នាថា ឱ្យទៅច្បាំងនឹងសៀមការពារស្រុកខ្មែរ ដែលត្រូវសៀមឈ្លានពាន ។ ម៉្លោះហើយខ្មែរទាំងសងខាងបាញ់តែគ្នាឯងស្លាប់អស់ច្រើន ។

២.លោកស៊ឺង ង៉ុកថាញ់ ជាជាតិខ្មែរកម្ពុជាក្រោម ។ នៅវេលាដែលត្រឡប់មកពីសិក្សាឯប្រទេសបារាំង,ត្រូវនាងកញ្ញាការប៉ឺឡេស (Melle Karpelés) ជាអ្នកគ្រប់គ្រងព្រះរាជបណ្ណាល័យកម្ពុជានិងជាអគ្គលេខាធិការនៃព្រះពុទ្ធសាសនបណ្ឌិត្យ នាំពីក្ដសាំងស៊ីន(កម្ពុជាក្រោម)មកឱ្យធ្វើការជាមួយ ។ ជាន់នោះលោកត្រូវតែងតាំងជាចៅក្រមក្នុងរាជការខ្មែរ ប៉ុន្តែដាក់ក្រៅតំណែងមកធ្វើការនៅព្រះរាជ បណ្ណាល័យវិញ ។ លោកជាអ្នកនយោបាយម្នាក់មានសេចក្ដីស្នេហាជាតិយ៉ាងមោះមុត,រាប់អានអ្នកពេញអ្នកក្រស្មើមុខគ្នា ។ លោកជាមេគំនិតនយោបាយខាងកាសែត,ប៉ុន្តែឥតឈ្មោះលោកទេ ដោយកាលជំនាន់នោះ អ្នករាជការសរសេរកាសែតពុំបានទេ ។

វាបានដណ្ដើមពីយើងទៅជិត១០០ឆ្នាំហើយ[(១)] ។

ពេលនោះស្រុកខ្មែរក្រកាសែតណាស់ កាសែតមួយឈ្មោះ*«ស្រុកខ្មែរ»*ឈ្មោះសោង. ហេ ហេរ៉ុង ធ្វើតែមិនបានប្រយោជន៍ដល់ខ្មែរទេព្រោះខ្លាចមិនហ៊ាននិយាយ ។

កាសែត *«នគរវត្ត»* ចាប់ចេញដំបូងតែពីរដងទេ ក្នុងមួយអាទិត្យទីស្នាក់ការនៅជ្រុងផ្លូវស៊ីសុវត្ថិ និងមាយវ៉ាន់ឈ្មោះសេឡិចហោតិល(ផ្ទះនោះនៅរហូតសព្វថ្ងៃ) នៅពីខាងមុខសេឡិច ហោតិលមានរង្គសាលមួយឈ្មោះឡារ៉ើស្តូកហាត់ទន្លេចតុមុខ ។ កាសែតនេះលក់១សន្លឹក៨សេន ។ លុះចេញយូរបន្តិចទៅកាន់តែលក់ដាច់ឡើងក៏បញ្ចុះតម្លៃមកនៅត្រឹម៥សេនវិញ ។

លោក*ប៉ាច ឈឺន* កាន់កាប់មុខងារជាចាងហ្វាងកាសែតព្រោះលោកជាវីរជនម្នាក់ស្នេហាជាតិបុគ្គលក្នុងពេលក្រុមបដិវត្តអាំងរស់ ។ ឯលោក*ម៉ៅ ហ្ស៊ុង* បានត្រូវឱ្យធ្វើជាគណនេយ្យករព្រោះលោកក៏ជាមនុស្សត្រង់ ហើយជាអ្នកស្នេហាជាតិដែរ ។ ចំណែកអ្នកនិពន្ធមាន លោក*ស៊ឹង ង៉ុកថាញ់* លោក*ប៉ាច ឈឺន* លោក*ស៊ឹម វ៉ារ* លោក*ពិទូរ កះសេម* និងលោក*ជុំ មួង* ។

ក្រោយមកទើបលោកមហា*ញ៉ុក ថែម*និងលោក*មហា សាមន* ចូលជួយទៀត ។ មុនដំបូងមានអស់លោកជាច្រើនប្រហែល២០នាក់ជាអ្នកជួយសរសេរដែរ ប៉ុន្តែចេះតែរបេះ អស់ដោយលោកមិនសូវស៊ូព្រោះធ្វើទទេឥតឈ្នួល នៅសល់តែប៉ុន្មាននាក់ដូចរាយនាមខាងលើ ។ កាលជាន់នោះអ្នករាជការពុំហ៊ានសរសេរកាសែតបានឡើយ ។ ហេតុនេះហើយបានជាពុំមានឈ្មោះ លោក*ស៊ឹង ង៉ុកថាញ់* និង *ជុំ មួង* ក្នុងកាសែតឃើញតែ*«នគរវត្ត»*ទទេ ។ កាសែតនេះជាឯកសារតំណាងតម្កល់ទុកនៅពុទ្ធសាសនបណ្ឌិត្យ និងបណ្ណាល័យជាតិ ។

១.បារាំងចូលមកកាន់កាប់កម្ពុជាពីឆ្នាំ១៨៦៣ តាំងពីព្រះបាទអង្គឌួងរហូតមកដល់ព្រះបាទនរោត្តម ទើបធ្វើសន្ធិសញ្ញាប្រគល់ឱ្យបារាំង ។



លុះកាសែតនេះដើរបន្តិចទៅ គឺថាបានចម្រើនដោយកាន់តែលក់ដាច់ឡើងក៏ចាប់ផ្ដើមធ្វើជាក្រុមហ៊ុនព្រមទាំងបណ្ណាគារខ្លួនឯងសម្រាប់បោះកាសែតខ្លួនឯង និងស៊ីឈ្នួលបោះសៀវភៅផង ដាក់លក់សៀវភៅព្រមទាំងប្រដាប់សម្រាប់ការិយាល័យផង ។ កាលពីមុនជួលរោងពុម្ពបារាំងឈ្មោះអាល្បឺយ៉េសបោះកាសែតនេះ ។ រោងពុម្ពគេធ្លាប់បោះកាសែតរដ្ឋមួយស្រាប់ឈ្មោះ *«កម្ពុជពតិមាន»* ។

កាលកាសែតនគរវត្តចេញដំបូងអ្នកដែលអានភាគច្រើនមានតែអ្នកក្រីក្រ និងកម្មករដែលពុំសូវចេះភាសាបារាំង អានកាសែតភាសាបារាំងមិនបាន ។ ឯអស់លោកនិងថៅកែគេមិនយកភ្នែកមើលទេ ដោយគេមើលងាយ ស្អប់ខ្ពើមអក្សរជាតិ ។ ជាពិសេសគឺអស់លោកជាន់នោះអានអក្សរខ្មែរពុំបានផង ព្រោះមិនខំរៀនអក្សរជាតិទេ គេខំរៀនអក្សរបារាំង ព្រោះអក្សរបារាំងមានតម្លៃខ្លាំងណាស់ ជាន់នោះឯអក្សរខ្មែរចុះទាបដល់ថ្នាក់ក្រោមសូន្យ ។ គេមើលតែកាសែតបារាំងឈ្មោះឡាវេរីតេ (La Vérité) អូពីនីញ៉ុង (Opiniion) អាំប៉ាស្យាល់ (Impartial) និង " Presse de saïgon" ជាដើម ។ បើគេចង់មើលកាសែតខ្មែរដោយព្វល្បីថាល្អមើល គេបត់ដាក់ពីក្នុងកាសែតបារាំងកុំឱ្យគេមើលឃើញ ខ្លាចថាគេអន់ឬមិនចេះបារាំង ។ ហេតុអ្វី ?មកពីបារាំងនៅជាន់ស្រុកយើង យើងនៅក្រោមគេ ម្ល៉ោះហើយឥទ្ធិពលបារាំងវាខ្លាំងដល់ទៅអក្សរវាទៅទៀត ។ សូមជម្រាបថា ជាន់នោះអ្នកណាមិនចេះអក្សរបារាំងចេះតែអក្សរខ្មែរ ឥតបានការអ្វីធ្វើនឹងគេទេ ព្រោះគេប្រើតែអក្សរបារាំង ទោះខាងរាជការក្ដី ខាងជំនួញក្ដីដូចគ្នា ។ អ្នកនិយាយបារាំងហ៊ឺហាណាស់ ដូចទេវតាចុះពីស្ថានសួគ៌ ។

ធ្វើពាក្យបណ្ដឹងឬពាក្យសុំអ្វីៗត្រូវតែធ្វើជាបារាំង ទោះខាងរាជការខ្មែរក្ដី ខាងរាជការបារាំងក្ដី ប្រើតែអក្សរបារាំងដូចគ្នា ។ បើមិនចេះ ត្រូវពឹងគេឬជួលគេធ្វើឱ្យទើបបានការ ។ មិនមែនតែភាសាឬអក្សរបារាំងទេ ដែលថ្លៃថ្នូរ សូម្បីតែស្រីបារាំងក៏ប្រុសខ្មែរយើងជាន់ជាយកធ្វើលេងមិនបានដែរ ។ និស្សិតខ្មែរដែលបានសញ្ញាប័ត្រខ្ពស់ពីស្រុកបារាំងលុះត្រឡប់មកវិញដោយទាំងប្រពន្ធបារាំងមកផង ដល់សុំធ្វើការក្នុងរាជការគេមិនឱ្យ គេប្រាប់ថា ទាល់តែលែងប្រពន្ធបារាំង

ទៅទើបឱ្យការធ្វើ ។ បុរសនោះបង្ខំចិត្តលែងប្រពន្ធបារាំងពៅ ទើបបារាំងគេឱ្យធ្វើជាមន្ត្រីខាងរាជការខ្មែរ ។ ឯនាងបារាំងនោះត្រូវគេបញ្ជូនត្រឡប់ទៅស្រុកបារាំងវិញទៅ ។ រឿងនេះមានច្រើនគ្នា តែសូមមិនបញ្ចេញឈ្មោះ ។ ឯយួនដែលជាខ្ញុំបារាំងដូចជាខ្មែរដែរ ប៉ុន្តែវាមានឥទ្ធិពលជាងខ្មែរវាក្តោងក្តាងដាក់ខ្មែរគ្រប់កន្លែងរាជការនិងជំនួញ ព្រោះវាចេះផ្គាប់ផ្គុន បារាំងៗស្រឡាញ់វាស្តាប់វាធ្វើបាបខ្មែរ ។ ចំណែកឯចិនវិញក៏វាឡើងចាងលើខ្មែរពេកស់ដែរ ព្រោះពួកគេច្រើនតែអ្នកមានសម្បត្តិ គេតាំងខ្លួនគេខ្ពស់នៅស្រុកខ្មែរប្រហែលនឹងបារាំងដែរ ។ កុំថាដល់ទៅស្រីល្អជាសូម្បីតែស្រីផ្កាមាសចិនក៏ខ្មែរយើងពុំអាចភប់ភ័នវាបានឡើយ ។ បើបានស្គាល់ចិនជិតដិតហើយវានាំទៅព្រៃចស្រីពេស្យាចិនជាមួយវាទើបបានខ្លះ ។ ខ្មែរជាន់នោះអន់ជាងយួនចិនទៅទៀត ។

សម័យនោះ ដោយអក្សរសាស្ត្របារាំង វប្បធម៌បារាំង ផ្សាយឥទ្ធិពលមកលើអក្សរសាស្ត្រខ្មែរលើវប្បធម៌ខ្មែរខ្លាំងណាស់ទៅ អក្សរសាស្ត្រយើង,វប្បធម៌ យើងក៏រត់ទៅពួនសម្ងំនៅក្នុងវត្តអារាមអស់ ។ បើកុំតែបានគុណព្រះសង្ឃខ្មែរដែលជាអ្នកទ្រទ្រង់ថែរក្សាទុក ឱ្យគង់វង្សដល់សព្វថ្ងៃកុំអីអក្សរសាស្ត្រខ្មែររលាយបាត់សូន្យឈឹងពីប្រទេសកម្ពុជាទៅហើយ ។ ចាប់ពីឆ្នាំ ១៩៤២ មកបារាំងលែងឱ្យសរសេរអក្សរខ្មែរជាផ្លូវការហើយ គេបង្កើតអក្សររ៉ូម៉ានីហ្សេ Romanisé ឬក៏ហៅថា កុកងឺខ្មែរ គឺឱ្យសរសេរពាក្យខ្មែរជាអក្សរបារាំងវិញ តាំងពីរាជការជាន់ខ្ពស់រហូតដល់ឃុំ ។ កាសែតក៏ចេញជាអក្សររ៉ូម៉ានីហ្សេដែរ ។ ហេតុអ្វី ? មកពីបារាំងគេធ្វើឱ្យជាតិគេងាយរៀនភាសាខ្មែរដោយសរសេរជារ៉ូម៉ានីហ្សេ ព្រោះតជាន់នោះបារាំងគេកំពុងតែដាក់គ្នាគេមកនៅស្រុកអាណានិគមឱ្យច្រើនហើយគេចង់បញ្ចូលស្រុកចំណុះគេ ធ្វើជាស្រុកបារាំងផង ហៅថាប្រទេសបារាំងឯនាយសមុទ្រ (La France d'outre Mer) គឺគេចង់សង្កត់យើងកុំឱ្យរើខ្លួនរួច ឱ្យក្លាយជាតិទៅជាបារាំងឱ្យអស់ទៅ ទោះចេះបារាំងក៏ដោយ មិនចេះក៏ដោយ ដូចជានៅប៉ុងឌីស៊ីរី-ចណ្ឌេនាគរ ។ល។ ជាខេត្តនៃប្រទេសឥណ្ឌា ដែលក្លឹង្គក្លាយសញ្ជាតិជាបារាំងខ្មៅអស់ ។ ឯខ្មែរយើងជាន់នោះ និងមុននោះមានសុំចូលជាតិជាបារាំងខ្លះដែរ ដោយគេយល់ឃើញថា ជាតិឯងថោកពេកណាស់ ហើយបានទាំងផ្លាស់ឈ្មោះទាំងត្រកូលទៅជាបារាំងអស់ គេសប្បាយចិត្តនឹងដូរជាតិ



ខ្មែរទាបថោកទៅជាជាតិបារាំងខ្ពង់ខ្ពស់ថ្លៃថ្លាទៅវិញ ។ ក៏ប៉ុន្តែសូមជ្រាបថានៅជំនាន់នោះ ខ្មែរនៅខំតស៊ូប្រើភាសាខ្មែរនៅបានច្រើននៅឡើយ ។ ដូចជាក្រសួងមហាផ្ទៃ យុត្តិធម៌ សិក្សាធិការជាតិ ក្រុមព្រះតម្រួត ។ល។ ជាដើម ។ ដល់ពេលទាមទារបានសេរីភាពឯករាជ្យពីបារាំងបានខ្លះនោះត្រឡប់ជាប្រើអក្សរបារាំងទៅវិញ ។

កាលពីឆ្នាំ១៩៤៧ ស្រុកខ្មែរបានកើតជារូបរាងរដ្ឋធម្មនុញ្ញមុនដំបូង ដោយវីរជនដូចជាទ្រង់ *យុត្តិវង្ស*,លោក*អៀវ កើស ,ឈាន វ៉ម* និងវីរជនឯទៀតជាច្រើន បានជំនុំគ្នាធ្វើ *រដ្ឋធម្មនុញ្ញបានចែងក្នុងមាត្រា២ ឱ្យប្រើភាសាខ្មែរជាផ្លូវការរហូតមកដល់ឆ្នាំ១៩៧០ គិតទៅ៣ឆ្នាំកន្លងមកអ្នករាជការខំប្រើភាសាបារាំងរឹតតែច្រើនទៅទៀត ។ សព្វថ្ងៃនេះចង់រហូតទៅមេឃុំទៅហើយអក្សរជាតិមើលមិនឃើញទេ គ្រប់ក្រសួងទាំងអស់ហើយប្រើភាសាបារាំងដោយនៅកំអែលអាណានិគមក្រាស់ណាស់* ។ ចំណែកជាតិយួនគេដើរទាន់សម័យគេដេញបារាំងចេញ គេប្រើភាសាជាតិគេជាផ្លូវការគេឱ្យកុមារា-កុមារីរៀនភាសា អង់គ្លេស ។ ពេលជប៉ុនចូលស្រុក គេឱ្យកូនចៅគេរៀនភាសាជប៉ុនឥឡូវនេះនៅសកលលោកទាំងមូលប្រទេសដែលទើបបានឯករាជ្យថ្មីៗ គេតែងតែប្រើភាសាជាតិគេស្ទើរតែគ្រប់ប្រទេសទៅហើយ ចម្លែកអីតែជនជាតិខ្មែរយើងនៅក្រាញដល់ណាទៀត ? សព្វថ្ងៃ សីលធម៌-វឌ្ឍនធម៌-ទំនៀមទម្លាប់ខ្មែរចង់រលំរលាយទៅ ចង់អស់ពីស្រុកខ្មែរទៅហើយ ! ហេតុនេះគួរបងប្អូនរួម ពហោមមេត្តាជួយគិតឱ្យបានវែងឆ្ងាយរឿងអក្សរជាតិយើងផង !

នេះគ្រាន់តែជាសេចក្តីរំលឹកប៉ុណ្ណោះ ឥឡូវចាប់និយាយរឿងដើមតទៅទៀត ;

លុះសារពត៌មាននគរវត្ត ចេញផ្សាយយូរបន្តិចទៅ,ប្រជារាស្ត្រខ្មែរដែលពីដើមដេកលក់យ៉ាងស្កប់ស្កល់ផង ,ដែលបាក់ស្បាតខ្លាចបារាំងផង ,ក៏បើកភ្នែកខ្លះ ,ភ្ញាក់រើកខ្លះ,ក្រោកពីដេកខ្លះ,ចេះស្រឡាញ់ជាតិ, ចេះជួយការពារគ្នាក្នុងគ្រាមានអាសន្ន, ហ៊ានតវ៉ាជាមួយបារាំងចំពោះអំពើរលោភនិងជិះជាន់ខ្លាំងលើខ្លួន ឬលើជនរួមជាតិ ។ គ្រានោះ,បារាំងបានដឹងខ្លួនថា ឥឡូវនេះ

ខ្មែរលើកពីដេកខ្លះហើយ ,មិនសូវខ្លាចវាដូចពីដើមដោយហេតុមកពីកាសែតនគរវត្តដែលមានលោក*ស៊ឹង ង៉ុកថាញ់* និងលោក*ប៉ាច ឈឺន*ជាមេក្លោង ជាអ្នកដឹកនាំ ។ វាក៏តាំងប្រើតប្រៀនមិនឱ្យកាសែតចេញតាមចិត្តយើងបាន,វាធ្វើការត្រួតពិនិត្យ (censure) គឺដកអត្ថបទល្អៗដែលយើងនិយាយប៉ះពាល់លើវាចេញ ។ ជួនណាយើងចេញតែក្រដាសសទទេ ត្បិតអត្ថបទសំខាន់វាដកចេញទៅហើយនៅសល់តែដំណើងផ្សេងៗនិងដំណឹងពាណិជ្ជកម្មដែលគេជួលឱ្យផ្សាយ ។ ម្លឹងហើយ ក៏នៅតែមានគេចូលចិត្តអានទៀតដោយគេយល់ថា កន្លែងក្រដាសសនោះប្រហែលជាមានរឿងអ្វីសំខាន់ហើយមើលទៅ, បានជាបាំងដកចេញមិនឱ្យផ្សាយ, ក៏នាំគ្នាស៊ើបសួរចចាក់ចច្ចចស៊ើបសួរគាស់កកាយរកការណ៍ពិតត្រង់កន្លែងសនោះ ។ តាំងពីនោះមកបារាំងប្រយ័ត្នប្រយែងកាន់តែខ្លាំង, ត្រួតកាសែតផង តាមឃ្លាំមើលសកម្មភាពនៃពួកកាសែតផង ,តើមាននរណាខ្លះជាក្រុមដឹកនាំប្រជារាស្ត្រប្រឆាំងនឹងវា ? ខាងរ៉េស៊ីដង្ស ស៊ុប៉េរីយ៉ើ គេបានទារពីព្រះរាជបណ្ណាល័យនូវសំណុំរឿងផ្ទាល់ខ្លួន (dossier de personnel)របស់លោក*ស៊ឹង ង៉ុកថាញ់* ទៅពិនិត្យមើលឱ្យស្គាល់សាវតារជាតិ និងពតិមានផ្សេងៗដើម្បីឱ្យងាយស្រួលក្នុងការចាប់ចងពីបទនាំបំបះបំបោររាស្ត្រប៉ុន្តែគេមិនទាន់ចាប់ទេ គឺគ្រាន់តែសម្គាល់ទុក ។

កាលជំនាន់នោះ, យើងមិនទាន់មានសេរីភាពក្នុងការសរសេរនៅឡើយ, ប៉ុន្តែកាសែត**នគរវត្ត**ហ៊ានសរសេរផ្សាយដោយរិះគន់បារាំងនិងរដ្ឋការខ្មែរធ្ងន់ៗ ខ្លាំងជាងកាសែតទាំងឡាយសព្វថ្ងៃនេះទៅទៀតដែលមានសេរីភាពក្នុងការសរសេរ ។

ឯឈ្មោះក្រុមអ្នកកាសែត**នគរវត្ត** គឺក្រុមបដិវត្តន៍នោះក៏បារាំងវាបានស៊ើបដឹង, ស្គាល់មុខគ្រប់គ្នាអស់ហើយដែរដោយសារតែចារបុរសជាតិខ្មែរគ្នាឯង ដែល ក្បត់ជាតិប្រាប់វាដោយផ្ដាច់ផ្ដួនចង់បានយសសក្ដិ ។

ពួកបដិវត្តគឺពួកកាសែត*នគរវត្ត* ជំនាន់នោះ មានប្រជាប្រិយភាពណាស់ គឺមានព្រះសង្ឃនិងអ្នកស្រែចម្ការ , កម្មករបម្រើរាជការរាប់អានស្រឡាញ់កាន់តែច្រើនឡើងៗ ។ ក្នុងពេលធ្វើទស្សកិច្ចម្ដងៗនៅគ្រប់ទីកន្លែង,លោក*ប៉ាច ឈឺន*លោក*ស៊ឹង ង៉ុកថាញ់*,លោក*ស៊ឹម វ៉ា* ។ល។



បានខំឧស្សាហ៍ពន្យល់,បំភ្លឺ,ណែនាំប្រជារាស្ត្រឱ្យភ្ញាក់ខ្លួនចំពោះនយោបាយត្រូវកទេស ក្រៅពីការផ្សាយក្នុងកាសែតទៀត ។ ហេតុនេះហើយបានជាពេលពួកនោះទៅម្ដងៗ ,ទៅវត្តអារាមក្ដីទៅកាន់ភូមិតូចធំឬទៅកាន់ទីរាជការក្ដី គេឃើញប្រជារាស្ត្រទាំងស្រីទាំងប្រុស,អ្នករាជការព្រមទាំងព្រះសង្ឃមកជួបជុំគ្នាចាំទទួលស្វាគមន៍ ធ្វើបដិសណ្ឋារកិច្ចដោយទឹកមុខរីករាយក្រៃលែងដោយចាំស្ដាប់សេចក្ដីអធិប្បាយពន្យល់ ពីនយោបាយត្រូវកទេស ព្រមទាំងបានរៀបចំទទួលភោជ-នាហារផងទៀត ។

ប៉ុន្តែអស់លោកឯទៀត ពុំសូវបានចេញទៅស្រុកក្រៅញឹកញាប់ទេ ត្បិតជាប់រវល់ធ្វើការរាជការមានតែលោក*ប៉ាច ឈឺន*ម្នាក់ឯងទេដែលបានធ្វើទស្សនកិច្ចនៅគ្រប់កន្លែងច្រើនជាងគេ ។ ហេតុនេះបានជាគេស្គាល់តែឈ្មោះនិងមុខលោក*ប៉ាច ឈឺន* ច្បាស់ជាងគេ , រាប់អានស្រឡាញ់ជាងគេ ។ មានកន្លែងខ្លះដែលមានលោកចាងហ្វាង*ប៉ាច ឈឺន* ចូលមិនដល់អ្នកស្រុកបបួលគ្នាសែងដង្ហែលោកទាល់តែដល់ទីកន្លែងដែលណាត់ប្រជុំ ។ សម័យនោះលោក*ប៉ាច ឈឺន* ឡើងដៃខ្ពស់មុខមាត់ជាងអស់លោកឯទៀត ។ *ដូចម្ដេចក៏ត្រូវគិតពីស្រុក ទេស ? ពីជាតិ ? ព្រោះថាយើងជាមនុស្សមានប្រទេសមានជាតិត្រូវស្វែងរកសុភមង្គលជារបស់ជាតិ កុំឱ្យជាតិដទៃមើលងាយគិតជាតិជាធំពុំមែនគិតខ្លួនជាធំទេ ។ អ្នកគិតដោយយកខ្លួនជាធំទៅជាអ្នកជិះជាន់ ជាតិខ្លួនឯង* ។

ក្រោយមក,ដោយយល់ឃើញថា គ្រាន់តែផ្សាយដំណឹងបណ្ដុះបណ្ដាលស្មារតីប្រជាជាតិខ្មែរឱ្យចេះស្នេហាជាតិតែតាមផ្លូវសារពតិមានប៉ុណ្ណោះ បានលទ្ធផលមិនទាន់គ្រប់គ្រាន់ទេ ដោយហេតុអត្ថបទល្អៗ សំខាន់ៗ ត្រូវបារាំងវាដកចេញមិនឱ្យចុះផ្សាយ ទើបលោក*ស៊ឹង-ង៉ុកថាញ់*បានជំនុំ គ្នាដើម្បីរកមធ្យោបាយបន្ថែមមួយផ្លូវទៀត ដើម្បីបន្ថែមឱ្យមានឥទ្ធិពលឡើងទៀត ,គឺលោក បំបែកគ្នាជាពីរក្រុម ។ ក្រុមទី១មានភារៈខាងធ្វើកាសែត មានលោក*ប៉ាច-ឈឺន*ជាមេ ជាមួយនឹងអស់លោកឯទៀត ,ក្រុមទី២សម្រាប់ដើរទាក់ទងផ្ទាល់នឹងប្រជារាស្ត្រ, នឹងក្រុមទាហានជើងក្រហម, ទាហានជើងខ្មៅ ព្រមទាំងរកលុយកាក់ ដើម្បីគិតធ្វើការបដិវត្តន៍

បណ្តេញបារាំងចេញឱ្យអស់ពីទឹកដី នៃមាតុប្រទេសយើង ដើម្បីយកទឹកដីយើងមកវិញ ,ឱ្យមានឥស្សរភាពដូចជំនាន់ដើមវិញ , ដូចជាប្រទេសនានាដែលគេមានឯករាជ្យភាពដូច្នេះឯង ។ ក្រុមទី២ នេះមានលោក*ស៊ឺង ង៉ុកថាញ់* ជាមេជាមួយនឹងខ្ញុំ*(ប៊ុណ្ណ ចន្ទម៉ុល)* លោក*នួន ឌួង* , លោកគ្រូអាចារ្យ*ហែម ចៀវ* និងលោកជុំ មួង ។ល។

*គួរកត់សម្គាល់ថា មនុស្សគ្រប់ជាតិពុំមែនមិនចេះស្រឡាញ់ជាតិទេស្ទើរតែទាំងអស់ចេះស្នេហាជាតិ តែការសំខាន់គឺមេដឹកនាំគឺមេដឹកនាំមានគំនិតភ្លឺថ្លាធ្វើការដើម្បីជាតិ (ស៊ូស្លាប់ទៅតាប់រសធមិកុំបីបង់) ការសេពគប់* (Fréquentation) *ប្រសើរណាស់ ។ មេឆ្វេងកូនឆ្វេង។*

គ្រានោះទោះបីចែកជាក្រុមដោយឡែកពីគ្នាហើយក្តី ក៏នៅតែជួយគ្នាទៅវិញទៅមកដដែល ឱ្យតែរាស្ត្រប្រជានាថបានយល់នូវនយោបាយស្រុកទេស ។

ជំនាន់នោះ, នាយទាហានជើងក្រហម និងជើងខ្មៅចេះតែទាស់គ្នាដោយប្រកាន់បក្សពួក បារាំងក៏សូមឱ្យមានព្រះសង្ឃខ្មែរ ទៅទេសនាទូន្មានទាហានទាំងនេះ គ្រប់បន្ទាយក្នុងមួយខែម្តង ដើម្បីអប់រំឱ្យមានសីលធមិនិងចរិយាមារយាទល្អឡើង.។

ទាហានជើងក្រហមគឺជាយុទ្ធជន (ទាហានចម្បាំង) រុំពោះរុំជើងក្រហម, កន្តិបក្រហម ។ ទាហានជើងខ្មៅរុំពោះ , រុំជើងខ្មៅ , កន្តិបខ្មៅ ហៅថាក្រុមរក្សាស្រុក ដែបគ្នានឹងតម្រួតយើងសព្វថ្ងៃនេះ ។

ការចាត់ព្រះសង្ឃឱ្យទៅទេសនា ឬធ្វើសន្និសីទ ដើម្បីអប់រំទាហានតាមលទ្ធិព្រះពុទ្ធសាសនា ជាភារៈលើពុទ្ធសាសនបណ្ឌិត្យ (Institut Bouddhique) ចាត់ ។ ជួនណាអានចាត់ព្រះសង្ឃឱ្យទៅទេសនាអប់រំទាហានខ្មែរក្រោម ដូចជានៅមាត់ជ្រូក (Chaudoc) ជាដើរ ។

កាលនោះ, លោក លោក*ស៊ឺង ង៉ុកថាញ់* ធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ និងព្រះរាជបណ្ណាល័យ ដែលរួមអគារជាមួយគ្នាក្រោមបង្គាប់នាងកញ្ញាជាតិបារាំងម្នាក់ឈ្មោះ*ការ ប៉ឺព្លែស*



*(Melle Karpelès)* ដែលបានរាំនៈជាអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ និងជាអ្នកគ្រប់គ្រងព្រះរាជបណ្ណាល័យ (Secrétaire la générale de l'Insittut Bouddhique et conservateur de la bibliothéque royale) ។ លោ*ស៊ឺង ង៉ុកថាញ់* ទទួលភារៈជាអ្នកភារៈជាអ្នកចាត់ព្រះសង្ឃឱ្យទៅទេសនាប្រដៅទាហានជំនួសកញ្ញា*ការប៉ឺឡែស* ។ ម្ល៉ោះហើយជាឱកាសល្អឱ្យលោកជ្រើសរើសតែព្រះសង្ឃណាដែលស្នេហាជាតិមុតមាំ និងបានរៀហារប៉ុនប្រសប់ពន្យល់ , បញ្ចុះបញ្ចូលពួកទាហានដោយអាស្រ័យព្រះធមិទេសនាឱ្យចេះស្រឡាញ់ជាតិ , ឱ្យចេះតស៊ូ ។បេ។

ឯព្រះសង្ឃដែលស្នេហាជាតិមុតមាំ គឺលោកអាចារ្យ*ហែម ចៀវ* ,សាស្ត្រាចារ្យភាសាបាលី,លោកគ្រូអាចារ្យ**ប៉ាង ខាត់** សាស្ត្រាចារ្យខាងភាសាសំស្ក្រឹត,លោកគ្រូអាចារ្យ*ស្វ ហាយ* ក្រុមជំនុំព្រះត្រៃបិដក,លោកគ្រូអាចារ្យ*អ៊ុក ជា*[១], លោកគ្រូអាចារ្យ*ខៀវ ជុំ* (ពីអង្គរនេះគង់វត្តលង្កា)ជាដើម ។

លុះត្រឡប់មកពីធ្វើសន្និសីទវិញ,ព្រះសង្ឃមួយអង្គៗ តែងធ្វើសេចក្តីរាយការណ៍ជាលាយលក្ខណ៍អក្សរជូនទៅអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ចំពោះលទ្ធផលនៃការទៅទេសនា ហើយនិងការរាយការណ៍ជូនលោក*ស៊ឺង ង៉ុកថាញ់* អំពីលទ្ធផលនៃការទាក់ទងជិតស្និទ្ធជាមួយនាយទាហានក្រោយពេលទេសនា។

លុះដឹងថានាយទាហានណាដែលសង្ឃឹមថា អាចនឹងចូលចិត្តរួបរួមពួតដៃគ្នាក្នុងការបដិវត្តន៍ដេញបារាំងបាន, លោក*ស៊ឺង ង៉ុកថាញ់* ក៏ចាត់លោក*ជុំ មួង* ឱ្យទៅបញ្ជាក់បន្ថែមឱ្យនាយទាហាននោះរិតតែច្បាស់ការតទៅទៀត ។ ក្នុងពេលដែលលោក*ជុំ មួង* ចូលទៅជួបនឹងនាយទាហានខ្មែរម្តងៗ,បេទាហានបារាំង (សក្តិធំៗ) ចេះតែសម្លឹងមើលលោកត្បិតជាមនុស្ស

១.លោកគ្រូអាចារ្យអ៊ុក ជាធ្វើជាគ្រូបង្រៀននៅពុទ្ធិកបឋមសិក្សាវត្តលង្កា ក្រោយមកបានរត់ទៅនៅបឹងកក់ ដើយបារាំងរកចាប់ខ្លួនក្នុងរឿងធ្វើបាតុកម្មសុំឱ្យបារាំងដោះលែងលោកអាចារ្យហែម ចៀវ(១៩៤២) ។

ចម្លែក ។ ជំនាន់នោះ,នាយទាហានខ្មែរមានសក្តិធំបំផុតត្រឹមអាដហ្សុយដង់ (adjudant) ប៉ុណ្ណោះ ។ មានទាហានជាច្រើនបានស្ម័គ្រចិត្តចូលដៃជាមួយ ។ ឯទាហានខ្លះដែលមិនទុកចិត្តដោយយល់ថាគេស្រឡាញ់បារាំងដុះស្លែងទៅហើយ ក៏មិនហ៊ាននៅជិតគេមខ្លាចរែកការណ៍ដឹងដល់បារាំង ។

ចំណែកខ្ញុំ*(ប៊ុណ្ណចន្ទ័ ម៉ុល)* និងលោក*នួន ខួង*[(១)] បានត្រូវចាត់ឱ្យដើរ បញ្ចុះបញ្ចូល, ទាក់ទងនឹងប្រជាជនខាងក្រៅព្រមទាំងតម្រូវឱ្យឃ្លបយកការណ៍ឱ្យពិតប្រាកដ ពីចំនួនទាហាន,ចំនួនសព្វាវុធ ព្រមទាំងទីកន្លែងបន្ទាយរបស់កងទ័ពបារាំងផង ។

បណ្តាក្រុមបដិវត្តទាំងអស់,មានតែខ្ញុំ*(ប៊ុណ្ណចន្ទ័ ម៉ុល)* ម្នាក់ទេដែលមានវ័យក្មេងជាងគេហើយការបានការគ្រប់យ៉ាង ។ នៅផ្ទះខ្ញុំ*(ប៊ុណ្ណចន្ទ័ ម៉ុល)* នៅផ្សារស៊ីញ្ញែក(ភ្នំពេញ) មានលក់កាហ្វេ_គុយទាវ ហើយជាកន្លែងប្រជុំសម្រាប់ពួកបដិវត្តផង ដែលតែងតែទៅទទួលទាននៅទីនោះហើយលបលួចខ្សឹបប្រាប់ហេតុការណ៍គ្នានិងគ្នា ។

បើមានពួកគិញបារាំងចូលមកទទួលទានដើម្បីស៊ើបការណ៍,ខ្ញុំ*(ប៊ុណ្ណចន្ទ័ ម៉ុល)* បានលើករូបផ្កែ[(២)] ដាក់ទៅលើជញ្ជាំងជាសញ្ញាប្រាប់គ្នាថា ប្រយ័ត្នកុំឱ្យនិយាយគ្នាពីនយោបាយដ្បិតមានគិញបារាំងនៅទីនេះដែរ ។ ឯពួកបដិវត្តកាលបើឃើញរូបផ្កែនៅលើជញ្ជាំងក៏ឈប់និយាយទៅដោយជឿខ្ញុំ*(ប៊ុណ្ណចន្ទ័ ម៉ុល)* ដែលបានស្គាល់គិញបារាំងស្ទើរតែទាំងអស់ ។ ក្នុងរឿងនេះ, ខ្ញុំ*(ប៊ុណ្ណចន្ទ័ ម៉ុល)* មានសហការីម្នាក់ទៀតឈ្មោះ*ជួន ប៊ុណ្ណារាហោង*[(៣)] ដែលធ្វើអាជ្ញាសាលានៅផ្ទះជាប់ល្វែងគ្នាជួយធ្វើការផង ។

១.លោកនួន ខួង,មានអាការរោគក្នុងខ្លួនដោយអាមណាមជាប់គុកកោះត្រឡាចមក,បានទទួលនិច្ចកម្មនៅមន្ទីរពេទ្យព្រះកេតុមាលា(ភ្នំពេញ) ។

២.រូបផ្កែនោះសម្រាប់ឱ្យសញ្ញាថាមានផ្កែបារាំងមកហើយ ។

៣.លោកជួន ប៊ុណ្ណារាហោង សព្វថ្ងៃនេះធ្វើតំណាងរាស្ត្រ ។



# -២-

# ការចូលមកដល់ នៃកងទ័ពជប៉ុន

បកដល់ឆ្នាំ១៩៤០ កាលកំពុងតែគូររឿងនយោបាយនេះ,ទទួលមានកងទ័ពជប៉ុនដែលធ្វើសង្គ្រាមតទល់នឹងពួកបច្ចាមិត្រ (គឺអាមេរិក, អង់គ្លេស, បារាំង ។ល។ ) បានចូលមកក្នុងប្រទេសឥណ្ឌូចិន តាមសេចក្តីព្រមព្រៀងសម្ងាត់ជាមួយ*គូវែរណើរហ្សេណេរ៉ាល់* នៅហាណូយដែលយល់ព្រមឱ្យចូលកាំងទើសទ័ល មកពីយល់ថាកងទ័ពបារាំងពុំអាចទល់ទល់នឹងជប៉ុនបានហើយ ក្រោយមកគូវែរណើរហ្សេណេរ៉ាល់នោះ ក៏គេចខ្លួនបាត់ទៅ ។

កងទ័ពជប៉ុនបានចូលមកដល់ប្រទេសកម្ពុជា មុនពេលរាជាភិសេកស្តេចសីហនុ (១) ។ ឆ្លៀតឱកាសនោះលោក*ស៊ឺង ង៉ុកថាញ់* បានទៅទាក់ទង ជាការសម្ងាត់ជាមួយមេទ័ពជប៉ុនតាមរយៈមេហាង *ដាយណង់គូស៊ុ* ដែលតាំងនៅមុខផ្សារចាស់(ភ្នំពេញ)នៅជ្រុងផ្លូវពីកែ(ឥឡូវវិថីឧកញ៉ាផ្លុង)និងជ្រុងផ្លូវអូហ៊ីយេ ឥឡូវនេះជាវិថីអង្គអេង ដើម្បីសុំជាជំនួយក័តរបស់គេឱ្យជួយធ្វើអន្តរាគមន៍ផង ក្រែងពួកបដិវត្តន៍ធ្វើការទៅហើយលោជាភ្លាត់បែកការណ៍ឡើងមុខជាបារាំងចាប់ ធ្វើទោសមិនខាន ។

សូមជ្រាបផងថាហាង *ដាយណង់គូស៊ី* ដែលចូលមកតាំងហាងលក់ទំនិញប៉ុន្មានឆ្នាំមុនសង្គ្រាមលោកលើកទី២នេះ គឺជាហាងសម្រាប់ធ្វើចារកម្មស៊ើបការណ៍ ចំនួនកងទ័ពនិងចំនួន

១.ស្តេចសីហនុប្រកាសជាមហាក្សត្រខ្មែរនៅថ្ងៃ២៥ មេសា ១៩៤១

យុទ្ធោបករណ៍របស់បារាំងដែរ ។ គេស៊ើបដឹងអស់ថាខ្មែរស្នេហាជាតិមានប៉ុន្មាននាក់ ហើយគេព្រមជួយក្នុងការទាក់ទងនេះ ដោយខ្លួនគេក៏ជានាយទាហានអ្នកចារកម្មដែរ ។ ហើយគេក៏បានទាក់ទងតទៅទៀត ជាមួយមេទ័ពធំរបស់គេទៀត ។ ឯការទាក់ទងរវាងលោក*ស៊ឹង ង៉ុកថាញ់* និងកងទ័ពជប៉ុនចេះតែមានរហូតមកដោយខ្ញុំ*(ប៊ុណ្ណ ច័ន្ទម៉ុល)*ជាអ្នកនាំសំបុត្រសម្ងាត់ទៅឱ្យពួកជប៉ុន ។

លោក*ស៊ឹង ង៉ុកថាញ់* បានប្រាប់ពួកបដិវត្តថាត្រូវធ្វើការឱ្យប្រយ័ត្នមែនទែន កុំឱ្យបែកការណ៍តែប្រហែលឱ្យបែកការណ៍មុខជាបារាំងវាចាប់ហើយ ។ ហើយបើមានការថ្លស់ធ្លោយដោយហេតុណាមួយ , ត្រូវតែប្រញាប់ប្រញាល់រត់ចូលទៅឯកងតម្រួតយោធាជប៉ុន (កងអាវុធហត្ថ)ដែលគេយកកន្លែងនោះ សង់ធនាគារជាតិកម្ពុជាសព្វថ្ងៃនេះ គេអាចការពារយើងមិនឱ្យបារាំងចូលទៅចាប់បាន ។

ចំណែកខាងព្រះសង្ឃមានលោកគ្រូអាចារ្យ *ហែម ចៀវ* ជាដើម , តែកាលណាមានឱកាសនិមន្តចេញទៅខេត្តក្រៅ ដោយមានការអ្វីក្តី ដោយត្រូវគេនិមន្តទៅទេសនាក្សី លោកតែងតែខិតខំជួយធ្វើការពន្យល់, បញ្ចុះបញ្ចូល, ណែនាំឱ្យភ្លឺរឿងស្នេហាជាតិ,ឱ្យអង់អាច, ក្លាហានក្នុងការតស៊ូធ្វើបដិវត្តយកឥស្សរភាពពីបារាំងមកវិញ , បានលទ្ធផលជាទីគាប់ចិត្ត ។

ប្រជារាស្ត្រខ្លះ មានសទ្ធាជ្រះថ្លា បានចូលកុសលជាប្រាក់ ដើម្បីយកមកចាត់ចែងចំណាយក្នុងរឿងនេះផង ។

ខាងគ្រហស្ថវិញ លោក*ជុំ មួង* ,ខ្ញុំ*(ប៊ុណ្ណ ច័ន្ទម៉ុល)* លោក*នួន ឌួង* និងមានគ្នាច្រើនបន្តទៅទៀត ក៏បានខំប្រឹងប្រែងធ្វើការដោយពេញសមត្ថភាពគ្រប់ៗគ្នាដែរ ។

សូមជម្រាបថា កាលណោះទាហានបារាំង មានតិចណាស់នៅស្រុកខ្មែរ ។ បន្ទាយមួយៗកានតែទាហានខ្មែរភាគច្រើនជាងដែលនៅក្រោមបង្គាប់នាយទាហានបារាំង ។ ឯពលទាហានបារាំងបានត្រូវស្លាប់ជាច្រើន កាលសង្គ្រាមរវាងបារាំងនិងសៀម ។ ក្រៅពីនេះត្រូវបញ្ជូនទៅ



ជួយច្បាំងឯប្រទេសបារាំង ។ ចំណែកបារាំងស៊ីវិលក៏ត្រូវជាប់កំណែណ្ឌចូលបម្រើក្នុងកងទ័ពវាត់តែង ប្រទេសបារាំង ។ ខេត្តខ្លះមានសល់បារាំងម្នាក់,ពីរនាក់,ខេត្តខ្លះ៤-៥នាក់ ។ ខេត្តកំពង់ស្ពឺឥតមាន បារាំងសោះ ,គេយកចៅហ្វាយខេត្តឱ្យកាន់កាប់ការងារជារ៉េស៊ីដង់ផង ។ ឃើញថា ផែនការបដិវត្ត ពុំសូវជាតឹងតែងប៉ុន្មានទេ,អាចនឹងប្រព្រឹត្តទៅបាន ។ ប៉ុន្តែការពំរោកទៅទៀតនោះលោកអ្នកនាង នឹងដឹងនៅខាងមុខ ។

***

# -៣-

# ការសម្ងាត់ផ្ទះឡើង ការចាប់លោកគ្រូអាចារ្យ ហែម ចៀវ និងលោកនួន ឌួង

ពួកបដិវត្តន៍កំពុងតែខំធ្វើការរៀងៗខ្លួន,ប៉ុន្តែដោយហេតុតែជើងថ្មីខ្ចីនយោបាយពុំទាន់មានការពិសោធន៍ដោយគ្រប់គ្រាន់ ក៏ផែនការនោះបែកធ្លាយឡើង ដឹងការណ៍ដល់បារាំងដោយពួក

---

១-លោកគ្រូហែម ចៀវ ជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់,លោកគង់នៅវត្តឧណ្ណាលោម, កុដិជាមួយនឹងសម្តេចសង្ឃរាជជោតញ្ញាណោ(ជួន ណាត) លោកជាសិស្សសំណព្វនៃសម្តេច ។ កាលណោះសម្តេចនៅឋានៈជាព្រះពុទ្ធឃោសាចារ្យ ។

ទាហានខ្មែរ ដែលបានមកទាក់ទងជាមួយលោកគ្រូអាចារ្យ*ហែម ចៀវ*[១] និងលោក*នួន.ឌួង*នោះ ,មានទាហានខ្លះដែលស្រឡាញ់បារាំងដុះស្លែក្នុងខ្លួរដុះមិនជ្រះនោះ,វានាំយករឿង សម្ងាត់នេះទៅប្រាប់បារាំងថា លោកគ្រូអាចារ្យ*ហែម ចៀវ* និងលោក*នួន ឌួង* មេដឹកនាំពួកទាហានឱ្យបះបោរប្រឆាំងនឹងបារាំង ។ ទាហានខ្មែរចំនួន១៥នាក់ត្រូវចាប់ស្លាត់ៗដើម្បីកុំឱ្យបែកការណ៍ ។

នៅថ្ងៃ*១៧ កក្កដា ១៩៤២* ស្រាប់តែឃើញចាងហ្វាងគិញបារាំងម្នាក់និងលេខាធិការខ្មែរពីរនាក់ទៀត មានកាន់សំណុំលិខិតមួយដុំទៅផង , បានទៅជួបលោក*អ៊ឹង អ៊ី*នាយករដ្ឋមន្ត្រីព្រមទាំង លោក*ទា សាន*,រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងធម្មការនិងមន្ត្រីឯទៀត ។

គ្រានោះ,លោក*ទា សាន* បានបញ្ជាលោក*ជុំ មួង* កាលណោះធ្វើលេខាធិការក្រោមបង្គាប់លោកឱ្យទៅនិមន្តលោកគ្រូអាចារ្យ *ហែម ចៀវ* មក ។ លោក*ជុំ មួង* នឹកភ័យថាប្រហែលជាមានការណ៍ធំហើយក្នុងរឿងសម្ងាត់ជាមួយគ្នា តែចាប់លោកគ្រូអាចារ្យ*ហែម.ចៀវ* ទៅនឹងរាលដាលមកដល់អាត្មាអញមិនខាន ប៉ុន្តែពុំទាន់ដឹងច្បាស់ជារឿងអ្វីដែរ ? ដោយពុំហ៊ានសួរគេ ។

លោក*ជុំ មួង* ក៏ទៅវត្តឧណ្ណាលោម និមន្តលោកគ្រូ**ហែម ចៀវ** លោកក៏បាននិមន្តមកជាមួយគ្នាជាបន្ទាន់ ។ តាមផ្លូវ , លោកក៏បានសួរលោក*ជុំ មួង*ពីដំណើរដែលលោករដ្ឋមន្ត្រីឱ្យមកនិមន្តនេះ ។ លោក*ជុំ មួង*ក៏ទូលលោកតាមដំណើរដែលបានឃើញតែពុំដឹងជារឿងអ្វី ។ លោកមានពុទ្ធដីកាថា : បើវាសួរពីរឿងយើង យើងឆ្លើយប្រកែកថាតែពុំបានដឹងទៅ ! រួចលោកមានពុទ្ធដីកាតមកទៀតថា លោក*ស៊ឹង ង៉ុកថាញ់* មានផ្តាំថា បើបារាំងវាដឹងរឿង,ត្រូវឱ្យប្រញាប់រត់ចូលទៅឯមន្ទីរកងអាវុធហត្ថជប៉ុនជាប្រញាប់ទើបរួចខ្លួន ! យោបល់ទាំងពីរនាក់យល់ថាច្បាស់ជាបារាំងវាដឹងរឿងសម្ងាត់ហើយ ប៉ុន្តែពុំបានគិតដល់រឿងអ្វីទេ នឹកថាប្រហែលជាវាគ្រាន់តែហៅសួរសិនតែប៉ុណ្ណោះទេយ៉ោងមើល៍ ?

លុះលោកគ្រូអាចារ្យ**ហែម ចៀវ** ទៅដល់ស្រាប់លោក *ទា សាន* ប្រើបម្រើឱ្យអៅ



ទិញអោ១អាវ១បកឱ្យលោកគ្រូអាចារ្យ*ហែម ចៀវ*ស្លៀក ដោយផ្លាស់ស្បង់ចីពរពីខ្លួនភ្លាមហើយបារាំងវានាំទៅតាមរថយន្តវាបាត់តែម្តងទៅ រកតែរត់ទៅប្រាប់អ្នកណាក៏មិនទាន់ ។ គិតទៅពួកគេចាប់លោកផ្សឹកទាំងឥតជិនុំសោះ !

លោក*ជុំ មួង* កាន់តែភ័យខ្លាំងថាច្បាស់ជាបារាំងចាប់ខ្លួនទៀតជាមិនខាន ។ លុះដល់ចេញពីធ្វើការក៏ទៅជម្រាបលោក*ស៊ឹង ង៉ុកថាញ់* តាមដំណើរ ។ លោកក៏ប្រាប់ថាឱ្យប្រយ័ត្នខ្លួនឱ្យមែនទែន បារាំងប្រាកដជាចាប់យើងហើយ ។

រឿងចាប់លោកគ្រូអាចារ្យ*ហែម ចៀវ* ក៏ឆ្អើលឆោឡោឡើង ក្នុងបណ្តាពួកលោកសង្ឃជានិស្សិតនៃសាលាបាលីជាន់ខ្ពស់ និងវត្តនានាក្នុងទីក្រុងភ្នំពេញ ដែលសុទ្ធតែជាមិត្តភក្តិនិងជាសិស្សរបស់លោក ។

ក្នុងពេលនោះ,លោក*នួន ឌួង*[១] ក៏ត្រូវគិញបារាំងទៅចាប់ឯផ្ទះដែរ ។

ឯក្រុមអ្នកបដិវត្ត ដោយមានព្រះសង្ឃជួយផង ក៏បានចាត់ចែងផ្សាយដំណឹងនេះ ទៅគ្រប់វត្តក្នុងទីក្រុងនិងទៅដល់ខេត្តក្រៅដែលនៅជិតទីក្រុងខ្លះ , នៅឆ្ងាយខ្លះដោយមធ្យោបាយដែលធ្វើបាន ។ តាមបញ្ជាពីលោក**ស៊ឹង ង៉ុកថាញ** ឱ្យទាំងអស់គ្នាបាតុកម្មនៅថ្ងៃ២០កក្កដា១៩៤២នៅមុខការិយាល័យនៃរ៉េស៊ីដង់ សុប៉េរីយើរ ដើម្បីតវ៉ាសូមឱ្យដោះលែងលោកគ្រូអាចារ្យហែម.ចៀវ និងលោកនួន ឌួង មកវិញ ។

បាតុកម្មនេះបានជាបន្លាយពេលវែងដល់ទៅថ្ងៃ២០កក្កដា នោះដោយហេតុនៅវេលាយប់ថ្ងៃ១៨កក្កដា, មានការជួបជុំព្រះសង្ឃនិងឧបាសក-ឧបាសិកាពីគ្រប់ទិសទី នៅវត្តលង្កាដើម្បីធ្វើពិធីបុណ្យចម្រើនព្រះជន្មវស្សាព្រះតេជគុណ ព្រះធម្មលិខិត*ល្វី ឯម* ,ចៅអធិការវត្តលង្កា និងជាចាង-ហ្វាងសាលាបាលីជាន់ខ្ពស់ផង ក្នុងឱកាសដែលលោកឡើងសមណសក្តិដ៏ខ្ពង់ខ្ពស់ជាទីសម្តេចព្រះធម្មលិខិត , ដោយក្នុងយប់នោះមានធ្វើពិធីចម្រើនព្រះបរិត្ត និងធម្មទេសនា ។ ដល់ព្រឹកឡើង

---

១.លោកនួន ឌួងធ្វើជាក្រុមជុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត ។ ផ្ទះនៅផ្សារកណ្តាលខាងជើងវត្តឧណ្ណាលោម មានលក់និងជួសជុលទោចក្រយាន

១៩កក្កដា ទើបរៀបចំពិធីស្រោចទឹកពុទ្ធមន្ត រួច វេរភត្តប្រគេនព្រះសង្ឃទៀតជាកិច្ចបង្ហើយបុណ្យ ។ ឃើញថាជាការងាយស្រួលនឹងផ្សាយដំណឹងប្រាប់គ្នីគ្នា ដែលមកពីទីជិតឆ្ងាយ មកកាន់ពិធីនេះ ។

ក្នុងឱកាសនោះ,ខ្ញុំ*(ប៊ុណ្ណច័ន្ទ ប៉ុល)* ជាអ្នកដើរការផ្សាយដំណឹងដល់ព្រះសង្ឃគ្រប់វត្តក្នុងទីក្រុងភ្នំពេញ ។ ពេលនោះខ្ញុំប្រើទោចក្រយានមួយរបស់ខ្លួនក្នុងបេសកកម្មនេះ ។

ចំណែកលោក*ស៊ឹង ង៉ុកថាញ់* ,ក្រោយពេលដែលអាចារ្យ*ហែម ចៀវ* និងលោក*នួន ឌួង* ត្រូវបារាំងចាប់ហើយលោកក៏បានភៀសខ្លួន ទៅពួនការិយាល័យនៃកងអាវុធហត្ថជប៉ុន (gendarmerie japonaise) ទៅ ដើម្បីគេចឱ្យផុតពីការចាប់ចងរបស់បារាំង សម្រាប់ដឹកនាំក្រុមបដិវត្តធ្វើការតទៅទៀត ។ ប៉ុន្តែការទាក់ទងរវាងលោកនឹងខ្ញុំ *(ប៊ុណ្ណច័ន្ទ ប៉ុល)* នៅតែមានដដែលតាមកុមារម្នាក់នៅផ្ទះលោក ដែលជាអ្នកនាំភោជនាហារទៅជូនលោក ។

នៅយប់ថ្ងៃ*១៩ កក្កដា*,លោក*ស៊ឹង ង៉ុកថាញ់* បានផ្តាំឱ្យខ្ញុំ*ប៊ុណ្ណច័ន្ទ ប៉ុល* ទៅយកកាំភ្លើងមួយដើមពីផ្ទះលោក ទៅជូនលោកឯការិល័យកងអាវុធហត្ថជប៉ុន ។ ខ្ញុំក៏ធ្វើតាមបញ្ជាលោកដោយមានលោក*ជួន ប៊ុណ្ណារ៉ាហេង* ជូនដំណើរទៅផង ។ លុះដល់មុខទីស្តីការកងអាវុធ-ហត្ថជប៉ុនហើយ,ខ្ញុំបានដាក់កាំភ្លើងផ្ទាប់នឹងដើមទ្រូង យកមាត់ព្រៃចុះក្រោមយកស្ទាយកាំភ្លើងឡើងលើ ហើយរត់ត្រុយចូលទៅតែម្នាក់ឯង ដោយទុកឱ្យលោក*ជួន ប៊ុណ្ណារ៉ាហេង* ឱ្យនៅចាំខាងក្រៅ ។

នៅវេលាដែលឃើញខ្ញុំទៅដល់,នាយទាហានជប៉ុនដែលឈរយាមមាត់ទ្វារ ភ្ជង់មាត់ព្រៃកាំភ្លើងមកចំដើមទ្រូងខ្ញុំ ។ ដោយឃើញគ្រោះថ្នាក់ដល់ជីវិតមកដល់ហើយៗ ពុំដឹងនិយាយគ្នាដូចម្តេចឱ្យស្តាប់បានដ្បិតខ្ញុំពិនចេះនិយាយជប៉ុនជប៉ុនមិនចេះនិយាយខ្មែរខ្ញុំមានសេចក្តីតក់ស្លុតក្រៃលែងក៏ប្រញាប់តបដោយភាសាអេរិញ ដោយរារាំងដៃយ៉ាងញាប់ស្អេក ហើយចង្អុលទៅខាងក្នុងដើម្បីឱ្យអ្នកយាមយល់ថាមានការរកអ្នកខាងក្នុងផ្ទះ ។ លុះយល់សេចក្តីហើយ អ្នកក៏ស្រែកហៅអ្នកខាងក្នុងដែលចេះខ្មែរចេញមកជួប ។ លុះសួរដឹងការណ៍ហើយ,គេក៏ខ្ញុំចូលទៅខាងក្នុង ខ្ញុំ



បានជួបនឹងលោក*ស៊ឹង ង៉ុកថាញ់* នៅចំពោះមុខសក្តិពាជប៉ុន ,ជានាយតម្រួតយោធាជប៉ុន ។ នាយតម្រួតជប៉ុន និងលោក*ស៊ឹង ង៉ុកថាញ់* បានផ្តាំហើយផ្តាំទៀតនឹងខ្ញុំថាបាតុកម្មដែលត្រូវធ្វើនៅថ្ងៃ ស្អែក,ត្រូវប្រតិបត្តិឱ្យទៀតទាត់តាមផែនការនិងកម្មវិធីដូចតទៅ ៖

នៅវេលាព្រឹកស្អែកនេះ,ត្រូវឱ្យលោកសង្ឃ និងគ្រហស្ថសបាតុករទាំងប៉ុន្មានធ្វើភត្តកិច្ច (ឆាន់បាយ)ឱ្យហើយស្រេចពីព្រលឹមម៉ោង៦ , រួចទៅជួបជុំគ្នានៅមហាវិថីឌូដាដឺឡាគ្រេ(ឥឡូវមហាវិថីនរោត្តម)ចំពីក្រោយមាត់ទ្វារពីខាងលិចព្រះរាជវាំង ។ លុះជួបជុំហើយត្រូវនាំគ្នាដើរជាក្បួនដោយសន្តិវិធី គឺដៃទទេរឥតសស្ត្រាវុធ,ឱ្យមានរបៀបរៀបរយនិងស្ងប់ស្ងៀម កុំឱ្យមាត់កឡើយ ហើយឱ្យមានបដាមួយផ្ទាំងពីខាងមុខផង ដោយចារិកពាក្យស្លោកថា*«យើងខ្ញុំសូមឱ្យដោះលែងលោកអាចារ្យ ហែម ចៀវ និងលោកនួន ឌួង មកវិញ»* រួចឱ្យក្បួនទៅឈប់នៅមុខការិយាល័យនៃរ៉េស៊ីដង់ស៊ុប៉េរីយើរ (១) ។ ថាបើប៉ូលីសវាដេញឬវាវាយ,ត្រូវឱ្យខំស៊ូទ្រាំនៅទៅទៀត កុំតដៃឡើយគឺកុំធ្វើអ្វីៗតបវិញឱ្យសោះ,ត្រូវនៅឱ្យស្ងៀម ។ ថាបើអង្គុយចាំរហូតហួសម៉ោង១២ថ្ងៃត្រង់ទៅហើយ , បារាំងនៅតែមិនសម្រេចឱ្យតាមការសុំទេនោះ,ក្បួនបាតុកម្មត្រូវត្រឡប់មកវិញហើយឈប់ពីមុខការិយាល័យកងអាវុធហត្ថជប៉ុន ថ្លែងការប្រាប់ក្រុមតម្រួតយោធាជប៉ុនតាមដំណើរនិងសុំឱ្យក្រុមនេះមេត្តាជួយធ្វើអន្តរាគមន៍ ចំពោះរដ្ឋាភិបាលបារាំងដើម្បីឱ្យអ្នកទាំងពីរដែលបារាំងចាប់យកនោះបានរួចខ្លួនមកវិញ ។ ផាត្រូវធ្វើតាមបញ្ហានេះ ទើបកងទ័ពជប៉ុនអាចនឹងជួយធ្វើអន្តរាគមន៍ទាក់ទងជាមួយរាជការបារាំងបាន ។

លុះត្រឡប់មកវិញខ្ញុំ*ប៊ុណ្ណច័ន្ទ ប៉ុល* ក៏បាននាំបណ្តាំនេះទៅប្រគេនព្រះសង្ឃគ្រប់វត្តក្នុងទីក្រុងពេនវត្តលង្កាជាដើម ព្រមទាំងបានចាត់ឱ្យផ្សាយប្រាប់គ្រហស្ថជាបាតុករ ព្រមទាំងជំរាបលោកប៉ាច ឈឺន ផង ។

***

១.ការិយាល័យនោះជាអគារបីជាន់ស្ថិតនៅខាងលិចវត្តភ្នំ ជិតសណ្ឋាគារឡឺរ៉ូយ៉ាល់,ឥឡូវធ្វើទីស្នាក់ការរដ្ឋមន្ត្រីក្រសួងផែនការ

## -៤-

# បាតុកម្មដាស់ខ្មែរមុនដំបូង
# ( ថ្ងៃទី២០ កក្កដា ១៩៤២ )

នៅថ្ងៃទី២០កក្កដា ១៩៤២វេលាម៉ោង៦,លុះជួបជុំគ្នាហើយក្បួនបាតុកម្មដែលមានលោកសង្ឃនិងគ្រហស្ថជាច្រើនមីដេរដាសពេញក្រុង បានចេញដំណើរពីទីណាត់ឆ្ពោះទៅការិយាល័យនៃរ៉េស៊ីដង់ ស៊ុប៉េរីយើរ ។ គឺវត្តលង្កាចេញពីវត្តលង្កា វត្តឧណ្ណាលោមចេញពីឧណ្ណាលោម ។ល។ មកប្រជុំគ្នានៅក្រោយវាំង និងមានលោក*ប៉ាច ឈឿន* ជាអគ្គនាយក,ដើរនាំមុខយ៉ាងអង់អាច, ក្លាហានផង ។ ក្បួនដើរបាតុកម្មយ៉ាងអង់អាចឥតភ្លឹក គិញបារាំង ខ្មែរ យួន ដើរហែតាមខាង ,តែមុខស្លេកស្លាំងបានខ្លាចបាតុករ ។ (គិញបារាំងឈ្មោះ Sambraige ប្រុងប្រយ័ត្នជាងគេ) ។ ទាំងអស់គ្នាឆ្ពោះទៅកាន់ការិយាល័យនៃរ៉េស៊ីដង់ស៊ុប៉េរីយើរ ។

លុះបានដល់នៅទីដៅហើយ,ពួកបាតុករ ក៏ឈប់កកកុញនៅទីនោះពាសពេញនៅខាងលិចវត្តភ្នំទល់មុខហោតិល Le Royal ដោយដាក់បដាពីមុខ ។ មុនដំបូង ,លោក*ប៉ាច ឈឿន* បានចេញមុខនិយាយប្រាប់ហេតុការតាមដំណើរជាមួយអ្នករាជការបារាំងខ្លះ ដែលចេញមកឈរនៅចាំមាត់ជណ្តើរខាងក្រោមហើយនិងសុំជួបនឹងរ៉េស៊ីដង់ស៊ុប៉េរីយើរ ។ ពួកបារាំងវាប្រាប់មកវិញថា : ចូលគ្នាច្រើនមិនបានទេ, ត្រូវឱ្យជ្រើសរើសតែមេៗបីបួននាក់ជាតំណាងទៅជួបនឹងរ៉េស៊ីដង់ស៊ុប៉េរីយើរទើបបាន ! ឮដូច្នេះ, ពួកបាតុករស្រែករញ៉ែឡើងថាទៅតែពីរបីនាក់មិនបានទេ ,វាចាក់ទៀតរហើយៗក៏ចេះតែរុញច្រានគ្នាចូលទៅមុខស្រុបន្ថែមទៀត ។ ដោយការរុញច្រានពីខាងក្រោយ



ខ្លាំងពេក ,អស់លោកខាងមុខទាំងព្រះសង្ឃទាំងគ្រហស្ថដែលមានលោក*ប៉ាច ឈឿន* ជាដើមក៏ជ្រុលខ្លួនចូលអគារធំនោះទៅ ។

ពួកបារាំងឃើញដូច្នេះ ក៏បិទទ្វារមុខមិនឱ្យក្រុមនេះចូលទៅបាន ហើយក៏ចាប់តែលោក*ប៉ាច ឈឿន* ម្នាក់នាំចូលទៅខាងក្នុង ,រួចវាបញ្ចេញតាមទ្វារក្រោយ ដាក់រថយន្តយកទៅបាត់ទៅ ។ ឯពួកប៉ូលីសក៏ខំខាឃាំងទប់កុំឱ្យពួកបាតុករចូលទៅបាន, ក៏បណ្តាលទៅជាវាយតប់គ្នាច្រួលច្របល់ឡើងពាសពេញទីនោះ ។ ពួកបាតុករខ្លះ ត្រូវរបួសនឹងដំបងប៉ូលីស,ចំណែកខាងប៉ូលីសក៏ត្រូវរបួសខ្លះនិងដងឆត្រលោកសង្ឃផង, នឹងដំបង, នឹងដុំឥដ្ឋ, នឹងកូនតឹង(១)ផង ។ បារាំងចាងហ្វាងគិញឈ្មោះ*ប្រ៊ូស្តិតុង* (Brocheton) ដែលក្បាលទំពែក បានត្រូវនឹងកូនតឹងដែលជាអាវុធពិសេស ក៏ហូរឈាមសស្រាក់មកលើមុខជិតអាវស្ទើមីក្រហមច្រាល...

ក្នុងពេលនោះ,ពួកបាតុករខ្លះដែលបានវាយពួកគិញក៏ត្រូវពួកគិញចាប់បានភ្លាមៗ នៅនឹងកន្លែងនោះទៅ ។ បាតុករខ្លះដែលវាចាប់បានភ្លាមៗមិនទាន់ វាក៏តាមរកស៊ើបចាប់តាមរូបថតដែលវាបានថតក្នុងពេលប្រឡូកគ្នានោះ ។ ពួកបាតុករខ្លះដែលពុំបានវាយតបទៅប៉ូលីសដូចគេក៏មានសេចក្តីភិតភ័យគេចវេះដោះខ្លួនចេញពីទីនោះ ដោយខ្លាចបារាំងចាប់ ។ ឯលោកគ្រូអាចារ្យប៉ាង ខាត់ ក៏ប្រឹងស្ទុះលោតចេញដកឃ្លាឱ្យផុតពីទីនោះដែរ ។ ប៉ុន្តែទោះបីគេចវេះយ៉ាងណា,ក៏បារាំងស្គាល់ឈ្មោះ,ស្គាល់មុខនៃព្រះសង្ឃជាមេៗច្បាស់អស់ទៅហើយ ។ ចំណែកខ្ញុំ(ប៊ុណ្ណចន្ទ-ម៉ុល)ដែលបានលើកទោចក្រយានគប់ប៉ូលីស ដោយស្វ័យប្រវត្តិ,ពុំដឹងជាខ្លួនលើកកង់គប់ប៉ូលីស

១-កូនតឹងនេះធ្វើដោយក្បាលឡោស៊ីដែកចងភ្ជាប់នឹងខ្សែកៅស៊ូវែង ។ កាលណាចោលទៅ,វាយឺត,លុះត្រូវហើយវាក៏មកត្រូវដៃវិញ កូនខ្លះគេយកដុំសំណធ្វើក៏បានដែរតាមដែលលោកជុំ មូងបានឃើញនឹងភ្នែកថាមានបាតុករម្នាក់ឈ្មោះរស់បានបង្ហាញថាអាវុធនេះលួចដាក់ទៅបង្ការខ្លួនក្រែងលោមានកើតហេតុក្នុងពេលបាតុកម្ម ។ ឈ្មោះរស់នេះត្រូវជាបងថ្លៃលោកអាចារ្យអ៊ុច រស់ ដែលជាមេហាងឱសថវិមានឯករាជ(មុខវត្តលង្កាភ្នំពេញ) ។ កាលពេលរត់ទៅជួបគ្នាឯបាត់ដំបង,លោករស់បានដំណាលប្រាប់លោកជុំមូងថាកាលបាតុកម្មនោះ,គាត់បានចោលកូនត្រូវបារាំង៤-៥នាក់ដែរ ។ ប៉ុន្តែតាមដំណឹងថាកាលនោះមានគ្នាច្រើនដែរដែលប្រើអាវុធពិសេសនេះ ។

ផងក៏ទៅមានជាប់រូបថតរបស់ប៉ូលីសដែរ។ការច្របូកច្របល់នេះ មិនដឹងជាថាដូចម្តេចឱ្យត្រឹមត្រូវទេព្រោះដែលខ្ញុំចាំបានឆត្រលោកសង្ឃក៏បានជាអាវុធពិសេស បុករុកត្រូវរបួសម្រេលេ ។ មានសាស្ត្រាចារ្យបារាំងម្នាក់បង្រៀនច្បាប់ សាលាច្បាប់(មន្ទីរសភាសព្វថ្ងៃនេះ)អធិប្បាយប្រាប់សិស្សរៀនច្បាប់ជំនាន់នោះថា «ដែលហៅថាអាវុធនោះមិនចាំបាច់តែកាំភ្លើង ដាវ លំពែងទេសូម្បីតែឆត្រលោកសង្ឃក៏ថាអាវុធបានដែរ» ។

សូមជម្រាបថា នៅពេលនោះ ប្រហែលខ្ញុំ(ប៊ុណ្ណចន្ទ ម៉ុល)លើកកង់ខាយវាំងពួកបាតុករកុំឱ្យគិញវាវាយទេ ,ប៉ុន្តែវាប្រចាប់ថាលើកកង់គប់វាទេវិញ ។ ក្នុងពេលនោះពួកគិញវាចាប់បានបាតុករជាច្រើននាក់ដាក់ឡានយកបាត់ទៅតែពុំអាចចំណាំបានថានរណាជានរណាឡើយ ត្បិតរវល់តែភ័យរៀងខ្លួន ហើយដោយគ្នាច្រើនពេក ពុំអាចស្គាល់មុខ ស្គាល់ឈ្មោះគ្រប់គ្នាបានឡើយ ។ ទ័ពជើងក្រហមបារាំងបាននាំយកមកគំរាមបាតុករ នៅពេលនោះជាច្រើនរយនាក់មានអាវុធគ្រប់ដៃ ។

ក្នុងពេលដែលពួកបាតុករកំពុងតែផ្អើលច្របូលច្របល់នោះ ខាងកងទ័ពជប៉ុនបានបញ្ជូនទាហានពីររថយន្តបន្ទុក ទៅឈប់នៅក្បែរនោះដែរ ប៉ុន្តែគេអាចជួយធ្វើអន្តរាគមន៍ជាមួយរដ្ឋាភិបាលបារាំងដូចម្តេចកើត ? បើវាខុសផែនការដែលគេបង្គាប់ឱ្យធ្វើអស់ទៅហើយ ។ ម្ល៉ោះហើយគេនៅតែស្ងៀមទៅ ។

ក្រោយពេលបាតុកម្មមិនសម្រេចនេះ ,បារាំងដើររកចាប់ម្នាក់ម្តង,ពីរនាក់ម្តង តាមរូបថត និងតាមដែលវាបានស្គាល់ពីមុនមកស្រាប់ផង ។ ម្ល៉ោះហើយពួកបាតុករដែលមានខ្លួនទាំងលោកសង្ឃទាំងគ្រហស្ថចេះតែគេចវេះ គេចខ្លួននិងរត់ចោលស្រុកអស់ជាច្រើននាក់ ។

ការធ្វើបដិវត្តន៍ពុំបានសម្រេច ការធ្វើបាតុកម្មក៏ពុំបានសម្រេចទៀត, មកពីពួកយើងចាប់ផ្តើមធ្វើមុនដំបូងផង និងមកពីកាលជំនាន់នោះ, ជាតិខ្មែរយើងនៅខ្ចីខ្លាំងណាស់ខាងនយោបាយស្រុកទេសត្បិតអីទើប នឹងបានបើកភ្នែកពុំទាន់បានប៉ុន្មានឆ្នាំផង ឯការបើកភ្នែកនេះក៏ដោយសារ



ការបំភ្លឺរបស់កាសែតនគរវត្តផង ដោយសារការខំប្រឹងប្រែងរបស់កាសែតនេះប៉ុណ្ណោះ ដែលខំចែកផ្លូវគ្នាដើរពន្យល់បញ្ចុះបញ្ចូល,បំភ្លឺប្រជាជាតិខ្មែរដែលដេកលក់ដោយខ្លាចពុកច្រវ៉ាក់ ។ សម័យនោះយើងមិនដែលនឹកនាចង់រើខ្លួន ឱ្យរួចពីខ្ញុំបារាំងសោះក្នុងរំឭកពីព្រោះសត្វត្បមកហើយដោយធ្លាប់ដឹងធ្លាប់ឮចាស់ៗដំណាលតៗគ្នាមកថា បារាំងបានចាប់អ្នកស្នេហាជាតិ,អ្នកនាំធ្វើបដិវត្តជំនាន់មុនៗដូចជាពោធិកំបោរ, ម៉ឺនពាង, អាចារ្យស្វា, ក្រឡាហោមគង់, ឧកញ៉ាពិត្ររលោកល្វេក , យកទៅព្រោសចោល ឯកោះត្រឡាចទាល់ស្លាប់ជាច្រើននាក់មកហើយ ឯអ្នកដែលក្បត់ជាតិគេឥតរវល់នឹងជាតិ គេខំតែផ្គាប់ផ្គុនបារាំង យកបុណ្យសក្តិទ្រព្យសម្បត្តិសម្បូរតែក្រុមគ្រួសារគេទៅ ។ ពួកនេះគឺពួកវាំង មានសីហនុជាដើម ខឹងនឹងខ្មែរគ្នាឯងជំនួសបារាំង ជេរប្រទេច,ជេរលោកសង្ឃថា«អាត្រងោល» ។

មួយវិញទៀត,កាលជំនាន់នោះ ,ពេលវេលាបានហុចឱ្យយើងល្មមតែបានសម្រេចដែរ ត្បិតកាលណោះ នៅឯស្រុកវាកំពុងជាប់ដៃនឹងសង្គ្រាមលោកលើកទីពីរ ,បារាំងនៅស្រុកយើងតិចណាស់ ហើយគ្រឿងសម្ភារៈសឹកក៏សុទ្ធតែចាស់ៗតាំង ពីសង្គ្រាមលោកលើកទីមួយ(១៩១៤-១៩១៨)មកម្ល៉េះ ។ វាពុំអាចបញ្ជូនទ័ពនឹងយុទ្ធោបករណ៍ពីស្រុកវាមកបង្ក្រាបយើងបានឡើយ។ គួរឱ្យស្តាយយ៉ាងក្រៃលែងដោយយើងធ្វើការឱ្យខុសផែនការ និងកម្មវិធីដែលត្រូវធ្វើនាំឱ្យខូចផែនការពុំបានសម្រេច។ គឺជាបដិវត្តដំបូងដែលនៅស្រុកយើងមិនដែលមានសោះ ។ ប៉ុន្តែបើទុកជាដូច្នេះក្តីក៏គឺជាគំរូ ជាលំអានល្អមួយទុកឱ្យកូនចៅ យុវជនជំនាន់ក្រោយដើរតាមដែរ ដោយគ្រាន់តែកែឬពិនិត្យឡើងវិញ នូវផែនការនិងកម្មវិធី ដែលពួកយើងបានធ្វើមិនបានសម្រេចនោះតើខុសត្រង់ណាឬមានឧបសគ្គអ្វីមកជំទាស់វាំង ទើបបានជាខកខានមិនបានសម្រេច ។ សូមជម្រាបថា ការដែលធ្វើដំបូងតែងមានខុសដូច្នេះ ទើបអាចរកត្រូវឃើញ ។ មានតែអ្នកឥតធ្វើអ្វីសោះដេកតែអេះពោះចាំមើលបំណាំទើបត្រូវរហូតឥតខុស ។ ប្រសិនបើនៅ ជំនាន់យើង,ឥតមានវីរជនណាម្នាក់គិតគូររើខ្លួនឱ្យរួចពីនឹមដែករបស់បារាំងទេ នោះយុវជនជំនាន់ក្រោយអាចនឹងបន្ទោសយើងបានថាយើងជា ចាស់ជំនាន់មុនឥតគិតរឿងសោះ បានជាបច្ឆាជនជំនាន់ក្រោយកើតឡើងនៅតែជាខ្ញុំបារាំងតទៅឥតមានពេលរួចជាអ្នកជាឡើយ ។

ហេតុនេះការបដិវត្តន៍ ដើម្បីរើបម្រះពីនឹមបារាំងនេះទោះបីខកខានមិនអានសម្រេចបែន , ក៏បានឈ្មោះថាពួកយើងបានត្រាយផ្លូវទុកឱ្យកូនចៅជំននាន់មុនដើរតាមដែរ ត្បិតប្រទេសឯទៀតៗ ដែលនៅក្នុងក្រញាំបរទេស មានប្រទេសឥណ្ឌាជាដើម ក៏គេខំរើបម្រះយកឥស្សរភាពដោយ សន្តិវិធី ឬវិធីអហិង្សាអស់ថិរវេលាយ៉ាងយូរដល់៣០ឆ្នាំ ស្លាប់មនុស្សរាប់សែននាក់ទម្រាំបាន សម្រេចបានឯករាជ្យ,មិនមែនធ្វើតែម្តងហើយបានសម្រេចទេ ។ ចុះបើយើងនោស្ងៀមមិនធ្វើអ្វី សោះ ? នោះរឹតតែលិចទៅទៀត ! នៅខ្ញុំគេរាប់ពាន់ឆ្នាំ,គ្មានពេលឃើញពន្លឺឯករាជ្យទេ ។

សូមនិយាយពីរេពងលោក*ជុំ មូង*បន្តិច ។ ក្នុងពេលបាតុកម្មនោះ,លោកពុំបានចូលរួមនឹង គេទេត្បិតត្រូវចាត់ឱ្យទៅស្តាប់ការនៅនឹងកន្លែងនៅក្រសួងធម្មការ ដែលជាកន្លែងធ្វើការតើរាជ-ការគេចាត់រឿងនេះដូចម្តេច?ប៉ុន្តែដោយអន្ទះសាចង់ដឹងរឿងពេក,ក៏បានចាត់លោក*អ៊ិត ធុយ*[១] ជាសិស្សសាលារដ្ឋបាល-តុលាការខ្មែរ ដែលនៅរៀនធ្វើការនៅក្រសួងមហាផ្ទៃនិងធម្មការឱ្យទៅ មើលការជំនួសក្នុងឋានៈជាប្រតិភូនៃក្រសួងធម្មការ ។ ហើយដើម្បីការពារខ្លួនកុំឱ្យបារាំងចាប់ លោកជុំ មូង បានធ្វើលិខិតមួយច្បាប់បោះត្រាក្រសួងធម្មការឱ្យកាន់កំដរខ្លួនផង ។

លុះលោក*អ៊ិតធុយ*ត្រឡប់មកវិញបានរាយការណ៍ថា បាតុកម្មនោះខកខានពុំបានសម្រេច ទេពួកបាតុករត្រូវបារាំងដេញចាប់រត់រប៉ាត់រប៉ាយអស់ហើយ ។

សូមជម្រាបបថា នៅល្ងាយថ្ងៃ១៩កក្កដា,ដោយភ័យខ្លាចក្រែងបារាំងចាប់មុនពេលបាតុកម្ម ត្បិតស៊ើបទៅដឹងថា មានឈ្មោះត្រូវចាប់នឹងគេដែរលោកមូង ក៏បានទៅទទួលទានដំណេកនៅផ្ទះ លោកញ៉ែម ធុច[២] នៅសង្កាត់ចាកអង្រែលើ,ខាងនាយស្ពានមុនីវង្ស,ទល់មុខនឹផ្ទះលោករស់[៣] ។

១-លោកអ៊ិត ធុយ ឥឡូវធ្វើជាអគ្គហេរញ្ញិកនៃអគ្គរតគារនៅភ្នំពេញលោកជាអ្នកស្នេហាជាតិម្នាក់ដែរ

២-លោកញ៉ែម ធុច គ្រានោះធ្វើលេខាធិការនៅក្រសួងធម្មការដែរ

៣-លោករស់ នេះហើយដែលលបដាក់កូនតឹងទៅផងក្នុងពេលបាតុកម្ម



លុះព្រឹកឡើងថ្ងៃទី២០កក្កដា ,ទើបនាំគ្នាទាំងបីនាក់នោះមកភ្នំពេញជាមួយគ្នា ប៉ុន្តែមក ដល់ភ្នំពេញក៏បានបែកគ្នា ។ លោករស់ ទៅចូលក្នុងពួកបាតុករ ។ ឯលោកញ៉ែម ធុច និងលោកជុំ-មូង ក៏ចូលទៅកាន់ការិយាល័យធ្វើការដូចធម្មតា ។

ដោយភិតភ័យញ័រសាច់ជាប់ ខ្លាចបារាំងចាប់ នៅយប់ថ្ងៃ២០កក្កដា នោះលោកជុំ មូង ទទួលទានដំណេកពុំលក់សោះ ។ គ្រាន់តែឮសូររថយន្តបើកមុខផ្ទះ,ក៏ភ័យស្លោភ្នែកដែរ ដោយស្មាន ថាប៉ូលីសគិញបារាំងមកចាប់ ។ លុះយប់ជ្រៅប្រហែលម៉ោង៣ បានលង់លក់បន្តិចទៅស្រាប់តែ យល់សប្តិឃើញទៅមើលគ្រេដងព្រោននៅមាត់សមុទ្រ ។ ថាចុះទៅក្នុងទឹករាក់ៗត្រឹមជង្គង់ ស្រាប់តែឮសូរខ្សែងក្តក់ប៉េះៗរួចក្រឡេកទៅឯនាយឆ្ងាយ ឃើញទឹកសមុទ្រឡើងកម្ពស់ចុងត្នោត កាន់តែលឿនជិតមក លោកនឹកភ័យក៏តតេះតតះឡើងរួចទៅលើមាត់ច្រាំងសមុទ្រ ហើយក៏ភ្ញាក់ ឡើង ។ ទើបសម្រេចចិត្តថាត្រូវតែរត់គេចទើបផុតភយន្តរាយ ដូចក្នុងការយល់សប្តិ ។

លុះដល់ម៉ោង៤កន្លះទៀបភ្លឺនៃថ្ងៃ២១កក្កដា ក៏ចេញដំណើរទៅបាត់ដំបង[១] តាមអយ-ស្ម័យយាន ដោយសរសេរសំបុត្រទុកឱ្យគេសុំច្បាប់ឱ្យ ដាក់ក្នុងសំបុត្រកុហកចោលដើងថាទៅ សួរបងឈឺធ្ងន់ឯព្រៃវែង,គិតថាបើសុំច្បាប់ត្រង់ច្បាស់ជាគេស្កាត់ទាន់កណ្តាលផ្លូវខកដំណើរ។ហេតុ នេះប្រាប់គេថាទៅព្រៃវែងហើយទៅបាត់ដំបងឯណោះទៅវិញ ។ ទៅដល់ពោធិ៍សាត់បានឃើញ គិញបារាំងចាប់លោកសង្ឃបាតុករពីរ-បីអង្គដែលរត់គិតឆ្លងទៅសៀមបញ្ជូនមកភ្នំពេញ ។ គិញ នោះឈ្មោះទីកុញូន ស្គាល់លោកជុំ មូង បានសួរថាទៅណា ? លោកឆ្លើយកុហកថាទៅត្រពាំង ជង[២] ,ប៉ុន្តែដោយមិនទាន់មានបង្គាប់ឱ្យចាប់លោកបានជាគិញមិនចាប់ ។

សំណាក់នៅត្រពាំងជងមួយយប់,ដល់វេលាម៉ោង៥ភ្លឺនៃថ្ងៃទី២២កក្កដា,ទើបជួលរទេះសេះ

១-កាលណោះបាត់ដំបងជាស្រុកសៀមដោយបារាំងបានកាត់ដីឱ្យទៅសៀម កាលដែលវាចាញ់សង្គ្រាមបារាំងសៀម

២-នៅត្រពាំងជងមានបងលោកជុំ ម៉ៅ ធ្វើចៅហ្វាយស្រុកនៅនោះ ។

ជូនដំណើរពីត្រពាំងជងទៅដល់ថ្លូវតាប៉ោង, ក៏បាននិយាយពោកហៅរ៉ុ (រ៉ៃ) ឱ្យជូនដំណើរឆ្លងស្ទឹងស្វាយជូនកែវទៅខាងដីសៀម ដោយគុហាកថាមានការប្រញាប់ទៅរកស្រវឹងជ្រោយស្ដៅ ,តុំប៉ាត្ល័រកិនពោន់ ។ ប៉ុន្តែដោយនៅក្រោមបង្គាប់បងលោកឈ្មោះជុំ ម៉ៅស្រាប់ ក៏ចាត់ជិទប់ប្រដាប់ដោយកាំភ្លើងមួស្គីតុងច្រកគ្រាប់ស្រេចជូនដំណើរពោលតែឆ្លងផុតស្ទឹងទៅខាងនាយទៅ ។

សូមជម្រាបពីព្រឹត្តិការណ៍នៅភ្នំពេញតទៅទៀត ៖

តពីថ្ងៃបាតុកម្មមក , ពួកគិញបារាំងចេះតែដើររកចាប់ក្រុមបាតុករគ្រប់កន្លែងនៅក្រុងភ្នំពេញ និងនៅខេត្តក្រៅ ។ ពួកបាតុករដែលមានឈ្មោះច្រើនជាងគេគឺនៅវត្តឧណ្ណាលោម និងនៅវត្តលង្កា ដែលជាមេតុកណ្ដោយឱ្យព្រះសង្ឃនិងគ្រហស្ថដែលមានឈ្មោះពីមុន និងដែលបានចូលធ្វើបាតុកម្ម ភិតភ័យរន្ធត់គេចរត់ទៅពួនឯស្រុកក្រៅជាច្រើន ។ ខ្លះក៏បានឆ្លងដែនទៅខេត្តបាត់ដំបងដែលគ្រានោះជាអាណាខេត្តសៀម ។

ចំណែកលោកគ្រូអាចារ្យប៉ាង ខាត់ ដោយភិតភ័យណាស់ក៏រត់ទៅសឹកជាគ្រហស្ថ ហើយទៅពួនសម្ងំនៅនឹងវត្តចិនដំបងដែក(ពិភព្ទេវង្សី)មិនសុខមិនសាប់ ដោយភ័យខ្លាចពួកវាពេកក៏ប្ដេជ្ញាចិត្តដើរចូលទៅឱ្យវាចាប់ឯក្រសួងធម្មការតែម្ដង ។

***



# អំពីការចាប់ខ្លួនខ្ញុំប៉ុណ្ណចន្ទ ម៉ុល

ក្រោយដែលត្រឡប់មកពីបាតុកម្មវិញ,ខ្ញុំប៉ុណ្ណចន្ទ ម៉ុល ក៏មកផ្ទះវិញធ្វើការបេក់ដួរធម្មតានៅឯផ្សារស៊ីញ៉ែ,ប៉ុន្តែនៅមានបារម្ភក្នុងចិត្តជានិច្ចថាថ្ងៃណាមួយមុខជាត្រូវបារាំងចាប់មិនខានទេ ។

លុះដល់ថ្ងៃទី*២៤ កក្កដា*១៩៤២ រសៀលម៉ោង១៥,ស្រាប់តែរថយន្តស្ងួមកឈប់នៅក្បែរផ្ទះលេខ២,មុខវត្តឧណ្ណាលោមដែលខ្ញុំកំពុងទទួលទានដំណេកនៅទីនោះ ។ ពេលនោះគិញខ្មែរ៦នាក់ និងបារាំង១នាក់ ចូលទៅសួរខ្ញុំ ហើយនាំខ្ញុំទៅប៉ុយរ៉ូគិញ ។ នៅទីនោះបារាំងវាសួរខ្ញុំថា បានទៅធ្វើបាតុកម្មនឹងគេទេ ? ខ្ញុំឆ្លើយប្រាប់វាថា បានទៅជាមួយគេដែរ ប៉ុន្តែពុំបានវាយពួកគិញទេ ។ លុះសួរចប់ហើយ,វាក៏បើកឱ្យមកផ្ទះវិញនៅវេលាម៉ោង១៦ល្ងាច ។ ដល់ស្អែកឡើង(២៥កក្កដា) វេលាម៉ោងប្រហែល៨ព្រឹក ,ខ្ញុំកំពុងតែលក់ដូរគុយទាវ កាហ្វេ,ស្រាប់តែគិញម្នាក់ទៅហៅខ្ញុំថា លោកចាងហ្វាងសុំឱ្យទៅជួបទៀតឡិតលោកសួរពីឡើលមិញពុំទាន់ចប់ ។ ខ្ញុំក៏បានទៅឯប៉ុយរ៉ូគិញនៅម៉ោងប្រហែល៩ ។ លុះសួររួចហើយ ,វាប្រាប់ខ្ញុំថាសុំឃុំខ្លួន ដោយមានសេចក្ដីសង្ស័យត្រូវសួរតទៅទៀត ហើយវាក៏ចាត់ឃុំខ្ញុំក្នុងគុកងងឹតនៃក្រុមព្រះនគរបាល (Sûreté) នោះទៅ ។

ក្រោយពីបានឃុំខ្លួននៅគុកគិញចំនួន៥ថ្ងៃ,វាក៏បញ្ជូនខ្ញុំទៅឯគុកធំ នៅថ្ងៃទី៣០ កក្កដា ។

នៅគុកធំ,ខ្ញុំបានជួបនឹងមិត្ត៤_៥នាក់ ដែលធ្លាប់ស្គាល់ហើយជាប់ទោសក្នុងរឿងជាមួយគ្នាដែរគឺលោក*ម៉ម លន់* ,នៅមុខវត្តលង្កា ឆៀងខាងត្បូង,លោក*គោគ នី* នៅខាងលិចវត្តលង្កា, លោក*អ៊ឹម*នៅឯខេត្តតាកែវ ,លោក*ព្រៃ អៀម* នៅសង្កាត់ព្រែកហ្លួង ស្រុកខ្សាច់កណ្ដាល (កណ្ដាលេ)និងពីរនាក់ទៀតពុំចាំឈ្មោះ ។

អស់លោកនិងមិត្តទាំងឡាយ ! មកដល់ដំណាក់កាលនេះហើយដែលជីវិតខ្ញុំបានចូលទៅនៅក្នុងគុក...គុកនៅភ្នំពេញដែលខ្ញុំនឹងជម្រាបតទៅទៀត...

# -៥-

# ជីវិតនៅក្នុងគុកធំភ្នំពេញ

ជីវភាពនៅក្នុងគុកធំភ្នំពេញ ខ្ញុំសូមជម្រាបពីជីវភាពនៃមនុស្សទោសក្នុងគុកធំកាលជំនាន់ខ្ញុំដូចតទៅ ៖

-មុនដំបូងបង្អស់,កាលដែលទើបចូលទៅដល់ គេឱ្យទៅនៅក្នុងបន្ទប់ធំមួយ,មានរានថ្នាក់ខ្ពស់ធ្វើដោយក្ដារកម្ពស់ប្រហែល៦០សង់ទីម៉ែត្រ(៦តឹក) ។ នៅនោះ,ឃើញមានកំណាត់ធុងដែក៦ដែលកាត់ផ្ដាច់ពីធុងប្រេងម៉ាស៊ីន,ចំណុះ២០០លីត្រដាក់នៅចុងជើង ។ ធុងមួយសម្រាប់ដាក់ទឹកទទួលទាន,ធុងមួយទៀតសម្រាប់បន្ទោរបង់។ នៅវេលាម៉ោង៦ល្ងាច,អ្នកយាមបានចូលមកដាក់ខ្នោះជើងទាំងពីរជាប់ដង្កៀគ្នាជាមួយអ្នកឯទៀត ,ខ្នោះនោះគឺខ្នោះដែកដែលមានរនុកវែងហួតចុះឡើងបាន រួចចាក់សោយ៉ាងមាំនៅខាងចុង ។ ពេលដែលត្រូវបត់ជើងតូច,ធំ ,ត្រូវដាស់គ្នាឱ្យជួយទាញឬរុញធុងលាមកមកជិត,ទើបអាចបន្ទោរបង់បាន តែដោយលំបាកផង ត្បិតជើងទាំងពីរជាប់ខ្នោះ ។ ដល់ព្រឹកឡើងប្រហែលម៉ោង៦ជាង ទើបអ្នកយាមចូលមកដោះខ្នោះពីជើងចេញហើយឱ្យដើរបានតែក្នុងកំពែងគុកនោះ ដែលមានទទឹងចំនួន៦ម៉ែត្រ,បណ្ដោយចំនួន៨ម៉ែត្រ ។ នៅវេលាម៉ោង១០ព្រឹក,ឮស្នូរអ្នកយាមវាយជួងប៉ុងៗ, ខ្ញុំក្រឡេកទៅខាងក្រៅ, ឃើញក្មេងអ្នកទោសដែលអាយុមិនដល់១៥ឆ្នាំ, វារត់ស្រទៅកាន់ចានដែកធ្វើរាយរាងដូចខ្ទះ[1] ដែលវាទើបនឹងដួសចូល

១.គេបានប្រើចានដែកបែបនេះដោយការពារកុំឱ្យបែក ហើយស្រួលប្រើការបានច្រើនយ៉ាង,ដូចជាយកទៅដួសទឹកសំអុយ,គើបសំរាម រួចយកទៅហោងទឹកដាក់បាយជាចុងក្រោយ ។



ចង្ក្រប្រឡាយបើកដែលលាយដី,សម្រាម,លាមកថ្មីៗ ទៅជ្រលក់ល្វទឹក(បាតរ្បាំង)គឺវាគ្រាន់តែជ្រលក់ផ្លុកទៅក្នុងទឹកនោះរួចលើកឡើងវិញ, រួចវាយកចាននោះឯងទៅដាក់បាយមកឱ្យខ្ញុំទទួលទាន ។ គេចូកបាយក្រហមពេញមួយចានដែកនោះ រួចដាក់ត្រីឆ្លាំងស្មោរពីរឬបី(តាមធំតាមតូច)ពីលើបាយ,មានអំបិលចំនួនមួយក្ដាប់ជាមួយម្ទេស៥-៦គ្រាប់ដាក់ពីលើត្រីនោះ ហើយមានទឹកត្រីដាក់ចានដែកធ្វើរាបតូចមួយ ដាក់ពីលើចានបាយនោះទៀតជាការស្រេច ។ សូមជម្រាបពីត្រីឆ្លាំងស្មោរនោះ មុនដំបូង, គេឥតបានធ្វើ, កោសអំបិល កាត់ធ្មុង, កាត់កន្ទុយ, កាត់ត្រចៀក, វះពោះយកអាចម៍ចេញទេ, ឥតលាងទឹកទេ គឺលើកត្រីទាំងក្រញ្ចៀងដែលទើបទិញមកពីផ្សារចាក់ឃ្លៅទៅក្នុងខ្ទះធ្លោត ដែលដាំចាំនោះតែម្ដង ។ កាលបើឃើញថាឆ្អិនល្មមហើយ ,គេយកកញ្ច្រែងយ៉ាងធំមួយទៅដួសតែត្រីមកដាក់ផ្ទាល់ដី ហើយទើបគេចាត់ចែងចាប់ដាក់គ្រប់ចានបាយ ។ ឯអ្នកធ្វើចង្ក្រានឬចុងភៅគឺជាមនុស្សទោសដូចគ្នា ។ លុះរៀបចំស្រេចហើយ,ទើបគេចាត់ឱ្យក្មេងៗលើកចានបាយនោះទៅដាក់ឱ្យទទួលទានក្នុងមួយវង់១ចានសម្រាប់មនុស្សទោស៦ឬ៧នាក់ ។ ដល់ពេលបាយម្ដងៗ,ខ្ញុំសង្កេតឃើញគេដាក់ចានបាយតម្រៀបរាប់រយចាន ។ បើគិតតាមចានបាយទាំងនោះ,អាចយល់បានថា មានមនុស្សទោសជាច្រើនរយនាក់នៅក្នុងគុក ប៉ុន្តែនៅសាល, បន្ទប់ដោយខ្លួនៗពីគ្នា ។

អស់លោកមិត្តភក្តិជាទីស្នេហា! មុនដំបូង,ខ្ញុំទទួលពុំកើតទេ។តើខ្ញុំទទួលម្ដេចបាន ,បើលូកដៃទៅចាប់បាយមកដាក់ក្នុងមាត់កាលណាក៏ធុំក្លិនអោមកជាប់មកនឹងបាយច្បាស់យ៉ាងនេះ !បាយមិនបានទេ ! ខ្ញុំទទួលទានតែទឹក រួចក៏សម្រាកទៅ ។ ចំណែកមិត្តភក្តិខ្ញុំទាំងប៉ុន្មានគេអាចទទួលទានបានជាធម្មតា ត្បិតគេជាប់ទោសនៅយូរមុនខ្ញុំ,គេថ្នឹកជាងខ្ញុំ ។ ប៉ុន្តែឯណា !ខ្ញុំអត់បាយបានត្រឹមតែបីថ្ងៃប៉ុណ្ណោះ ! ។ លុះដល់ថ្ងៃទី៤ ,ស្អុះឯណារួច,ដោយឃ្លានខ្លាំងពេក,អត់ទ្រាំទៅទៀតពុំបាន,ទើបខ្ញុំអាចទទួលទានបាន,ដូចគេឯងដែរ ,ប៉ុន្តែមុនដំបូងទ្រង់ចបិចបឿម,ខំប្រឹងលេបកុំឱ្យតែឃ្លានពេក ។ ដល់ប្ដូរពេលពីរពេលទៅ ,ក៏ទទួលទានបានច្រើន ហើយឆ្ងាញ់ដូចគេដែរ ។ ឯត្រីស្មោរទាំងធ្មុង ទាំងកន្ទុយ ទាំងអំបិល ទាំងអាចម៍ក៏ក្លាយទៅជាម្ហូបពិសេសយ៉ាងឆ្ងាញ់ពិសាប្រៀប

នឹងម្ហូបបរិភោគ សម្រាប់មនុស្សទោសក្នុងគុកទៅវិញ ។ នៅគ្រានោះហើយ នាំឱ្យនឹកឃើញដល់សុភាសិតខ្មែរបុរាណមួយឃ្លាថា *«ឃ្លានឆ្ងាញ់ ស្រឡាញ់ល្អ»* ។

ចាប់តាំងពីថ្ងៃទី៤ រហូតទៅ,ខ្ញុំទន្ទឹងចាំតែដល់ពេលបាយនឹងរវាលទទួលទានហើយម្ហូបទានយ៉ាងឆ្ងាញ់ជាធម្មតាដូចគេឯងទៀតដែរ ,បាត់ធុំលាមក,បាត់ធុំឆ្អាបត្រី,បាត់ឆ្អើមញញើតញញើមអ្វីទាំងអស់គឺទទួលទានឃ្លេមៗយ៉ាងចាស់ដៃឱ្យខាងតែឆ្អែត ដោយហេតុតែឃ្លានពេកទៅ ត្បិតក្នុងមួយថ្ងៃៗទទួលបាយតែពីរដង គឺពេលព្រឹកនៅម៉ោង១០ ពេលល្ងាចនៅម៉ោង១៦ឥតដែលបានអ្វីស្រស់ស្រូបបន្តិចបន្តួចមុនពេលបាយឡើយ គឺពោះទទេធេង រង់ចាំតែពេលបាយពីរដងក្នុងមួយថ្ងៃប៉ុណ្ណោះ ។ កាលនោះ ,ខ្ញុំទើបបានអាយុ២២ឆ្នាំ កំពុងពេញទទួលទានច្រើនណាស់ផង ។

លុះនៅក្នុងគុកធំបាន៦ថ្ងៃ, ទើបគេនាំខ្ញុំជាមួយអ្នកឯទៀតទៅថតរូបឯការិយាល័យអត្តសញ្ញាណ គឺជាប៉ុស្ដិ៍គិញផ្នែកថតរូប,ផ្តិតដៃ ។ ពេលនោះហើយដែលខ្ញុំនៅចាំច្បាស់អស់មួយជីវិតឥតភ្លេចឡើយ ។ មុនដំបូង,ប្រហែលម៉ោង៧កន្លះព្រឹក,អ្នកយាមមកបើកទ្វារគុកឱ្យយើងចេញ ហើយគេនាំទាំងអស់គ្នាដើរត្រសងជាមួយគេ ទៅដល់កន្លែងមួយជិតមាត់ទ្វារក្នុងគឺទ្វារទីមួយគេឱ្យយើងអង្គុយចុលទើបគេបញ្ជាឱ្យស្រាតខោអាវស៊ីវិលចេញទាំងអស់គ្នា ,យកខោអាវទៅដាក់មួយដុំរួមគ្នានៅទីនោះ ។ យើងឃើញក្មេងអ្នកទោសយកខោអាវខ្លីៗមកប្រគល់ឱ្យមួយសម្រាប់ម្នាក់ ។ លុះស្លៀកពាក់គ្រប់គ្នាហើយ,ទើបគេនាំចេញតាមទ្វារទីពីរទៅក្រៅគុក ដើម្បីឡើងជិះឡានដែលឈប់ចាំនៅនោះ ។ រថយន្តបើកចេញពីនោះបត់ទៅទិសខាងលិច តម្រង់ទៅការិយាល័យអត្តសញ្ញាណ (Identité) គេឱ្យខ្ញុំថតរូបផ្តិតដៃគ្រប់សព្វ ។ កាលថតរូបរួចហើយគេក៏នាំត្រឡប់មកគុកធំវិញតាមរថយន្តដដែល,ទើបគេបញ្ជូនខ្ញុំនឹងមិត្តភក្តិ៦នាក់ទៀតទៅក្នុងបន្ទប់តូចមួយ គឺគុកងងឹត ដែលមានទទឹងប្រហែល២,៥០ម៉ែត្របណ្តោយចំនួន៣ម៉ែត្រ ។ បន្ទប់នោះជិតទាំងអស់មានតែចន្លោះតូចមួយចោះនៅសន្ទះទ្វារ ,មានចម្រឹងដែកយ៉ាងមាំចាក់សោជាប់ ,មានពន្លឺចូលមកខាងក្នុងយ៉ាងតិចបំផុត,ប្រៀបបាននឹងទូដែកយ៉ាងដូច្នោះឯង ។



ថ្លែងពីខោអាវដែលគេចែកឱ្យនោះ, ជាសម្លៀកបំពាក់យ៉ាងចាស់មិនដឹងពីកាលណា,ឥតដែលបានបោកលាងម្តងណាសោះ ។ បើជានៅថ្មីវិញ,ទម្ងន់ប្រហែល៣០០ក្រាមប៉ុណ្ណោះ ,តែនេះជាខោអាវចាស់យូរមកហើយ ,មិនដឹងពីឆ្នាំណា,ធុំក្លិនមិនជាបើសោះ,ស្អិតដោយក្អែលនិងញើសកាន់ ក្រាស់ឃ្មឹក ប្រៀបបាននឹងសំពត់ដែលជ្រលក់ដោយទឹកក្រមួនឡើងក្រាំងស្អិតដូច្នោះឯង ។

ជាការជាក់ច្បាស់ណាស់ ដូចមិត្តអ្នកអានឃើញរូបថតខ្ញុំដែលខ្ញុំផ្តិតនៅទំព័រខាងមុខនៃសៀវភៅនេះស្រាប់ ដែលគេថតខ្ញុំកាលដែលចូលទៅមន្ទីរអត្តសញ្ញាណនោះ ពិនិត្យចុះ អាវដែលពាក់នោះជ្រួញឬបន្ទះៗដូចគេយកភក់ទៅប៉ាត អាចឱ្យលោកអ្នកយល់បានថាអាវនោះមានភាពរឹងគោកក្រទាំង ក្រាស់ឃ្មឹកសម្បើមហើយពភ្លក់ គគ្រិចនិយាយពុំបាន ។

ខ្ញុំបានថែរក្សារូបនោះរហូតមក ទុកជាអនុស្សាវរីយ៍នៃជីវិតដ៏សែនពបីចាប់ ខ្លោចផ្សាររបស់ខ្ញុំ ដែលមានអាវនោះពាក់ជាប់នឹងខ្លួនជាភស្តុតាងស្រាប់ ។ ក្នុងគុកនោះមនុស្សទោសគគោកពេញទាំងគុក ម្តេចមិនប្រើឱ្យបោកលាងឱ្យស្អាត ? ឆ្លើយថា : គេមិនរវល់ទេ ,គេទុកឱ្យវាមានសភាពដូច្នេះចុះដើម្បីបន្ទាបបន្ថោក,បង្អាប់កិត្តិយសឬផ្ចាល់ផ្ចាញ់ឱ្យយើងរាងចាល ,ឱ្យយើងបាក់ស្បាតរាបដូចកន្ទេលកុំឱ្យយើងហ៊ានរើខ្លួនឱ្យរួចពីខ្ញុំកញ្ចះគេឡើយ តាមរបៀបអាណានិគមនិយមដែលគេធ្លាប់តែធ្វើដូច្នេះនៅគ្រប់ទីកន្លែង ។

នៅកន្លែងថ្មីគឺគុកងងឹតនេះ ឥតមានកន្ទេលខ្នើយអ្វីទទួលទានដំណេកផ្ទាល់នឹងឥដ្ឋបេតុងដែលគេធ្វើជារានខ្ពស់ខាងក្បាលដំណេកខ្ពស់ជាងខាងចុងជើងបន្តិច ។ នៅទីនេះគេប្រើបំពង់ឫស្សីដូចជាបំពង់ទឹកត្នោត ទុកសម្រាប់ឱ្យបត់ជើងមួយ,ទុកសម្រាប់ដាក់ទឹកឱ្យទទួលទានមួយ ។ ឯជើងទាំងពីរត្រូវដាក់ខ្នោះភ្ជាប់ដូចជានៅសាលធំដែរ ។ ដល់ពេលបត់ជើងម្តងៗ,មានការលំបាកណាស់ ត្បិតកជើងជាប់ខ្នោះ ប៉ុន្តែមុនដំបូង,ត្រូវសម្រូតជើងខោម្ខាងឱ្យចេញផុតពីជើងម្ខាងសិនទើបដោះខោពីជើងម្ខាងទៀតបាន ។

សូមបញ្ឈប់រឿងនេះបន្តិច ក្រែងអស់លោកអ្នកស្តាប់មិនទាន់បាន,មិនយល់ ។ របៀប

ត្រូវស្រាតខោតាមជើងម្ដងមួយ ជើងណាមុនក៏បាន ។ ឧបមាថាស្រាតតាមជើងឆ្វេងមុន ។ ពេលដែលជើងខោឆ្វេងទៅដល់កជើង ឆ្វេងត្រូវយកដៃទាំងពីរជួយឆ្នួល សង្កត់ជើងខោឱ្យណែនឱ្យតូចរុញរុលប្រជ្រៀតតាមប្រហោងខ្នោះ ឱ្យទាល់តែផុតខ្នោះទៅដល់ប្រអប់ជើង,រួចព្យាយាមទាញជើងខោនោះឱយផុតប្រអប់ជើងទៅទៀត, ផុតប្រអប់ជើងហើយ ទើបទាញជើងខោនោះណាត់បកមកតាមប្រហោងខ្នោះវិញ ។ នេះរបូតជើងខោមួយពីជើងមួយហើយ ។ របូតជើងខោពីជើងនេះបានហើយត្រូវចាប់ស្រាតជើងខោម្ខាងទៀត ។ របៀបស្រាតខោរំពីជើងម្ខាងទៀតនេះ មានរបៀបដូចស្រាតជើងខោមុននោះដែរ ។ ធ្វើយ៉ាងនេះទើបអាចស្រោតខោចេញពីខ្លួនបាន ។

បើមនុស្សឥតប្រាជ្ញាមិនឈ្លាសវៃ មិនងាយដោះរួចឡើយ ។ ប្រហែលម៉ោង៤រសៀល,គេឱ្យងូតទឹក ។ ក្នុងពេលងូតទឹកនេះ, គេបើកទ្វារបន្ទប់ចំហ ហើយប្រាប់ឱ្យស្រាតខោអាវ បោះចេញទៅក្រៅទាំងអស់ ,នៅតែខ្លួនទទេ ហើយជាប់ខ្នោះផង រួចគេយកចានសម្រាប់ដាក់បាយយទៅដួសទឹកក្នុងធុងមួយដែលដាក់នៅជិតនោះជះមកពីចម្ងាយឱ្យពីរបីចាន ហើយប្រាប់ឱ្យដុសក្អែលទៅកំពុងតែដុសក្អែលមិនទាន់បានប៉ុន្មានផង គេក៏ជះទឹកពីរបីចានទៀតជាការស្រេច ។ សូមជម្រាបថាទឹកពីបីចានប៉ុណ្ណោះ ពុំអាចទទឹកជោកសព្វខ្លួនបានទេ ត្បិតនៅសល់ភាគចំហៀងម្ខាងដែលពុំត្រូវទឹក ។ ឯក្អែលក៏ពុំអាចដុសបានឡើយ ត្បិតទឹកតិចពេកហើយពេលក៏ខ្លីរកដុសពុំបានលុះចប់កិច្ចនេះហើយ គេបោះខោអាវចូលមកឱ្យវិញក៏ទទឹកអស់នឹងទឹកដែលទើបងូតហើយ ។ ខ្ញុំយកខោអាវទទឹកនោះជូតមុខខ្លួនប្រាណរួចសំដិលបន្តិចទើបស្លៀកពាក់ទៅវិញ យ៉ាងពិបាកដោយជើងជាប់ខ្នោះនោះ ។

ឯរបៀបទៅវិញនោះក៏ត្រូវស្លៀករុញជើងខោតាមកជើង កាត់តាមប្រហោងខ្នោះដូចកាលដែលស្រាតនោះដែរ និងប្រើពេលព្យាយាមដូចគ្នាដែរ ។

លុះនៅក្នុងគុកធំបានប្រហែលមួយអាទិត្យគេបញ្ជូនត្រឡប់ទៅឯប៉ុយេរ៉ូគិញវិញ ។ ក្រោយពីនោះប្រហែល៥ថ្ងៃទើបគេឱ្យស្លៀកខោអាវស៊ីវិលរបស់ខ្ញុំពីដើមវិញ រួចគេដាក់ខ្នោះដៃឱ្យឡើងរថយន្តទៅចុះកប៉ាល់ចម្បាំងសកម្មក្រុមទ័រពីយ៉័រ ដែលជាកប៉ាល់ប្រដេញលឿនបំផុតសម័យនោះ



របស់អាណានិគម ។ កប៉ាល់នោះចតនៅមុខផ្ទះរ៉េស៊ីដង់ស៊ុប៉េរីយើរ ដែលឥឡូវនេះជាសណ្ឋាគារនៃរដ្ឋាភិបាលខ្មែរ ។ នៅក្នុងកប៉ាល់គេពុំដោះខ្នោះដៃចេញទេ ។ ទៅក្នុងកប៉ាល់ខ្ញុំភ្ញាក់ព្រើតតែម្ដងត្បិតឃើញមិត្តភក្ដិឯទៀតគឺលោកគ្រូអាចារ្យប៉ាង ខាត់ និងទាហានជើងក្រហម៧-៨នាក់មានឈ្មោះស៊ុតជាដើមដែលបានត្រូវគេនាំពីទីឃុំឃាំងផ្សេងៗ គ្នាមកជួបជុំគ្នាក្នុងកប៉ាល់នោះដែរ ។ នៅវេលារសៀលប្រហែលម៉ោង១៦ កប៉ាល់បានបើកចេញពីភ្នំពេញឆ្ពោះទៅព្រៃនគរ ។ ក្នុងកប៉ាល់មានគ្នាប្រហែល១០នាក់ ។ គេដាក់ប្រតែងគ្នាទាំង១០នៅបាតកប៉ាល់ ។ មនុស្សដែលខ្ញុំអាណិតជាងគេ គឺលោកគ្រូប៉ាងខាត់ ដោយធ្លាប់នៅបួសស្រណុក ហើយមកជាប់ខ្នោះដូច្នេះវេទនាណាស់ខ្ញុំជួយការពារសុំឱ្យគេអនុគ្រោះឱ្យនំបុ័ងឆាន់ ព្រោះឆាន់តែមួយពេលដូចនៅជាលោកសង្ឃ។ ទាហានបារាំងវាមាត់ឡូឡាអាណិតដែរ វាឱ្យនំបុ័ងលោកឆាន់ នំបុ័ងសម័យនោះគឺនំបុ័ងម្សៅស្រូវយើងព្រោះឥតមានម្សៅសាឡីទេ ។ យើងទាំងអស់គ្នាអត់ទ្រាំចាំ ដល់ពេលបាយលុះដល់ពេលបាយមានតែត្រីងៀតសម្អុយភាយក្លិនស្អុយឡប់ ។

ដោយប្រើរយៈវេលាប្រហែល៥ម៉ោងកប៉ាល់ក៏បានទៅដល់ក្រុងព្រៃនគរ ។ នៅទីនោះគេនាំនៅចូលក្នុងគុកធំឈ្មោះ (Prison Centrale) ។

ថេរវេលាតាំងពីចាប់រហូតដល់ចូលគុកនៅព្រៃនគរបូករួមទាំងអស់ចំនួនជាងមួយខែ ។

***

# -៦-

# ជីវិតនៅក្នុងគុកធំព្រៃនគរ

គ្រាដែលចូលដល់គុកធំភ្លាម គេបង្គាប់ឱ្យដោះសម្លៀកបំពាក់របស់ខ្លួនចេញហើយឱ្យផ្ញើទុកទាំងអស់នៅក្នុងឃ្លាំង រួចគេឱ្យយើងចុះហត្ថលេខាក្នុងសៀវភៅបញ្ជីទុកជាសំគាល់ ។ របស់ដែលខ្ញុំផ្ញើទុកនោះគឺខោ_អាវ_ចិញ្ចៀនមាស_នាឡិកាដៃ និងប្រាក់ចំនួន១២រៀល ។ គេឱ្យខោវែងអាវវែងយ៉ាងថ្មីស្អាត សម្រាប់ឱ្យស្លៀកពាក់ព្រមទាំងកន្ទេលចចូតថ្មីមួយផង សម្រាប់យកទៅដេកសាលធំ ។ លុះគេនាំចូលទៅក្នុងសាលធំនៅជាន់ទី៤ សាលលេខ៣ធំហើយក៏បានជួបនឹងលោកគ្រូអាចារ្យហែម ចៀវ និងលោកនួន ឌួងដែលគេបានបញ្ជូនមកពីថ្ងៃមុន ហើយ ។ ចំណែកលោកគ្រូអាចារ្យប៉ាង ខាត់គេនាំទៅដាក់សាលទី១៥ ផ្សេងពីខ្ញុំ ។

បងប្អូនជាទីស្នេហា ! តាំងពីចូលគុកធំព្រៃនគរកាលណាខ្ញុំបានយកចិត្តទុកដាក់ពិនិត្យមើលស្ថានភាពគុកយួនព្រៃនគរព្រមទាំងជីវភាពនៃមនុស្សទោសរាប់ពាន់នាក់ ដែលភាគច្រើនជាជាតិយួន ។ ក្នុងកំពែងគុកធំ មានអគារតូចធំជាច្រើនខ្លះមួយជាន់ ខ្លះពីរជាន់ អគារដែលធំហើយវែងជាងគេមាន២សង់ជា៤ថ្នាក់ ។ អគារទាំងនេះសម្រាប់ដាក់មនុស្សទោសចំនួន៣.០០០នាក់ ប៉ុន្តែបើមានមនុស្សទោសចូលច្រើនពេក គេអាចដាក់បន្ថែមចំនួនជិត៤.០០០នាក់ក៏បាន ។ នៅអគារធំនីមួយៗគ្រាប់ជាន់ អាចដាក់មនុស្សទោសចំនួន៤រយនាក់ គឺគេចែកសាលធំជា២កន្លែង ។ ក្នុងកន្លែងនីមួយៗគេអាចដាក់មនុស្សទោសបាន២០០នាក់ ។ កន្លែងនោះមានមាត់ទ្វារដែកចាក់សោយ៉ាងរាំទប់មុខគ្នាហាំងដោយចម្រឹងដែកធំៗ រហូតដល់ដំបូលបើទុកឱ្យមានចន្លោះកណ្ដាលប្រហែល២ម៉ែត្រសម្រាប់ដើរធ្វើការ ឬត្រួតត្រាមើលមនុស្សទោសបានទាំងពីរខាង ។ ក្នុងកន្លែងផ្លូវៗគេបានចែកជាពីរផ្នែកទៅទៀត ហើយគេបានលើកជាថ្នាក់ខ្ពស់ទាំងពីរខាង ធ្វើដោយឈើទុក



ចោលឱ្យមានចន្លោះកណ្ដាលប្រហែលពីរម៉ែត្រស្ថិតនៅចំមាត់ទ្វារទាំងពីរខាង សាលធំទាំងពីរនោះមានទ្វារដែកក្រៅយ៉ាងមាំមួយជាន់ទៀត មានចោះប្រហោងតូចមួយនៅសន្លឹះទ្វារ សម្រាប់អ្នកយាមពិនិត្យមើលមកខាងក្នុងសាលនៅពេលដែលគេមិនត្រូវការចូលខាងក្នុង ។ ក្នុងសាលធំនីមួយៗមានបង្គន់មួយមានម៉ាស៊ីនទឹកមួយ ។ ប៉ុន្តែជាន់លើទឹកមិនសូវចេញទេ ត្បិតខ្ពស់ពេក ។

នៅគុកព្រៃនគរ,គេមិនដាក់ខ្នោះជើងមនុស្សទោសទេ ។ សាលក៏ធំទូលាយស្អាត ,ស្រឡះមុខមាត់,បើរដ្ឋការគុកសង្កត់សង្កិនមនុស្សទោសដោយប្រការណាមួយ បិទសិទ្ធិខុសច្បាប់ ដោយឱ្យបាយឆៅបាយលាយស្រូវច្រើនឬបាយខ្លោច ឬមួយឱ្យសាច់ ឬត្រីមិនគ្រប់កំណត់តាមច្បាប់, មនុស្សទោសអាចតវ៉ាបានរហូតដល់អាជ្ញាធរជាន់ខ្ពស់ ។ ឃើញដូច្នេះខ្ញុំនឹកថាឱ ! មនុស្សទោសខាងយួនមានសិទ្ធិសេរីភាពជាងមនុស្សទោសខ្មែរឆ្ងាយណាស់ ចំណែកម្ហូបអាហារក៏ល្អជាងខាងគុកភ្នំពេញ ។ នៅរាល់ថ្ងៃសៅរ៍, តែងមានអ្នកតំណាងខាងតុលាការចូលទៅចាប់ដៃមនុស្សទោសសួរសុខទុក្ខ ក្រែងខាងអាជ្ញាធរខាងគុកធ្វើការសង្កត់សង្កិនធ្វើខុសច្បាប់ ។ មនុស្សទោសគេមានសិទ្ធិទទួលសំបុត្រ ដែលគេផ្ញើពីក្រៅទៅ ហើយនិងអាចសរសេរសំបុត្រផ្ញើទៅសួរសុខទុក្ខគ្រួសារបានដោយមិនបាច់បិទតែមប្រ៊ីឡើយ ។ ឯខាងគុកភ្នំពេញយើងមនុស្សទោសជាប់ខ្នោះ, អាហារមិនល្អ,សាលចង្អៀតដូចទ្រុងជ្រូកឥតសិទ្ធិសេរីភាពអ្វីសោះ ។ សូមបងប្អូនជួយពិចារណាមើល ? នៅឆ្នាំ១៩៤២ ដែលខ្ញុំជាប់គុកនៅភ្នំពេញប្រៀបបាននឹងធ្លាក់នរក ហើយក្នុងឆ្នាំដដែលនេះខ្ញុំទៅជាប់គុកព្រៃនគរទៀតចាប់តាំងពីចូលទៅដល់ហើយផ្លាស់ខោអាវថ្មីៗ របស់គេកាលណាមនោ-សញ្ចេតនាខ្ញុំហាក់ដូចជាមិនមកជាប់គុកទេ,ផ្ទុយទៅវិញហាក់ដូច ជាចូលធ្វើទាហានខោអាវដែលគេចែកឱ្យហាក់ដូចជាខោអាវទាហាន ។ ក្នុងឆ្នាំនោះ ស្រុកយួនគេមិនទាន់បានឯករាជ្យដូចតែយើងដែរ,ប៉ុន្តែគេមានគំនិតរៀបចំទុកជាកន្លែងស្អាតបាត ដែលជាកន្លែងសម្រាប់មនុស្សនៅបាន ,មិនមែនទុកជានរកឬទ្រុងជ្រូកទេពីព្រោះជាផ្ទះសម្រាប់ មនុស្សនៅ ,ជាពិសេសគឺសម្រាប់ជាតិយួនគ្នាគេដែលមានទោសនៅ ។ គេរៀបចំឱ្យមានអាហារល្អ ឱ្យមានសិទ្ធិសេរីភាពដល់មនុស្សទោសគ្នាគេ ក្នុងពេលដែលគេនៅជាខ្ញុំបារាំងដូចតែខ្មែរដែរ តើវាខុសគ្នាយ៉ាងណា ? ម្យ៉ាងទៀតមនុស្សទោស

ដែលនៅក្នុងគុកនោះ នៅមិនទាន់តុលាការកាត់ទោសនៅឡើយ ហេតុនេះតុលាការនៅធានារ៉ាប់រងឱ្យអ្នកជាប់ចោទគេមានសេរីភាពជានិច្ច ។ ឯខាង ស្រុកខ្មែរយើងវិញឥតមាននរណាគិតគូរឡើយ ,បានជាមនុស្សទោសខ្មែរឥតមានសិទ្ធិអ្វីសោះ ហើយកែកំហុសខ្លួនមិនកើត(គុកគឺសាលាទូន្មានមនុស្សខូចព្រោះអប់រំមនុស្សខូចឱ្យល្អ) ។

ខ្ញុំបាទសូមជម្រាបពីស្ថានភាពក្នុងគុកព្រៃនគរតទៅទៀត ។

ផ្នែកទី១ នៃសាលធំគេឱ្យមនុស្សទោសខ្មែរនៅ,ឯផ្នែកទី២សម្រាប់មនុស្សទោសយួន ។ ខាងផ្នែកខ្មែរ មានមនុស្សទោសខ្មែរម្នាក់ជាជាតិខ្មែរកម្ពុជាក្រោម(ខ្ញុំភ្លេចឈ្មោះ)ជាទាហានជាប់ទោសយូរឆ្នាំហើយ ។ គេតម្រូវឱ្យមនុស្សនេះធ្វើមេ(កាប៉ូរ៉ាល់)ឬហៅដៃប៊ីរ តាមពាក្យយួនសម្រាប់ត្រួតត្រាលើមនុស្សទោសខ្មែរ ដូចគ្នាក្នុងផ្នែកសាលខ្មែរ បុរសនេះមានឯកអាមាត្រជាអង្គរក្សអមខ្លួនគេចំនួន៧នាក់ផង ។ មនុស្សទោសទាំងអស់ ត្រូវនៅក្រោមឱវាទនៃកាប៉ូរ៉ាល់នេះ ឥតនរណាម្នាក់ហ៊ានខ្ទើកឡើយយ ដោយខ្លាចអំណាចគេផង ខ្លាចឯកអាមាត្រនោះផង ។ បើកាប៉ូរ៉ាល់នេះគេខឹងឬទាស់ចិត្តនឹងមនុស្សទោសណាម្នាក់ គេជេរ វាយ ទាត់ ធាក់បានតាមចិត្តឥតអាណិតអាសូរ ឥតមានច្បាប់អ្វី និងឥតមានអ្នកណាម្នាក់ហ៊ានតដៃនឹងគេឡើយ ។ គេធ្វើដូច្នេះដើម្បីបំបាក់អ្នកចូលថ្មី ឱ្យបាក់បបខ្លបខ្លាចគេបាក់ស្បាតលែងហ៊ានតវ៉ាអ្វីទាំងអស់ ។ ឯមនុស្សដែលទើបចូលទៅដល់ថ្មី ជាចាំបាច់ត្រូវតែវារពីចម្ងាយទៅដល់ជិតគេ ហើយលើកដៃសំពះសូមជ្រកកោននឹងគេ ទើបបានសុខ ។ ប៉ុន្តែបើនិយាយរាយការណ៍ទៅទាស់ចិត្តគេ ក៏គេទាត់ធាក់បំបាក់ពីដំបូងដែរ ។

នេះគឺជារបៀបផ្ដាច់ការបួយ ដែលជាកំរែលអាណានិគមនិយមឆ្លងមកដល់ជនជាតិខ្មែរយើងឱ្យចេះប្រើរបបផ្ដាច់ការដែរ ។ សូម្បីតែខ្លួនជាប់ទោសដូចតែបងប្អូនរួមជាតិខ្លួនដែរគួរតែមានចិត្តមេត្តា ដល់គ្នាផង ហេតុអ្វីក៏នៅតែប្រើអំណាចសង្កត់សង្កិនគ្នាឯងក្នុងគុកបៀតដូច្នេះ ? នេះហេតុតែតាំងខ្លួនធំប្រើអំណាចដូចជាស្ដេច នៅក្នុងគុកដូច្នោះដែរ ។



ចំពោះរឿងនេះ លោកគ្រូអាចារ្យហែម ចៀវ បានជំរាបប្រាប់ខ្ញុំតាំងពីទើបចូលទៅដល់ដំបូងម្ល៉េះ ។ លោកថាកាលខ្លួនលោកទើបចូលទៅដល់ដំបូង មានមនុស្សទោសមុនគេបានខ្សឹបប្រាប់លោកឱ្យធ្វើកិច្ចលុតក្រាបចំពោះកាប៉ូរ៉ាល់នេះទើបបានសុខ ។ លោកបានបន្ថែមទៀតថាលោកនួន ឌួងកាលដែលចូលទៅដល់ដំបូង ក៏បានធ្វើកិច្ចគោរពប្រណិប័តន៍គេនេះដែរ ប៉ុន្តែនៅតែខុសទាស់ចិត្តគេទៀត។ មុនដំបូងលោកនួន ឌួងបានវារពីចម្ងាយប្រហែលប្អូនម៉ែត្រលុះចូលទៅជិតក៏លើកដៃសំពះគេដោយពេញវាចាថា ខ្ញុំបាទសូមជ្រកក្រោមម្លប់ព្រះតេជគុណផង សូមមេត្តាមើលការខុសត្រូវឱ្យបានផង ! កាប៉ូរ៉ាល់នោះសួរថា អាប្អែងមានរឿង អីបានជាជាប់គុក ?លោកនួន ឌួង ឆ្លើយថា គេចោទថាខ្ញុំបាទបះបោរក្បត់បារាំង ! គ្រាន់តែឮសួរថាក្បត់បារាំងដូច្នេះឥតបានសួរបញ្ជាក់អ្វីទៀតទេ បុរសនោះក៏ស្រែកឡើងថា «យើ !អាហ្អែងក្បត់បារាំងផង ! » គ្រាន់តែឮពាក្យចៅហ្វាយគេថា «យើ ! អាហ្អែងក្បត់បារាំងផង» ប៉ុណ្ណោះ ពួកឯកអាមាត្រគេប៉ុន្មាននាក់ក៏ស្ទុះឡើងទាត់ ធាក់ លោកនួន ឌួង ព្រមគ្នាឥតអាណិតអាសូរអ្វីឡើយ ។ ទាល់តែធ្លាក់ពីថ្នាក់លើទៅក្នុងចន្លោះក្រោមចំហាត់ទ្វារសន្លប់ឥតដឹងខ្លួន ។ លោកគ្រូអាចារ្យហែម ចៀវ បានបន្តទៅទៀតថាចំណែកខ្លួនលោកក៏ធ្វើរបៀបលុតក្រាបតាមក្រោយលោកនួន ឌួងដែរ[1] ។ លុះលោកវារទៅដល់គេបែរមកសួរលោកថា ចុះអាកញ្ជ្រួបឯងនេះមានរឿងអីដែរបានជាប់គុក ? លោកក៏ឆ្លើយថាខ្ញុំបាទនេះជាលោកសង្ឃទេ ម្នាក់អប្បាញ់មិញក៏ជាអាចារ្យ មានរឿងជាមួយខ្ញុំបាទដែរ គេសួរទៀតថា ,ហ៊ឺះ ! បើលោកសង្ឃ ម្ដេចក៏ជាប់គុក ? មានរឿងអី ! លោកឆ្លើយថា ខ្ញុំបាទធ្លាប់បានទៅទេសនាគ្រប់ទីកន្លែងមានឧបាសក ឧបាសិកាចូលចិត្តស្ដាប់ធម៌អាថ៌ជាច្រើនគ្នា ។ បារាំងមិនយល់ភ័យខ្លួនស្រាប់តែចោទខ្ញុំថានាំរាស្ត្របះបោរ ហើយគេចាប់ខ្ញុំបាទផ្សឹកយកមកដាក់គុកនេះឯង! លុះឮលោកថ្លែងការណ៍ប្រាប់ដូច្នេះហើយ គេក៏សុំឱ្យលោកអធិប្បាយរឿងនេះដោយពិស្ដារឱ្យគេស្ដាប់ទៀត ។ គ្រាន់តែបានស្ដាប់សេចក្ដីអធិប្បាយរបស់លោករួចហើយកាប៉ូរ៉ាល់នោះព្រឺបទាំងឯកអាមាត្រគេហាក់ដូចជាភ្ញាក់ខ្លួនមានចិត្តទោរទន់ នឹកអាណិតលោកនួន ឌួង គេក៏បង្គាប់គ្នាគេឱ្យជួយរឹតលោកនួន ឌួងឱ្យដឹងខ្លួនឡើងវិញ ហើយទើបលើកដាក់មកលើថ្នាក់វិញ ។ ចាប់តាំងពីពេល

១-លោកអាចារ្យហែម ចៀវជាមនុស្សឆ្លាតវៃ បានឃើញអាចារ្យនួន ឌួង គេវាយសន្លប់ទៅហើយលោកក៏នឹកទាន់

នោះមកបុរសនោះហាក់ដូចជាស្លូតបូតជាងមុន មិនឃើញធ្វើទារុណកម្មមនុស្សទោសគ្នាឯងឡើយ ។ លោកគ្រូអាចារ្យហែម ចៀវ លោកជាអ្នកទោសនាដើងឯកមួយក្នុងបណ្ដាលោកសង្ឃអ្នកទោសទាំងអស់ហេតុនេះហើយបានជាលោកអាចដោះកុនបាន ។ សរបដូចសុភាសិតខ្មែរយើងថា សម្ដីជាឯង ។ ប៉ុន្តែចំណែកខាងមនុស្សទោសឯទៀតនៅតែកោតគោរពគេដូចពីដើរដដែល ។

នៅពេលដែលក្រុមខ្ញុំ(ប៊ុណ្ណច័ន្ទ ម៉ុល)ចូលទៅដល់ក្រោយលោកគ្រូអាចារ្យហែម ចៀវបានប្រាប់ទៅកាប៉ូរ៉ាល់នោះថា ពួកចូលក្រោយនេះគឺជាពួករបស់លោកដែលមានរឿងជាមួយគ្នាដែរក៏បានសេចក្ដីសុខតមកទៀត ។ ក្រោយដែលខ្ញុំ(ប៊ុណ្ណច័ន្ទ ម៉ុល)ធ្វើកិច្ចលុតក្រាបរួចហើយ គេគ្រាន់តែសួរពីរ_បីម៉ាត់ ។ លុះដឹងថាខ្ញុំបានពួកលោកគ្រូអាចារ្យហែម ចៀវហើយ គេក៏នៅស្ងៀមទៅ ។ ខ្ញុំមានសេចក្ដីត្រេកអរឥតឧបមាហើយក៏សំពះលាគេមកកន្លែងខ្លួនវិញ ។

រឿងនេះសូមអស់លោកមិត្តជាទីស្នេហាជួយពិចារណាមើលៈបើខាងក្រៅត្រូវរាណានិគមនិយមបារាំងធ្វើទារុណកម្មបំបាក់ឱ្យបាក់ស្បាត ឱ្យខ្លាចរអាដោយសំឡុតគ្រប់យ៉ាងដល់ចូលទៅក្នុងគុកក៏មានប្រើអំណាចផ្ដាច់ការសង្កត់សង្កិនរវាងមនុស្សទោសគ្នាឯងទៀត ។ តើឱ្យប្រជារាស្ត្រខ្មែរយើងហ៊ានតស៊ូយកឥស្សរភាពបែបណាទៅកើត ?

ឯចំណែកខាងមនុស្សទោសយួនវិញ នៅក្នុងសាលជាមួយខ្មែរដែរតែម្នាងម្នាក់ក៏គេមិនធ្វើដូចជាខ្មែរទេ ព្រោះគេមានការអប់រំយូរយារណាស់មកហើយ គេរាប់អានមនុស្សទោសដូចគ្នាហាក់បីដូចជាបងប្អូនបង្កើតនៅពេលចូលទៅក្នុងកន្លែងគុក ហើយគេតែងពន្យល់អ្នកថ្មីឱ្យស្គាល់បាននូវរបៀបរស់នៅក្នុងគុកមួយចប់តែម្ដង គេមិនសំឡុតដូចយើងខ្មែរទេ ។

នៅគុកព្រៃនគរគេបានទទួលទានអាហាររួមគ្នាក្នុង១វង់១០នាក់ ។ ឯម្ហូបគេនោះឃើញគ្រាន់បើជាងខាងគុកយើងភ្នំពេញ ប៉ុន្តែទាស់បន្តិចត្រង់ឱ្យបាយតិចពេក ។ ខ្លួនខ្ញុំកំពុងពេញកម្លាំងទទួលទានចំណែកបាយនោះមិនឆ្អែតទេ ។ គេវាល់បាយចែកក្នុងម្នាក់១ព្រាំប្លយចានតូចស្មើរប៉ុនពែង ។ បើទទួលទានធំបែនខែនបានប្រហែល៤_៥ម៉ាត់ប៉ុណ្ណោះអស់ហើយ ។ ប៉ុន្តែជាគុករ



ដែរដោយពេលល្ងាចខ្ញុំត្រឡប់ជាមានភ័ព្វសម្បូរណ៍បាយទៅវិញ ត្បិតលោកគ្រូអាចារ្យហែម ចៀវនិងលោកនួន ឌួង លោកមិនពិសាពេលល្ងាច, លោករក្សាសីលវេរាលថ្ងៃតមបាយល្ងាចរហូត ។ ម្លោះហើយបាយជាចំណែករបស់លោកទាំងពីរ ត្រូវធ្លាក់មកលើខ្លួនខ្ញុំជាអ្នករ៉ាប់ទាំងអស់គឺបាយរបស់អ្នកទាំងពីរនាក់និងបាយចំណែកខ្លួនខ្ញុំផងរួមជាបីចំណែក,ខ្ញុំទទួលទានម្នាក់ឯងយ៉ាងឆ្អែតមែនទែន,ខ្ញុំបានបាយឆ្អែតបរិបូណ៌តែពេលល្ងាច ។

ចំណែកលោកគ្រូអាចារ្យប៉ាង ខាត់ ដែលគេយកទៅនៅកន្លែងផ្សេងនោះពុំដែលបានដំណឹងសុខទុក្ខអ្វីឡើយ ។ ឯលោកប៉ាច ឈឿន ក៏ដូច្នេះដែរដោយលោកត្រូវនៅគុកងងឹតឯបាតដីឯណោះ ។

មានមួយថ្ងៃដែលខ្ញុំទើបទៅដល់គុកព្រៃនគរ, ខាងតុលាការសឹកបានហៅខ្ញុំទៅសួរចម្លើយនៅឯបន្ទាយទាហានបារាំងខ្ញុំត្រូវអង្គុយផ្ទាល់លើឥដ្ឋការ៉ូចាំគេហៅសួរ ។ បងប្អូនរួមជាតិអើយ ! ពេលខ្ញុំក្រឡេកទៅក្រោមតុសរសេរឃើញនំប៉័ងមួយប្រហែលប៉ុនកដៃដុះផ្សិតខ្លះនៅល្អខ្លះ ដែលគេបោះចោលនៅទីនោះ មិនដឹងជាពីថ្ងៃណាមកទេ ។ ដោយអំណាចឃ្លានពេកទៅជាស្រក់ទឹកមាត់គិតប្រថុយរើសនំប៉័ងនោះយកមកទទួលទានតែដល់គិតវែងខ្លីទៅក៏ខំទប់ចិត្តអាក់ខានទៅវិញដោយខ្លាចត្រូវនឹងស្ទ័យកាំភ្លើងរបស់ទាហានយាមជាជាងឃ្លាន ។ មួយវិញទៀតមានមិត្តភក្តិជាច្រើនញៀនបារីខ្លាំងទៅហើយពុំដែលបានទទួលទានសោះ,មានលោកភោគ នី[(១)] លោកគ្រូអាចារ្យហែម-ចៀវ ជាដើម បានពោលថាបើបានទទួលទានបារីស៊ូអត់បាយ១ពេលពីរពេលបាន ។ ចំណែកលោកភោគ នី ឃើញដូចញៀនជាងគេ ។ ឯខ្លួនខ្ញុំចេះទទួលទាន់បារីទេហើយគិតក្នុងចិត្តថា អ្នកញៀនបារីឆ្ងាញ់ផ្សែងនិងឃ្លានដល់ថ្នាក់ហ្នឹងហ្ន៎ ! ។ ហេតុនេះ,នៅពេលដែលខ្ញុំបានចេញទៅធ្វើការនៅបន្ទាយទាហាងក្រៅគុកម្ដង១,ខ្ញុំរើសគន្លុយបារីដែលគេជក់សល់បោះចោលនៅដី យកមកប្រមូលរែកយកតែថ្នាំខ្ចប់អកម្មកផ្ញើមិត្តភក្តិដែលញៀននៅឯសាល ដើម្បីចែកបន្តិច១ម្នាក់ ។ ក្នុងការរើសគន្លុយបារីនេះក៏ពុំបានស្រួលដែរ គោងតែដណ្ដើមយកតែឈ្នះដៃទើបបានច្រើន ត្បិតអ្នកដែលបានចេញទៅធ្វើការក្រៅជាមួយខ្ញុំសុទ្ធតែញៀនបារីដែរ ត្រូវការរើសគន្លុយបារីដូចគ្នា ។ នៅវេលា

១.លោកភោគនីឥឡូវនេះបួសគង់នៅមុំបឹងតាពន់ ជិតចំការដូងស្ទឹងមានជ័យ ។

ដែលឃើញអ្នកធ្វើការឯក្រៅបានកន្ទុយបារីមកផ្ញើ, អ្នកដែលញៀននៅក្នុងគុកត្រេកអរក្រៃលែង, បានឱ្យពរសព្ទសាធុការដល់ខ្ញុំ ។ លុះបានចំណែកថ្នាំកន្ទុយបារីហើយ, ពួកមិត្តភក្តិដែលញៀននោះយកក្រដាសកាសែតមកមូរទទួលទានដោយសំចៃ មិនហ៊ានដាក់ថ្នាំច្រើនទេគឺដាក់ថ្នាំតែបន្តិចៗ នៅចុងក្រដាសហើយទុកក្រដាសរមូរខាងបៀមឱ្យវែងដើម្បីជក់ទៅឱ្យឆេះអស់កុំឱ្យសល់ ។

ពេលដែលខ្ញុំចេញនៅធ្វើការឯក្រៅគុកម្តងៗ ពួកអ្នកញៀនស្រែកផ្តាំរញ៉េថាឱ្យខំរើសកន្ទុយបារីមកផ្ញើផង ។ ខ្ញុំមានចិត្តអាណិតមិត្តភក្តិក្រៃលែងចេះតែខំរើសមកផ្ញើមិនដែលខានក្នុងពេលដែលបានចេញទៅធ្វើការខាងក្រៅគុក ។

ក្នុងគុកព្រៃនគរ នៅពេលបុណ្យជាតិគេម្តងៗ ដូចជាបុណ្យចូលឆ្នាំបុណ្យសែនក្បាលទឹក ។ល។ បងប្អូនគ្រួសារគេយកអីវ៉ាន់ដូចនំអន្សម,ម្ហូបអាហារ,ចំណីចំណុក,ផ្លែឈើជាដើមមកឱ្យបងប្អូនគេដែលជាប់ឃុំឃាំង យ៉ាងសម្បូរហូរហៀរ ។ ពួកទាំងនោះគេចែកអាហារនោះតមកខាងខ្មែរទៀតឱ្យបានបរិបូណ៌ដែរ ។ ដល់ថ្ងៃបុណ្យបារាំងដូចចូលឆ្នាំនិងថ្ងៃ១៤កក្កដា ខាងអាជ្ញាធរគុកគេធ្វើម្ហូបពិសេសៗ ឱ្យមនុស្សទោសទាំងអស់បានឆ្ងាញ់ពីរដងដែលក្នុងមួយឆ្នាំ ។

***



# ដល់ថ្ងៃតុលាការសឹកកាត់ទោស

មុនកាត់ទោសច្រើនថ្ងៃ តុលាការសឹកបានហៅទៅសួរម្តងព្រមជាមួយនិងមិត្តភក្តិឯទៀត។ នៅពេលនោះហើយទើបខ្ញុំបានជួបនិងលោកប៉ាច ឈឿន ជាលើកទី២ ។ តពីនោះមក១៥ថ្ងៃ ទើបគេហៅទៅសួរម្តងទៀតជាចុងក្រោយបង្អស់ ។ លុះត្រឡប់មកវិញគេបញ្ចូលទៅក្នុងបន្ទប់មួយផ្សេង ក៏បានជួបនិងលោកគ្រូអាចារ្យប៉ាង ខាត់ ដែលបានសួរសុខទុក្ខខ្ញុំរួចលោកប្រាប់ថា អ្នកណាដែលបាននៅបន្ទប់នេះ (Salle15) គឺជាអ្នកទោសធ្ងន់បំផុតត្រូវទទួលទោសពី៥ឆ្នាំទៅរហូតសម្លាប់ចោលឬទៅកោះត្រឡាចមួយជីវិត ឬបើមិនជាប់ពិរុទ្ធទេ នឹងបានរួចខ្លួនក្នុងពេលឆាប់ៗដោយឥតកាត់សេចក្តីទេ ។ នៅបន្ទប់នេះបានតែមួយថ្ងៃគេនាំទៅនៅបន្ទប់ខ្ញុំដដែលវិញ បានជាខ្ញុំនឹកឃើញប្រហែលជាគេយកទៅឱ្យនៅបន្ទប់ជាមួយលោកអាចារ្យប៉ាង ខាត់ដោយភ័ន្តច្រឡំទេដឹង ? លុះដល់គេហៅលើកក្រោយទៅកាត់សេចក្តីទើបខ្ញុំនឹកឃើញថា គេយកទៅដាក់នៅបន្ទប់ជាមួយលោកគ្រូអាចារ្យប៉ាង ខាត់ រឿងនេះមកពីរកទោសយើងមិនទាន់អស់ដែលគេហៅទៅវិញដោយមានរឿងថ្មីថែមទៀត ។ គេបញ្ជូនទៅសាល១៥ (salle 15) គេទុកជាមានទោសធ្ងន់បំផុតហើយតទៅគេត្រូវបញ្ជូនទៅកោះត្រឡាច ។ ចំណែកលោកគ្រូអាចារ្យប៉ាង ខាត់ ពេលក្រោយមកលោកត្រូវរួចខ្លួនដោយតុលាការឥតកាត់ទោសដូចខ្ញុំឡើយ ។

មុនកាត់សេចក្តីមានមេធាវីជាតិបារាំងម្នាក់ បានទៅជួបខ្ញុំនៅឯតុលាការសឹកប្រាប់ខ្ញុំថា ឪពុកខ្ញុំជួលគេឱ្យជួយការពាររឿងខ្ញុំនាំឱ្យខ្ញុំមានសង្ឃឹមថា មុខជាបានរួចខ្លួនមិនខាន ។ លុះចូលទៅអង្គុយចាំក្នុងសាលកាត់ទោសបានបន្តិចឮស្នូរកណ្តឹងរោរ៉ីរ៉ាវរួចក៏ឃើញទាហានបារាំង២២នាក់ ដើរស្រូចូលមកឈរជាពីរជួរប្រកបដោយកាំភ្លើងព្រមទាំងចំពុះទង់ដោតនៅចុងស្រាប់ ។ លុះកណ្តឹងរោរ៉ីលើកទី២ទាហានទាំងនោះក៏គំនាប់អាវុធព្រីបស្មើគ្នា ក្រោមស្នូរបញ្ជារនៃនាយទាហានរួចឃើញសេនានីទាហាន៤_៥នាក់ ចេញមកពីបន្ទប់, គឺសក្តិ២មួយនាក់,សក្តិ៣ពីរនាក់ , សក្តិ៥ម្នាក់ហើយ

មានសក្តិ៣ម្នាក់ទៀតជាអ្នកចោទតំណាងរាជការ (Procureur de la République) បើខ្មែរយើងពីដើមហៅថា«ព្រះរាជអាជ្ញា» ។ លុះដល់លោកតុលាការបានអង្គុយតាមកន្លែងរៀងខ្លួនហើយ, ទើបនាយទាហានបញ្ជាឱ្យដាក់អាវុធ ហើយមកឈរតម្រៀបគ្នាពីក្រោយពួកមនុស្សជាប់ចោទ ។

ក្នុងពេលនោះក្រោយដែលក្រឡាបញ្ជីបានសូត្រលិខិតចោទគ្រប់គ្នាហើយ ទើបសក្តិ៥ចាងហ្វាងគេហៅឈ្មោះសួរម្នាក់ម្តងៗតាមខចោទ ។ លុះសួរចប់ហើយទើបសក្តិ៣តំណាងរាជការគេចោទទម្ងន់ទោសគ្រប់ៗគ្នា ។ ក្រោយនោះត្រូវវេនមេធាវីការពារ ដើម្បីសម្រាលទោស ។ រួចទើបសក្តិ៥ចាងហ្វាងហៅឈ្មោះយើងសួរគ្រប់គ្នាក្រែងមានយោបល់អ្វីតវ៉ាថែមផ្សេងទៀត ។ លុះយើងរាល់គ្នាឆ្លើយថាឥតមានអ្វីតវ៉ាទៀតទេ ទើបគេក្រោកឡើងព្រឹបទង្គិចតុភ្លាំងៗហើយនាំគ្នាចូលទៅក្នុង ដើម្បីពិភាក្សាទោសដែលត្រូវកាត់ចំពោះអ្នកជាប់ចោទម្នាក់ៗ ។ ឯពួកទាហាននៅតែចាំគំនាប់គ្រប់ពេលដែលគេចូលទៅក្នុង និងពេលចេញមកវិញ ។ ចំណែកមេធាវីមានសិទ្ធិគ្រាន់តែទៅស្តាប់គេពិភាក្សាឥតមានសម្លេងអ្វីតវ៉ាទេក្នុងពេលពិភាក្សានោះ ។

លុះចេញពីពិភាក្សាមកវិញ ,ទាហានឈរគំនាប់ត្រង់ជើងម្តងទៀត,ទើបគេហៅឈ្មោះប្រាប់ទោសគ្រប់គ្នាម្នាក់ម្តងៗ ។ ក្នុងពេលប្រាប់ទោសមានអ្នកប្រែភាសាខ្មែរម្នាក់ស្រែកប្រាប់ថាចាំស្តាប់សេចក្តីសម្រេចរបស់តុលាការ ! គេហៅឈ្មោះប៉ាច ឈឿនមុនគេ,លោកឆ្លើយបាទ !_អ្នកឯងត្រូវទោសប្រហារជីវិតបង់ ! រួចហែម ចៀវ ! បាទ!អ្នកឯងត្រូវទោសប្រហារជីវិតបង់ !_នួន ឌួង អ្នកឯងត្រូវទោសប្រហារជីវិតបង់!តមក : ប៉ុណ្ណចន្ទ ប៉ុល ! បាទ ! អ្នកឯងត្រូវទោសគុក៥ឆ្នាំ និង១៥ឆ្នាំ នីរទេសមិនឱ្យនៅក្នុងស្រុក ! ។ រួចហៅតៗទាល់តែគ្រប់គ្នា... ។

មិត្តជាទីស្នេហា ! កាលដែលបានឮថាគុក៥ឆ្នាំ, នីរទេស១៥ឆ្នាំ,ខ្ញុំក៏ស្លុតចិត្តរន្ធត់ស្មារតី,ដូចជាគេយកដុំទឹកកក១ដុំធំទម្ងន់៥០គីឡូក្រាមដាក់លើក្បាល ហើយធាតុត្រជាក់នៃទឹកកកនោះក៏ធ្លាក់ស្រឹតៗតាំងពីក្បាលចុះមកក្រោម ត្រជាក់សព្វសាច់ស្រាលខ្លួនស្មើនឹងខ្យល់ចាប់មួយរំពេចដោយ



តាំងពីកើតមកដល់ធំប៉ុណ្ណេះមិនដែលមានទោសអ្វីសោះ សូម្បីតែទោសមួយម៉ោងក៏គ្មានដែរស្រាប់តែត្រូវទោសធ្ងន់តែម្តង ។ ខ្ញុំនឹកឃើញថារាសីខ្ញុំចុះអស់រលីងដល់ថ្នាក់ក្រោមបំផុតហើយ ។

ចំណែកលោកប៉ាច ឈឿន ,លោកគ្រូអាចារ្យហែម ចៀវ, លោកនួន ឌួង ,ក្រោយដែលបានប្រកាសទោសរួចហើយ,គេបានប្រាប់អ្នកទាំង៣នាក់នេះដែលត្រូវទោសប្រហារជីវិត, គេនឹងបញ្ជូនសំណុំរឿងទៅលោកប្រេស៊ីដង់រេពុប្លិក ប្រមុខរដ្ឋាភិបាលបារាំង ដើម្បីសុំអនុគ្រោះទោសតាមសមគួរ។ ក្រោយពេលនេះ,គេក៏ឱ្យពួកយើងតម្រៀបជួរហើយឱ្យត្រឡប់មកគុកធំវិញ ។ ឯរូបខ្ញុំនិងមិត្ត៣នាក់ទៀត គេយកទៅដាក់ក្នុងបន្ទប់តូចល្មមមួយទទឹងប្រហែល៣ម៉ែត្រ , បណ្តោយប្រហែល៦ម៉ែត្រ ។ នៅនោះខ្ញុំបានឃើញអ្នកទោសជាតិយួន៧នាក់នៅនោះដែរ ។ ពួកយួនសួរខ្ញុំជាភាសាយួនថាគេដាក់ទោសប៉ុន្មានឆ្នាំ ? ខ្ញុំឆ្លើយថាណាំណាំ(៥ឆ្នាំ) _ពួកនោះនាំគ្នាសើចគិលឡើងថាប៊ីឌីកូងឡូង់រ៉ូយ ! ។ ខ្ញុំមិនចេះពាក្យ«កូងឡូង»នេះសោះ,មិនដឹងថាយ៉ាងម៉េច,គិតមិនយល់ន័យសោះ ខ្ញុំថាមិនយល់ទេ,ខ្ញុំគិតទៅឃើញថាក្រែងគេបញ្ជូនទៅពេជ្រនិលត្បិតនៅស្រុកខ្មែរមានកន្លែងពេជ្រនិលនេះឬទេជាកន្លែងចាញ់សម្រាប់ឃុំមនុស្សទោសឧក្រិដ្ឋ ។ គិតចុះគិតឡើងនៅតែមិនយល់ដដែល ។

មិត្តខ្ញុំពីរនាក់ទៀតសួរថា : គេសើចរឿងអី ? គេបញ្ជូនពួកយើងទៅណា ? គ្រានោះមានខ្មែរក្រោមម្នាក់ក្នុងចំណោមយួនទាំង៧នាក់នោះដែលខ្ញុំស្មានថាជាយួនទាំងអស់គ្នា,ខ្មែរនោះអត់មិនបានក៏ឆ្លើយប្រាប់ថាកូងឡូងនោះ គឺកោះត្រឡាច!ឮពាក្យថាកោះត្រឡាចភ្លាម,ខ្ញុំក៏ភ្ញាក់ខ្លួនដូចគេកន្ត្រាក់តែម្តង,ត្រចៀកហឹងអស់ ស្តាប់អ្វីលែងឮហើយដោយនឹកឃើញថារញ្ជួយម្តងហ្នឹង,អស់សង្ឃឹមថានឹងរស់រានមានជីវិតត្រឡប់មកស្រុកវិញហើយ ត្បិតធ្លាប់ឮគេនិយាយតៗមកថា កោះត្រឡាចនោះនៅកណ្តាលសមុទ្រឆ្ងាយណាស់,ជាកន្លែងដាក់មនុស្សទោសឧក្រិដ្ឋ ។ ក្រោយនោះ,ខ្ញុំក៏ក្រោកទៅអង្គុយជិតខ្មែរក្រោមនោះ ហើយសួរពីស្ថានភាពកោះត្រឡាចយ៉ាងម៉េចខ្លះ ។ គាត់នោះបានអធិប្បាយសព្វគ្រប់ប្រាប់ខ្ញុំ ហើយគាត់ប្រាប់ថាគាត់ឯងគេដាក់ទោសប្រាំឆ្នាំមិនយូរប៉ុន្មាន

ទេ នឹងរួចមកវិញហើយកុំភ័យអី!អម្បាលដល់ពួកអញនេះគេកាត់ទោសដល់៣០ឆ្នាំម្ដេចអញមិនសូវគិតគួរប៉ុន្មាន ។ ខ្ញុំសួរគេវិញថាបងឯងទោសអី?គាត់ឆ្លើយថា អញទោសសម្លាប់គេហើយទោសប្លន់ថែមទៀត ។

បងប្អូនជួយពិចារណាមើលៈជាតិខ្មែរដូចគ្នាមិនព្រមទទួលស្គាល់ខ្មែរគ្នាឯងទេ, មិនព្រមនិយាយភាសាខ្មែរទេ ប៉ុន្តែដោយអង្គុយស្ដាប់ទៅប្រហែលជាតឹងទ្រូងណាស់មើលទៅ,បានជាគេព្រមនិយាយខ្មែរមករកខ្ញុំ ។ គ្រានោះខ្ញុំសួរទៅវិញថា បងឯងខ្មែរម៉េចមិនព្រមនិយាយខ្មែរណែនាំពួកខ្ញុំផងព្រោះពួកខ្ញុំមិនចេះយួនទេ ! គេឆ្លើយថានិយាយខ្មែរទៅពួកយួនមើលងាយអញ ,ថាអញជាជាតិខ្មែរ ។ សូមបងប្អូនជួយស្ដាប់មើលចុះ!ជាតិខ្មែរយើងឱ្យតែចេះភាសាបរទេសហើយនិយាយតែភាសាគេ,លែងនិយាយភាសាខ្លួនឯងសោះ ថាជាតិឯងជាជាតិថោកទាបទៅវិញ ។ ដូចយ៉ាងជាតិខ្មែរយើងដែលចេះភាសាបារាំងសែស,ខ្លះជាវរជនផង, គេនាំកូនចៅគ្រួសារគេនិយាយតែបារាំងរហូតដល់ភ្លេចភាសាជាតិចោលអស់ ថាជាភាសាថោកទាបទៅវិញ ។ មើលចុះស្រីយួនដែលយកប្ដីបារាំង,ដល់មានកូនគេបង្ហាត់ឱ្យនិយាយតែពាក្យយួនឱ្យស្រឡាញ់ជាតិយួនខាងម្ដាយជាងឪពុក ។ បើជាស្ត្រីខ្មែរយើងវិញ ,បើបានប្ដីបារាំងហើយ,កូនប្រុសស្រីនិយាយតែបារាំងឥតចេះខ្មែរសោះ,អប់រំស្រឡាញ់ជាតិឪពុកជាងជាតិម្ដាយ ។ បើនិយាយខ្មែរទៅខ្លាចគេថាមិនមែនកូនបារាំង,នេះជាគំនិតខ្ញុំគេតព្វជត្រកូលឥតភ្ញាក់រលឹកសោះ ។ បើមានជាតិខ្មែរណាភ្ញាក់រលឹកជួយណែនាំតាមផ្លូវនយោបាយ ដើម្បីឱ្យប្រទេសជាតិរួចពីទាសភាព,មានសេរីភាពឡើងវិញ, អ្នកនោះគេសម្គាល់ថាជាមនុស្សថោកទាប,អាវ៉ាសែឥតខ្លឹមសារ,គេឥតហ៊ានដើរជិតទេខ្លាចមានរឿងដល់ខ្លួនគេទៀត ។

គំនិតនេះផុំក្នុងខួរក្បាលខ្ញុំក្នុងគ្រានោះ ដែលនាំឱ្យខ្ញុំរឹតតែខ្លោចចិត្តអាណិតជាតិខ្មែរទ្វេឡើង ។

នៅក្នុងគុកធំព្រៃនគរបានជាងពីរខែ, ទើបគេនាំខ្ញុំព្រមទាំងពួកមិត្តទាំងរស់ទៅចុះកប៉ាល់ជំនួញមួយយ៉ាងធំដែលនឹងបើកចេញទៅកោះត្រឡាច ។ កោះត្រឡាចជាកោះរបស់ខ្មែរកើតពី



ដើមតែបារាំងឱ្យយួន នៅចម្ងាយជាង៣០០គីឡូម៉ែត្រពីដីគោកក្នុងសមុទ្រចិន ។ អ្នកទោសដែលបារាំងយកទៅដាក់នៅគុកកោះត្រឡាច ឥតសង្ឃឹមថាបានមកស្រុកវិញឡើយ ។

លោកអ្នកនឹងជ្រាបអំពីទុក្ខវេទនានៅទីនោះយ៉ាងណាៗតទៅទៀត... ។

***

## -៧-

# ដំណើរទៅកោះត្រឡាច

ប្រហែលម៉ោង១៧ល្ងាច, អ្នកបម្រើក្នុងកប៉ាល់បានលើកបាយស១ឆ្នាំងធំព្រមទាំងទឹកសម្លមួយមុខមកឱ្យទទួលទាន គឺជាត្រឡាចស្ងោរជាមួយឆ្អឹងជំនីរជ្រូកបង់តាំងឆាយខ្ទឹមស និងម្រេចនៅក្ដៅៗ ។ សូមមិត្តជាទីស្នេហាជ្រាបថាតាំងពីខ្ញុំចូលទៅរងទុក្ខវេទនានៅគុកភ្នំពេញរហូតដល់គុកព្រៃនគររួមទាំងអស់ចំនួន៣ខែ២០ថ្ងៃហើយ ខ្ញុំពុំដែលបានទទួលទានបាយអង្ករសម្ដងណាឡើយ ។ ទើបតែនៅពេលដែលមកប៉ះលើបាយស និងម្ហូបកប៉ាល់យ៉ាងគួរសមនាំឱ្យខ្ញុំទទួលទានបានច្រើន ទាល់តែតឹងពោះហួសកំណត់ម៉ោជាបាល់ឆ្លល់ពោះផ្អើះៗដកដង្ហើមស្ទើរមិនចេញរួច ក៏ប្រាស់ដេកលើក្ដារកប៉ាល់នោះតែម្ដងទាល់តែបានមិត្តខ្ញុំឈ្មោះរឹមនៅតាកែវមកជួយរឹតពោះឱ្យស្រកឆាប់ៗ ។ មិត្តរឹម រឹតផងស្ដីបន្ទោសឱ្យខ្ញុំផងថាស៊ីអីក៏ស៊ីមិនដឹងប្រមាណ ទាល់តែចាកប្រាស់ដូច្នេះ ។ លុះរឹតបានបន្តិចទៅពោះកាន់តែស្រកធូរខ្ញុំបានស្រួលខ្លួនគ្រាន់បើ ។ ប្រហែលម៉ោង១៨ជាង ទើបអ្នកយាមចូលមកដាក់ខ្នោះជើងទាំង២គ្រាប់ៗគ្នា ។ គេឱ្យដេកសម្រាកនៅទីនេះទៅ ។ ក្រោយពេលនេះបន្តិចឮស៊ីប្លេ(កញ្ចែ)កប៉ាល់សញ្ញាថាចេញពីផែហើយ នៅវេលាប្រហែលម៉ោង២០ ។ ក្រោយ

នោះឃើញកម្មករម្នាក់យកពោងមកចែកម្នាក់មួយៗគ្រប់គ្នាហើយក៏ចាក់សោបន្ទរតែជើងនៅជាជាប់ខ្នោះដដែលដោយប្រាប់ថាបើមានអាសន្នមកដល់ពេលណា ឯងទាំងអស់គ្នាត្រូវដោះខ្នោះនេះចេញហើយលោតទឹកហែលយកតែរួចខ្លួនទៅចុះ ។ ឮដូច្នេះខ្ញុំនឹកឆ្ងល់ក៏សួរទៅមិត្តខ្មែរក្រោម ម្នាក់ដែលធ្លាប់ស្គាល់កោះត្រឡាចថា ហេតុអីក៏គេឱ្យយើងប្រុងប្រយ័ត្នដូច្នេះ ? មិត្តនោះប្រាប់មកវិញថាកប៉ាល់បើកដល់ត្រង់នេះចូលដល់សមុទ្រកាម៉ៅ ហើយជាកន្លែងទឹកជ្រៅណាស់ផុតពីកាប់សាំង-ហ្សាក់ (Cap Saint-Jacque) ពីរ-បីគីឡូហើយថាដែលគេឱ្យប្រយ័ត្ននោះខ្លាចកប៉ាល់ត្រូវគ្រាប់បែកបណ្ដែត(មីន)របស់ជប៉ុនដែលវាបណ្ដែតពាសពេញទឹកសមុទ្រឱ្យរសាត់ទៅរលកជាហេតុ នាំឱ្យមានអន្តរាយជាច្រើន បើកប៉ាល់ត្រូវមីនយើងទាំងអស់គ្នានឹងទៅជាចំណីត្រីហើយ ។ ពួកខ្ញុំគេឱ្យអង្គុយនៅបាតកប៉ាល់ខាងមុខបង្អស់ដែលស្រួចល្ហៃម ។ បើកាលណាមានគ្រោះថ្នាក់មុខជាស្លាប់មុនគេបង្អស់ដោយកន្លែងមុខកប៉ាល់តែងតែប៉ះ មីនមុនកន្លែងឯទៀត ហើយម្យ៉ាងគ្មាននរណាជួយហូតរនុកខ្នោះដែកពីជើងចេញផងត្បិតគេរវល់តែភ័យរកច្រកចេញយកតែប្រាស់អាយុគ្រប់គ្នាដែរ ។ ហើយបើដោះទាន់ក៏មិនអាចចេញពីក្នុងឃ្លុប កប៉ាល់ទាន់ដែរ គិតទៅគិតមកឥតមានសង្ឃឹមអ្វីឡើយ មានតែរំលឹកគុណព្រះពុទ្ធព្រះធម៌ព្រះសង្ឃនិងគុណមាតាបិតាជាទីពឹងសូមឱ្យជួយប៉ុណ្ណោះឥតនរណាជួយនរណាឡើយ ។

លុះកប៉ាល់ចេញបានពីរបីម៉ោង, មិត្តខ្ញុំទាំងអស់ក៏តាំងពុលរលកក្អួតចង្អោរសឹងតែគ្រប់គ្នានាំឱ្យធុំស្អុយឆ្អាបសឹងបែកក្បាលស្លាប់,ឥតមានអ្វីការពារឡើយ ។ ចំណែកខ្ញុំទ្រាំបានជាងគេបន្តិចក៏តាំងពុលនឹងគេដែរ ,បាយដែលឆ្អាញ់ដល់ចុកពោះក៏នាំគ្នាចេញមកក្រៅវិញ,នៅតែពោះទទេ ។ ទាំងអស់គ្នាទៅជាឈឺក្បាលវិលមុខ រង៉ាប់រង៉ើរួចប្រាស់ដេកលក់រពេតរហូតដល់ភ្លឺតែម្ដង ។ លុះដឹងខ្លួនឡើង,ស្រាប់តែដឹងខ្លួនថាកប៉ាល់ឈប់នៅនឹងថ្កល់ ។ ប្រហែលមួយម៉ោងក្រោយមក,ទើបឃើញគេបើកគម្របឃ្លុបកប៉ាល់ចេញ,ខ្ញុំក្រឡេកទៅឃើញមនុស្សជាច្រើននាក់ ឈ្លោកមើលក្នុងកប៉ាល់ហើយនិយាយថា «គីណាំថ្ងណាអិច» ខ្ញុំសួរទៅមិត្តកម្ពុជាក្រោមថាគេនិយាយអ្វី? គាត់ថា«គេថាជើងនេះមនុស្សទោសតិចទេ» ។ ក្រោយនេះ មួយស្របក់ ឮសូរគេស្ទូចរបស់ពីក្នុងកប៉ាល់ដាក់ទៅក្នុងទូកធំៗ ដើម្បីនាំទៅកាន់ច្រាំងកោះត្រឡាច ដែលនៅចម្ងាយប្រហែល២គីឡូម៉ែត្រ ។ លុះខា



ឥវ៉ាន់ដាក់ទូកទាំងពីរហើយ , ទើបគេដោះខ្នោះជើងពួកខ្ញុំចេញ ហើយឱ្យឡើងទៅខាងលើកនៃកប៉ាល់ ។ ពេលនោះខ្ញុំក្រឡេកឃើញដីគោក (នៃកោះត្រឡាច) ឃើញទេសភាពល្អគួរគយគន់ពេកណាស់ ។

មិត្តអើយ ! ខ្ញុំមិននឹកស្មានថា កោះត្រឡាចធំដល់ម្លឹងសោះគឺធំជាងទីប្រជុំជនខេត្តកំពង់ស្ពឺទៅទៀត មានផ្ទះថ្មធំតូចសង់ហូរហែគួរឱ្យសប្បាយណាស់ ។ ប៉ុន្តែយើងខ្ញុំដែលជាមនុស្សមានទោសធ្វើម្ដេចនឹងសប្បាយចិត្តកើត បើរស់តែជាប់ក្ដី មានពេលឯណាទៅដើរឱ្យសប្បាយបានហើយចេះតែនឹកថាមិនដឹងគេនាំយើងទៅដល់កន្លែងណាទៀតទេ ។ គ្រានោះ ពួកតម្រួតគេបានបង្គាប់ឱ្យពួកខ្ញុំចុះទៅក្នុងទូក ឱ្យអង្គុយលើបាវអង្ករដែលគេផ្ទុកជាមួយឪទិនទឹកត្រីនិងកញ្ចៀត្រី-ងៀត រួចហើយកាណូតក៏បើកសណ្ដោងទូកនោះទៅដល់កំពង់ផែកោះត្រឡាច ។ នោះតម្រួតនាំឡើងពីទូកទៅលើគោកក៏បង្គាប់ឱ្យអង្គុយជាពីរជួរទើបមេតម្រួតនៅកោះ គេមករាប់ទទួលពីតម្រួតទៅពីនាយរួចទើប គេនាំយើងទៅកាន់ទីឃុំឃាំងមួយចម្ងាយប្រហែល ២គីឡូម៉ែត្រពីផែកប៉ាល់ ។ ឯពួកមនុស្សទោសមានខ្មែរមានយួនដែលមកចាំទទួលលីសែងអីវ៉ាន់ពីទូក ទៅចេះតែនិយាយសុំទិញស្បែកជើងខ្ញុំគ្រប់ គ្នាថាខ្ញុំលក់ថ្លៃប៉ុន្មាន ? ត្បិតស្បែងជើងខ្ញុំជាស្បែកជើងនៅល្អនៅឡើយ ។ ប៉ុន្តែមិត្តខ្ញុំម្នាក់ដែល ធ្លាប់មានការពិសោធន៍បានឃាត់ថាកុំអាលលក់ វាឱ្យថោកណាស់ ចាំទៅដល់ទីគុកសឹមលក់ទើបបានថ្លៃ ។ ខ្ញុំដើរបណ្ដើរស្ដាប់គេនិយាយបណ្ដើរស្រាប់តែដល់កន្លែងគុកតូចមួយសម្រាប់ឱ្យមនុស្ស ទោសដែលមកដល់កោះត្រឡាចថ្មីចូលសម្រាក ។ នៅទីនោះគេឱ្យយើងឈរតម្រៀបគ្នាជា២ជួរ ហើយគេបង្គាប់ឱ្យស្រាតខោអាវគ្រប់គ្នាយកទៅដាក់ពីមុខគ្រប់គ្នាទើបគេហៅឱ្យចូលទៅខាងមុខ គេម្នាក់ម្ដងៗ ដើម្បីឆែកឆេរដោយតម្រួតជាតិយួនពីរបីនាក់ ដែលមានមេតម្រួតជាតិបារាំងម្នាក់មាឌ ធំឈរចាំត្រួតមើលមួយជាន់ទៀត ។ មុនដំបូងគេឱ្យហាមាត់យ៉ាងធំហើយឱ្យក្អកយ៉ាងខ្លាំងៗ ដើម្បីឱ្យគេសង្កេតរកមើលក្រែងយើងលាក់សំបុត្រអ្វីៗឬមួយខ្លាចយើងលាក់ក្រដាសប្រាក់ ១០០រៀលក្នុងបំពង់ក ឬក្នុងមាត់រួចគេឱ្យឱនក្បាលចុះចំតិតក្ដិតឡើងដោយបេះជើងឱ្យធំដើម្បីឱ្យ ចំរោរន្ធក្ដិតជាការងាយគេនឹងពិនិត្យរកក្រដាសប្រាក់នេះទៀត ។

ទិដ្ឋភាពកោះត្រឡាចឆ្នាំ១៩៤២



គេបង្គាប់ឱ្យមនុស្សទោស ម្នាក់មកហែកចង្កេះក្តិតយើងពិនិត្យមើលផែមទៀត , រួចហើយគេឱ្យយើងងើបត្រង់ឡើងវិញហើយឱនក្បាលចុះបន្តិច, ទើបគេយកដៃមកវែកសក់ក្បាលយើងមើលព្រមទាំងមើលរន្ធត្រចៀកផង ។ លុះពិនិត្យមើលរួចសព្វគ្រប់ហើយទើបគេឱ្យទៅឈរតាមជួរដើមវិញ ។ គេធ្វើដូច្នេះប្តូង ម្នាក់ៗទាល់តែគ្រប់គ្នា ។ សូមជម្រាបថាក្នុងការពិនិត្យមានមិត្តខ្ញុំពីរបីនាក់បានត្រូវគេធ្វើទារុណកម្មដោយវាយនិងរំពាត់ផ្តៅដំបង,រំពាត់ក្តគោយ៉ាងខ្លាំង ទាល់តែព្រោមខ្លួនដោយហេតុក្អកមិនខ្លាំង, ចំតិតក្តិតមិនត្រូវតាមបំណងគេ ។ ចំណែកខ្លួនខ្ញុំជាសំណាងល្អដែរ,បានគេចផុតពីទណ្ឌកម្មយ៉ាង វេទនានេះ,ដោយហេតុមកពីខ្ញុំឈរនៅលេខទី៥ ,ខ្ញុំខំសង្កេតអ្នកទោសដែលត្រូវគេចែកមុនខ្ញុំនោះ គេធ្វើម្តេចខ្លះ ។ លុះដល់វេនខ្ញុំៗធ្វើតាមរបៀបគេមុន ។ លុះគេបានសាកសួរតាមតែនឹកឃើញរួច ហើយទើបគេអនុញ្ញាតឱ្យស្លៀកពាក់ដូចដើមវិញ ហើយគេនាំឱ្យទៅសម្រាកនៅក្នុងគុកនោះចំនួន ១៥ថ្ងៃមិនទាន់ឱ្យធ្វើការអ្វីឡើយ ។ បានជាឱ្យសម្រាកដូច្នេះដើម្បីបំបាត់រោគពុលរលកឱ្យជាស្រួលបួល សិន,ទើបគេចាត់ឱ្យធ្វើការផ្សេងៗ ។

ក្នុងពេលសម្រាកនេះ,មិត្តភក្តិដែលគេបានមកនៅកោះត្រឡាចមុន បាននិយាយប្រាប់ខ្ញុំសព្វគ្រប់ដែលជាហេតុនាំឱ្យខ្ញុំភ័យព្រួយពន់ពេកណាស់ ។ គេថានៅទីនេះបារាំងឱ្យធ្វើការច្រើនយ៉ាងណាស់មានធ្ងន់មានស្រាលតាមតែយើងស្ម័គ្រធ្វើ ។ ប៉ុន្តែពេលដែលយើងចូលទៅស្ម័គ្រនោះជួនណាហេងជួនណោស៊យ ។ ឯការធ្ងន់មានកាប់អុស,មុជក្នុងសមុទ្រកាច់ផ្កាថ្មយកមកដុតកំបោរសម្រាប់សង់ផ្ទះ,យកស្រូវកិនឱ្យបានជាអង្ករក្រហម,នេសាទត្រីសមុទ្រកាប់ឈើហ៊ុប,ធ្វើអំបិលស,អំបិលខ្មៅ ។ល។ ... ការស្រាលគឺធ្វើបោយ បារាំង(ប៉ុន្តែមុខការនេះមានតែជាតិយួនទេ, ចំណែកខ្មែរយើងបារាំងវាមិនប្រើទេ) ដុតធ្យូង,ធ្វើឥដ្ឋធ្វើ ការចំការដំណាំផ្សេងៗ ។ គេចម្លងដាក់ទៅកោះតូចៗក្បែរនោះឱ្យរើសពងល្មេច ។ មានមួយពួកទៀត គឺឱ្យធ្វើគិញ (recherche) សម្រាប់ដើរចាប់មនុស្សទោសដែលប្រុងនឹងរត់ទៅដីគោកវិញតាមទូកសំពាត់ឬក្បូនឫស្សី ។ គេបានរៀបរាប់ពីការស្រួលនិងលំបាកឱ្យខ្ញុំដឹងដូចតទៅ ៖

ការដែលធ្ងន់មាន៦យ៉ាងគឺ ៖ ទី១- ក្នុង១ថ្ងៃ,មនុស្សទោសម្នាក់ ត្រូវកាប់អុសនិងកាំបិតឬ

ពួថៅលើភ្នំ១ថ្ងៃឱ្យបានកំពស់១ប៉ែត្រ ទទឹង០,៨០ម៉ែត្រទើបបានសុខខ្លួន ។ បើមិនបានទេនឹងត្រូវទណ្ឌកម្មដោយវាយដល់សន្លប់ក៏មាន,ដល់ស្លាប់ក៏បាន ។ បើវាយមិនស្លាប់ទេ,គេយកទៅដាក់គុកងងឹតពី១០ថ្ងៃទៅ១៥ថ្ងៃទទួលទានបាយសាបរហូតទើបឱ្យរួចទោសបាន ។ ទី២ក្រុមនេះត្រូវមុជទឹកកាច់ផ្កាថ្មនៅបាតសមុទ្រឱ្យបានច្រើន ក្នុងជម្រៅទឹកប្រហែល៣ឬ៤ម៉ែត្រ ។ បើមិនបានទេ តម្រួតខាងលើយកថ្នោលដែលខាងចុងមានចំពាមពីរចាក់ត្រង់កឬស្នាដោយជ្រមុជទៅក្នុងទឹកឱ្យខំកាច់ថ្មឱ្យបាន ទើបវាព្រមឱ្យឡើងមកលើសាឡាង ។ បើមិនបាន,គេមិនឱ្យឡើងទេ,ណាប្អូយរងាផង ,ឈ្លក់ទឹកផឹកទឹកប្រៃជាតិអំបិលផង ។ ទី៣_ពួកកិនស្រូវក្នុងរោងត្រូវកិនឱ្យបានជាអង្ករសផង អង្ករក្រហមផង ដោយត្បាល់កិនដោយដៃដូចជាគេធ្លាប់ប្រើនៅស្រុកយើងពីដើម ។ ក្នុងត្បាល់កិនមួយបនុស្សទោស៣នាក់គឺ២នាក់កិន,ម្នាក់នាក់ចាក់ស្រូវ ។ ធ្វើការពីម៉ោង៧ដល់ម៉ោង១១ព្រឹក ទើបឈប់សម្រាកទទួលទានបាយ, រួចចាប់ធ្វើពេលល្ងាចពីម៉ោង១៣ដល់ម៉ោង១៧ទើបឈប់ ។ វេទនាណាស់!នៅពេលនៅពេលធ្វើការក្នុងរោងកិនស្រូវ, គេឃើញតែអង្កាមនិងកន្ទក់ហុយហើរព្រោងព្រាតប្រឡាក់ស្រមកពេញទាំងខ្លួន រកមើលមុខមាត់អ្វីមិនឃើញទេពីព្រោះកន្លែងនីមួយៗមានត្បាល់កិនច្រើនពី៣០ទៅ៤០ ហើយគ្មានការពារសុខភាពគឺគ្រាន់តែហែកខោអាវចាស់យកមករុំបិទច្រមុះកុំឱ្យកន្ទក់វាចូលប៉ុណ្ណោះ, ប៉ុន្តែចំណែកខាងភ្នែកបិទមិនកើតទេជាហេតុនាំឱ្យមានជំងឺភ្នែក ។ ខ្លះចូលទៅធ្វើការរោងកិនស្រូវបានតែ៤_៥ថ្ងៃក៏ឈឺភ្នែកហើមពោររហូតដល់ហានខ្ទុះ,ទើបគេឱ្យទៅព្យាបាលនៅមន្ទីរពេទ្យខាងក្រៅ ។ ដល់ជាទៅ,បើមានវាសនា,គេបញ្ជូនទៅធ្វើការនៅកន្លែងផ្សេងទៅ ។ បើឥតភ័ព្វ,គេឱ្យមកធ្វើការនៅរោងកិនស្រូវដដែលទៀត,ជាហេតុនាំឱ្យរោគពបីភ្នែករីរីតតែខ្លាំងទៀត, ជួនណាបណ្ដាលឱ្យភ្នែកនោះខ្វាក់ក៏មាន, ទើបផ្លាស់ឱ្យទៅកន្លែងពុះឫស្សី,បិតផ្ដៅធ្វើកៅអី,ធ្វើកញ្ច្រែង ឬរបស់អ្វីតាមគេតម្រូវឱ្យធ្វើ ។ មិនមែនថាខ្វាក់ហើយឱ្យរួចខ្លួនឥតធ្វើការនោះទេ ។ សូមជម្រាបថាក្នុងឆ្នាំ១៩៤២នោះ,ស្រុកទេសកំពុងកើតចប្បាំង,រកថ្នាំសង្កូវអ្វីគ្មានទេ,ក្រណាស់ ។ នៅកោះត្រឡាចពេលនោះ,គឺនីន១គ្រាប់៣០រៀលរកមិនបានផង ។ ហេតុនេះហើយ,សេចក្ដីវេទនាគ្រប់បែបយ៉ាងត្រូវតែបានដល់បនុស្សទោសទាំងនោះតាមយថាកម្មដេកចាំតែស្លាប់មួយមុខប៉ុណ្ណោះ។បើបានកើតរោគរាកឬប្លូស,គេនាំបនុស្សនោះទៅព្យាបាលឯផ្ទះពេទ្យ , គ្រូពេទ្យបារាំងជំនាន់នោះ , វាយកទឹកសមុទ្រមួយកំប៉ុងពីក



ដោះគោមកឱ្យផឹក,បើកអ្នកជំងឺ នោះមិនផឹកទេ,វាវាយបង្ខំឱ្យផឹក ។

ឯមនុស្សទោសដែលវាប្រើបង្ខំឱ្យធ្វើការវាឥតមានត្រាប្រណី ឱ្យឈប់សម្រាកអ្វីបន្តិចឡើយ គឺប្រើឱ្យធ្វើការទាល់តែដល់ម៉ោងទើបឱ្យឈប់ប្រៀបបាននឹងគ្រឿងចក្រ(ម៉ាស៊ីន) ដូចជាកន្លែង កិនស្រូវជាដើម ។

ពួកទី៤_គឺពួកនេសាត្រីសមុទ្រ ។ នៅវេលាម៉ោង៣ទាបភ្លឺ,គេឱ្យចេញទៅជីកអួននៅសមុទ្រ,មានតម្រួតពីរបីតាមមៅផង ។ ក្នុងទូកមួយមានមនុស្សពីរ១០នាក់ទៅ១២នាក់តាមចំនួនទូកធំតូចមិនកំណត់ស្រេចតែលើបញ្ជារបស់នាយតម្រួត ។ បើអាកាសល្អឥតភ្លៀវខ្យល់,ទូកត្រូវចេញច្រើន,បើអាកាសប្រកបដោយភ្លៀងខ្យល់វិញ,គេឱ្យទូកតិចទៅនេសាទ ។ បើមងជាប់នឹងផ្កាថ្មនៅបាតសមុទ្រ, គេបង្គាប់ឱ្យមនុស្សទោសលោតទៅមុជចុះទៅដោះឱ្យរួចឥតអាណិតអាសូរថាគ្នាត្រូវរងារដោយខយល់ផងដោយទឹកផងទេ ។ ក្នុងពេលមុជទឹកទៅដោះមងនោះជួនណាមុតដៃនឹងផ្កាថ្មក៏មាន, ជួនណាប្រទះនឹងសត្វបបែលវាយកកន្ទុយវាចាក់ត្រូវដៃបណ្ដាលឱ្យចុកចាប់ឈឺផ្សា ប្រៀបបាននឹងពិសពស់វែកដូច្នេះឯង,ហើយត្រូវរងទុក្ខឈឺចាប់រហូតដល់ពេលត្រឡប់មកវិញ,ទើបគេឱ្យព្យាលឯមន្ទីរពេទ្យ,ជួនណាមនុស្សទោសគ្នាឯងរកថ្នាំអាយ ដូចជាស្មៅឬស្លឹកឈើព្រៃផ្សំលាបបិទមុខឱ្យក៏មាន ហើយនឹងបណ្ដាលឱ្យដៃរបួសនោះស្វិតដោយត្រូវដាច់សរសៃឈាម ។ មានពេលខ្លះមុជចុះទៅប្រទះនឹងសត្វឆ្លាមវាកាត់ដាច់ដៃជើងពិការមួយជីវិតក៏មាន ។

ចំណែកមនុស្សទោសពួកទី៥ ផ្នែកកាប់ឈើលើខ្នងភ្នំនោះច្រើនមានគ្រោះថ្នាក់ដូចតទៅ ៖

កាលណាកាប់ឈើហ៊ុបធំៗលើភ្នំបានហើយ គេត្រូវធ្វើផ្លូវសម្រាប់អូសឈើហ៊ុបនោះទម្លាក់ទៅក្នុងសមុទ្រ ដើម្បីចងជាក្បូននាំទៅកាន់រោងអារឈើនៅកន្លែងផ្សេងទៀត ។ លុះធ្វើផ្លូវរួចហើយ គេចងទាក់ឈើនោះដោយខ្សែពួរ ហើយនាំគ្នាអូសទម្លាក់ពីលើភ្នំមកជើងភ្នំ ។ មានឈើខ្លះប្រវែងជាង១០ម៉ែត្រ ក្នុងពេលអូសវាវាត់ចុះវាត់ឡើងទៅបុកដើមឈើក្បែរផ្លូវក៏មានជួនជ្រុលលឿនខ្លាំងពេកទៅកិនសង្កត់ឬបុកមនុស្សទោស ដែលគេចមិនទាន់បណ្ដាលឱ្យបាក់ដៃ បាក់

ជើងឬក៏កិនស្លាប់មួយនាក់ ឬពីរបីនាក់នៅនឹងកន្លែងក៏ច្រើនគួរឱ្យវេទនាក្រៃលែងឯកន្លែងដែលកាប់ឈើជាកន្លែងចាញ់ខ្លាំងផងទៀត បើមានកន្លែងណាមានឈើច្រើន មនុស្សទោសត្រូវទៅដេកនៅនោះយូរថ្ងៃដើម្បីកាប់ឈើឱ្យទាល់តែបានច្រើនដើម ។ ពេលដេកក្នុងព្រៃឥតមុងត្រូវមូសខាំផងទៅជាមានជំងឺគ្រុនចាញ់បណាដាលដល់ស្លាប់ក៏មាន ។ ឯចាញ់នោះបណ្ដាលមកពីមូសខាំផងបណ្ដាលមកពីព្រៃឈើធំអាប់អួរឥតមានអាកាសល្អផង ។

ទី៦.ក្រុមធ្វើអំបិល ក្រុមនេះជាមនុស្សទោសស្រាលសឹងតែជាមនុស្សឥតទោសធម្មតាយួនហៅថា«ទោសល្អ»គឺមនុស្សដែលមានទោសជាប់គុកបីដងក្នុង១ជីវិតខ្លួន នៅពេលដែលរួចទោសគេឱ្យទៅធ្វើអំបិល ។ ការរស់នៅនៃមនុស្សទាំងនេះដូចជាមនុស្សទោសដែរ ប៉ុន្តែឥតទោសទេ ប៉ុន្តែនៅកោះត្រឡាច គេខ្លាចមនុស្សពួកនេះ ណាស់ត្បិតវាចេះលួចដោយប៉ិនប្រសប់ណាស់គឺវត្ថុអ្វីក៏វាលួចដែរ តាំងពីខោអាវប្រាក់កាសជាដើមហើយមានពុតត្បុតផង ។

អ្នកទោសស្រាលធ្វើការស្រាលនោះគឺក្រុមធ្វើបោយបារាំង, គឺបម្រើនៅតាមផ្ទះបារាំង ។ មួយក្រុមទៀតសម្រាប់ធ្វើម្ហូបឱ្យបារាំង ។ មនុស្ស ទោសទាំងពីរពួកនេះ មានតែជាតិយួនទេ ខ្មែរយើងឥតបានធ្វើទេ ។

មួយក្រុមទៀតសម្រាប់ឡធ្យូង ដុតឡដែលជាការមិនជាលំបាកប៉ុន្មានទេ ពីព្រោះអុសសម្រាប់ដុតធ្យូងមានស្រាប់ ឯដីសម្រាប់ធ្វើឥដ្ឋក៏មានស្រាប់ដែរគឺគ្រាន់តែជាន់ដីនោះឱ្យម៉ត់បន្តិចរួចសូនដុំៗ រួចគប់ចូលក្នុងពុម្ពកៀស ឱ្យស្មើគោះឱ្យធូរបន្តិចរួចលើកពុម្ពឡើង ក៏បានទៅរូបរាងឥដ្ឋហើយយកទៅហាលឱ្យស្ងួតហើយយកទៅរៀបក្នុងឡ ទើបដុតឱ្យឆ្អិនទៅជាការស្រេច ។ ក្រុមនេះ មានពេលទំនេរច្រើនតែកាលធ្វើការរួចហើយនាំគ្នាផឹកតែជជែកគ្នាលេង,មានផ្ទះតូចល្មមនៅរៀងខ្លួន ហៅថាផ្ទះតៀម ឥតនៅជាមួយគេក្នុងគុកទេព្រមទាំងមានពេលទំនេរ ទៅរកចាប់ត្រីសមុទ្រយកមកអាស្រ័យបានទៀត ។

ក្រុមមួយទៀតសម្រាប់ធ្វើចំការ ។ គេចែកដីឱ្យ២៥ រង គេឱ្យដាំសាឡាត,ខាត់ណា,ស្ពៃ,



បន្លែផ្សេងៗ ,តាមតែគេតម្រូវឱ្យដាំ ។ ក្នុងមួយអាទិត្យ ,រដ្ឋការកណ្ដាលគេបើកអង្ករត្រីងៀតឱ្យរ៉ុងយកទៅផ្ទះរៀងខ្លួន,ដាំស្លទទួលមានខ្លួនឯង ។ ពួកនេះមាន ផ្ទះនៅក្រៅគុកដែរមានការរស់នៅធូរប្រពៃ។គួរសប្បាយគ្រាន់បើ មានរបស់របរប្រើប្រាស់ច្រើន ខាងគ្រឿងបរិភោគក៏ បរិបូណ៌ ។

ឯមួយក្រុមទៀតជាក្រុមគិញហៅថាក្រុមរ៉ឺសៀក,ជាក្រុមដើរស៊ើបការណ៍ចាប់ចង ដូចក្រុមគិញសម្ងាត់ខាងរដ្ឋការដែរ ។ ក្រុមនេះមានគ្នាច្រើនចំនួន៣០០ទៅ៤០០នាក់ហើយច្រើនតែជាជាតិខ្មែរ ។ គឺជានយោបាយបំបែកបំបាក់ដើម្បីត្រួតឱ្យបានស្រួល របស់បារាំងដែលឱ្យខ្មែរចាប់យួនធ្វើបាបតាមចិត្ត,មិនខុសពីជាតិខ្មែរយើងធ្វើជាភ្នាក់ងារក្រុមសម្ងាត់បារាំង ហើយធ្វើទារុណកម្មដល់ជាតិឯងឡើយ ។ ប្រដាប់សម្រាប់ធ្វើទារុណកម្មមាន ច្រើនបែបដែលមនុស្សតែងខ្លាចរអាគ្រប់គ្នា ។ ឯរបៀបធ្វើទារុណកម្មមានដូចតទៅ :

១-គេចាប់មនុស្សទោស ដែលប្រព្រឹត្តខុសឱ្យមានទោសមួយជាន់លើទោសចាស់ទៀតទៅធ្វើទារុណកម្ម ដោយចងស្លាបសេក(ចងដៃផ្ដោបគ្នាទៅខាងក្រោយ) ហើយយកទៅចងភ្ជាប់នឹងចុងខ្សែម្ខាង ,រួចយកចុងខ្សែម្ខាងសិកទៅក្នុងរ៉កកម្ពស់២ម៉ែត្រទៅ៣ម៉ែត្រ ទើបគេទាញចុងខ្សែរ៉កឡើងលើ ដើម្បីឱ្យជើងផុតពីដីប្រហែលកន្លះម៉ោង ទើបគេសួរចម្លើយតាមអំពើដែលខ្លួនប្រព្រឹត្តខុស ។ បើប្រកែក គេទាត់ឬដាល់ពោះទាល់តែសន្លប់ក៏មាន,ដល់ស្លាប់ក៏មាន ។ ជួនឆ្លើយតាមសំណួរគេមិនបានសព្វ ក៏គេវាយដែរ តែមិនដល់ការប្រកែកដាច់អង្គការឡើយ ។ លុះគេលែងមកវិញបានប្រហែល១០ឬ១៥ថ្ងៃក៏ឈឺស្លាប់ទៅ ដោយបណ្ដាលមកពីឈឺពោះ ឈឺពោះវៀន ដែលគេប្រហារនោះហើយដែលគ្មានថ្នាំអ្វីមើលខ្លួនឱ្យជាផង ។

២-គេឱ្យមនុស្សទោសស្រាតនៅខ្លួនទទេ ហើយឱ្យដេកផ្ងារលើតុវែងមួយ ដែលមានខ្សែចងសំបុងពីលើពិតានមក ហើយយកចុងម្ខាងនោះចងស្វាសឱ្យមាំយ៉ាងតឹងឬគេច្របាច់ស្វាសយ៉ាងខ្លាំងក្នុងការសួរចម្លើយ ។ បើមនុស្សនោះឆ្លើយប្រាប់តាមត្រង់ទៅគេស្រាយលែងភ្លាម ។ បើប្រកែកពុំព្រមឆ្លើយប្រាប់ហេតុពិត គេចងស្វាសឱ្យតឹងជាងមុនហើយទាញចុងខ្សែនោះឡើង

លើបន្តិច ។ សូមមិត្តពិចារណាមើល ! តើវាឈឺយ៉ាងណា ? យើងទ្រាំបានទេ ? ជួនណារៅជាសន្លប់ ។ តពីនោះទៅក៏រស់មិនបានយូរដែរ ។ ឯស្វាសនោះឈឺគ្រាំគ្រាកែមិនឡើងទេ នៅរបេកសុទ្ធតែឈាម ឬខ្ទុះក៏មាន, ជួនណានោមមិនចេញក៏មានឥតឱសថអ្វីព្យាបាលទេ ។ តពីនេះ,គេរបេកទៅដាក់គុកងងឹតទៀតចំនួន១០,១៥ឬ៣០ថ្ងៃតាមទោសស្រាលឬធ្ងន់ ។

៣-គេឱ្យមនុស្សទោស ដែលមានទោសលើទោសនោះរង្គុយសណ្ដូកជើងហើយរបេកឃ្នាបធ្វើដោយឈើថ្លឹក ឬឈើបែងសំរ៉ែតដែលគេចងភ្ជាប់គ្នានៅចុងម្ខាង ទុកឱ្យច្រហកចុងក្រោងយកមកសឹកប្រហាកកជើងម្ខាងចូលក្នុងឃ្នាបនោះ ហើយគេរឹតចុងឃ្នាបបន្តិចម្ដង១ទើបគេសួរចម្លើយ ។ បើមិនព្រមឆ្លើយ គេរឹតឃ្នាបឱ្យរឹតតែតឹងឡើង១ ។ មនុស្សទោសនៅកោះត្រឡាចខ្លាចឃ្នាបនេះណាស់ ពីព្រោះវាហើមកជើងហើយត្រូវចូលដេកពេទ្យ ហើយត្រូវតែកាត់ជើងចោលទៀតត្បិតពុំមានឱសថអ្វីព្យាបាលឱ្យជាបានឡើយដោយស្រុកកំពុងកើតចម្បាំងគ្មានថាំសង្កូវអ្វីទេ ។

ចំណែកឯគ្រូពេទ្យជាតិបារាំងក្ដី ជាតិយួនក្ដីដែលមកធ្វើការឯកោះត្រឡាច ហាក់បីដូចជាមករៀនកម្មសិក្សាបន្តវិជ្ជាពេទ្យឱ្យបានជំនាញពូកែដែរ ត្បិតអាចនឹងវះកាត់ឬធ្វើអ្វីតាមអំពើចិត្តឥតនរណាឃាត់ឃាំងឡើយ ហើយឥតមាននរណាតវ៉ាផង ត្បិតមនុស្សនោះគេទុកដូចជាសត្វចង់ស្លាប់ឬពិរាពិការប៉ុន្មានក៏គេឥតឈឺក្បាលអាណិតអាសូរឡើយ ។ គេធ្វើការនៅនេះដូចជាគេនៅបង្រៀនវិជ្ជាពេទ្យឱ្យរឹតតែពូកែឱ្យមានការពិសោធន៍ច្រើនរៀនក្នុងវិជ្ជារបស់គេ ។ បើជំងឺត្រូវមើលដោយឱសថជា ក៏គេត្រូវតែវះកាត់ដែរ ។

គិតទៅកោះត្រឡាចនេះជាកោះឧក្រិដ្ឋ សម្រាប់សម្លាប់មនុស្សតែម្ដង ។ រឿងដែលអ្នកជាប់ទោសមុនគេបាននិយាយនេះ ធ្វើឱ្យខ្ញុំនឹកភ័យព្រួយចំពោះជោគវាសនាខ្លួនឯងខ្លាំងណាស់ ! មិនដឹងជានឹងទទួលទោសរបៀបណាទេ ក្នុងចំណោមមហន្តទោសទាំងនោះ... ។

***



-៨-

# ជីវភាពនៅគុកកោះត្រឡាច

ក្នុងពេលឃប់សម្រាក១៥ថ្ងៃនោះ គេឱយទទួលទានម្ហូបអាហារគ្រប់គ្រាន់ដោយហេតុថាកន្លែងដែលសម្រាកនោះជាកន្លែងព្យាបាលជំងឺ គេត្រូវថែរក្សាឱ្យបានស្រួលមានកម្លាំងកំហែងសិនអាហារក៏ឱ្យទទួលទានបរិបូណ៌គឺមានម្ហូបធ្វើដោយត្រីសមុទ្រ, ស៊ុតមាន់,សាច់សត្វល្មេចក៏មានដែលគេយកទៅស្ងោរស្លឹកថ្នឹងឬស្លឹកទ្រមូងតាមតែអ្នកធ្វើម្ហូបគេលៃលក យើញឆ្ងាញ់ពិសាជាងម្ហូបនៅគុកព្រៃនគរ ។ ឯបាយក្រហមក៏ឱ្យច្រើនបរិភោគមិនអស់ ។ ក្រោយពេលបាយព្រឹកនាំគ្នាសម្រាក រួចនាំគ្នានិយាយលេងកម្សាន្តពីនេះពីនោះ មានរឿងប្រលោមលោកជាដើម ។ ក្រោយពេលបាយល្ងាចគេដាក់ខ្នោះជើងទាំងពីររហូតដល់ព្រឹកឡើងប្រហែលម៉ោង៦ ទើបគេឱ្យបរិភោគបបររនិងត្រីកញ្ចុះប្រៃចៀន ។

លុះសម្រាកគ្រប់១៥ថ្ងៃហើយ ទើបឃើញនាយតម្រួត៤-៥នាក់មកបើកទ្វារបញ្ចេញពួកយើងខ្ញុំទៅក្រៅទាំងអស់ឱ្យឈរជាជួរដើម្បីនាយតម្រួតធំគេត្រួតមើលសិន ,ទើបគេឱ្យដើរជាពីរជួរឆ្ពោះទៅគុកធំ ដែលមានទំហំធំជាងគុកសម្រាកនោះមួយជាពីរ ហើយនឹងធំជាងគុកនៅភ្នំពេញទៅទៀតហើយដែលមានមនុស្សជាង ៤.០០០០នាក់រស់នៅទីនោះ ។ គុកនោះគេហៅថា *គុកបម្រុង* គឺជាកន្លែងដែលគេត្រូវជ្រើសរើសបែងចែកអ្នកទោសឱ្យទៅធ្វើការនៅកន្លែងដទៃទៀតឆ្ងាយ១ក្នុងនាទីកោះត្រឡាច ។

គ្រាដែលទៅដល់គុកធំនេះ ,ក្រោយពីបានចំណែកកន្ទេលចចូត១ម្នាក់ហើយ,គេបញ្ជូនទៅក្នុងសាលទី៦ក្នុងបណ្ដាសាលទាំង១០នៃគុកធំនោះនៅវេលាប្រហែលម៉ោង៨ព្រឹក ។ លុះសម្រាកបានបន្តិចក៏ដល់ពេលបាយថ្ងៃត្រង់ហើយឮសូរគេវាយស្គរទូង១ សូរមនុស្សនិយាយគ្នាអ៊ូរអរខាង

ក្រៅនៅខាងមុខគុក ។ មិត្តខ្ញុំបានប្រាប់ខ្ញុំថា នេះជាពេលដែលមនុស្សទោសត្រឡប់ពីធ្វើការវិញ ។ ក្រោយនោះបន្តិច ទើបឃើញតម្រួតមកបើកទ្វារបញ្ចេញយើងខ្ញុំទៅក្រៅ ,ឱ្យអង្គុយជាក្រុមក្នុងមួយក្រុម៦នាក់ ។ គេដាក់ស្នូកបាយធំៗ មានចានគោមធំមួយ,ត្រឡោកដូង៦-៧ព្រមទាំងចង្កឹះ១បាច់ផង មានកូនចានតូចមួយដាក់ទឹកត្រី ។ ឯម្ហូបមានតែត្រីកញ្ចុះចៀនមួយមុខគត់ ត្រីកញ្ចុះនោះស្អុយពុកមិនដឹងពីកាលណាទេ ។ ក្រោយពេលដែលបរិភោគ ហើយគេបញ្ជូនទៅគុកវិញនៅវេលាប្រហែលម៉ោង១០កន្លះ ។

នៅពេលនោះ ,ខ្ញុំសង្កេតឃើញមនុស្សទោស ខ្លះសម្រាកខ្លះនិយាយគ្នាលេង ខ្លះលេងចត្រង្គ,លេងវិក ។ ចម្លែកតែត្រង់មួយក្រុមទៀតឃើញខំរៀនអក្សរអង់គ្លេស , បារាំង ,រុស្ស៊ីជាដើម ។ ក្នុងមួយក្រុមៗប្រហែល៥-៦នាក់ប៉ុណ្ណោះ ។ គេយកកំបោរសធ្វើជាដីសសរសេរនៅលើឥដ្ឋបេតុងដែលជាកន្លែងដេកនោះឯង ។ ខ្ញុំបានសង្កេតម៉្យាងទៀត ឃើញច្រើនតែជាតិយួនដែលជាក្រុមអ្នកនយោបាយដែលហៅថា ពួកយៀកមិញ ។ ពួកនេះគេអប់រំគ្នាគេជានិច្ចពីរឿងនយោបាយគឺធ្វើយ៉ាងណាឱ្យក្រុមគេខំ តស៊ូតាមផ្លូវចិត្ត កុំឱ្យភ្លេច ។ មួយទៀតក្រុមនេះចូលចិត្តខំព្យាបាលអប់រំមនុស្សទោសធម្មតា (droit commun) ដែលពុំមែនទោសនយោបាយមានទោសចោរកម្មជាដើម ឱ្យចូលចិត្តលុះក្នុងការណែនាំរបស់គេ ,ឱ្យយល់នូវឧត្តមគតិល្អ ,ឱ្យដើរតាមផ្លូវត្រូវឆ្ពោះទៅរកសេចក្តីចម្រើនល្អតលាស់ ។ ប៉ុន្តែនៅមានមនុស្សទោសខ្លះដែលប្រកាន់អស្មិមានះរឹងរូសពុំយកតាមដំបូន្មានល្អជាច្រើនដែរ ដែលពួកគេលើកទុកដោយឡែក សម្រាប់ប្រើការផ្សេងៗក្រៅពីនយោបាយបានទៀត ។ ឧទាហរណ៍ក្រុមគេ(ពួកនយោបាយ)ត្រូវតម្រួតបារាំងផ្លាស់គ្នាគេទៅឱ្យនៅជាមួយពួកទោសធម្មតានេះ ,គេក៏ផ្តាំផ្ញើឱ្យមើលការខុសត្រូវដល់ពួកគេផង ។ ឯពួកអ្នកទោសធម្មតានៅតែទទួលស្គាល់ពួកគេនេះ ជាពួកអ្នកតស៊ូខាងនយោបាយរំដោះជាតិពីនឹមបារាំងដរាប,គេឥតប្រឆាំងអ្វីទេ ដែលជាហេតុនាំឱ្យពួកអ្នកនយោបាយទាំងនោះសុខស្រួលប្រកបដោយសេចក្តីក្លាហានឥតរួញរាក្នុងការតស៊ូខាងនយោបាយតទៅទៀត ។

នេះជារឿងពិតក្នុងឆ្នាំ១៩៤២ ដែលខ្ញុំ(ប៊ុណ្ណចន្ទ ម៉ុល)បានឃើញច្បាស់នឹងភ្នែកឯង ដែល



ជាហេតុនាំឱ្យខ្ញុំខំព្យាយាម ចងចាំនូវរឿងជាតិគេទុកក្នុងសន្តានចិត្តចិត្តរហូតមក ដើម្បីខ្ញុំនឹងសរសេររឿងពិតទាំងនេះជូនបងប្អូនរួមជាតិបានដឹងបានឮទុកជាមេរៀនតទៅ ។ យួនគេខ្ញុំបារាំងដូចយើងដែរ គេចេះបបួលគ្នាខំរើខ្លួនពីទាសភាពបារាំង,ចុះខ្មែរម្តេចក៏សុខចិត្តនៅស្ងៀមធ្វើខ្ញុំបារាំង ? បើយើងធ្វើមិនបានស្មើនឹងយួន,ក៏បានតែពាក់កណ្តាលគេទៅចុះ !នេះមិនដូច្នេះ ,ឃើងរហូតតែម្តង,ឥត រវល់សោះ! ឱ្យតែខ្មែរណាមានចិត្តតស៊ូការពារជាតិនោះ,តាំងចោទគ្នាថាជាមនុស្សពោលម្សៀត មិនបានការមិនការ មិនទាំងហ៊ានមើលមុខឬស្តីរកគ្នាផងថែមទាំងជួយផ្តន្ទាទោសគ្នាទៀត ។ មាន ខ្លះលបប្រាប់បារាំងឱ្យធ្វើបាបខ្មែរណាដែលតស៊ូថែមទៀតផងក៏មាន ។ ខ្មែរយើងច្រើនតែយក ពាក្យមួយម៉ាត់ថា «កុំយកពងមាន់ទៅជល់នឹងថ្ម» ហើយនឹងបង្អាក់បំភ័យឱ្យរួញរា ។ ប្រាសចាក សេចក្តីក្លាហានថា : «យើងពផែនដីតែម្នាក់ឯងម្តេចរួចបើគេឯទៀតមិនរវល់រាល់គ្នានោះ ? » ពាក្យទាំងនេះល្មមយើងរាល់គ្នាឈប់យកមកប្រើទៀតទៅពីព្រោះជាពាក្យដែលនាំឱ្យយុវជន ជំនាន់ក្រោយបាត់សេចក្តី ក្លាហានបាត់ការតស៊ូដើម្បីប្រយោជន៍ជាតិអស់ ដូនកាលជំនាន់យើងខ្ញុំនោះ ។ សម័យបច្ចុប្បន្ននេះមនុស្សលោកបានឡើងដល់ព្រះច័ន្ទទៅហើយ ខ្មែរយើងនៅតែមិន ទាន់ភ្ញាក់ខ្លួនទៀត ទាល់តែរលាយជាតិដូចជាចាមទៅឬទើបភ្ញាក់ខ្លួន ?

នៅពេលសម្រាកថ្ងៃត្រង់ពួកគេនាំគ្នារៀនបានមួយម៉ោង ពេលយប់ចាប់ពីម៉ោង១៨ទៅពួកគេនាំគ្នារៀនបានពីរបីទៅបួនម៉ោងទៀតទើបគេនាំគ្នាដេក ។ នេះជាការពិត ។ គេនាំគ្នានិយាយថា ការតស៊ូជាករណីយកិច្ចរបស់ប្រជាពលរដ្ឋយួនទាំងស្រីទាំងប្រុស ទាំងក្មេងទាំងចាស់ដើម្បីជួយរំដោះប្រទេសគេឱ្យរួចពីនឹមបារាំងទោះឆាប់ក្តីយូរក្តី គឺថាត្រូវតែរួបរួមគ្នាកុំបីខាន ប្រយោជន៍នឹងជួយកូនចៅរបស់គេជំនាន់ក្រោយឱ្យបានសេរីភាពបានសុខសន្តិភាពតទៅ ។ គេហាមគ្នាមិនឱ្យនិយាយពី រឿងខ្លាចស្លាប់ ពីរឿងរាថយក្រោយឡើយ តែយើងខ្លាចស្លាប់មិនដឹងជាពេលណាយើងនឹងបានរួចខ្លួនជាអ្នកជាឡើយ ។ ហើយកូន ចៅយើង ជំនាន់ក្រោយវានឹងតិះដៀលប្រទេចផ្តាសាយើងជំនាន់មុនយ៉ាងណាទៅ ? -ហេតុនេះ យើងជាជាតិខ្មែរត្រូវតាំងចិត្តរួបរួមគ្នា ខំប្រឹងតស៊ូឡើងកុំខ្លាចស្លាប់ឱ្យទាល់តែបានសម្រេចនូវគោលដៅរបស់យើង ។

ដល់មកត្រង់ណេះខ្ញុំសូមសាទៅជម្រាបរឿង កាលដែលខ្ញុំនៅគុកធំព្រៃនគរនៅឡើយម្តងទៀត ។

នៅគុកព្រៃនគរពួកអ្នកទោសនយោបាយជាតិយួន តែងអប់រំគ្នាគេឱ្យខំប្រឹងតស៊ូរំដោះជាតិគេជានិច្ចដែរ ។ ខ្ញុំ(ប៊ុណ្ណច័ន្ទ ម៉ុល)បានជួបនិងលោកគ្រូអាចារ្យហែម ចៀវ និងលោកនួន ឌួងម្តង ។ លោកទាំងពីរមានភ័ព្វបានទៅនៅជាមួយពួកមនុស្សទោសនយោបាយជាតិយួន ។ លោកបានជ្រាបហេតុការណ៍នេះដោយផ្ទាល់ខ្លួនលោក ។ កន្លែងដែលលោកទាំងពីរនៅនោះជាកន្លែងទោសឧក្រិដ្ឋគេដាក់លោកជាមួយពួកយួនដើម្បីរង់ចាំសេចក្តីសម្រេចពីលោក ហ្សេណេរ៉ាល់ ប៉េតាំង ឯក្រុងប៉ារីសដែលគេផ្ញើសំណុំរឿងប្រហារជីវិតទៅសុំសេចក្តីអនុគ្រោះ បើលោកប៉េតាំងយល់ព្រមតាមសាលក្រមឱ្យសម្លាប់គេក៏សម្លាប់ភ្លាម ។ បើលោកប៉េតាំងត្រាប្រណីបន្ថយទោសត្រឹមមួយជីវិត គេក៏សម្រេចតាមដែរ ។

ខ្ញុំសូមជម្រាបមិត្តថា គុកនៅព្រៃនគរគេតែងនាំមនុស្សទៅប្រហារជីវិតនៅវេលាម៉ោង៥ភ្លឺ ។ មនុស្សនោះតែងស្រែកលាមិត្តភក្តិរួមជាតិរបស់គេថា «មិត្តរួមឈាមអើយ ! យើងសូមលាទៅស្លាប់មុនហើយ សូមមិត្តរាល់គ្នាកុំភ្លេចខំតស៊ូទៅទៀតឱ្យទាល់តែបានសម្រេច» ។ ក្នុងពេលនោះពួកមិត្តភក្តិគេនៅគ្រប់សាលនាំគ្នាក្រោកឈរឡើង ស្រែកច្រៀងបទជូនដំណើរមិត្តគេទៅស្លាប់យ៉ាងអង់អាចក្លាហាន គេស្រែក«ជយោហូជីមិញ១១១»ហើយអ្នកដែលឥតទាន់ប្រហារជីវិតទេបាននិយាយថា មិត្តយើងមិនភ្លេចបណ្តាំមិត្តទេ ពួកយើងនៅតស៊ូ១១១លុះត្រាបានសម្រេច(១) ។ ហើយឈរត្រង់ខ្លួនដើម្បីគោរពវិញ្ញាណក្ខន្ធនៃវីរបុរសដែលស្លាប់នោះ ។ លុះតម្រួតនាំមនុស្សទោសនោះចេញផុតពីទ្វាគុកហើយទើបគេនាំគ្នាសម្រាកទៅវិញ ។

១-កាលនោះឈ្មោះហូជីមិញជាអ្នកបដិវត្តដ៏សំខាន់ ជនជាតិយួនដើរតាមគំនិតហូជីមិញមាំណាស់ស ឱ្យឃើញថាពួកយួនគេចេះភ្ជាក់រលឹកមានសាមគ្គីដើរតាមក្រោយអ្នកដឹកនាំឥតរួញរាសោះឡើយ !



សូមមិត្តកុំឆ្ងល់ថា ម្តេចក៏មនុស្សទោសនៅក្នុងគុកមានសេរីភាពអាចស្រែកច្រៀង ឬធ្វើអ្វីតាមចិត្តម្ល៉េះ?-សូមមិត្តជ្រាបថា ទោសដល់ប្រហារជីវិតទៅហើយគេឥតប្រកាន់ទេគឺធ្វើអ្វីបានតាមចិត្តចង់ដេរនរណាក៏បានដែរ ។

មិត្តជ្រាបទេទើបតែនៅឆ្នាំ១៩៤២នោះហើយ ដែលមានមនុស្សទោសនយោបាយជាតិខ្មែរទៅជាប់គុកនៅព្រៃនគរ ពីមុនមកគ្មានសោះ ។ ហេតុនេះហើយបានជាពួកនយោបាយយួនគេរាប់អានពួកអ្នកទោសនយោបាយខ្មែរគេនាំគ្នាឱ្យម្ហូបអាហារចំណីចំណុកទទួលទានគ្រប់ៗគ្នា ។ អាហារនោះពួកញាតិមិត្តឬពួកក្រុមគេនៅឯក្រៅគុក មានសិទ្ធិយកមកឱ្យបងប្អូនឬជាមិត្តនៅក្នុងគុករាល់ថ្ងៃសៅមិនដែលខានឡើយ ។ ពួកអ្នកទោសនយោបាយួនគេមានសេចក្តីត្រេកអរ ដោយឃើញមានពួកខ្មែរទៅជាប់គុកកាលឆ្នាំ១៩៤២នោះដែរ ។ គេនិយាយថាដល់ពេលយើងរួបរួមគ្នាវាយក្បាលបារាំងហើយបារាំងមិនអាចនាំបងប្អូនខ្មែរទៅវាយពួកគេបានទេ ។ គេនាំគ្នាថែទាំលោកគ្រូអាចារ្យ*ហែម ចៀវ* លោក*នួន ឌួង* និង*ប៉ាច ឈឿន*ណាស់ព្រោះជាប្រយោជន៍សម្រាប់គេដែរ ។

ខ្ញុំសូមស្លេះត្រឹមនេះ ហើយសូមមិត្តបែរមកមើលឯកោះត្រឡាចតទៅទៀត ។

លុះដល់ពេលម៉ោង១៣ថ្ងៃត្រង់ឮគេវាយស្គរម្តងទៀត ដើម្បីឱ្យមនុស្សទោសទៅធ្វើការរៀងខ្លួនម្តងទៀត ។ មិត្តភក្តិឯទៀតនិងខ្ញុំបានចេញជាមួយក្រុមមនុស្សទោសឯទៀតដែរ ។ គេឱ្យឈរជាពីរជួរ រួចមេតម្រួតគេកាន់បញ្ជីមួយសន្លឹកដើរាប់យកមនុស្សទោសទាំងនោះ តាមសេចក្តីត្រូវការរបស់គេ ។ ឧបមាថាគេត្រូវការបនុសសទោស១៥នាក់ ឱ្យទៅកាប់អុស ១៥នាក់ឱ្យទៅធ្វើថ្នល់ ៤០នាក់ឱ្យទៅជញ្ជូនអីវ៉ាន់ផ្សេងៗតាមតែត្រូវការ ។ល។

នៅថ្ងៃនោះខ្ញុំព្រមទាំងមិត្តខ្ញុំចំនួន២៥នាក់ មានវាសនាបានទៅធ្វើថ្នល់ក្នុងបន្ទាយទាហាននៅចម្ងាយពីគុកទៅប្រហែលជាង១គីឡូ ។ លុះទៅដល់ហើយក៏ចាប់ធ្វើការតាមបង្គាប់គេ មានបោសថ្នល់រៀបចំឱ្យរទេះរ៉ូឡូ (Rouleau) កិនចាក់ថ្នល់កៅស៊ូ ។ នៅពេលនោះខ្ញុំខំប្រមូលកន្ទុយ

បារីបានថ្នាំប្រហែលមួយក្តាប់ធំដាក់ក្នុងហោប៉ៅអាវ ទុកផ្ញើមិត្តភក្តិឯក្នុងគុក ដែលអត់យូរថ្ងៃហើយ ។ លុះដល់ម៉ោង១៦និង៣០នាយតម្រួតបាននាំពួកធ្វើការទាំងអស់ ត្រឡប់មកគុកវិញ ។ គេឱ្យលុបលាងមុខ ជូតខ្លួនបន្តិចទើបគេឱ្យអង្គុយជាជួរតាមសំយ៉ាបមុខគុក បានបន្តិចរួចគេលើកបាយស្ងោកមកដាក់ឱ្យទទួលទានជាក្រុមៗដូចកាលពីមុន ។ បាយស្ងោតទាំងនោះ សត្វរុយរោមពេញយកដៃបក់រុយមិនចេញបរិភោគតែម្តង ពីព្រោះបាយនោះអ្នកទោសចុងភៅដួសទុកមុនមួយម៉ោងកន្លះយ៉ាងតិច ពីព្រោះមនុស្សទោសច្រើនពេករាប់ពាន់នាក់ឯណោះ ។ ក្រោយបាយនោះទើបគេបញ្ជូនទៅក្នុងគុកវិញទៅ ។ មិត្តភក្តិខ្ញុំមានសេចក្តីត្រេកអរណាស់ ដោយទទួលចំណែកថ្នាំកន្ទុយបារីបន្តិចៗម្នាក់ដែលខ្ញុំចែកឱ្យ ក៏ឱ្យពរសព្ទសាធុការដល់ខ្ញុំយ៉ាងច្រើន ។

លុះព្រឹកឡើងម៉ោង៥ នាំគ្នាក្រោយឡើងមុីម្នាតាមស្ករស្គរដែលគេវាយជាសញ្ញាឱ្យភ្ញាក់ទៅធ្វើការ ក៏នាំគ្នាចេញមកក្រៅទាំងមុខសើងម៉ើង ដោយឥតបានលុបមុខមាត់អ្វីទៀតខាងក្នុងសាលឥតមានទឹកសម្រាប់ប្រើឡើយ មានតែទឹកធុងសម្រាប់ចាក់បង្គន់ក្នុងគ្រាប់ជើងប៉ុណ្ណោះ ។ សូមជម្រាបថានៅក្នុងគុកឥតទឹកសម្រាប់ទទួលទានទេ ។ បើមានជំងឺឈឺ មានគ្រុនចាញ់ជាដើម ឬបើពេលណាក្តៅខ្លាំងឬហើយស្រេកទឹក តោងតែទទួលទានទឹកបង្គន់នោះជាការចាំបាច់ ដែលធុំក្លិនយោមកបន្តិចៗផង ។ បើមិនផឹកមានតែស្លាប់ប៉ុណ្ណោះ ។

ថ្ងៃមួយក្រោយពីពេលបបរព្រឹករួច មេតម្រួតជ្រើសរើសអ្នកទោសមាឌធំមាំៗហើយខ្លាំងចំនួន៤៥នាក់ ពីរក្នុងជួរដែលគេឱ្យឈរម្តុំបំរុងចាត់ឱ្យទៅធ្វើការ ។ ក្នុងចំនួននេះដោយខ្លួនខ្ញុំជាមួយដែរហើយអតមានស្គាល់នរណាម្នាក់សោះឡើយ ។ នៅពេលមនុស្សឯទៀតចេញផុតអស់ទៅនាយតម្រួតប្រើពួកខ្ញុំឱ្យចូលទៅក្នុងគុកវិញ យកកន្ទេលទៅតាមរៀងៗខ្លួន ។ លុះគេបណ្តើរបានបន្តិចខ្ញុំសួរមនុស្សទោសដូចគ្នាដោយសេចក្តីសង្ស័យថាគេនាំយើងទៅណា ? ឥតអ្នកណាដឹងថាគេនាំទៅណាឡើយ ។ លុះទៅដល់មាត់សមុទ្រ ទើបគេនាំទៅចុះក្នុងសាឡាងមួយយ៉ាងធំដែលមានកាណូតមួយនាំមុខឆ្ពោះទៅកាន់កោះមួយទៀតនៅឆ្ងាយពីកោះត្រឡាច ដោយប្រើពេលវេលាប្រហែលជាងពីរម៉ោង ទើបទៅដល់កោះនោះ ។ ទើបនាយតម្រួតបញ្ជាឱ្យនាំគ្នាចុះដើរលុយទឹក



សមុទ្រត្រឹមចង្កេះទៅកាន់មាត់ច្រាំង ។ នៅពេលជិតដល់កោះនោះ ខ្ញុំក្រឡេកទៅឃើញនៅលើកំពូលភ្នំនោះ មានសើន(ប៉ម) មួយយ៉ាងធំដាក់ phare សម្រាប់ឱ្យសញ្ញាដល់កប៉ាល់សមុទ្រទាំងឡាយ ដែលបើកបរក្នុងវេលាយប់តាមផ្លូវនេះ ។ លុះដល់ដីគោកជាយកោះហើយគេក៏ឱ្យសម្រាកចំនួន១០នាទីទើបគេផ្តុំកញ្ចែប្រជុំគ្នាមួយកន្លែងហើយចែកសំបកប៉ោតប្រេងកាតចំនួន១៦នាក់ ។ ឯមនុស្សទោសក្រៅពីនេះ គេចែកបារស៊ីម៉ងត៍១ម្នាក់គ្រប់គ្នា ។ ឯកន្ទេលចចូតដែលគេចែក១ម្នាក់នោះក៏មូរឱ្យតូចរួចចងចុងផ្តោបគ្នា រួចស៊កពាក់ឆៀងលើស្មាម្ខាង សម្រាប់ទុកក្រាលទទួលទានដំណេកនៅពេលយប់សម្រាក ។ តពីនេះគេនាំទៅកើបអាចម៍ផ្កាយនិងខ្សាច់នៅកន្លែងជិតនោះគឺប៉ោតដាក់ក្រួសស៊ីម៉ងត៍ដាក់ខ្សាច់ពេញទាំងអស់ ។ ប៉ោតនិងបារនោះ ត្រូវលី សែង ទូល ក៏បាន ឱ្យតែបានដល់លើកំពូលភ្នំ ដែលមានកំពស់ប្រហែល ៧០០ម៉ែត្រ ដែលគេមានរៀបចំដាក់កាំជណ្តើរថ្មរហូតដល់លើកំពូលភ្នំទៀត ។ តាមដងផ្លូវឡើង ទៅលើកំពូលភ្នំមានដើមទំពាំងបាយ-ជូរព្រៃដុះដេរដាស ប្រកបដោយផ្លែទុំឡើងពណ៌ខ្មៅរលោង ពួកអ្នកទោសនាំគ្នាបេះទទួលទានបណ្តើរនាំឱ្យរមាស់កបន្តិចៗ ប៉ុន្តែផ្លែដែលទុំក៏មានជាតិផ្អែមដែរ ។ ចាប់ឡើងពីក្រោមទៅប្រហែលម៉ោង៥ព្រឹក ប្រហែល៣ឬ៤ម៉ោងទើបដល់កំពូលភ្នំជាកន្លែងទុកក្រួសខ្សាច់ ។ នៅលើភ្នំសង់ផ្ទះថ្មធ្វើជាថែវរាងមូលព័ទ្ធពីក្រោយប៉មសម្រាប់ជាលំនៅនៃក្រុមរក្សាប៉ម ដែលជាតិបារាំង៥នាក់ ជាតិយួន៣នាក់ ឥតមនុស្សទោសនៅទីនោះទេ ។ កន្លែងសង់ប៉មនិងផ្ទះក្បែរនោះមានទំហំប្រហែលជា៥០ម៉ែត្រ៤ជ្រុង ។ នៅខាងមុខប៉មបើក្រឡេកទៅផ្ទៃសមុទ្រឃើញទឹកសមុទ្រឡើងពណ៌ខៀវស្រងាត់គួរឱ្យគយគន់ពេក ។ នៅលើភ្នំទាំងមូលដុះសុទ្ធតែដើមឈើធំៗ ច្រូងច្រាងពណ៌បៃតងពាសពេញផ្ទៃភ្នំ ។ ខាងក្រោយកោះនេះមានភ្នំតូចធំដុះលិចចេញពីផ្ទៃទឹកសមុទ្ររកូតជាច្រើន ដែលក្នុងចំណោមកោះទាំងនោះមានភ្នំកោះត្រឡាចនៅនោះដែរ ប៉ុន្តែភ្នំកោះត្រឡាចធំជាងគេ ។ ឯឆ្នេរសមុទ្រដែលមានខ្សាច់សក្បុសដុះនារលយទៅកណ្តាលសមុទ្រជាកន្លែងងូតទឹកយ៉ាងសប្បាយល្អជាឆ្នេរនៅកែបឆ្ងាយណាស់ ។ បើយើងគ្មានទោសពៃរ៍អ្វីទៅសម្រាកលេងនៅទីនោះបានចំនួន១០ឬ១៥ថ្ងៃ ម្លេះសមសប្បាយពេកណាស់ហើយស្រួលខ្លួនផង ដោយអាកាសសមុទ្រត្រជាក់ស្វាត់ ទេសភាពល្អ ខុសពីកន្លែងនានានៃស្រុកខ្មែរយើង ។

លុះចាក់ក្រួសខ្សាច់លើខ្នងភ្នំហើយគេឱ្យនាំគ្នាចំអិនអាហារព្រឹកទទួលទាន ។ ក្រោយនេះ

ប្រហែលម៉ោង២ទើបគេនាំចុះមកក្រោមវិញ ។ នាយតម្រួតបាននិយាយថាថ្ងៃនេះយើងធ្វើការបានតែ១ជើងទេ ដល់ថ្ងៃស្អែកយើងខំធ្វើឱ្យបានពីរជើងគឺព្រឹក១ជើង ល្ងាច១ជើងរួចគេឱ្យធ្វើពាយទទួលទានពេលល្ងាច ខ្ញុំឆ្លៀតឱកាសក្នុងពេលនោះដើរចូលទៅក្នុងព្រៃភ្នំនោះ ក្រឡេកទៅខាងស្តាំដៃឃើញម្ទេសខ្មាំងចំនួនជា១០ដើម មានផ្លែស្រោចដើមទុំក្រហមឆ្អៅ ។ នៅទីនោះទាំងលើកំពូលភ្នំ ទាំងជើងភ្នំសម្បូរដើមម្ទេសណាស់ ដោយមនុស្សទោសដែលទៅធ្វើការពីមុនៗ ធ្វើឱ្យជ្រុះឬក៏ចោលម្ទេសនៅនោះផង ឬមួយសត្វវាពាំមកស៊ីជុះដាក់នៅទីនេះក៏ដុះឡើងផង រួចក៏ចេះតែដុះតៗគ្នាទៀត ផ្លែចោលឥតមានមនុស្សបេះ ។ ឯចំណែកទំពាំងបាយជូរវិញផ្លែចោលដេរដាស ជួនណាមនុស្សទោសបេះយកទៅធ្វើទឹកខ្មេះ ជួនណាយកទៅធ្វើស្រា«ទំពាំងបាយជូរ» ។ ដើម្បីធ្វើស្រា គេយកផ្លែទំពាំងបាយជូរទៅបុកឱ្យបែក ច្របាច់យកទឹកច្រកដបទុកចំនួន២០ឬ៣០ថ្ងៃ វានឹងឡើងទៅជាស្រាអាចទទួលទានបានស្រវឹងស្រៀងៗដែរ តែវមាស់កបន្តិច ហើយមិនឆ្ងាញ់ដូចស្រាទំពាំងបាយជូរមកពីស្រុកបារាំងទេ ។

នៅយប់នោះយើង ទាំងអស់គ្នាបានទទួលទានដំណេកក្រោមដើមឈើធំមួយ លុះដល់កណ្តាលអាធ្រាត្រស្រាប់តែមានភ្លៀងធ្លាក់មកទទឹកអស់សំពត់អាវកន្ទេល ប៉ុន្តែដោយឥតមានអ្វីជាជម្រក ក៏ចេះតែទ្រាំនាំគ្នាទទួលទានដំណេករហូតដល់ភ្លឺទៅ ។ លុះម៉ោង៥ភ្លឺទើបគេផ្លុំកញ្ចែដាស់ឱ្យក្រោកឡើងឱ្យដាំបបរទទួលទានរួចទៅកើបក្រួស ខ្សាច់នៅម៉ោងប្រហែល៦ជាងព្រឹក ។ ប្រហែលម៉ោង១០ ទើបចុះពីលើកំពូលភ្នំមកវិញ ក្រោយដែលបានចាក់ក្រួសខ្សាច់នៅលើកំពូលភ្នំរួចដើម្បីមករៀបចំអាហារព្រឹកទទួលទាន ។ ក្នុងពេលនោះនាយតម្រួតបានប្រកាសប្រាប់ថា បើនរណាខំជញ្ជូនក្រួសខ្សាច់បានពីរជើងហើយត្រូវឱ្យឈប់ចុះ ដែលជាហេតុនាំឱ្យយើងរាល់គ្នាខំប្រឹងធ្វើឱ្យឆាប់រួចនិងអាលបានឈប់សម្រាកពីថ្ងៃបន្តិចប្រយោជន៍នឹងមានឱកាសដើររករបស់របរទទួលទាន។ តែមិត្តអើយ ! ដូចម៉ោងខ្ញុំកំពុងពេញកម្លាំងរួចបាយភ្លាមក៏ប្ញីប្ញាទៅរកកើបក្រួសលីរត់ឡើងទៅលើកំពូលភ្នំក៏គង់តែដល់ម៉ោង៥ល្ងាចទើបហើយការ។ ឯអ្នកទោសខ្លះដែលគ្នាមានកម្លាំងខ្សោយគ្នាធ្វើរហូតដល់ម៉ោង៨យប់ទើបហើយប៉ុន្តែជាកុសលដែរ ដោយយប់នោះត្រូវចំលើខែភ្លឺផង កុំអីពិបាកណាស់ខ្លាំងដោយមើលផ្លូវមិនឃើញ ។



សម្រាកនៅជើងភ្នំនោះមួយយប់ទៀតទើបប្រជុំគ្នាចុះ សាឡាងត្រឡប់មកកោះត្រឡាចវិញ ។

ពេលខ្ញុំមកដល់កោះត្រឡាចហើយ គេក៏នាំចូលទៅគុកដដែលវិញ ។ នៅថ្ងៃបន្ទាប់មកខ្ញុំក៏បានចេញមកពីក្នុងគុកជាមួយពួកក្រុមខ្ញុំទទួលទានបបររួច គេបានឱ្យមកឈរជាពីរជួរ ទើបនាយតម្រួតដើរមករាប់មនុស្សទោសទាំងនោះមកដល់ខ្ញុំមានចំនួន ៤០នាក់ហើយនាយតម្រួតបញ្ជាឱ្យទៅឈរមួយកន្លែង ទើបគេនាំឱ្យទៅតាមគេទៅកន្លែងមួយចម្ងាយផ្លូវប្រហែល៣គីឡូម៉ែត្រពីទីគុកដែលខ្ញុំសំណាក់ ។ នៅពេលទៅដល់កន្លែងនោះគេឱ្យក្រុមខ្ញុំឈប់សម្រាក ប្រហែលជា ១០នាទីទើបនាយតម្រួត គេចែកក្រុមមនុស្សទាំង៤០នាក់ ទៅជាបីក្រុមក្នុងមួយក្រុមៗមានគ្នាប្រហែល១៣នាក់ទើបគេនាំគ្នាទៅកាន់រទេះដែកមួយដែលជារទេះដឹកដី នៅលើភ្នំខ្សាច់មួយកម្ពស់ប្រហែល១២ម៉ែត្រមានផ្លូវដែកដូចជារទេះភ្លើងធម្មតានៅស្រុកយើង តែត្រង់ទូរថភ្លើងដឹកដីនេះទទឹង៣ម៉ែត្រ ប្រវែង៦ម៉ែត្រ គេឱ្យមនុស្សទោសរុញរទេះនោះឡើងទៅលើភ្នំនោះចម្ងាយប្រហែល៨០០ម៉ែត្រ ទើបទៅដល់កន្លែងយកដីខ្សាច់នោះ ។ នៅពេលមនុស្សទោសរុញរទេះឡើងទៅកាន់គោលដៅនោះបើរុញឡើងមិនរួចទេ ឬមួយរុញដូចជាយឺតបន្តិច នាយតម្រួតបារាំងនោះគេស្រែកឱ្យឈប់ ។ នៅពេលឈប់ម្តងៗត្រូវយកកំណាត់ឈើមួយកងពីរកងកល់កង់រទេះទើបឈប់បាន ។ នៅពេលរទេះបានឈប់ហើយ តម្រួតនោះក៏ដើរទៅរាប់មនុស្សទោសណាដែលមានមាឌធំមាំប្រាប់ឱ្យដើរចេញពីរទេះដែកនោះចំនួន៤_៥នាក់ រួចហើយគេក៏បញ្ជាមនុស្សដែលនៅសល់ទាំងប៉ុន្មានឱ្យរុញរទេះនោះតទៅទៀត។ នៅពេលនោះខ្ញុំនៅក្នុងក្រុមរុញរទេះនេះ។ មិត្តជ្រាបទេ ? នៅពេលនោះហើយនាយតម្រួតគេត្រូវដើរវាយមនុស្សទោសដែលនៅសល់ចំនួន ៧_៨នាក់នោះដោយរំពាត់ផ្តៅដំបងប៉ុនកដៃកូនក្មេង វាយត្រូវទាំងអស់គ្នា ។ នៅពេលដែលមនុស្សទោសទាំងនោះកំពុងតែខំរុញរទេះនោះ ខ្ញុំកំពុងយកស្មាខ្ញុំរុញពិតនៅត្រង់ជ្រុងរទេះ ខាងក្រោយមិត្តខ្ញុំទាំងអស់គ្នា នៅពេលនោះនាយតម្រួតមកវាយខ្ញុំពីរដំបងយ៉ាងធ្ងន់ដៃ ! នៅពេលនោះហើយខ្ញុំឈឺចាប់យ៉ាងខ្លាំងរហូតដល់ស្រក់ទឹកភ្នែកដូចកូនក្មេង...គិតមើល ? ខ្ញុំកំពុងខំអស់សមត្ថភាព កំពុងតែឱនខំរុញរទេះនោះ គេវាយពីលើយ៉ាងអស់ដៃ តើវាធ្ងន់យ៉ាងណា ? សឹងតែបាក់ឆ្អឹងខ្នងតែម្តង ! នៅពេលគេបង្ខំហើយធ្វើទារុណកម្មយ៉ាងនោះ រទេះនោះក៏ឡើងទៅរួចដោយស្រួល ។ នៅពេលរទេះ

ទៅដល់លើភ្នំខ្សាច់ហើយ គេគ្មានឱ្យឈប់សម្រាកទេ គេឱ្យចូកខ្សាច់ដាក់លើរទេះនោះភ្លាម ។ ខ្សាច់ពេញរទេះ ហើយនាយតម្រួតក៏បញ្ជាឱ្យរុញរទេះនោះចុះមកវិញពេលរុញចុះពីខ្នងភ្នំខ្សាច់នោះមក ផ្លូវនោះវាចោត ពេលរទេះចុះទៅកាន់ផ្លូវចោទនោះ ហើយជ្រុលលឿនទៅមុខនោះ មនុស្សទោសដែលរុញរទេះទាំងនោះ ត្រូវលោកឡើងជិះតោងរទេះនោះនៅតែម្តង ដើម្បីឱ្យបានទាន់រទេះនោះ ហើយរុញតទៅទៀត បើទៅមិនទាន់រទេះនោះទេ នាយតម្រួតនឹងវាយទៀត ។ នៅពេលរទេះនោះកំពុងជ្រុលចុះតាមផ្លូវចោតយ៉ាងលឿនដូច្នេះ ជួនកាលធ្វើឱ្យរទេះនោះភ្លាត់ចេញពីផ្លូវដែក ហើយក្រឡាប់ក៏មាន ។ រទេះរលំក្រឡាប់ម្តងៗមានគ្រោះថ្នាក់ដល់មនុស្សមានស្លាប់ មានរបួសជាទម្ងន់ជាច្រើននាក់ ។ ដោយមនុស្សទាំងនោះឡើងអង្គុយលើរទេះខ្សាច់ទាំងនោះ ។ ទោះបីមានរបួសនៅរស់ឬក៏ស្លាប់ក៏គេនាំទៅផ្ទះពេទ្យដែរ បើស្លាប់វិញគេយកទៅកប់តែម្តង ។ បើនៅរស់វិញគេព្យាបាលនៅឯផ្ទះពេទ្យ តាមយថាកម្មទៅទៀត... នៅពេលនោះខ្វះថ្នាំពេទ្យច្រើនណាស់ ត្បិតស្រុកកំពុងកើតសង្គ្រាមលោកលើកទី២នៅឡើយ ។

នៅពេលធ្វើការនាំដីខ្សាច់ទៅចាក់ តាមគោលដៅគ្រួចស្រេចហើយ ដល់ពេលម៉ោងឈប់ តម្រួតក៏នាំទៅកាន់គុកដដែលនោះតទៅទៀត ។ លុះនៅក្នុងគុកនោះប្រហែល៦-៧ថ្ងៃ ខ្ញុំបានទៅកាប់អុសជាមួយក្រុមមនុស្សទោសចំនួន៣០នាក់ ។ ក្រុមនេះគេមិនឱ្យត្រឡប់មកគុកវិញទេ គឺឱ្យនៅកាប់ពេញមួយថ្ងៃ លុះត្រាតែបានអុសគ្រប់ចំនួនហើយ នៅម៉ោង១៦,៣០គេផ្លុំកញ្ចែបីដង ប្រមូលរាប់ឱ្យគ្រប់ចំនួនហើយទើបនាំត្រឡប់មកគុកវិញ ។ ឯបាយព្រឹកគេឱ្យដណ្តាំមទូលទាន ឯកន្លែងធ្វើការឯនោះ ។ រឿងកាប់អុសនោះ,កាលខ្ញុំបានទទួលពូថៅពុះអុសមួយហើយ , ខ្ញុំក៏ដើរទៅតាមមិត្តខ្ញុំដែលគេពន្យល់ឱ្យកាប់ គឺគេបង្គាប់ឱ្យកាប់ដើមស្នាច់ទាំងដើម ទាំងឫសយកប្រវែង៤០ស.ម រួចជញ្ជូនមករៀបឱ្យបានកម្ពស់១ម៉ែត្រឱ្យគេ តាមកន្លែងដែលគេកំណត់ឱ្យនោះជាការស្រេចយើងបានឈប់សម្រាកមុនម៉ោង ។

ខ្ញុំខំធ្វើការចំនួន៣-៤ម៉ោងបានហើយស្រេចឃើញស្រួល គ្រាន់បើ ជាហេតុនាំឱ្យបានចិត្តរហូតដល់មើលងាយការកាប់អុសថា ជាការស្រួល ត្បិតបានហើយឆាប់ ហើយបានឈប់២-៣



ម៉ោងមុនត្រឡប់ទៅគុកវិញ ។ ធ្វើដូច្នេះបាន៥ថ្ងៃខ្ញុំក៏បានបបួលមិត្តខ្ញុំពីរ-បីនាក់ឱ្យចូលស្ម័គ្រក្នុងក្រុមកាប់អុសជាមួយពួកចាស់ៗ ដើម្បីឱ្យបានស្រួលទាំងអស់គ្នា ។ ពួកចាស់ៗគេបានឃាត់ខ្ញុំថាកុំឱ្យស្ម័គ្រខាងក្រុមកាប់អុសអី ត្បិតជាការលំបាកណាស់ ដែលពួកអ្នកទោសនោះត្រូវឡាចគេខ្លាចរអារអូមគ្រប់គ្នា ,ប៉ុន្តែខ្ញុំពុំព្រមស្តាប់គេសោះ ចេះតែជំនះសុំស្ម័គ្រក្នុងក្រុមនេះរហូតតែបាន ដោយយល់ឃើញថានៅធ្វើការក្នុងគុកធំ វាអផ្សុកតុះគំនិតប្រាជ្ញា ជាងការចេញទៅធ្វើការក្រៅ ត្បិតបានឃើញទេសភាពអ្វីៗប្លែកៗនាំឱ្យបាត់អផ្សុក ។ ម្យ៉ាងទៀតមកពីខ្ញុំធ្លាប់មានការពិសោធន៍៥-៦ថ្ងៃមកហើយឃើញថាស្ទុះរួច ។ ពេលក្រោយមិត្តខ្ញុំបីនាក់គឺលោកភោគនី,រ៉ុំ,ផារួមផង យើងបានចេញបម្រុងទៅធ្វើការដូចសព្វដង ។ ខ្ញុំបានឈរនៅកន្លែងដែលមនុស្សទោសស្ម័គ្រទៅធ្វើការឯកន្លែងផ្សេងៗ ។ ខណៈនោះតម្រួតក៏មករាប់យក៣០នាក់ ឱ្យឈរមួយកន្លែងផ្សេងពីគ្រួចគេរាប់តទៅទៀតរហូតដល់អស់ ។ តម្រួតនោះឡើងទៅលើការិយាល័យចាត់ការបានបន្តិច ឃើញតម្រួតពីរបីនាក់ផ្សេង ទៀតចុះមកបង្គាប់ពួកខ្ញុំឱ្យតម្រង់ជួរ ជាពីរជួរហើយគេក៏នាំដើរប្រហែលបីគីឡូ ទើបដល់កន្លែង គុកដែលគេឱ្យមនុស្សទោសកាប់អុស គេក៏យកបញ្ជីទៅប្រគល់ឱ្យតម្រួតនៅកន្លែងនោះពិនិត្យ ។ លុះពិនិត្យរាប់ត្រូវតាមបញ្ជីហើយគេក៏នាំពួកខ្ញុំបញ្ចូលក្នុងគុកទីនោះទៅទៀត ដើម្បីរង់ចាំបញ្ជាពីមេតម្រួតជាតិបារាំងសែសទៀត ។

នៅកន្លែងនោះ , មានកិច្ចការច្រើនផ្នែក គឺដាំដំណាំផ្សេងៗមានជី ,ប៉េងប៉ោះ,សាឡាត់, បន្លែផ្សេងៗជាច្រើន ។ មានកន្លែងមួយទៀតគឺគេឱ្យទៅធ្វើឡធ្យូង ដុតឥដ្ឋ ដុតកំបោរ ដែលជាកន្លែងស្រួលជាងកន្លែងឯទៀត ។ មួយក្រុមទៀតឱ្យទៅឃ្វាលគោ ជ្រូក ។ នៅកន្លែងកាប់អុសគេឱ្យធ្វើការធ្ងន់មែន តែដល់មានជំងឺអ្វីឡើង គេឱ្យទៅព្យាបាលឯផ្ទះពេទ្យបាន៣-៤ថ្ងៃទើបត្រឡប់មកវិញ ។ បើយើងមានប្រាក់១០០ឬ២០០រៀលសូកគ្រូពេទ្យ គេដាក់ថាមនុស្សទោសនេះត្រូវឱ្យសម្រាក ធ្វើការស្រាលៗចំនួន១៥ឬ២០ថ្ងៃក៏នឹងបានកន្លែងធ្វើការផ្សេងៗពីការកាប់អុសដូចបានជូនដំណឹងពីខាងដើមមកហើយ ។

ពេលដែលពួកខ្ញុំនៅរង់ចាំបន្តិចនោះក៏ឃើញនាយតម្រួតមកចាក់សោ បញ្ចេញពួកយើងមកក្រៅគុក ឈរជាពីរជួររង់ចាំមេតម្រួតជាតិបារាំងសែស គេជ្រើសរើសតាមចិត្តគេ ។ ប្រហែល

កន្លះម៉ោង ទើបឃើញតម្រួតបារាំងចេញពីការិយាល័យដើរមកសម្លឹងជ្រើសរើសមនុស្សទាំង ៣០នាក់នេះ ។ មុនដំបូងគេរើសយកមនុស្សមាឌមាំៗឱ្យចេញពីរជួរមកឈរមួយកន្លែង ។ នៅពេលនោះ ខ្លួនខ្ញុំត្រូវគេជ្រើសទី៣ មានគ្នាចំនួន១៣នាក់ ។ បានទៅឈរនៅកន្លែងមួយផ្សេងទៀត ។ រួចគេនាំក្រុមខ្ញុំឱ្យចូលទៅក្នុងគុកវិញចំណែកមិត្តខ្ញុំ៣-៤នាក់ ត្រូវគេ នាំទៅដាក់គុកមួយផ្សេងទៀត ។ នៅពេលនោះ ខ្ញុំចេះតែនឹកព្រួយក្នុងចិត្តថា គេនាំពួកខ្ញុំទៅកន្លែង ណាអ៊ីចេះ ?-លុះដល់ពេលបាយថ្ងៃត្រង់ទើបមានខ្មែរម្នាក់និយាយប្រាប់ថា ពួកខ្ញុំនេះត្រូវកាប់អុសហើយ ! ខ្ញុំនឹកក្នុងចិត្តថា ខ្ញុំមិខ្លាចទេកាប់អុសនោះ ហើយសួរទៅគេវិញថា ចុះក្រុមមួយទៀតទៅធ្វើអី ? គេប្រាប់ទៀតថា គេឱ្យដាំដំណាំ ធ្វើការក្នុងឡផ្សែង តាមតែបារាំងវាប្រើមិនទៀងទេ ។

លុះដល់ម៉ោង៥ភ្លឺ ទើបតម្រួតមកចាក់សោបើកទ្វារបញ្ចេញមនុស្សទោសទាំងអស់មកក្រៅ ។ ក្រោយពីឱ្យទទួលទានបបរនិងស្ករអំពៅហើយ គេបង្គាប់ឱ្យទៅយកពូថៅមួយម្នាក់ហើយនិងចបកាប់មួយផង រួចគេនាំទៅកន្លែងដែលខ្ញុំបាទទៅកាប់អុសពីថ្ងៃមុន ។ ដល់ធ្វើការនៅនោះបានតែបីថ្ងៃស្រាប់តែមេតម្រួតជាតិបារាំងវាមកត្រួតមើលអុសនោះ ហើយស្រែកថា : អុសតូចៗណាស់ប្រើការមិនកើតទេ ត្រូវឱ្យទៅកាប់ឯខ្នងភ្នំឯណោះវិញ ។ ខណៈនោះមានមិត្តខ្ញុំម្នាក់ជាជើងកាប់អុសនៅកន្លែងនោះមុនខ្ញុំគេយល់ការច្រើន គេក៏ប្រាប់ខ្ញុំថា : ចាប់ពីថ្ងៃស្អែកនេះទៅ ពួកឯងនិងវេទនាហើយត្បិតបារាំងមេតម្រួតធំគេប្រាប់ឱ្យយើងទៅកាប់អុសលើខ្នងភ្នំឯណោះនិយាយផងដៃគេចង្អុលទៅភ្នំនោះផង ។ ខ្ញុំមើលតាមចង្អុលដៃរបស់គេទៅ ឃើញភ្នំនោះមានកំពស់មិនខុសពីភ្នំស្រង់ ស្រុកគងពិសី(កំពង់ស្ពឺ) យើងនេះទេ ។ ស្អែកឡើងគេនាំពួកខ្ញុំទៅកាន់ទីភ្នំនោះ ។ នៅទីនោះខ្ញុំឃើញខ្សែដែក (Câble) មួយទំហំប៉ុនកដៃកូនក្មេងតចុះពីលើកំពូលភ្នំមកចងនឹងគល់ឈើនៅជើងភ្នំរឹតយ៉ាងតឹង ។ គេថាការរឹតឱ្យតឹងនេះប្រើមនុស្សទោសដល់ទៅ ១០០នាក់ឯណោះឱ្យទាញ ។ ខ្សែដែកនោះប្រវែង ៥០០ទៅ៦០០ម៉ែត្រ ។ កាលណាគេឱ្យចងចុងខ្សែដែកឱ្យរឹងមាំទាំហើយទើបប្រើការបាន ។ កន្លែងដែលកាប់អុសនីមួយៗនោះមានកំណត់ពេលវេលា១ឆ្នាំក៏មានតាមកន្លែងដែលមានអុសច្រើនឬតិច ។ លុះកន្លែងនោះអស់អុសហើយ ទើបគេឱ្យស្រាយខ្សែដែក



នោះទៅចងនៅកន្លែងណាផ្សេងទៀតដែលមានអុសច្រើន ។ ចំពោះការទម្លាក់អុស ចុះក្រោមគេប្រាប់ខ្ញុំថា កាលណាយើងកាប់អុសបានគ្រាប់ចំនួនហើយ យើងត្រូវសែងអុសនោះ យកទៅដាក់ចងនៅកន្លែងចងខ្សែនោះ ។ យើងតែងរកគ្នាឱ្យបាន៣នាក់ឱ្យជួយ គឺចាត់ឱ្យម្នាក់ទៅចាំទទួលអុសនៅខាងក្រោមពីរនាក់នៅសែងអុសនិងរៀបចំទម្លាក់ពីខាងលើ ។ ឯរបៀបចង់អុសគឺយកខ្សែដែក (Câble) ទំហំប៉ុនមេដៃពីរខ្សែប្រវែង ៣-៤ម៉ែត្រចងអុសចំនួន៣ម៉ែត្រឱ្យយ៉ាងតឹងដោយប្រុងប្រយ័ត្នបំផុត បើឃើញនៅមានចន្លោះប្រហោងត្រង់ណា គេយកអុសទៅស៊កបោះស្នៀតត្រង់នោះឱ្យអាល់តែណែនក្តន់មែនទែន បង្ការកុំឱ្យរបូតពេលទម្លាក់សម្រូតចុះទៅនោះ ។ រួចគេនាំគ្នាសែងអុសនោះលើ ទៅដាក់លើរានឈើមួយកំពស់១ម៉ែត្រប្រវែង៣ម៉ែត្រនៅពីខាងក្រោមខ្សែដែក ដែលគេធ្វើ សម្រាប់ដាក់អុសហើយគេចងនៅចុងខ្សែដែកខាងលើកំពូលភ្នំ ។ ពេលចងអុសស្រួលបួលហើយ ត្រូវប្រុងប្រយ័ត្នថែមទៀតក្នុងការទម្លាក់មកក្រោម ពីព្រោះថាជាធម្មតាតែងមានមិត្តយើងឯទៀត គេបានទម្លាក់អុសគេទៅមុខខ្លះដែរ ដូច្នេះយើងត្រូវបង្អង់បានយូរបន្តិចទុកចាំឱ្យខ្សែនេះ រលាស់យោលបានបីបួនដងសិន ទើបគេដាក់ទម្លាក់តាមក្រោយគេទៀតបាន ។ បើមិនដូច្នេះទេ យើងបង្ខំទម្លាក់ដោយឥតពិចារណាអុសយើងទម្លាក់នោះ មុខជាធ្លាក់កណ្ដាលផ្លូវនៅចង្កេះភ្នំបាត់ រកមិនឃើញមិនលែងទាំងបីនាក់ ដែលខំធ្វើការមួយថ្ងៃទល់ព្រលប់ទៅជាឥតបានប្រយោជន៍អ្វីទាំងអស់ ។ ក្នុងការកាប់អុសលើខ្នងភ្នំត្រូវរកមិត្តជាមួយមនុស្សទោសជើងចាស់ម្នាក់ឱ្យគេចូលជាមួយយើងទើបបានត្បិតគេមានការពិសោធន៍ច្រើនក្នុងការកាប់អុសនោះ ។ សូមជម្រាបថាខ្ញុំបានចូលទៅ ធ្វើការនេះនៅពេលនោះ ។ ក្នុងពេលដែលក្រុមនីមួយៗទម្លាក់ម្ដងៗ អ្នកនៅឯលើនិងអ្នកនៅ ឯក្រោមត្រូវតែស្រែកបង្អកឱ្យដំណឹងគ្នាឱ្យដឹងជាមុនសិនទើបអាចទម្លាក់អុសចុះបាន ដើម្បីឱ្យអ្នកខាងក្រោមប្រុងប្រៀបចាំទទួលកុំឱ្យច្រឡំក្រុមគ្នា ។ បើអ្នកឯក្រោមមិនដឹងដំណឹងមុនទេ ប្រាកដជាបាត់ខុសខ្លះមិនខាន ត្បិតមនុស្សទោសក្រុមដោយខ្លួនពីយើងដែលនៅចាំខាងក្រោម ដូចគ្នាដែរ អាចនឹងច្រឡំឬអាចនឹងលួចជញ្ជូនយកអុសយើងទៅតម្រៀបធ្វើជាអុសរបស់គេទៅ ។ ចំណែកក្រុមយើងទាំង៣នាក់ នឹងខ្វះចំនួនអុសមិនបានពេញម៉ែត្រឱ្យតម្រួតឡើយ នឹងត្រូវទទួលទណ្ឌកម្មជាមិនខានឬក៏សុំជំពាក់ការប៉ូវ៉ាល់ទៅសិនទើបបាន ។ ប៉ុន្តែបើកាប៉ូវ៉ាល់នោះមិនព្រមផង យើងត្រូវតែមានទោសជាមិនខាន ។ មួយទៀតដល់ថ្ងៃស្អែកឡើង

យើងត្រូវលំបាកនឹងខំកាប់អុសទ្វេជាងពីថ្ងៃមុន ដើម្បីសងអុសដែលខ្វះពីប៉ុរិលផង និងដើម្បីឱ្យបានពេញមួយប៉ែត្រសម្រាប់ថ្ងៃ នេះផង ឃើញថាមានការយ៉ាប់យ៉ឺនពេកណាស់ស្ទុះពិន្ទួចទេ ។ ក្នុងពេលទម្លាក់អុសម្តងៗកងដែលវិលលើខ្សែដែក (câble) នោះឱ្យសម្លេងពីដូចយន្តហោះប្រតិកម្មសម្រាប់ទម្លាក់គ្រាប់ បែកដូច្នោះឯង ។ វេលាដែលវាយដកកំណល់អុសដែលកពរ់នោះចេញអុសបាច់នៅក្នុងរាននោះ ក៏ រអិលចុះយ៉ាងលឿនក្រៃពេលងឮស្ងួរ!...យ៉ាងវែងរួចឮក្ទាំង ! នៅខាងក្រោមឯណោះមានពេល ខ្លះដែលមិនបានដាក់ខ្លាញ់ក្នុងកងនោះទេមើលទៅឃើញភ្លើងព្រិចៗចេញពីកងនិងខ្សែដែកនោះ គួរកយខ្លាចក្រៃលែង ។ លុះដល់ទម្លាក់អុសអស់ហើយទើបអ្នកខាងលើរៀបចំពូថៅខោអាវនាំគ្នាចុះមកក្រោមតាមអុសនោះទៀត ដើម្បីទៅជួយមិត្តម្នាក់នៅឯក្រោមក្នុងការជញ្ជូនអុសយកទៅរៀបជាម៉ែត្រឱ្យបានហើយពីក្បាលព្រលប់រួចក៏នាំគ្នាដើរត្រឡប់ទៅគុកវិញ ។

សូមជម្រាបថា ក្នុងការកាប់អុសនេះ មនុស្សទោសទាំងអស់ត្រូវតែស្រាតខោអាវនៅខ្លួនទទេទាំងអស់គ្នា ដើម្បីឱ្យស្រួលធ្វើការផង កុំឱ្យប្រឡាក់ខោអាវផងឱ្យស្រួលនឹងដើររុកព្រៃញឹករកអុសផង ។ ខ្សែដែកដែលគេប្រើសម្រាប់ទម្លាក់អុសពីលើភ្នំមកក្រោមនោះ គេទើបនឹងមានប្រើចំនួនបួយខែមុនខ្ញុំទៅ កាប់អុសនៅលើភ្នំនោះ ។ ពីមុនមកពុំដឹងជាគេប្រើមធ្យោបាយដូចម្តេចទេ សម្រាប់ទម្លាក់អុសមកក្រោម ។ ម្យ៉ាងទៀតដោយទើបទៅកាប់អុសនៅកន្លែងនោះទើបអុសនៅទីនោះហានសម្បូរនៅឡើយ ។ ការកាប់អុសលើភ្នំខុសគ្នាពីការកាប់អុសខាងក្រោមដែលអុសតូចៗប៉ុនកដៃដកជើងក៏គេយកដែរ , ឯចំណែកពួកលើភ្នំវិញគេឱ្យរើសយកតែអុសធំៗតាំងពីប៉ុនកំភួនជើង ទៅដល់ ប៉ុនភ្លៅហើយត្រូវដើររកនៅទីឆ្ងាយៗចំនួន៦០០ម៉ែត្រទៅ៧០០ម៉ែត្រ ត្បិតនៅទីជិតៗគេកាប់អស់ ទៅហើយ ។ ឯដីលើខ្នងភ្នំក៏ពុំរាបស្មើ,ច្រើនតែខ្ពស់ទាប, មានដុំថ្មតូចធំរដិបរដុបនាំឱ្យពិបាក សែងអុសពីកន្លែងកាប់មកកន្លែងចុងខ្សែដែកយ៉ាងក្រៃពេរង ជួនណាពីព្រឹកទល់ល្ងាចសឹងតែរក មិនបានគ្រប់មួយម៉ែត្រផង ។ ណោបួយពេរកំតរព្រោកធ្វើបារទឹកទទួលទានខ្លួនឯងផងទៀត ។



នៅពេលនោះខ្ញុំចេះទទួលទានសាច់សត្វគ្រប់យ៉ាងតាំងពីបង្កួយ ថ្លែន ពស់ ប្រជៀវ កណ្តុរភ្នំ ត្រកួត ។ល។ ដែលពីដើមខ្ញុំមិនដែលទទួលទានសោះ ។ សាច់សត្វទាំងនេះដល់ធ្វើស្អាតបាត, ពោងទឹករួចយកទៅចិញ្រ្ចាំឱ្យម៉ដ្ឋបន្តិច ស្លជាមួយម្អូរស្លឹកថ្នឹង,ស្លឹកសណ្តាន់ ឬផ្លែសណ្តាន់ បង់អំបិលដាក់ទឹកត្រី,បង់ម្ទេសឬម្រះព្រៅទៅធុំក្លិនឈ្ងុយស្រក់ទឹកមាត់ ទទួលទានឆ្ងាញ់គួរសមដែរថែមទាំងឃ្លានផុំផងទៅ ឆ្ងាញ់បែនមែន បានបាយយ៉ាងច្រើនមានកម្លាំងព្រឹស ។ មិត្តគង់តែទទួលទានកើតដូចខ្ញុំដែរចំពោះសាច់សត្វទាំងនេះ ពីព្រោះកាលៈទេសៈមកដល់ហើយគឺថា វាទាល់ហើយមិនដឹងបានអីទទួលទានក្រៅពីសាច់សត្វអស់នេះ បើមិនទទួលទានអានតែអត់ បើអត់មានកម្លាំងឯណាធ្វើការឱ្យគេ ? ក្នុងពេលកាប់អុសត្រូវឆ្លៀតរកម្ហូបផង ឱ្យតែឃើញសត្វអីក៏ដោយត្រូវតែខំដេញឬធ្វើម្តេចឱ្យតែខាងតែបានសម្រាប់ធ្វើម្ហូប ។ ចំណែកខ្ញុំគ្រាន់តែដណ្តាំបាយទេ ឯខាងម្ហូបស្រេចលើមិត្តយួនៗគេអ្នកធ្វើទាំងអស់ ត្បិតគេដើងចាស់មានការពិសោធន៍គ្រប់យ៉ាង គេនៅទីនោះមុនយើង ។ មុនដំបូងដែលមិនធ្លាប់ទទួលទានសាច់សត្វអស់នោះសោះ រាងដូចជាឆ្អើមៗមិនស្និទ្ធដែរ ,ប៉ុន្តែដល់បានភ្លក្សម្តងហើយ ,វាឆ្ងាញ់ដូចសាច់សត្វធម្មតាអីចឹងដែរ ។ ហេតុនេះបានជាខ្ញុំយល់ថា សាច់សត្វអីក៏ដោយ ឱ្យតែផ្សំគ្រឿងត្រូវ ហើយឃ្លានផង សុទ្ធតែឆ្ងាញ់ដូចគ្នាទាំងអស់ ត្បិតខំប្រឹងធ្វើការហួសកម្លាំងតាំងពីព្រឹកដល់ថ្ងៃត្រង់ ឥតអ្វីក្នុងពោះសោះ ក្រៅពីបបរបន្តិចពីព្រលឹមនោះ ។

លុះធ្វើការខាងកាប់អុសបានចំនួន ១០ថ្ងៃ ដៃខ្ញុំទាំងពីរឡើងហើមប្រេះក្រហែងឈឺរអាមកាន់ពូថៅកាប់អុសពុំបាន ។ ខ្ញុំបានទៅសុំពេទ្យគេគ្រាន់តែលាបថ្នាំឱ្យបន្តិចឥតឱ្យច្បាប់អ្វីសោះ ។ ខ្ញុំត្រូវត្រឡប់ទៅធ្វើការដូចដើមធម្មតាវិញ ។ ខ្ញុំខំព្យាយាមធ្វើការតទៅទៀតលែងកើតសោះដោយឈឺដៃទាំងពីរខ្លាំងពេក ទើបខ្ញុំប្រាប់ទៅមិត្តខ្ញុំថា បើខ្ញុំឈឺខ្លាំងធ្វើការមិនកើតដូច្នេះ តើត្រូវគិតយ៉ាងម៉េច ? គេប្រាប់ថា ត្រូវទៅប្រាប់កាប៉ូរ៉ាល់សុំឈប់ទៅ ។ ក្នុងថ្ងៃនោះ មិត្តខ្ញុំគេបានជួយកាប់អុសបំពេញចំនួនឱ្យគ្រប់ឱ្យ ។ ឯខ្ញុំធានាជាអ្នកសែងអុសនោះយកមកដាក់នៅដើមខ្សែដែក ។ របៀបសែងអុសនោះ មនុស្សទោសគេធ្វើស្នែងនឹងឈើតាមរបៀបស្នែងកម្មករលីសែង នៅកំពង់ផែកប៉ាល់ភ្នំពេញយើង ដែលខ្ញុំធ្លាប់បានឃើញកាលពីនៅក្មេង ។ បើមនុស្សខ្លាំងសែងម្តង

បានកន្លះម៉ែត្រ, បើមនុស្សខ្សោយវិញបានតែបីឬបួនតឹកប៉ុណ្ណោះ ។ ចំណែកខ្លួនខ្ញុំពេលនោះកំពុងពេញកម្លាំងដោយអាយុ២២ឆ្នាំ ខ្ញុំអាចសែងអុសម្ដងបាន៥០សង្ទីម៉ែត្រ ។ ខ្ញុំអាចសែងអុសខ្លួនឯងផងអុសរបស់មិត្តភក្ដិផង ដោយខ្ញុំកាប់មិនកើត ។ ប៉ុន្តែការជួយប្រវាស់កម្លាំងគ្នាបានតែបីថ្ងៃ, មិត្តខ្ញុំក៏ឈឺទៅទៀត,ខ្ញុំរកដៃគូមិនបានក៏អស់សង្ឃឹមត្រឹមនេះសម្រេចចិត្តថា ត្រូវឈប់កាប់អុសទោះបី គេធ្វើ ទុក្ខធ្វើបាបដូចម្ដេចក្ដី ,ស៊ូតែទ្រាំទៅចុះ ឮិតប្រឹងលែងរួចទៅហើយ ។ ខ្ញុំនឹកឃើញទោសកំហុសដែលត្រូវទទួលយ៉ាងវេទនា ខ្ញុំព្រួយណាស់ ហើយខ្ញុំនឹកថាមិត្តដែលគេនិយាយប្រាប់ខ្ញុំនូវរឿង មហន្តទោសនោះប្រាកដជាពិតមែនហើយ ខ្ញុំមុខជានឹងត្រូវរងហើយ ។ ក្នុងគ្រានោះ,ខ្ញុំនឹកបួងសួងដល់បុណ្យគុណដែលខ្ញុំបានធ្វើមកប៉ុន្មាន ព្រមទាំងគុណមាតាបិតាជីដូនជីតាទាំងប៉ុន្មានសូមជួយ ជ្រោមជ្រែងបញ្ចូលចិត្តកុំឱ្យតម្រួតវាធ្វើបាបខ្លាំងពេក ហើយក៏អង្គុយលើឈើងាប់មួយដើមស្រក់ ទឹកភ្នែក ដោយនឹកភ័យខ្លាចដល់ពេលល្ងាចដែលត្រឡប់ទៅគុកវិញ មិនដឹងជាពួកតម្រួតវាទាត់ ធាក់យ៉ាងណាទេ ព្បិតធ្លាប់បានឃើញផ្ទាល់នឹងភ្នែកខ្លួនឯងស្រាប់មកហើយ ។ ក្នុងពេលធ្វើការឱ្យគេមិនបានសម្រេចម្ដងៗ , ពួកតម្រួតវាហៅឈ្មោះមនុស្សទោសម្នាក់ម្ដងៗទៅឈរដោយ ឡែកពីគេ ហើយវាវាយទាត់ធាក់ធ្វើបាបមនុស្សទោសទឿមក្នុងម្ដងៗបីបួននាក់ដើម្បីឱ្យមនុស្ស ឯទៀតរាងចាល ខំប្រឹងធ្វើការឡើងដោយគេចោទថាយើងមិនព្រមធ្វើការ, គេមិនមែនយល់ថា យើងខំធ្វើការណាស់ដែរ តែវាហួសកម្លាំងទៅមិនរួចនោះទេ ។

ហេតុនេះហើយ ,បានជាខ្ញុំព្រួយចិត្តខ្លាំងខ្លាចក្រែងគេធ្វើទារុណកម្មខ្លាំង ទៅជាសម្រក់ទឹកភ្នែកតែម្ដង ដោយក្នុងជីវិតខ្ញុំមិនដែលជួបប្រទះនឹងសេចក្ដីទុក្ខដូចគ្រានេះឡើយ ។

មិត្តជាទីស្នេហា ! ក្នុងពេលកំពុងអង្គុយសម្រក់ទឹកភ្នែកស្រាប់តែឮសូរសម្លេងមួយម៉ាត់គាត់ប្រាប់ថា «ខំទៅ» ខ្ញុំងើបក្បាលងាកមើលតាមរកម្ចាស់សម្លេងមិនឃើញសោះ ។ ហេតុអ្វីក៏ឮសម្លេងមនុស្សដូច្នេះ ? ដល់នឹកយូរៗទៅ ទើបសម្រេចចិត្តថា ត្រូវតែខំប្រឹងប្រែងរកអុសបន្ថែមទៀត , លុះខំរកបានប្រហែល៧តឹក ក៏ដល់ម៉ោង៥ល្ងាចទៅហើយ ខ្ញុំក៏សម្រេចចិត្តត្រូវតែប្រថុយទៅសុំ ទោសចំពោះកាប៉ូរ៉ាល់ឱ្យគេជួយកត់បំពេញថា គ្រប់ហើយទៅ,ចាំដល់ថ្ងៃស្អែកសឹមខំរកអុសសងគេឱ្យគ្រប់ចំនួនវិញ ។ លុះចុះពីលើភ្នំមកដល់ដីហើយ,ខ្ញុំដើរចូលទៅសំពះកាប៉ូរ៉ាល់នោះ



សុំឱ្យគេ ជួយ ។ ក្នុងពេលនោះគេក៏មានចិត្តប្រណីអនុគ្រោះឱ្យតាមសុំ ,ប៉ុន្តែគេបានប្រាប់ថា ដល់ថ្ងៃស្អែក ត្រូវតែរកសងវិញកុំខាន ។ ខ្ញុំមានសេចក្ដីត្រេកអរកអ្វីប្រៀបពុំបានឡើយ ។ នៅពេលដែលត្រឡប់មកគុកវិញ ខ្ញុំក៏ទៅអង្គុយព្រួយចិត្តផ្អែកខ្នងនឹងគល់ព្រីងមួយនៅមុខគុកដោយបណ្ដែតអារម្មណ៍អស់សង្ឃឹមទៅរកថ្ងៃព្រឹកស្អែកទៀត ។ កំពុងតែអង្គុយសម្រាកបន្តិចមិនទាន់បានទទួលទានបាយផង , ស្រាប់តែឮសូរសម្លេងលោកម្នាក់ជាតិខ្មែរ ធ្វើការនៅការិយាល័យលោកប្រតិភូ (Délégué) នៅកោះត្រឡាចនោះស្រែកសួរថា អាណាឈ្មោះប៉ុណ្ណ ច័ន្ទ ម៉ុល ? មានឈ្មោះប៉ុណ្ណច័ន្ទម៉ុលនៅទីនេះ ទេ ? ខ្ញុំក៏ឆ្លើយទៅវិញថា :

ខ្ញុំបាទនេះហើយឈ្មោះប៉ុណ្ណ ច័ន្ទ ម៉ុល ។

ទើបលោកនោះហៅខ្ញុំឱ្យដើរតាមគាត់បន្តិចទៅ,ហើយក៏ចង្អុលទៅទិសខាងកើត និយាយប្រាប់ខ្ញុំថា : ព្រឹកស្អែកនៅពេលចេញពីគុក ឯងទៅរកខ្ញុំនៅផ្ទះលេខ១៨កុំខាន ។ ខ្ញុំឈ្មោះ*អង់ដ្រេ ដកម៉ែ* អ្នកបកប្រែភាសាខ្មែរបារាំង ។ ខ្ញុំទទួលពាក្យគាត់ហើយ គាត់ក៏ទៅផ្ទះគាត់ទៅ ។ លុះដល់ម៉ោង៧យប់ ,គេវាយរតាំងបញ្ចូលមនុស្សទោសទាំងអស់ទៅក្នុងគុក ។ ល្ងាចនេះខ្ញុំទទួលទានដំណេកពុំបានសោះ ចេះតែនឹកទៅដល់ព្រឹកស្អែកដែលត្រូវរកអុសទ្វេឡើង សម្រាប់សងគេពីមុនផង សម្រាប់ថ្ងៃស្អែកមួយម៉ែត្រទៀតផង តើធ្វើយ៉ាងម៉េច ? រកគិតមិនលេចសោះ ។

ល្ងាចនោះខ្ញុំទន្ទឹងឱ្យភ្លឺឆាប់នឹងទៅរកលោក*អង់ដ្រេ ដកម៉ែ* ។

លុះព្រឹកឡើងម៉ោង៥ភ្លឺ, ខ្ញុំក៏ចេញពីគុកមកក្រៅជាមួយមនុស្សទោសឯទៀត,ប៉ុន្តែពុំអាចទៅរកលោកនោះភ្លាមតាមបំណងរបស់គាត់បានឡើយ ,ខ្ញុំត្រូវរង់ចាំទាល់តែដល់ម៉ោង៦ទើបហ៊ានដើរទៅរកគាត់ឯផ្ទះលេខ១៨ ។ លុះទៅដល់ ឃើញលោកនោះ នៅចាំខ្ញុំជាស្រេច ។ នៅពេលជួបគ្នាលោកបានប្រាប់ខ្ញុំថាឱ្យខ្ញុំប្រយ័ត្នកុំឱ្យនរណាដឹងចំពោះរឿងខ្ញុំនិងគាត់ឱ្យសោះ តែបែកការណ៍ហើយ , ខ្លួនខ្ញុំនឹងត្រូវគេវាយដំច្រំធាក់យកទៅដាក់គុកងងឹត,ឯចំណែកខ្លួនគាត់វិញ ក៏ត្រូវផ្លាស់២៤ម៉ោង ។ នេះជាច្បាប់គុកនៅកោះត្រឡាច ស្ដាប់បានទេ ? ខ្ញុំទទួលពាក្យគាត់ហើយ ទើបគាត់

ប្រាប់ថា៖ឥឡូវបងប្អូនខ្ញុំផ្ញើគ្រឿងម្ហូបកំប៉ុងផ្សេងៗមក ,មានកាពិផាវ,កាពិឃិញ,នំផ្សេងៗជាច្រើនកំប៉ុងមកឱ្យព្រមទាំងប្រាក់៦០០រៀលផង ។ គាត់ថា ខ្ញុំយករបស់ទាំងនេះទៅទុកមិនបានទេពីព្រោះខ្ញុំនៅក្នុងគុក ។ ប៉ុន្តែបើចង់ទទួលទានអ្វីៗត្រូវមកយកពកផ្ទះគាត់បន្តិចម្តងៗទៅ ។ ឯប្រាក់បើត្រូវការចាយប៉ុន្មានមកយកទៅចុះ ! ឮដូច្នេះខ្ញុំមានសេចក្តីត្រេកអរឥតឧបមា រួចបានសូមយកប្រាក់ពីគាត់ចំនួន២០រៀល ដោយមានសង្ឃឹមថានឹងបានធូរក្នុងការកាប់អុសដោយសារប្រាក់នេះ ។

សូមជម្រាបថា នៅកោះត្រឡាចឱ្យតែមានប្រាក់មួយរៀលអាចញ៉ាំងជីវិតឱ្យធូរស្រាលបានមួយថ្ងៃ ជាពិសេសក្នុងក្រុមកាប់អុសដោយជួលគេឱ្យកាប់អុសជួសបាន១ម៉ែត្រដែរ ត្បិតមានមនុស្សទោសចាស់ៗនៅរាប់ឆ្នាំមកហើយ ពូកែកាប់អុសណាស់ គេអាចកាប់៣ឬ៤ម៉ែត្រក្នុងមួយថ្ងៃយ៉ាងធូរ ។ ចំណែកខ្ញុំកាប់តែ១ម៉ែត្រក្នុងមួយថ្ងៃបានយ៉ាងត្រដាបត្រដួស ។ នៅវេលាដែលខ្ញុំយកប្រាក់ពីលោកដកម៉ែ២០រៀលទៅខ្ញុំយក១រៀលទៅជួលគេកាប់ជួសបានមួយថ្ងៃ ហើយយកមួយរៀលទៀត ទៅជូនកាប៉ូរ៉ាល់ដែលខ្ញុំខ្វះអុសគេពីថ្ងៃមុន ។ ថ្ងៃហ្នឹងខ្ញុំបានសម្រាកកម្លាំងមួយថ្ងៃ បានដើរទៅសួរមិត្តភក្តិដែលឈឺនៅព្យាបាលរោគឯផ្ទះពេទ្យ ព្រមទាំងបានឱ្យប្រាក់៥រៀលទុកទិញថ្នាំព្យាបាលរោគផង ។ មនុស្សទោសដែលពូកែកាប់អុសនៅទីនោះមិនសមជាពូកែសោះ ត្បិតពួកនោះជាអ្នកលេងល្បែងគ្រប់យ៉ាងមានបៀបារាំង,ធួ,យូគីជាដើម ហើយពុំសូវមានពេលដេកផង,ក្នុងមួយយប់វាដេកបានតែចំនួន៣ម៉ោងប៉ុណ្ណោះ វាច្រើនតែលេងល្បែង ។

តាំងពីបានប្រាក់មក ខ្ញុំមានពេលសម្រាកបានដើរលេងនៅតាមភូមិតូចធំក្នុងកោះបានទៅស្គាល់មិត្តខ្មែរម្នាក់ឈ្មោះខាត់ នៅខេត្តតាកែវ បារាំងឱ្យធ្វើកាប៉ូរ៉ាល់ខាងដាំដំឡូងឱ្យត្រួតមនុស្សទោស១៥នាក់ ។ ខ្ញុំនៅលេងនៅកន្លែងនោះតាំងពីព្រឹករហូតដល់ល្ងាចទើបដើរទៅចូលគុកខាងផ្នែកកាប់អុសនោះវិញ ។ ខ្ញុំបានឱ្យប្រាក់៥រៀល ទៅកាប៉ូរ៉ាល់កាប់អុសដើម្បីបានឈប់៥ថ្ងៃតទៅទៀត ។

សូមជម្រាបថា ៖ គឺអាស្រ័យប្រាក់ដែលបងប្អូនផ្ញើមកពីស្រុកកាត់សមុទ្រ កាត់ប្រទេសនោះហើយទើបខ្ញុំបានធូរខ្លួនរំដោះពីទុក្ខទោសបានមួយគ្រាដ៏ធំ ។



# -៩-

# ការប្រដាល់នៅកោះត្រឡាច

ក្រោយពីឈប់កាប់អុសបាន១០ថ្ងៃ,ដល់ថ្ងៃទី៨ ខែធ្នូ ១៩៤២ ខ្ញុំបានកាត់ទៅសួរសុខទុក្ខលោកតាភោគ នី នៅកន្លែងឡឥដ្ឋឡធ្យូង ដែលមានមិត្តភក្តិ៣-៤នាក់ធ្វើការនៅនោះ ។ កំពុងតែនិយាយគ្នាលេងពីនេះពីនោះ ស្រាប់តែមានតម្រួតជាតិខ្មែរម្នាក់ឈ្មោះស៊ុម នៅទីនោះបានមកឈរនិយាយលេងជាមួយដែរ ។ គាត់ថា គាត់ស្គាល់ពូជអម្បូរខ្ញុំច្បាស់នៅសង្កាត់ច្បាររំពៅ, ខេត្តកណ្តាល គាត់ថាចាំមានឱកាសស្រួល ,គាត់នឹងសុំខ្ញុំឱ្យធ្វើការនៅឡធ្យូង ជាមួយតាភោគ នីវិញដើម្បីឱ្យបានជួបជុំគ្នា ។ ខ្ញុំក៏បានថ្លែងអំណរគុណចំពោះគាត់វិញ ។ ក្រោយនោះលោកភោគ នីបានជំរាបទៅលោកស៊ុមនោះថា ប្អូនប៊ុណ្ណចន្ទ ម៉ុល ចេះដាល់ពូកែចំណាប់ ។ លោកស៊ុម ក៏សួរបញ្ជាក់ខ្ញុំថា ចេះមែនឬ ?ខ្ញុំក៏ជម្រាបគាត់វិញថា ចេះខ្លះដែរ តែពុំដែលបាន ប្រកួតប្រជែងនឹងគេឡើយ ,គ្រាន់តែធ្លាប់បានហាត់កីឡាប្រដាល់ច្រើនមុខជាងកីឡាឯទៀតៗ ។ គាត់សួរបញ្ជាក់ខ្ញុំទៀតថា ឯងចេះកីឡាច្រើនមុខផង ? ខ្ញុំឆ្លើយប្រាប់គាត់ថា ខ្ញុំចេះច្រើនមុខសឹងតែគ្រប់កីឡាទាំងអស់ ដែលនៅស្រុកខ្មែរគេនិយមរាប់អាន ។ គាត់ក៏ថាឥឡូវនេះ នៅកោះត្រឡាចគេកំពុងរកជាតិខ្មែរយើងម្នាក់ទៅប្រដាល់ជាមួយជាតិយួនម្នាក់ឈ្មោះអាបេ ,ធ្វើការនៅក្រុមសាធារណការកោះត្រឡាច ។ វាជាអ្នកបើកបររ៉ឺឡឺកិនថ្ម តាមផ្លូវថ្នល់នៅមាត់សមុទ្រ ។ អាបេ វាដាល់ឈ្នះខ្មែរយើងរាប់ចំនួន៧ឆ្នាំកន្លងមកហើយ ឥតនរណាហ៊ានដាល់នឹងវាទៀតទេ ។ ឥឡូវនេះជិតចូលឆ្នាំបារាំងទៀតហើយ ,ឮសួរគេសួររកគូប្រដាល់ឱ្យទៅប្រកួតនឹងអាបេ ទៀតតើឯងហ៊ានលេងនឹងវាទេ ? វាជាមនុស្សខ្លាំងហើយពូកែរហ័សរហួនណាស់ ,ពួកខ្មែរយើងនៅកោះត្រឡាចខ្លាចវាទាំងអស់ ។ គ្រានោះខ្ញុំនៅស្ងៀមឥតឆ្លើយថាអ្វីឡើយចេះតែគិតពិចារណាក្នុងចិត្តថា អាបេអីគេនោះពោះប៉ុនណាទៅ ? លោកក៏បញ្ជាក់ខ្ញុំទៀតថា ៖ ហ៊ានប៉ះនឹងវាទេ ? ខ្ញុំក៏ឆ្លើយថា ៖

បាទមិនទាន់ហ៊ានថាទេ ចាំខ្ញុំបាទទៅរកមើលរូបរាងវាឱ្យច្បាស់សិន ,បើល្មមតស៊ូបាន ខ្ញុំបាទនឹងជូនដំណឹងលោកក្នុងរវាងពីរថ្ងៃទៀត !

ដល់ព្រឹកស្អែកឡើង ខ្ញុំក៏ដើរទៅរកពិនិត្យមើលរូបរាងអាបេនោះនៅត្រង់មាត់សមុទ្រ ឃើញវាកំពុងបើករ៉ូឡូកិនថ្មធ្វើថ្នល់ ។ ខ្ញុំពិនិត្យរូបរាងវាសព្វគ្រប់ទៅ ឃើញវាទាបជាងខ្ញុំបន្តិច, ចង្កេះវាមូលទំនងជាអ្នករហ័សរហួនមែន តែដោយវាមកជាប់គុកនៅកោះត្រឡាចចំនួន៨ឆ្នាំទៅហើយ,ឃើញថាចំណេះវាមិនជាប៉ុន្មានទេ ។ ម្យ៉ាងទៀតខ្ញុំយល់ឃើញថាអ្នកប្រដាល់ឱ្យតែមានមាឌធំ,ខ្ពស់ជាងគូប្រកួតហើយ តែងមានប្រៀបជាងគូប្រកួតបន្តិចហើយ ។ ចំណែកឯស្នៀតវាបើទុកជាយ៉ាងណា ក៏នៅតែជាបុរាណដែរ ត្បិតវាជាប់គុកយូរហើយ ។ លុះសង្កេតរូបរាងវាចំនួនកន្លះម៉ោងហើយ,ខ្ញុំក៏ត្រឡប់ទៅរកលោកស៊ុមវិញនៅឯឡឥដ្ឋ ។ គាត់ហៅខ្ញុំឱ្យចូលជិតហើយសួរខ្ញុំថា ម៉េចបានឃើញអាបេច្បាស់ហើយឬនៅ !ខ្ញុំជម្រាបគាត់ថា បានឃើញហើយ ! គាត់សួរទៀតថា , ម៉េចហ៊ានប្រកួតនឹងវាទេ ?ជួយយកឈ្មោះខ្មែរយើងម្តងទៅ ត្បិតវាឈ្នះគេរាប៧ឆ្នាំមកហើយ, លោកធំ[១] តែងតែឱ្យរកគូប្រកួតនឹងវារាល់ឆ្នាំគ្រប់កន្លែងគុកនៅកោះត្រឡាច តែរកមិនបានឥតមាននរណាហ៊ានលេងនឹងវាសោះ ។ ខ្ញុំជម្រាបទៅគាត់វិញថា ខ្ញុំបានសង្កេតមើលទៅឃើញវាថាមិនជាប៉ុន្មានទេ ,ប៉ុន្តែខ្ញុំបាទមិនហ៊ានមើលងាយគូសត្រូវឡើយ ។ ឥឡូវបើលោកឱ្យខ្ញុំបាទស្ម័គ្រចិត្ត,ខ្ញុំបាទក៏ហ៊ានស្ម័គ្រលមើលដែរ ប៉ុន្តែត្រង់ឈ្នះឬចាញ់ខ្ញុំបាទមិនហ៊ានធានាទេ ,ផ្សងតាមវាសនាទៅចុះ ! គ្រានោះលោកស៊ុមស្រែកជយោ ! មានខ្មែរហ៊ានស្ម័គ្រចិត្តនឹងអាបេហើយ !ល្អៗ ! រួចគាត់ស្ទុះមកអង្រន់ស្មាខ្ញុំហើយថា : ស្អែកអញនឹងទៅប្រាប់លោកធំឱ្យឯងបានឈប់សម្រាកបានហាត់តទៅទៀតទម្រាំដល់ថ្ងៃ១ មករា ឆ្នាំ១៩៤២ នឹងចូលប្រកួតតែម្តង ។

នៅពេលនោះ ,ខ្ញុំដូចជាអរបន្តិចព្រួយបន្តិច ដោយមកពីខ្លួនខ្ញុំមិនដែលចុះស្នាមម្តងណា

១.ពាក្យលោកធំនេះជាពាក្យសម្រាប់ហៅអ្នកណាដែលធំជាងគេ ទោះបារាំងក្តី ខ្មែរក្តី ។ ប៉ុន្តែក្នុងទីនេះហៅសំដៅទៅលោក ឌីពឌីនឡូឌី ជាតិបារាំងធំជាងគេនៅកោះត្រឡាច ។



តោះផងរកពីល្បីថា អាបេនោះវាខ្លាំងណាស់ តែវាជាប៉េត្រូវមួយដៃមុខជាក្អកធ្លាក់ឈាមស្លាប់មិនខាន ហើយបើទាត់ត្រូវមួយជើងវិញ ក៏តោងក្អកធ្លាក់ឈាមដូចគ្នាឃើញថាគួរឱ្យខ្លាចវាដែរ ប៉ុន្តែត្រូវតែប្រុងស្មៀតជានិច្ចមិនឱ្យវារំលោភរំលងលើបានទេ បើជាត្រូវស្លាបវិញ ធ្វើម្តេចអាយុវាត្រូវរស់ត្រឹមនេះឯង ។ ចិត្តខ្ញុំនៅអល់ឯកបែកជាពីរជានិច្ច មកពីពួកយួននិងខ្មែរទាំងអស់វាខ្លាចអាបេដូចខ្លាទៅហើយ ,ឥតនរណាហ៊ានប្រកួតនឹងវាឡើយ ។ ស្រាប់តែដល់ពេលនេះ ទើបមានរូបខ្ញុំម្នាក់គត់ដែលហ៊ានចេញមុខសុំប្រកួតនឹងវា ។

តពីនោះបានតែ៣_៤ថ្ងៃ ដំណឹងនេះបានឮសុសសាយពេញកោះត្រឡាចអ្នកទោសជាតិយួនៗខ្លះផ្តើលថា មានជាតិខ្មែរម្នាក់ទើបតែមកដល់ថ្មីៗ ហ៊ានប្រកួតនឹងបងបេយើងផង ,អានោះមុខជាងាប់ឆាប់ហើយ បងបេដាក់តែមួយដៃមួយជើង,វាប្រកាច់ស្លាប់ទៅហើយ ។ គឺជាទម្លាប់នៃចិត្តគំនិតរបស់ជនជាតិយួនដូច្នេះឯង ,បើហ៊ានៗណាស់,លោតែខ្លាចវិញ ,តែមុខយើងក៏មិនហ៊ានងាកមើលចំផង ។ នេះជារឿងពិតដែលខ្ញុំបានទៅរស់នៅជាមួយពួកវាបានដឹងស្គាល់គំនិតវាសព្វគ្រប់អស់ ។ ដូចពាក្យបុរាណថា រស់ជាមួយចោរហោរយដូច្នោះ ដឹងរឿងវាទាំងអស់ ។

ចំណែកអាបេវិញ,វាត្រូវបានឈប់សម្រាក ដើម្បីឱ្យហាត់បម្រុងប្រកួតជាមួយខ្ញុំ ដូចជាខ្ញុំដែរ ។

តាំងពីនោះមក និយាយពីពួកបងប្អូនខ្មែរយើងជាមនុស្សទោសដូចគ្នា បាននាំគ្នាយកថ្នាំបៀម,ថ្នាំចងកំភួនដៃមកឱ្យខ្ញុំ ។ ឯលោកតាភោគ នី បានយកឫសឈើម្យ៉ាងមកឱ្យខ្ញុំបៀមដែរ ។ ខ្ញុំចេះតែទទួលពីមិត្តភក្តិដោយចិត្តរំភើបរីករាយដើម្បីកុំឱ្យមិត្តខ្ញុំទាំងនោះខូចទឹកចិត្ត ។

ថ្ងៃខែចេះតែកន្លងទៅ,ថ្ងៃទី១មករា១៩៤៣ បានមកដល់,ការប្រកួតគ្នាក៏ចាប់ប្រព្រឹត្តឡើងនៅក្នុងរោងល្ខោនមួយដែលគេបានចាត់ចែងឡើងដោយយកឆាកល្ខោនធ្វើជាទីប្រកួត ។ ចំណែកអ្នកមើលហេនជាតិបារាំង,យួន,ខ្មែរជាស៊ីវិលស្ទើរតែទាំងអស់បានមកទស្សនា ជាមួយមនុស្សទោសរាប់ពាន់នាក់កកកុញពាសពេញរោងល្ខោនរហូតដល់រហែកជញ្ជាំងស្លឹកអស់រលីងទៅទៀត។

យប់នោះមានគូប្រដាល់៥គូ គឺក្នុងមួយគូ មានយួនម្នាក់ ខ្មែរម្នាក់គ្រប់គូទាំងអស់ ។ គូទីមួយខ្មែរចាញ់យួន ។ គូទី២ស្មើគ្នា ។ គូទីបីខ្មែរចាញ់យួន ។ គូទីបួន ខ្មែរឈ្នះយួន ។ ឯគូទីប្រាំគឺអាបេនិងខ្ញុំនេះឯង ។ មុនចូលទៅប្រកួតខ្ញុំនឹកបន់ស្រន់ដល់គុណបុណ្យ ដែលខ្ញុំបានធ្វើគ្រប់បែបយ៉ាងព្រមទាំងគុណមាតាបិតាសូមឱ្យជួយខ្ញុំ ឱ្យឈ្នះគូប្រកួតដើម្បីលើកតម្កើងកេរ្តិ៍ឈ្មោះជាតិខ្មែរយើងនៅកោះត្រឡាច ។ នៅពេលនោះខ្ញុំនឹកសង្ស័យច្រើន ដោយឃើញអាបេ វាឡើងមកលើវានប្រយុទ្ធ, វាបញ្ចេញស្នៀតប្រយុទ្ធរបៀបបុរាណ ដែលយួនហៅថា«យ៉ស៊ី»ជាស្នៀតចិនប៉ាហ៊ី ។ ខ្ញុំនឹកក្នុងចិត្តថា បើវាប្រើស្នៀតនេះជាមួយខ្ញុំ ខ្ញុំមុខជាឈ្នះវាពិតប្រាកដ ។

លុះដល់ម៉ោង ,អាជ្ញាកណ្ដាលក៏តាំងវាយរគាំងម៉ូង៧ខ្ញុំនិងអាបេក៏បានក្រោកឡើងដើរចូលរកគ្នា ។ ពេលនោះអាបេវាចេញស្នៀតបុរាណ វាតាំងដាល់ខ្ញុំមុន តែខុសដោយខ្ញុំគេចផុត វាបែរមករកខ្ញុំម្ដងទៀត វាដាល់ថែមមួយដៃទៀត,ខ្ញុំគេចខុសទៀត ។ ដល់លើកទីបី,វាលុកចូលមកបម្រុងដាល់ចំមុខខ្ញុំទៀត ,ខ្ញុំគេចមុខផុតទៅទៀត ,ទើបខ្ញុំប្រញាប់ដាល់សងមួយដៃស្ដាំចំមុខវាវិញ ដែលវាភាត់មិនទាន់ ហើយខ្ញុំដាក់មួយដៃស្ដាំភ្លាម១ទៅទៀត ត្រូវចំក្រោមចង្កាវា ហើយក្បាលជង្គង់ខ្ញុំក៏ចុកបណ្ដោយភ្លាមទៅទៀត ត្រូវត្រង់ពោះបាយវា ហើយខ្ញុំប្រញាប់លោតថយក្រោយវិញភ្លាម ,ឯវាក៏រលំដួលគ្រាំង ក្រាបស្រប៉ាបនឹងក្ដារវានប្រដាល់តែម្ដង ។ ចំណែកអាជ្ញាកណ្ដាលក៏រាប់១-២ដល់៧ ថាឱ្យខំក្រោកឡើង តែវាបានលើកដៃទាំងពីរសុំញ៉មតែម្ដង ដោយហេតុថាវានៅងោងស្រវាំងមិន ទាន់ស្វាងនៅឡើយ ទើបវាសុំចាញ់ក្នុងទឹកដំបូងតែម្ដង ។

នៅពេលនោះ,ក្រុមខ្មែរ,បារាំង,យួន, ស្រែកហ៊ោយ៉ាងខ្លាំងធ្វើឱ្យខ្ញុំព្រឺក្បាល ណាមួយភ័យថែមទៀត ។ រំពេចនោះមានមេតម្រួតគិញម្នាក់ជាតិបារាំងឈ្មោះទូសទូ បានឡើងលើវានប្រយុទ្ធហើយអង្អែលស្មាខ្ញុំ ព្រមទាំងសួរឈ្មោះនិងលេខប្រចាំខ្លួនខ្ញុំសព្វគ្រប់កត់ចុះក្នុងកូនសៀវភៅមួយ,រួចញញឹមរកខ្ញុំហើយយក៏ចេញបាត់ទៅ ។ ចំណែកមេតម្រួតបារាំងខ្លះដែលបានមកទស្សនា បានឱ្យប្រាក់ខ្ញុំ ខ្លះ៥រៀល ,ខ្លះ១០រៀល រួមទាំងអស់បានចំនួន៥០រៀល ។ ឯមនុស្សទោសជាតិខ្មែររាប់រយនាក់បានមកឱបរឹតខ្ញុំនឹងរកតែផ្លូវចេញមិនរួច ។ មានខ្លះបានស្រែកថា ៖ នេះ



ចំជាខ្មែរដៃឆើតមែន ,អាចបំបាក់អាបេបាន ។ ជយោ !ខ្មែរយើង !

និយាយពីលោកស៊ុម អរណាស់គាត់បានទៅសុំអនុញ្ញាតពីមេតម្រួតបារាំងខាងគុកកាប់អុសឱ្យខ្ញុំបានទៅដេកនៅក្រៅគុកមួយយប់ ។ ខ្ញុំក៏បានមកនៅកន្លែងឡឥដ្ឋជាមួយគាត់ យប់នោះគាត់បានឱ្យពួកបោយគាត់កាប់មាន់បបរទទួលទាន ដោយមានស្រាថ្នាំរបស់គាត់អែបជាមួយទៀត មានមនុស្សទោសជាច្រើនបានរួមទទួលទានបបរជាមួយគ្នា ។ យប់នោះខ្ញុំបានសប្បាយជាមួយគេឯងរហូតដល់ម៉ោង៣ទៀបភ្លឺ ទើបបានសម្រាកទទួលទានដំណេក ។

លុះព្រឹកឡើង ,ខ្ញុំបានលាលោកស៊ុមកាត់ទៅលេងនឹងកាប៉ូរ៉ាល់ខាត់ ឯចំការដាំដំឡូង ។ គ្រាន់តែក្រឡេកឃើញខ្ញុំទៅដល់ភ្លាម ,បងខាត់ស្ទុះមកឱបខ្ញុំហើយពោលថា បងមិនបានដឹងថាប្អូនឯងចេះដាល់សោះ ទើបតែពីយប់នោះ បងក៏ទៅមើលនឹងគេដែរ,ដំបូងពួកយួនវាទាយថាប្អូនឯងស៊ូនឹងអាបេមិនបានមួយទឹកទេ ,មុខជាក្អួតឈាមស្លាប់ហើយ ។ ដល់សម្រេចសម្រួលទៅមានឯណា ? ប្អូនឯងដាក់វាដួលទាល់តែក្រោកមិនរួច,ស្រាប់តែពួកអាយួនទាំងអស់បាត់មាត់ឈឹងដូចគេចុកតែម្ដង ។ ឥឡូវនេះ ប្អូនឯងល្បីឈ្មោះហើយនៅលើកោះនេះ ពីព្រោះតាំងពី៧ឆ្នាំកន្លងមកហើយ គ្មានជាតិខ្មែរណាម្នាក់បំបាក់អាបេបានទេ វាឈរឈ្មោះជាជើងឯករហូតមក ។

នៅថ្ងៃនោះ ,បងខាត់ព្រមទាំងសហការីរបស់គាត់ខាងដាំដំឡូងបាននាំគ្នាចាប់មាន់,ទាធ្វើម្ហូបយ៉ាងច្រើនជប់លៀងខ្ញុំជាកិត្តិយសដល់ជ័យជំនះរបស់ជាតិខ្មែរ នៅកោះត្រឡាច ។ ខ្ញុំក៏មានចិត្តសប្បាយរីករាយក្រៃលែងរកកល់ភ្លេចខ្លួនថាមនុស្សទោសទៅទៀត ដោយហេតុអ្នកដែលទៅរួមប្រជុំទទួលទានជាមួយគ្នានោះ សូម្បីតែជាតិយួនក៏នាំគ្នានិយាយតែពីជ័យជំនះរបស់ខ្ញុំដែរព្រមទាំងសរសើរពីស្នៀតប្រដាល់របស់ខ្ញុំថាវិសេសវិសាលណាស់ ដែលគេមិនធ្លាប់បានឃើញដូច្នេះដល់ម្ដងណាសោះ ។ ខ្ញុំនៅលេងជាមួយមិត្តទាំងនេះរហូតដល់ពេលល្ងាច,ទើបត្រឡប់ទៅចូលគុកខាងកាប់អុសវិញ។ នៅឆ្នាំ១៩៤២ដែលខ្ញុំបានទៅដល់កោះត្រឡាចខ្ញុំបានដំណឹងថាមនុស្សទោសនៅក្នុងឆ្នាំនោះមានជាង៦.០០០នាក់ ចំណែកឯអ្នករដ្ឋការជាតិបារាំង,យួន , ខ្មែរជាទាហាន

វិញមានចំនួន៥០០នាក់យ៉ាងច្រើន ។

ព្រឹកឡើងទៀត មានតម្រួតម្នាក់កាន់សំបុត្រពីក្រសួងសម្ងាត់ មកកោះហៅខ្ញុំឱ្យចូលខ្លួនទៅ ។ ខ្ញុំក៏ដើរតាមតម្រួតនោះទៅកាន់ទីចាត់ការនៃក្រសួងសម្ងាត់នោះ កាលចូលទៅដល់ ,លោកទូសទូ ជាចាងហ្វាងមិននៅទេ ។ លុះចាំបន្តិចទើបឃើញលោកមកដល់ លោកញញឹមមកកាន់ខ្ញុំហើយសួរថា ឯងចង់មកនៅក្រសួងសម្ងាត់ទេ ? ខ្ញុំឆ្លើយជម្រាបលោកថា តាមតែលោកមេត្តាឱ្យខ្ញុំបាទធ្វើអ្វីក៏ខ្ញុំបាទធ្វើដែរ ! លោកងក់ក្បាលញញឹម ហើយឡើងទៅឯមន្ទីរចាត់ការបាត់ទៅ ។ លុះលោកត្រឡប់មកវិញក៏ឱ្យមនុស្សម្នាក់នាំខ្ញុំទៅកាន់កន្លែងធ្វើការនៅក្រសួងសម្ងាត់នោះទៅ ។ ទីនោះមិនមែនជាគុកទេ គឺជាកន្លែងដែលមានសង់ផ្ទះតូចៗជាច្រើន ។ ខ្ញុំនឹកឃើញពាក្យដែលមិត្តខ្ញុំគេនិយាយប្រាប់ពីដំបូងនោះ ជីវភាពខ្ញុំត្រូវចូលមកជាក្រុមសម្ងាត់ ហើយគេឱ្យមនុស្សទោសនៅតាមសេចក្តីស្ម័គ្រ គឺនៅម្នាក់ឯងក៏បាន ពីរនាក់ក៏បានតាមការស្រុះស្រួលគ្នាឯងចុះ ។ ដាំស្លតាមចិត្តរៀងៗខ្លួនមានរបស់ទទួលទានគ្រប់គ្រន់ មិនសូវខ្វះខាងអ្វីឡើយ ។ ឯមុខងារធ្វើគឺរក្សាមនុស្សទោសកុំឱ្យរត់ពីកោះត្រឡាចទៅស្រុកវិញបាន ។ ប៉ុន្តែបើមានមនុស្សទោសរត់បាត់ឬយ៉ាងណា ,ក្រុមសម្ងាត់ត្រូវទទួលរុករកតាមដានឱ្យទាល់តែឃើញវិញ ។ បើប្រសិនជារកមិនឃើញ,ត្រូវចៅហ្វាយនាយជេស្តីបន្ទោសយ៉ាងខ្លាំងដែ ។

និយាយពីមនុស្សទោសនៅលើកោះនោះ,តាំងពីដើមមកទល់ពេលដែលខ្ញុំទៅដល់ មានលបធ្វើក្បូនដោយឈើគីដើមគរ,ស្តង់,ឫស្សីជាដើម ហើយនាំគ្នារត់នៅពេលម៉ោង១៥ល្ងាច នារដូវចូលឆ្នាំចិន,ដោយហេតុនៅពេលនោះត្រូវលើខ្យល់បក់បោកនៅដីគោកឥណ្ឌូចិន ចំជ្រោយកាម៉ៅតែប្តូង ។ បើរត់ខុសខែមិនចំលើរដូវចូលឆ្នាំចិនទេ,ក្បូននឹងរសាត់តាមខ្យល់ទៅឯស្រុកសៀមឬទៅឯហ្វីលីពីនទៅវិញ នាំឱ្យយូរពេលវេលាហើយអស់ទឹករស់អាហារនឹងបណ្តាលឱ្យស្លាប់ទាំងអស់គ្នាលើក្បូនក៏មាន ។ ជួនណាប្រទះលើកប៉ាល់សមុទ្រវាស្រង់យកទៅឱ្យបារាំងវិញក៏មាន ។

នៅឱកាសដែលខ្ញុំទៅដល់ ,មនុស្សទោសបែកប្រាជ្ញាធ្វើទូកដោយសំពត់អោរាវដែលរដ្ឋការ



បើកឱ្យ ។

ខ្ញុំសូមអធិប្បាយរឿងនេះជូនបន្តិច ។ កាលពីឆ្នាំ១៨៣៥ មនុស្សទោសដែលរត់គោងធ្វើទូកដោយក្តារលាបជ័រម្រ័ក្ស ដូចជាទូកយើងធម្មតា ។ ដល់មកឆ្នាំ១៨៤០,ពួកអ្នកទោសនយោបាយមានចំណេះវិជ្ជាជ្រៅជ្រះបាននាំគ្នាធ្វើទូកតាមវិទ្យាសាស្ត្រ គឺគេយកសំពត់ខោអាវ ដែលរដ្ឋការបើកឱ្យ,ប្រមូលគ្នាបាន៤-៥នាក់ ហើយទិញខោអាវក្រៅថែមពីរសម្រាប់ទៀតគ្រប់គ្រាន់ហើយ គេយកខោអាវនោះទៅកាត់រួចដេរប៉ះភ្ជាប់ឱ្យស្អាតត្រឹមត្រូវហើយ ,គេយកផ្តៅដំបង៤-៥ដើមកាត់ប្រវែង៣ម៉ែត្រហើយចងផ្តោបគ្នាខាងចុង និងខាងដើម គេយកឈើទន់កណ្តាលឱ្យប៉ោងឡើងដូចជារាងទូកធម្មតា ទើបគេយកសំពត់ពាសពីខាងក្រៅរាងផ្តៅដំបងនោះដោយចងឱ្យជាប់មាំហើយ គេយកជ័រម្រ័ក្សលាបខាងក្នុងនិងខាងក្រៅឱ្យសព្វ ។ គេកាប់ឫស្សី៧-៨ដើមប្រវែង១-៧ម៉ែត្រដោយរើសយកតែឫស្សីដើមត្រង់ៗយកទៅចងផ្តោបនឹងតួទូកទាំងសងខាងឱ្យត្រឹមស្មើនឹងក្បាលទូក ហើយទុកឱ្យសល់វែងនៅខាងចុង គឺខាងកន្សៃទូក សម្រាប់ទប់ទល់នឹងរលកកុំឱ្យបក់មកត្រូវខ្លាំងពេក ព្រមទាំងកុំឱ្យឃ្លោងផង ។ គេយកដើមឫស្សីពីរណាត់ទំហំប៉ុនកដៃ ធ្វើដងក្តោងនិងយកជួយធ្វើស្លាបក្តោង ។ ទូកនេះចំណុះបានតែ៤-៥នាក់យ៉ាងច្រើន ។ ឯស្បៀងអាហារគេធ្វើនំអន្សមសម្រាប់ទទួលទានបានពីរថ្ងៃប៉ុណ្ណោះ ។ ជួនណាយកបាយទៅហាលបម្រុងទុកដែរ ។ ឯទឹកសាបគេដាក់ក្នុងប៉ោតប្រេងកាតដោយផ្សារមាត់ឱ្យជិតខ្លាចក្រឡុកកំពប់អស់ គេចោះតែរន្ធតូចមួយរួចស៊កឫស្សីពកទៅក្នុងនោះ សម្រាប់បឺតបន្តិចម្នាក់ៗនៅពេលត្រូវការដោយប្រុងប្រយ័ត្នបំផុត ខ្លាចក្រែងខ្យល់បក់មិនស្រួល មិនបានដល់ត្រើយក្នុងរវាងពីរថ្ងៃ នាំឱ្យមានគ្រោះថ្នាក់ដល់ជីវិត ។ នៅពេលដែលបានចេញផុតពីច្រាំងចំនួន១០ម៉ោងហើយ,បើទុកជាយកកាណូតយ៉ាងលឿនទៅដេញតាមក៏មិនទាន់ដែរ ត្បិតទូកនោះលឿនណាស់តាមរលកធំៗប៉ុនភ្នំដែលបោកបក់ជូនតៗទៅ ។ ឯរដូវដែលរត់បានគឺខែទី១និងទី២,តែដល់ខែទី៣,គេមិនហ៊ានរត់ទេក្រែងរត់មិនរួចដោយខ្យល់បក់វិលចុះឡើងមិនទៀងទាត់ ។ ក្នុងការរត់នេះគេប្រយ័ត្នបំផុតមិនឱ្យដឹងដល់គ្នាច្រើន

ខ្លាចបែកការណ៍ ។ កាលេជិនាន់ឆ្នាំ១៩៣០ គេរត់ដោយក្បូនដែលគេរេបហោក់ធ្វើដោយឈើឬដោយឫស្សីទុកបម្រុងលើភ្នំ លុះដល់ពេលរត់ទើបសែងមកដាក់ទឹកតែម្តង ។ ប៉ុន្តែការធ្វើក្បូនត្រូវប្រើពេលយូរថ្ងៃទើបហើយ ជាហេតុនាំឱ្យបែកការណ៍ដឹងដល់ពួករ៉ីសេក (recherече) ។

នៅកោះត្រឡាចក្រុមសម្ងាត់មានការប្រុងប្រយ័ត្នខ្លាំងណាស់ គឺយាមទាំងយប់ទាំងថ្ងៃនៅដើមឆ្នាំចាប់ពីខែមករាទៅដល់ខែមីនា ត្បិតជារដូវដែលមានខ្យល់ល្អសម្រាប់ឱ្យមនុស្សទោសអាចរត់បាន ។ ក្រៅពីរដូវនេះ អ្នកទោសពុំហ៊ានរត់ទេ ។ បើគេដឹងថាមនុស្សទោសរត់ហើយគេឱ្យដំណឹងទៅក្រុមសម្ងាត់ភ្លាមដើម្បីឱ្យស៊ើបរុករកចាប់ បើរកចាប់មិនបានទេ ត្រូវទទួលទោសយ៉ាងធ្ងន់ដល់ក្រុមសសម្ងាត់ត្រង់បរិវេណដែលខ្លួនត្រូវយាមថែរក្សា។ ឯក្រុមសម្ងាត់ដែលមានទោសនេះត្រូវគេបញ្ជូនទៅដាក់គុកងងឹតចំនួន២០ថ្ងៃយ៉ាងតិច ។ ផុតពីនេះ ត្រូវបញ្ជូនទៅក្នុងគុកធម្មតាទៀតជាហេតុនាំឱ្យមនុស្សទោសឯទៀតស្អប់ខឹងនឹងខ្លួនថែមទៀតដោយដឹងថា ខ្លួនជាក្រុមសម្ងាត់ហើយគេធ្វើទុក្ខធ្វើបាបមិនឱ្យបានសុខគឺគេប្រើឱ្យថែរក្សាបង្គន់ ,បង្ខំឱ្យអាស្រ័យលាមកដែលជាទារុណកម្មយ៉ាងព្រៃផ្សៃ។ ជួនណាគេវាយទាល់តែសន្លប់ឬស្លាប់ក៏មានគឺគេសម្គាល់ថាខ្លួនជាសត្រូវរបស់គេនាំឱ្យគេពិបាករត់ ហើយនិងសម្គាល់ថា ខ្លួនជាអ្នកយកការពីគេឱ្យរដ្ឋការ ។ ម្ល៉ោះហើយពួកគិញទាំងអស់មានការប្រុងប្រយ័ត្ន ខ្លួន ជាទីបំផុត,ខ្លាចក្រែងមានគ្រោះថ្នាក់ដល់ខ្លួន ។ បើប្រសិនជាមានរឿងចូលទៅក្នុងគុកជាមួយមនុស្សទោសឯទៀតនោះកម្រនឹងបានមកវិញណាស់ ។

ចំណែករបៀបរត់តាមបែបថ្មីនោះ មិនសូវដែលបែកការណ៍ដល់ពួកគិញទេ ត្បិតគេបានប្រុងប្រៀបឧបករណ៍សម្រាប់ធ្វើទូកជាមុនស្រេច ទើបគេធ្វើដូចបានអធិប្បាយខាងលើ ។ លុះគេធ្វើក៏ឆាប់ហើយចំនួនប្រហែលមួយថ្ងៃប៉ុណ្ណោះ ក៏នាំគ្នារត់តែម្តង ហើយពួកគិញក៏ពិបាករកដោយគ្មានដានថារត់ផងគឺគ្រាន់តែស្មានថា ប្រហែលជារត់ហើយ នៅវេលាដែលបាត់ខ្លួន ។ តាមក្រុមសម្ងាត់និយាយប្រាប់ខ្ញុំថា ទើបតែប្រហែលមួយខែមុនខ្ញុំទៅដល់ទេ ដែលរដ្ឋការគេឱ្យសង់ផ្ទះតូចៗរាយគ្នាតាមមាត់សមុទ្រចម្ងាយពីរ-បីគីឡូម៉ែត្រពីគ្នាជុំវិញកោះ ការពារពុំឱ្យមានមនុស្សរត់រត់រួចដូចមុនៗទៀតបាន ។



# -១០-

# ជីវភាពនៅតំបន់ជីកយុក

នៅកន្លែងសម្ងាត់បានចំនួន២០ថ្ងៃ លោកធំទូសទូមកហៅខ្ញុំឱ្យទៅធ្វើការកន្លែងមួយផ្សេងទៀតឈ្មោះ Guérêt យួនហៅថា*ជីកយុក* ជាកន្លែងដាំដំណាំគ្រប់យ៉ាង ដូចជាដូង,អំពៅ,សាម្បាត់,ខាត់ណា,ជីរគ្រប់មុខ,ម្នាស់,ក្រូចឆ្មារ ។ល។ កន្លែងនោះនៅលើខ្នងភ្នំឆ្ងាយពីទីក្រុងប្រហែល១២ឬ១៣គីឡូម៉ែត្រ បើឡើងពីជើងភ្នំក្រោមទៅដល់លើកំពូលភ្នំតាមផ្លូវលំ ដែលមានចម្ងាយ៣គីឡូម៉ែត្រនោះត្រូវដើរនោះប្រហែល៣គីឡូម៉ែត្រទៀត ទើបដល់កន្លែងដាំដំណាំ ។ នៅនោះឥតមានជនស៊ីវិលម្នាក់ទេគឺមានសុទ្ធតែមនុស្សទោសចំនួន៣០នាក់ជាអ្នកដាំចំការ។លោកទូស-ទូ បានតម្រូវឱ្យខ្ញុំធ្វើកាប៉ូរាល់ត្រួតត្រាមនុស្សទោសទាំងអស់នៅទីនោះ។ កន្លែងនោះមានទេសភាពល្អណាស់ប៉ុន្តែពុំមែនជាកន្លែងស្រួលទេ គឺកន្លែងចាញ់ផងប្រកបដោយគ្រោះថ្នាក់ដោយមនុស្សគ្នាឯងផង ដែលសុទ្ធតែជាអ្នកទោសធ្ងន់ និងទោសអស់ជីវិត ដែលពីដើមច្រើនតែជាអ្នកប្រព្រឹត្តចោរកម្ម កាប់សម្លាប់កាចសាហាវឃោរឃៅ ។ ខ្ញុំបានប្រែជីវភាពពីក្រុមសម្ងាត់មកជាអ្នកមើលការខុសត្រូវ (caporal) លើពួកនេះវិញម្តង ។

លុះបានដំណឹងថា នៅទីនេះមិនស្រួល មុននឹងទៅខ្ញុំបានសូមអនុញ្ញាតពីលោកទូសទូដើម្បីរកមិត្តយួនរបស់ខ្ញុំឈ្មោះ *អាន់បាហ* ដែលជាមនុស្សទោសជាន់ចាស់ធ្លាប់ដឹងកន្លុកកន្លៀតច្រើនឱ្យមកនៅជាមួយគ្រាន់ជាជំនួយ ។ ឈ្មោះ*ហ*នេះជាមនុស្សទោសនយោបាយពួកយៀកមិញបានទោស១០ឆ្នាំ តែគេនៅកោះត្រឡាចមុនខ្ញុំពីរឆ្នាំ ហើយបានកាប់អុសជាមួយខ្ញុំ ។ កាលដែលនៅកាប់អុសជាមួយខ្ញុំនោះគាត់មានជំងឺគ្រុនចាញ់ ក៏នៅបែកគ្នារហូតដល់ខ្ញុំដាល់ឈ្នះអាបេ ទើបគាត់កាត់បកជួបនឹងខ្ញុំនៅកន្លែងសម្ងាត់ ។ ឯនៅកន្លែងគាត់ធ្វើការនៅក្នុងក្រុមដាំដំណាំនៅចំការ១ឆ្នាំពីកោះត្រឡាច ។ គាត់មានការពិសោធន៍ច្រើន ។

ក្រោយពីខ្ញុំស្នើសុំឈ្មោះ*ហា* ឱ្យទៅធ្វើការជាមួយខ្ញុំនោះបាន២ថ្ងៃ លោកទូសទូបានឱ្យគេនាំមកកាន់ក្រុមសម្ងាត់នូវឈ្មោះ*ហា* ដែលនាំឱ្យឈ្មោះនេះមានសេចក្ដីភិតភ័យខ្លាចមានរឿងអ្វី ត្បិតគាត់មិនដឹងថាខ្ញុំគាត់មកនៅជាមួយខ្ញុំទេ ។ លុះមកដល់ខ្ញុំបាននិយាយប្រាប់រឿងរ៉ាវទើបគាត់បាត់ភ័យហើយបន្ទោសខ្ញុំថា : បើអ៊ីចឹងក៏មិនប្រាប់ពីមុនកុំឱ្យគ្នាភ័យ ។ ឈ្មោះ*ហា* បានមកនៅជាមួយខ្ញុំ ។ គាត់បានពន្យល់ខ្ញុំថានៅទីនោះជាទីចាញ់ផង ប៉ុន្តែមិនជាអ្វីទេត្បិតយើងដឹងការមុនហើយយើងអាចប្រុងប្រយ័ត្នខ្លួនបាន ។

លុះព្រឹកស្អែកប្រហែលម៉ោង៨ លោកទូសបាននាំខ្ញុំនិងឈ្មោះ*ហា* ធ្វើដំណើរដោយជើងរហូតទៅដល់ភ្នំហើយឡើងភ្នំទៅទើបទៅដល់ផ្ទះកាប៉ូរ៉ាល់ដែលត្រួតចំការ ។ លុះបានឱ្យវាយរគាំងនិងហៅមនុស្សទោសទាំងអស់មកជួបជុំហើយ លោកទូសទូក៏បាននិយាយប្រាប់ក្រុមនោះថាលោកបានចាត់ឈ្មោះប៊ុណ្ណចន្ទ ម៉ុល ឱ្យមកធ្វើកាប៉ូរ៉ាល់នៅទីនេះ ដើម្បីឱ្យចម្រើនកិច្ចការខាងដំណាំអ្នកទាំងអស់ត្រូវខំធ្វើការក្រោមការបង្គាប់កាប៉ូរ៉ាល់ថ្មីនេះឱ្យម៉ត់ចត់ ។ ល្ងីកណាបើឈ្មោះប៊ុណ្ណចន្ទ ម៉ុល ប្ដឹងគាត់ថាឈ្មោះណាមួយរឹងទទឹងមិនស្ដាប់បង្គាប់ទេ គាត់នឹងចាប់អ្នកនោះទៅបញ្ចូលគុកភ្លាម៖ហើយគាត់សួរថាស្ដាប់បានទាំងអស់គ្នាហើយ? ក្រុមនោះឆ្លើយថាស្ដាប់បានហើយ ! រួចពីនោះគាត់ក៏ត្រឡប់ទៅវិញខ្ញុំបានជូនដំណើរគាត់រហូតដល់ជើងភ្នំទើបគាត់លាខ្ញុំទៅលោកទូសទូមានមាឌធំដំបង មុខលោកសម្បើមគួរឱ្យមនុស្សទោសគ្រប់គ្នាខ្លាចណាស់ ។

ឯក្រុមនោះក៏បានរៀបបាយទឹកទទួលខ្ញុំដែលជាកាប៉ូរ៉ាល់ថ្មី ដោយម្ហូបចំណីយ៉ាងសម្បូរព្រោះកន្លែងនោះសម្បូរគ្រឿងក្លែមស្រាប់ផង ហើយមានមនុស្សទៅបំរើដាំស្លជាប់ពីកាប៉ូរ៉ាល់មុនមកផង ។ ផ្ទះដែលនៅនោះជារបៀបផ្ទះតៀមទទឹង៨ម៉ែត្រ បណ្ដោយ១២ម៉ែត្រមានពីរបន្ទប់ប្រក់ស្បូវជញ្ជាំងស្បូវតែទ្វារពីមុខធ្វើក្ដារស្រឡៅយ៉ាងស្អាត ។ ផ្ទះបាយដោយខ្លួនប្រក់ស្បូវជញ្ជាំងស្បូវដូចគ្នា ។

និយាយពីទេសភាពកន្លែងនៅដិកយុក នោះមានទំហំដីចំនួនប្រហែលជាង៣០ ហិកតាមានដើមចេកនិងដូងច្រើនណាស់ ។ មានភ្នំថ្មនៅពីខាងក្រោយកំពស់ប្រហែល ៤០០ ម៉ែត្រ



ហើយមានភ្នំខ្សាច់នៅមុខកំពស់ប្រហែល៣០ម៉ែត្រ ប្រវែងប្រហែល២គីឡូម៉ែត្រ ។ ចុះទៅខាងឆ្វេងមានព្រែកមួយវែងដែលរដូវភ្លៀងហូរធ្លាក់ចូលទៅក្នុងសមុទ្រ ។ ប៉ុន្តែដល់ខែប្រាំងវិញព្រែកនោះក៏រីងទឹកហើយសម្បូរត្រីទឹកសាបណាស់ ដូចជាត្រីរ៉ស់ ត្រីក្រាញ់ ត្រីអណ្ដែង ស្រីស្លាត ។ល។ កន្លែងដិកយុក នោះដូចជាពាក់កណ្ដាលខ្លះដែលដល់រដូវវស្សាមានខ្យល់បក់មកពីសមុទ្រយ៉ាងខ្លាំងទៅប៉ះនឹងភ្នំថ្មខាងក្រោយហើយវិលត្រឡប់ទៅកាន់សមុទ្រវិញ គឺគួចវិលអើវិលមកតែដូច្នេះឯង ។ លើភ្នំនោះ មានដើមឈើធំៗដុះច្រូវច្រាងពាសសពេញភ្នំ មើលទៅខៀវស្រងាត់ ។ ចំណែកភ្នំខ្សាច់វិញ,មើលទៅសមុទ្រឃើញទឹកខៀវស្រស់គួរឱ្យសប្បាយរីករាយ ។ តាមមាត់សមុទ្រដីខ្សាច់សស្គុសមើលទៅដូចស្ករស ឬអំបិលសដូច្នេះឯង ។

ក្រោយពេលបាយ ខ្ញុំបានសួរពត៌មានពីអ្នកបម្រើម្នាក់ជាតិយួន ។ យួននោះឈ្មោះ*ស្មៀង-វី* ជាពួកកៅដាយជាប់ចោទពីបទនាំបះបោរប្រឆាំងនឹងបារាំង ។ វាបានប្រាប់ថា នៅកន្លែងនេះគ្មានអ្វីជាការលំបាកប៉ុន្មានទេ ត្បិតកាប៉ូរ៉ាល់មុនគេបានរៀបចំចែកមុខការរួចស្រេចហើយ គឺក្នុងមនុស្សទោសម្នាក់ៗឱ្យកាន់កាប់ថែរក្សាដំណាំចំនួន២៥រង ។ ឯដំណាំអ្វីៗស្រេចនៅលើកាប៉ូរ៉ាល់គេបញ្ជាឱ្យដាំ ចំពោះគ្រាប់ពូជបន្លែគេមានទុកបម្រុងស្រាប់ ។ រីឯចំការចេក គេចាត់ឱ្យម្នាក់ថែរក្សាពីរហិកតា ។ ចំណែកខាងចំការដូងឥតមានចាត់ឱ្យថែរក្សាទេ ។ ឯមនុស្សទោស១០ឬ១២នាក់គេទុកបម្រុងសម្រាប់ធ្វើកិច្ចការផ្សេងៗ សម្រាប់ឱ្យកាប់គាស់រានព្រៃចំនួន៤-៥ ហិកតាទុកបម្រុងដាំត្រម្សាច ល្ពៅនៅរដូវភ្លៀងតាមត្រូវការ ។ នៅកន្លែងដិកយុកនេះដីមានជីជាតិល្អណាស់ ពីព្រោះដីតែងតែហូរទម្លាក់ពីលើភ្នំមកលើដីទំនាបទាំងអស់នោះ,សូម្បីនៅខែប្រាំងក៏ដីនោះនៅសើមៗដែរ ។ គេជីករណ្ដៅងជម្រៅចំនួន១ម៉ែត្រកន្លះអាចចេញទឹកកន្លះម៉ែត្រហើយមិនចេះរីង ។ មនុស្សចំនួន១០នាក់ដែលនៅផ្ទះ៧-៨ខ្នង ប្រើទឹកតែអណ្ដូងមួយប៉ុណ្ណោះបានយ៉ាងគ្រប់គ្រាន់ឥតខ្វះខាតអីកឡើយ ។ ទឹកនោះថ្លាស្អាតបានឱជារសពិសាឥតភ្លាវឡើយ រអាចដាំហើយឆុងតែបានយ៉ាងមានឱជារសផង ទៀត ។ នៅកន្លែងនោះមានអាកាសត្រជាក់ណាស់ ដោយនៅរដូវវស្សាមានភ្លៀងធ្លាក់មិនដាច់ ជួនណាភ្លៀងជាប់៣ថ្ងៃ៣យប់ក៏មាន ជាហេតុនាំឱ្យត្រជាក់ស្រើតៗព្រឺឆ្អឹងខ្នង ទៅជា

ស្រៀវគ្រុន ។ ឯជំងឺគ្រុនចាញ់បណ្ដាលមកពីអាកាសត្រជាក់ផងមកពីខ្យល់វិលវល់នោះផងកពីមូស ដែកគោលខាំផង ។ គេត្រូវប្រយ័ត្នណាស់នៅកន្លែងនោះ ប៉ុន្តែមនុស្សទោសគ្នាមិនដឹងបានអីប្រយ័ត្នទេបើមុងក៏គ្មានថ្នាំសង្កូវក៏គ្មាន ។ គ្នាត្រូវតែផ្សងតាមយកថាកម្មស្លាប់អង្កាល់ក៏ស្លាប់ទៅ ។

ខ្ញុំទៅនៅជិតដីកយុក បាន២០ថ្ងៃក៏ចាប់មានជំងឺគ្រុនចាញ់ឡើង ។ មុនដំបូងស្រៀវគ្រុនឈឺក្បាល រហូតដល់គ្រុនខ្លាំងរហូតដល់ដោះទុក្ខសត្វតូចធំនៅនឹងកន្លែងដោយងើបដើរទៅណាមិនរួច គ្មានសង្ឃឹមថាបានរស់រានមានជីវិតត្រឡប់មកស្រុកវិញបានឡើយ ។ ពេលមួយនោះខ្ញុំប្រឹងប្រែងជំនះនឹងចិត្តដើរទៅបត់ជើងនៅខាងក្រៅផ្ទះដើរបានតែ២_៣ជំហាន ស្រាប់តែវិលមុខងងឹតមុខដួលប្រុសទៅដីដោយមិនដឹងខ្លួនសោះហើយឥតនរណាដឹងសោះ ។ ជួនពេលនោះអ្នកដាំបាយក៏មិននៅបងហក៏មិននៅ ។ ប្រហែលមួយម៉ោង ទើបបងហត្រឡប់មកពីរកថ្នាំឬសឈើវិញបានឃើញខ្ញុំដួលនៅដី គាត់ភិតភ័យលើកគ្រាហ៍ខ្ញុំនាំចូលទៅក្នុងបន្ទប់វិញ ។ សូមជម្រាបថាខ្លួនខ្ញុំពេលនោះស្គុយចេញពីខ្លួន ស្គមនៅតែឆ្អឹងរគាម បាយបបរអ្វីក៏ទទួលទានមិនកើត ។ មិត្តហបានទៅរកឬសឈើព្រៃមកដាំឱ្យទទួលទាន ព្រមទាំងលេបគីណាគ្រីនដែលលោកទូសទូទុកឱ្យ ១០គ្រាប់ផងក៏បានធូរគ្រាន់បើអស់រយៈមួយខែទើបជា ។ មិត្តហបាននិយាយប្រាប់ខ្ញុំថាគាត់មិនស្មានថា ខ្ញុំបានជាឡើយ ។ មែនហើយខ្ញុំក៏នឹកស្មានយ៉ាងនោះដែរ ។ ការរស់នៅនេះគឺ រស់ដោយសារគុណបុណ្យមាតាបិតាជួយជ្រោមជ្រែងឱ្យមានជីវិតមិនឱ្យស្លាប់ ។

លុះខ្ញុំបានជាស្រួលបួលឡើងវិញហើយ ទើបមិត្តហគាត់បាននិយាយប្រាប់ខ្ញុំថា នៅកន្លែងយើងសព្វថ្ងៃនេះមាន មនុស្សទោសក្បាលខូច៤_៥នាក់ ជាមេរឹងរូសប្រឆាំងនិងកិច្ចការដែលបានដាក់ឱ្យធ្វើ នាំឱ្យមនុស្សឯទៀតយកតម្រាប់តាមមានឈ្មោះ*អាន់ បាឌិក* និងឈ្មោះ*ទ្រីវ៉ាង* ជាដើម ។ ពួកវានេះ ដូចជាសត្វខ្លាដំបងសុទ្ធតែមានទោសឧក្រិដ្ឋដល់អាយុទាំងអស់គ្នា ដោយជាប់ចោទពីបទលួចប្លន់ និងធ្វើមនុស្សឃាត ។ ខ្លួនវាបានសាក់ខ្មៅងងឹតពេញខ្លួន ពីកជើងដល់ក ។ មានសាក់ជារូបនាគនៅដើមទ្រូង ។ ឯពោះវាសាក់រូប ខ្លាដំបងមើលទៅគួរឱ្យខ្លាចណាស់ ។ ភ្នែកវាឡើងក្រហមបើសម្លឹងយូរៗ ទៅដូចជាមិនមែនជាមនុស្សទេ ខ្ញុំបានសុំឱ្យបង ហ ជួយដោះ



ដោះស្រាយបញ្ហានេះ ។ គាត់ក៏បានឆ្លើយថាត្រូវតែធ្វើយ៉ាងម៉េចកុំឱ្យមនុស្សទុច្ចរិតប៉ុន្មាននាក់នេះនៅកន្លែងនេះបាន ។ បើយើងមិនកំចាត់វាទេយើងនៅកន្លែងនេះពុំបានសុខឡើយ ។ មុនដំបូងខ្ញុំគិតថាត្រូវតែប្ដឹងឱ្យលោកទូសទូសូមឱ្យផ្លាស់វាចេញពីទីនេះ ត្បិតវាជាមនុស្សអាក្រក់នាំបះបោរ ប៉ុន្តែមិត្តហប្រាប់ថាធ្វើដូច្នេះទៅ បើលោកទូសទូមិនរវល់ចាត់ការតាមយើងសុំ ត្រឡប់ទៅជាថាយើងមិនចេះធ្វើការ ធ្វើការប៉ុណ្ណឹងមិនកើត យើងនឹងអាក្រក់ទៅវិញ ។ មិត្តហឱ្យយោបល់ថា ត្រូវឱ្យខ្ញុំធ្វើការវាយ៉ាងណា ឱ្យក្ដៅដៃបំផុតដើម្បីបំបាត់វាឱ្យបាក់ស្បាត់តែម្ដងឱ្យខ្លាចខ្ញុំរាប!ទាំងពួកវាទាំងពួកមនុស្សទោសឯទៀតផង ព្រោះខ្លួនខ្ញុំក៏ធ្លាប់ល្បីឈ្មោះជាអ្នកកីឡាជើងឯក គេខ្លាចស្រាប់ហើយ ។ ដល់ជំនុំគ្នារកឧបាយឃើញហើយ ទើបខ្ញុំចាត់បងហឱ្យទៅកាប់ចេកនៅចំការបាន២ស្ទងយកទៅដាក់ទុកក្បែរផ្ទះពួកវានោះក្នុងវេលាយប់ ព្រមទាំងយកខោអាវពីរសម្រាប់និងប៉ោតប្រេង-កាតទទេ១ទៅជាមួយផងត្បិតនៅផ្ទះពួកវានៅខាងក្រោយឆ្ងាយជាព្រៃភ្នំញឹកថែមទៀតជាការងាយស្រួលនឹងធ្វើកលល្បិច។

លុះកន្លងបានមួយថ្ងៃ អ្នកយាមចំការចេកបានមកប្ដឹងថាមានចោរលួចចេកបាត់ពីរស្ទងធំៗពីរយប់មិញ ។ ខ្ញុំបញ្ជាគេឱ្យវាយរគាំងប្រជុំពួកមនុស្សទោសទាំងអស់នៅមុខផ្ទះខ្ញុំដើម្បីឱ្យជួយរកចេកនោះ ។ ខ្ញុំបានឱយខ្មែរក្រោមម្នាក់ចាំប្រែភាសាខ្មែរជាយួនឱ្យពួកនោះទាំងអស់ស្ដាប់ ។ ខ្ញុំថាឥឡូវមានចោរលួចចេកពីរស្ទងនៅចំការ តាមស្មានទៅមិនមែនចោរពីណាក្រៅ ពីក្រុមយើងឡើយ ។ ខ្ញុំមិនមកនៅទីនេះ៣ខែហើយមិនដែលធ្វើអ្វីឱ្យព្រួយបារម្ភណ៍ដល់បងប្អូនឡើយ ទើបតែពេលនេះមានកើតចោរកម្មនៅបរិវេណកន្លែងយើង ។ ហេតុនេះខ្ញុំត្រូវការរកមុខចោរលួចនោះឱ្យឃើញ ។ បើបងប្អូនណាបានជាជ្រុលលួចទៅហើយសុំនិយាយតាមត្រង់ចុះ ។ បើមិនដូច្នេះទេ តែបើខ្ញុំរកឃើញរបស់ដែលបាត់នោះនៅក្នុងផ្ទះក្ដី ក្រៅផ្ទះរបស់បងប្អូនណា ខ្ញុំនឹងសុំធ្វើទោសផ្ទាល់ដៃខ្ញុំតែម្ដង ហើយកុំថាខ្ញុំកាចឱ្យសោះ!ខ្ញុំសួរថាស្ដាប់បានទេ ? ពួកទាំងនោះឆ្លើយគ្រប់គ្នាថាបាទស្ដាប់បានហើយ!ខ្ញុំក៏ប្រកាសតទៅទៀតថា ៖ ខ្ញុំសុំទុកពេលឱ្យ១០នាទី សម្រាប់គិតឱ្យវែងឆ្ងាយបន្តិច ប៉ុន្តែបើគ្រប់១០នាទីហើយគ្មានបងប្អូនណាទទួលសារភាពទេ ខ្ញុំនឹងចាត់ការទៅតាមច្បាប់ !

១០នាទីកន្លងទៅ ខ្ញុំចាត់ឱ្យមនុស្សទោសទាំងអស់បំបែកគ្នាជាបួនក្រុម ទើបខ្ញុំចាត់ឱ្យក្រុម

ណានៅខាងកើត ឱ្យទៅរកទិសខាងលិច ។ ក្រុមខាងលិចឱ្យទៅរកខាងកើត ។ ក្រុមខាងត្បូងឱ្យទៅរកខាងជើង ។ ឯក្រុមខាងជើងឱ្យទៅរកខាងត្បូងវិញ ។ ខ្ញុំថា ក្នុងរយៈពេលពីពីរទៅ៣ម៉ោង ត្រូវនាំដំណឹងមកប្រាប់ខ្ញុំវិញ ។ ក្រោយពេលដែលបានចាត់ឱ្យទៅអស់ហើយ ហើយខ្ញុំនៅរង់ចាំទទួលលទ្ធផល ។

ប្រមាណជាជាងពីរម៉ោង នៅវេលាដែលក្រឡេកឃើញជនពីរនាក់ ដើរយ៉ាងលឿនសំដៅមកផ្ទះខ្ញុំ ខ្ញុំក៏ក្រោកឡើងទទួល ។ គេនិយាយប្រាប់ខ្ញុំថា ឃើញចេកនោះ ហើយព្រមទាំងមានខោអាវពីរសម្រាប់និងប៉ោតប្រេងកាតមួយផង លាក់នៅក្រោយផ្ទះអាន់បាឱក ចំនួនប្រហែល ១០០ម៉ែត្រ ។ ឮដូច្នេះ ខ្ញុំក៏ទៅជាមួយអ្នកពីរនាក់នោះទៅដល់ទីកន្លែង ក៏បានឃើញច្បាស់នឹងភ្នែកមែន ។ ទើបខ្ញុំប្រើគេឱ្យរត់ទៅវាយគងប្រជុំគ្នាជាប្រញាប់ ។ ប្រហែលមួយម៉ោងក្រោយគឺម៉ោង១១ថ្ងៃត្រង់ ដែលជាវេលាជិតដល់ពេលបាយ នៅពេលមនុស្សទោសជួបជុំហើយបានប្រកាសថា : ថ្ងៃនេះនៅក្នុងបរិវេណយើង មានមនុស្សទោសមានបំណងចង់ធ្វើទូករត់ ។ ហេតុនេះ ខ្ញុំសុំបងប្អូនជួយកិច្ចការនេះឱ្យស្រេច ។ ឥឡូវនេះសុំទៅតាមខ្ញុំទាំងអស់គ្នា ។ ខ្ញុំនាំអ្នកទាំងនោះទៅផ្ទះឈ្មោះឱក ។ ខ្ញុំសួរទៅឈ្មោះឱកថា ផ្ទះនេះជាផ្ទះនរណា ? ឈ្មោះ ឱកឆ្លើយថា ផ្ទះរបស់ខ្ញុំ ! ខ្ញុំសួរតទៅទៀតថា បងឯងមានលួចចេកពីរស្ទង ព្រមទាំងសំពត់អាវនិង ប៉ោតទេ ? ឈ្មោះនេះឆ្លើយថា ឥតបានលួចទេ ។ ខ្ញុំនាំសាមីខ្លួន ព្រមទាំងអ្នកឯទៀតទៅកន្លែង នោះហើយចង្អុលទៅវត្ថុទាំងនោះហើយសួរថាជារបស់អ្នកណា ? វាឆ្លើយថាមិនមែនរបស់វាទេ ! ខ្ញុំក៏បញ្ជាឱ្យមនុស្សទោសឯទៀតជញ្ជូនរបស់ទាំងនោះទៅឯផ្ទះខ្ញុំវិញ ។ ខ្ញុំបង្គាប់ឱ្យទាំងអស់គ្នាឈរតម្រៀបជាពីរជួរទើបខ្ញុំហៅឈ្មោះឱកឱ្យចេញមកឈរចំពោះមុខខ្ញុំ ។ ទើបខ្ញុំសួរដោយទន់ភ្លន់មុនដំបូងថា : ឱកឯងនិយាយឱ្យត្រង់មកចុះ ខ្ញុំមិនធ្វើបាបអ្វីទេ ឱកឯងដឹងស្រាប់ហើយ ខ្ញុំចូលចិត្តតែមនុស្សល្អ មិនចូលចិត្តមនុស្សរាក្រកវិង្វេសដាក់ខ្ញុំទេ ខ្ញុំចូលចិត្តធ្វើល្អនឹងមនុស្សគ្នាឯងណាស់ តែខ្ញុំសុំឱ្យឱកឯងនិងបងប្អូនទាំងអស់ស្តាប់សក្តីខ្ញុំឱ្យច្បាស់ តែបានមនុស្សមើលងាយខ្ញុំឬប្អូនរករឿងហេតុនឹងខ្ញុំនោះ ខ្ញុំលែងខ្លាចអ្នកនោះហើយព្រោះហាំងសង្ឃារ៉េថាមនុស្សនោះជា



សត្រូវនឹងខ្ញុំថែមទៀត ! ហើយខ្ញុំក៏ឈប់គោរពរាប់អានអ្នកនោះតទៅទៀត ទុកឱ្យគេធំតែម្នាក់ឯងទៅចុះ ។ ពេលនេះខ្ញុំសុំឱ្យបងឱកឯងប្រាប់ឱ្យត្រង់មកមើល តើខ្លួនបម្រុងនឹងធ្វើទូករត់មែនទេ ? មានបក្សពួកខ្លួនប៉ុន្មាននាក់ ? ឈ្មោះណាខ្លះ ? សុំឱកឯងប្រាប់ឱ្យត្រង់មក វាឆ្លើយបដិសេធថា ពុំបានធ្វើទូកបម្រុងរត់ទេ ! ខ្ញុំសួរបន្ថែមទៅទៀតថា បើដូច្នេះម្តេចក៏មានចេក សំពត់អាវ និងប៉ោតនៅក្រោយផ្ទះខ្លួន ? ឱ្យខ្ញុំជឿដូចម្តេចកើត ! វាឆ្លើយបដិសេធដដែល ។ ខ្ញុំក៏ដើរចូលទៅជិតហើយពោលបន្ថែមចុងក្រោយថា ប្រាកដជាគ្មានមែនឬ ? រួចខ្ញុំក៏ដាល់មួយដៃភឹបត្រង់ដើមទ្រូងវារួចប្រាប់ថាឆ្លើយឱ្យត្រង់មក ! វានៅតែប្រកាន់ពាក្យមុនថាទេ ទេដដែល ។ តាមពិតវាមិនដឹងមែនប៉ុន្តែខ្ញុំត្រូវបង្ក្រាបវាឱ្យហើយ កុំឱ្យវាបះបោរទាន់ ខ្ញុំក៏ដាក់ថែមមួយដៃទៀតត្រង់ថ្គាម វាក៏ដួលនៅដីហើយស្រែកអង្វរខ្ញុំ ខ្ញុំក៏ទាត់ថែមមួយជើងចំមុខទៀតរមៀលពីរបីត្រឡប់ ។ ខ្ញុំហៅឱ្យក្រោកឈរឡើង លុះក្រោកឡើងក៏សំពះក្រាបក្បាលដល់ដីដោយពោលថា អត់ទោសកាប៉ូរ៉ាល់ខ្ញុំអត់ធ្វើដូច្នេះទេហើយឥតបក្សពួកទេ ។ ជាការបដិសេធរបស់វា ដែលធ្វើឱ្យខ្ញុំមានកំហឹង ខ្ញុំដាល់ថែមមួយដៃទៀតចំមុខ ចេញឈាមរ៉ាវពីមាត់ពីច្រមុះដួលទៅដីម្តងទៀត ។លុះវាក្រោកឈរឡើងតាមបង្គាប់ខ្ញុំម្តងទៀត ខ្ញុំក៏ចូលទៅជិតវារួចយកដៃទាំងពីរទៅទាញក្បាលមកជិត ហើយខ្ញុំលើកជង្គង់បុកចំកណ្តាលដើមទ្រូងនិងចំមុខវាថែមម្តងទៀត ។ លើកក្រោយនេះអាឱកដួលលែងងើបរួចតែម្តង ដេកផ្ងារពោះនៅកណ្តាលចំណោមមនុស្សទាំងនោះ ។ ទើបខ្ញុំនិយាយដោយកំហឹងខ្លាំងៗថា : នៅក្នុងចំណោមអ្នកទាំងអស់គ្នានេះ នៅមានបក្សពួកអាឱកទៀត ប្រយ័ត្នណា ! ។ បងប្អូនឃើញច្បាស់នឹងភ្នែកស្រាប់ហើយ មិនគួរបើខ្ញុំដែលជាអ្នកទោសដូចបងប្អូនដែរ ហើយទៅវាយដំបងប្អូនអ្នកទោសដូចគ្នាយ៉ាងនេះសោះ ។ នេះមកពីឈ្មោះឱកមិនព្រមឆ្លើយត្រង់ប្រាប់ខ្ញុំ ! ហេតុនេះ ខ្ញុំត្រូវតែធ្វើឱ្យដឹងដៃខ្ញុំ ដែលខ្ញុំមកត្រួតត្រានៅទីនេះគឺលោកទូសទូមេក្រសួងសម្ងាត់លោកចាត់ខ្ញុំមកដើម្បីរក្សាសេចក្តីរៀបរយ ការពារកុំឱ្យមានមនុស្សទោសធ្វើទូករត់ឥឡូវឈ្មោះឱកបានបំពារបំពានប៊ិនធ្វើទូកក្នុងបំណងរត់ទៅដីគោក តើឱ្យខ្ញុំអត់ឱនដូចម្តេចបាន ? ឥឡូវខ្ញុំសម្រេចចិត្តត្រូវបញ្ជូនឈ្មោះឱកទៅជូនលោកធំ តាមតែលោកសម្រេចយ៉ាងណាទៅចុះ ហេតុនេះសុំបងប្អូនបំបែកជួរទៅបាយទឹកចុះ ប៉ុន្តែសុំយកឈ្មោះឱកទៅចងដៃជើងទុកមួយអន្លើសិនចាំព្រឹកស្អែកសឹមបញ្ជូនទៅក្រុង !

លុះស្អែកឡើង ខ្ញុំបានធ្វើសេចក្តីរាយការណ៍បញ្ជូនឈ្មោះឱកទៅកាន់ទីក្រុងកោះត្រឡាច។ ឈ្មោះឱកត្រូវគេចងជើងដៃដូចសត្វជ្រូកហើយមនុស្សទោសបួននាក់សែងទៅជារបៀបសែងជ្រូកដែរ ព្រមទាំងរបស់ទាំងអស់ គឺចេកពីរស្ទូង ខោអាវនិងប៉ោត ដើម្បីជាភស្តុតាង ។ លុះទៅដល់ក្រសួងសម្ងាត់ ក្រឡេកឃើញដូច្នេះ លោកទូសទូបានចុះពីលើផ្ទះមកសួរខ្ញុំថា មានរឿងអ្វី ? ខ្ញុំក៏ជម្រាបលោកវិញតាមដំណើរដែលឈ្មោះឱកមានគម្រោងការធ្វើទូកបម្រុងរត់ តែដោយខ្ញុំដឹងការណ៍ ក៏បំណងរបស់វាពុំបានសម្រេច ។ ខ្ញុំបានទៅចាប់វា ហើយវាចង់តដៃនឹងខ្ញុំ គឺចង់ចាក់ខ្ញុំវិញ ។ លោកងក់ក្បាលរួចទទួលពាក្យពីខ្ញុំ ក៏ដើរឡើងទៅលើទីចាត់ការ ។ ក្រោយនោះបន្តិចឃើញមានសំបុត្រមួយច្បាប់ចេញមកបង្គាប់ឱ្យយកអាឱកទៅទុកឯគុកលេខ៧ ដែលជាកន្លែងធ្វើទារុណកម្មធំបង្អស់នៅកោះត្រឡាច ។ ខ្ញុំនឹកថាគ្រោងការរបស់ខ្ញុំបានសម្រេចហើយ រួចខ្ញុំត្រឡប់ទៅចាំលោកធំទូសទូឯផ្ទះលោក ដើម្បីជម្រាបពីបក្ខពួករបស់អាឱកដែលនៅសល់បន្ថែមលើសេចក្តីរាយការណ៍ ឱ្យរឹតតែច្បាស់ឡើងទៀត ។ នៅវេលាដែលលោកអញ្ជើញមកដល់ផ្ទះនៅវេលាម៉ោង១១កន្លះខ្ញុំក៏បានរៀបរាប់សព្វគ្រប់ បន្ថែមលើលិខិតជាលាយលក្ខណ៍អក្សរទៀតដោយសុំឱ្យលោកចាត់ឱ្យទៅចាប់បក្ខពួកវាឈ្មោះទ្រីវ៉ាំងទៀត ។

កន្លងមកបាន៤ថ្ងៃ ខ្ញុំបានឃើញក្រុមសម្ងាត់ពីរនាក់ទៅចាប់ឈ្មោះទ្រី វ៉ាំង ។ ឈ្មោះនេះបានសំពះខ្ញុំ សុំឱ្យជួយធ្វើអន្តរាគមន៍ឱ្យវាផង ខ្ញុំឆ្លើយថា ខ្ញុំអាណិតបងឯងណាស់ ប៉ុន្តែធ្វើម៉េចបើមានអាជ្ញាពីលោកធំមក ឱ្យចាប់យ៉ាងនេះ ។

សូមជម្រាបថា ខ្មែរយើងអ្នកកាន់ព្រះពុទ្ធសាសនា តែងតែមានធម៌មេត្តាជានិច្ច ប៉ុន្តែនេះជាបញ្ហាស្លាប់រស់របស់ខ្ញុំផ្ទាល់ ខុសពីរឿងធម្មតា នឹងទុកសត្រូវតទៅទៀតពុំបាន ត្រូវតែកម្ចាត់សត្រូវជាមុន កុំឱ្យវាបានសម្រេចតាមគោលបំណងអាក្រក់របស់វាមកលើយើងបាន ។ មុននឹងប្រើឧបាយកលនេះ ខ្ញុំបានគិតហើយគិតទៀតទម្រាំបានសម្រេចចិត្តថាត្រូវតែធ្វើយ៉ាងណាឱ្យពួកនេះខ្ចាតចេញពីកន្លែងខ្ញុំ ។ ម្យ៉ាងវិញទៀតពួកឃ្លុនធ្វើស្លូតរកវានោះ វាឥតយោគយល់យើងទេ វារឹតតែសាហាវយោរយៅដាក់យើងថែមទៀត យើងនឹងរងគ្រោះថ្នាក់ដោយសារវាមិនខាន ។ ម្យ៉ាងទៀតពួកវាទាំងនេះ ជាមនុស្សសាហាវ មិនដឹងជាវាបានប្លន់កាប់សម្លាប់គេរស់ប៉ុន្មានរួចទៅហើយទេ ទម្រាំតែចាប់យកមកឱ្យនៅទីនេះបាននោះ ។ ពួកទាំងនេះបែងពានចិត្តគំនិតអ្វីជា



មនុស្សសូម្បីតែបន្តិចសោះហើយ ។ យើងមើលតែសញ្ញាដែលវាសាក់ឆ្លាក់ជាប់នឹងសាច់វាតាំងពីរជើងដល់ក្បាលនោះ ក៏អាចយល់បានណាស់ទៅហើយ ។ វាសាក់ជារូបខ្លាដំបងនៅពោះវា គឺវាពិតជាចង់តាំងខ្លួនវាជាខ្លាដំបង ។ បើវាជាខ្លាដំបងហើយវាគ្មានស្គាល់មនុស្សទេ ។ ហើយចំពោះខ្ញុំវិញ ដែលត្រូតត្រាវានោះវាចាត់ទុកដូចជារំពាវាស្រេចទៅហើយ ដែលចាំតែមានឱកាសល្អ វាក៏នឹងលោត្របាក់បង្ហើយជីវិតទៅតែប៉ុណ្ណោះ ។ ឯនៅលើដើមទ្រូងវា វាសាក់ឆ្លាក់សាច់ជារូបនាគ គឺវាបានប្រកាសប្រាប់ភ្នែកមនុស្សជាស្រេចហើយថា វាជានាគរាជ វាជាសត្វមានពិសអស្ចារ្យ ដែលមនុស្សត្រូវតែខ្លាច ត្រូវតែរន្ធត់ ។ ដូច្នេះវាលែងមានលក្ខណៈជាមនុស្សហើយ ។ វាជាសត្វយ៉ាងសាហាវបំផុត ។

ព្រោះហេតុតែដូច្នេះ ទើបខ្ញុំត្រូវថែរក្សាពួកវាដែលមានចិត្តសាហាវដូចខ្លាដំបងមានពិសដូចពស់វែកនោះទុកនៅឱ្យនៅទាល់តែវាទះក្បាលយើង ចឹកយើងសម្លាប់នោះទេ ។ ត្រូវតែធ្វើឱ្យវាបាក់ស្បាតមុនឱ្យហើយ ឱ្យវាខ្លាចចុះញ៉មឱ្យហើយ ទើបយើងបានសេចក្តីសុខឥតព្រួយបារម្ភអ្វី ។ ឯការងារដែលត្រូវធ្វើនៅកន្លែងចំការនោះ ក៏ប្រព្រឹត្តទៅដោយបានចម្រើនល្អតលាស់ជាងមុនដោយឥតមាននរណាហ៊ានបង្អាក់បង្ខូចកិច្ចការរបស់ខ្ញុំឡើយ ។ លុះឃើញខ្ញុំធ្វើការបានចម្រើនជាងពីជំនាន់កាប៉ូរ៉ាល់មុន ទើបលោកទូសទូលោកពេញចិត្តបានសរសើរខ្ញុំថា ធ្វើការបានល្អ ។ ព្រមទាំងបានផ្តល់ឱ្យខ្ញុំនូវតែ កាហ្វេ ស្ករស ទឹកដោះគោកំប៉ុង ទឹកដោះគោស្រស់ ដែលជារបស់កម្ររកបានទៅទីនោះ ហើយនៅទីនោះគេហាមឃាត់មិនឱ្យមនុស្សទោស មានរបស់ទាំងនេះបរិភោគទេ ប៉ុន្តែដោយអំណាចលោកទូសទូស្រឡាញ់រាប់អានខ្ញុំដោយស្មោះ បានជាខ្ញុំមានសិទ្ធិបរិភោគរបស់កម្រនេះ ។ មួយទៀតលោកធំនេះបានបង្គាប់ឱ្យខ្ញុំចិញ្ចឹមមាន់ និងក្ងានជាច្រើន គឺមាន់ប្រហែល២០០ ក្ងាន៣០ ។ ក្នុងមួយអាទិត្យលក់ពងមាន់ម្តង បានចំនួន១០រៀល ឬ១៥រៀល យកទៅជូនលោកតាមចំនួនពងមានតិចច្រើន ។ ពងមាន់១០លក់បាន២រ.២៥ ឯមេមាន់មួយតម្លៃពី៤រ៥០ទៅ៥រ ។ នៅពេលចង់បរិភោគសាច់មាន់ លោកបង្គាប់បោយឱ្យមកសុំខ្ញុំចាប់យកមាន់មួយឬពីរទៅ ។ ក្នុងមួយខែលោកបើកស្រូវឱ្យពីរបាវរៀងរាល់ខែទុកឱ្យមាន់អាស្រ័យ ។

ឯចំណែកអ្នកទោសនយោបាយជាតិយួនច្រើនគ្នា ក៏តែងរាប់អានខ្ញុំក្នុងចំនងយកចិត្តទុកដាក់ណាស់ ។

ក្នុងចំណោមនោះមានសាស្ត្រាចារ្យម្នាក់ ដែលជាប់ទោសខាងនយោបាយដែរ រាប់អានខ្ញុំណាស់ គាត់ជាអ្នកចេះគូររូបផង ។ គាត់បានគូររូបខ្ញុំ ឱយខ្ញុំទុកជាអនុស្សាវរីយ៍ ។ រូបនោះគូរលើក្រដាសស្តើង មិនគួរនឹងរក្សាបានយូរទេ ប៉ុន្តែដោយចិត្តខ្ញុំស្រឡាញ់រូបនោះ ដែលខ្ញុំកំពុងស្ថិតនៅដ៏សែនឆ្ងាយពីទឹកដីកំណើត និងឆ្ងាយពីមាតាបិតាបងប្អូន យ៉ាងដាច់ស្រយាលលន្លង់លន្លោចនោះខ្ញុំក៏ចេះតែខំរក្សាថ្នាក់ថ្នមរូបគំនូរនោះរហូតមក លុះគ្រាតែបានយកមកផ្តិតនៅលើទំព័រទី៩៣នៃសៀវភៅនេះជូនអស់មិត្តបានឃើញនេះឯង !

នៅនោះ ខ្ញុំរស់នៅដោយស្រួលសុខសប្បាយដូចមិនមែនជាមនុស្សទោសឡើយ ។ ខ្ញុំមានមនុស្សទោសខាងក្រុមសម្ងាត់៨នាក់នៅក្រោមបង្គាប់ខ្ញុំ ដែលនៅយាមតាមមាត់សមុទ្រហើយជាអ្នកនេសាទត្រីផង គេយកត្រីមកឱ្យខ្ញុំមិនដែលខាន ។ មនុស្សទាំងនេះបានសង់ខ្ទមតូចៗនៅតាមមាត់សមុទ្រនិងតាមជើងភ្នំ ។ គេដាក់លបនិងដើរឆ្លុះត្រីនៅពេលយប់ដោយគប់ភ្លើង ដែលធ្វើដូចជាចន្លុះដូច្នេះ ។ ការឆ្លុះត្រីនេះធ្វើបានតែខែងងឹត បើខែភ្លឺឆ្លុះមិនកើតទេ ។ សូមជម្រាបថាគេដើរឆ្លុះប្រហែលពីរបីម៉ោងប៉ុណ្ណោះអាចចាប់ត្រីបានយ៉ាងច្រើន រហូតដល់នាំទៅលក់ឯទីក្រុងកោះត្រឡាចទៀត ប៉ុន្តែបើមានខ្យល់បោកបក់រលកខ្លាំងក៏រកមិនសូវបានដែរ បានគ្រាន់តែល្មមទទួលទានតែគ្នាគេនោះដែរ ។ យប់មួយ ខ្ញុំបានធ្វើការពិសោធន៍ ចុះទៅសមុទ្រ រកត្រីជាមួយគេដែរ ។ ដៃឆ្វេងកាន់គប់ភ្លើងដៃស្តាំកាន់ស្នផ្លែបី មានកន្ត្រកមួយមានខ្សែពីរស្ពាយពីក្រោយខ្នងផង នៅវេលាយប់ប្រហែលម៉ោង២០ឬ២១ ពេលដែលរលកស្ងប់ហើយស្ងាត់ផង ជាការស្រួលដល់ការដើរនេសាទបានស្រួល ។ លុះដើរឆ្លុះបន្តិចទៅខ្ញុំឃើញត្រីស្តង់មួយហែលសំដៅមករកឃើញភ្លើង ។ ខ្ញុំភ័យផងអរផងដោយមួយជីវិតនេះខ្ញុំមិនដែលឆ្លុះត្រីឡើយខ្ញុំខំប្រឹងស្មារតីឱ្យនឹងនរ ទើបខ្ញុំចាក់និងស្នតម្រង់ទៅចំខ្នងវាហើយលើកឡើងខ្ញុំបំបែរ ដងស្នចុះទៅក្នុងទឹកហើយយកក្បាលជង្គង់ទាំងពីរគាបដងស្ននោះឱ្យជាប់ ទើបយកដៃស្តាំទៅដោះត្រីដាក់ក្នុងកន្ត្រករួចហើយក៏ដើរទៅមុខទៀត ។

មិត្តជ្រាបទេ ? បើមិនចេះវិធីក្នុងការនេសាទនេះ និងមានគ្រោះជាទម្ងន់ ។ បើមិនចេះ



គូរនៅថ្ងៃទី១៦-០៦-៤៣ នៅកោះត្រឡាច,កាត់ទោសដាក់គុក៥ឆ្នាំធ្វើការដោយបង្ខំនិងនិរទេស ១៥ឆ្នាំមិនឱ្យចូលស្រុកខ្មែរ(ចម្លងចេញពីចំណាងជើងរូបថតនេះដែលសរសេរតាំងពីនៅកោះត្រឡា)

នេសាទ ជួនណាចាក់ទៅលើត្រីបបែលេ ដល់យើងប្រូកដៃទៅដោះខ្លួនវាពីស្នូស្រាប់តែកន្ទុយវាវាត់មកចាក់ត្រូវដៃ ឬសាច់ត្រង់ណាទៅជាចុកចាប់ប្រៀបបាននឹងពិសពស់វែកដូច្នេះឯង ប៉ុន្តែមិនស្លាប់ទេ គ្រាន់តែសម្លប់បាត់ស្មារតីក៏មាន ។ ហេតុនេះអ្នកនេសាទ បើគេរកបានត្រីល្មមគួរ-សមហើយ គេមិនរវល់នឹងត្រីបបែលេឡើយ ទោះបីប្រទះឃើញមានច្រើនក៏ដោយពីព្រោះពិបាកនឹងចាប់វា ។ ប្រសិនបើចាក់វាបានត្រូវនាំវាទៅលើគោកយកកាំបិតកាត់កន្ទុយវាដែលមានពិសចេញសិនទើបគេដោះខ្លួនវាចេញពីស្នូ ។ រីឯសាច់បបែលេយកទៅស្លម្ជូរស្លឹកទ្រម្ទូង ឬស្លឹកសណ្តាន់បង់ម្រេះព្រៅឬម្អមព្រមទាំងគ្រឿងគ្រៅទៅវាមានឱជារសឆ្ងាញ់ជាងត្រីរស់យើងទៅទៀត ។

ក្រុមសម្ងាត់៨នាក់សុទ្ធតែជាអ្នកនេសាទ គេដាក់វេនគ្នាឱ្យសាច់ត្រីខ្ញុំរៀងរាល់ថ្ងៃ ពីព្រោះនៅកន្លែងឃាមនោះ ឥតមានធ្វើការអ្វីឡើយជាហេតុនាំឱ្យមនុស្សទោសជាច្រើនប្រាថ្នាចង់ទៅនៅកន្លែងនោះ គេយកត្រីមកឱ្យខ្ញុំជាធម្មតា ទើបបានខ្ញុំដឹងថាជាទម្លាប់របស់គេពីមុនមកដូច្នេះឯង ដែលគេធ្លាប់ខ្លាចកាប៉ូរ៉ាល់ប្តឹងឱ្យផ្លាស់ចេញពីកន្លែងនោះ ។

ដល់ពេលទឹកសមុទ្រជោរឡើងធំម្តង១ ពួកមនុស្សទោសបានមកសុំច្បាប់ខ្ញុំទៅរកចាប់ត្រីទឹកសាបក្នុងព្រែកមួយក្នុងចន្លោះភ្នំថ្មនិងភ្នំខ្សាច់ ដែលមានទឹកសមុទ្រជោរឡើងចូលទៅក្នុងព្រែកនោះជាហេតុនាំឱ្យទឹកសាបលោតឡើងលើទៅនៅផ្តុំគ្នាមីរត្រង់កន្លែងទឹកធ្លាក់ ដែលមានប្រវែងចំនួន៥ម៉ែត្រ ដែលវាពុំអាចទៅមុខទៀតបាន។គេទៅដល់កន្លែងនោះយកមងទៅក្បៀរត្រីទាំងនោះឡើងគោករួចគេចាប់ដាក់ប៉ោតប្រេងកាត ដាក់ធុងស្រោចដំណាំកុំឱ្យវាឆាប់ស្លាប់ហើយយកទៅព្រោះទុកក្នុងពាងឯផ្ទះ ទុកទទួលទានបានពី១០ទៅ១៥ថ្ងៃ ។ ត្រីនោះមានគ្រប់មុខប៉ុន្តែត្រីដែលអាយុវែងជាងគេគឺត្រីអណ្តែង និងត្រីក្រាញ់ ។ ដល់រដូវភ្លៀងត្រីទឹកសាបមិនសូវមាននៅក្នុងព្រែកនោះទេសំបូរតែត្រីសមុទ្រ ។

លុះរដូវប្រាំងគេនាំគ្នាបណ្តើរឆ្កែទៅរកសត្វត្រកួតឬទន្សាយ ។ ឯឆ្កែវាបោលទៅរុករកមុនកាលេណាឮសូរឆ្កែព្រុះពួកគេ៤-៥នាក់ ក៏រត់តម្រង់ទៅកន្លែងនោះ ដើម្បីចាប់ទាំងរស់ឬបាញ់នឹងស្នា ។ បើមានពេលទំនេរគេនាំគ្នាដាក់អន្ទាក់យកមាន់ព្រៃដែលនៅនោះមានសំបូរណាស់ ។ មាន



ថ្ងៃនោះ ពួកអ្នកទាក់មាន់ព្រៃទៅប្រទះឃើញពស់ថ្លាន់មួយធំប្រហែលប៉ុនភ្លៅមនុស្សចាស់ ប្រវែងប្រហែលជា៣ម៉ែត្រក៏នាំគ្នាចាប់ពស់នោះមកធ្វើអាហារបរិភោគទៅ ។ ជួនណាគេនាំគ្នាទៅរកសត្វស្វា សត្វឆ្មាព្រៃ ។ រូបរាងឆ្មាព្រៃដូចឆ្មាស្រុកបេះបិទ តែធំធាត់ជាង ។ ចំណែកសាច់សត្វស្វាគេយកមកធ្វើម្ហូប មានរ៉ូទិទឹកដូងជាដើម ។ ដើម្បីធ្វើរ៉ូទិគេយកទឹកដូង ទៅដាំរម្ងាស់ឱ្យរីងបន្តិចយកសាច់ស្វាដែលគេធ្វើរួចស្រេច បង់ទៅក្នុងនោះហើយរម្ងាស់ថែមតទៅទៀត ។ ទើបគេបង់គ្រឿង បន្លែ គឺប៉េងប៉ោះ ,ការុត,ខ្ទឹមស,ខ្ទឹមក្រហមអំបិល ,ទឹកត្រី ហើយរំងាស់យូរបន្តិចទៅទៀត គេរៀបសាឡាដ១ចានធំដើម្បីបរិភោគជាមួយសាច់ស្វានោះមានឱជារសឆ្ងាញ់ណាស់ ។ ឯសាច់ឆ្មាព្រៃក៏គេយកមកធ្វើម្ហូបបរិភោគដូចគ្នានឹងសត្វស្វាដែរ ។ ចំណែកឯក្បាលស្វាវិញ គេធ្វើឱ្យស្អាតហើយយកទៅធ្វើបបរជាមួយសណ្តែកបាយ ។ លុះផុយសណ្តែកបន្តិចហើយ គេយកទៅហាលទឹកសន្សើមមួយយប់សម្រាប់ឱ្យមនុស្សកើតហឺតហឺតឬរីងរៃស្គមក្តៅខ្លួនទទួលទាន ។ ខ្ញុំសង្កេតឃើញអ្នកមានរោគទាំងប៉ុន្មានប្រភេទខាងលើនេះ បានជាសះស្បើយសមប្រកបបានច្រើនគ្នាមែន ។ ម្យ៉ាងទៀតគេចាប់សត្វតុក្កែមួយឬពីរវាយឱ្យស្លាប់ គេរោលភ្លើងឱ្យរបកស្បែកក្រៅអស់ គេចិញ្ច្រាំសាច់វាឱ្យម៉ដ្ឋហើយផ្សំគ្រឿងបបរជាមួយអង្ករក្រហម ធ្វើតាមរបៀបយើងបបរមាន់ដូច្នោះដែរ ។ បបរឱសថនេះទទួលទានទៅស្រួលខ្លួនអាចរំងាប់មេរោគដូចពោលខាងលើបាន ។ នេះគឺថ្នាំកែរោគតាមរបៀបចិនយួន ដែលពួកគេធ្លាប់ប្រើតាំងពីបុរាណកាលមក ។

នៅជិតយុកកន្លែងមាត់សមុទ្ររដូវរាំងភ្លៀង ពួកមនុស្សទោសតែងនាំគ្នាទៅមើលសត្វល្មេចនៅមាត់សមុទ្រវេលាម៉ោង១៥ល្ងាច ។ សត្វល្មេចមានរូបរាងដូចអណ្តើកដល់ពេលវារៀបពងម្តង១វាតោងឡើងពីទឹកសមុទ្រមកគយគន់រកមើលទីកន្លែងសម្រាប់ពងនៅឆ្នេរខ្សាច់ ដែលមានដុះខ្សាច់ជាពំនូក១រកេតរកួតពាសពេញ ។ សត្វល្មេចវាច្រើនអើតក្បាលពីទឹកនៅវេលាម៉ោង ១៥-១៦ ល្ងាច ។ បើមិនឃើញមានមនុស្សម្នាទេ នៅពេលម៉ោង១៨ព្រលប់វាក៏ឡើងមករកពង ។ ឯពួកមនុស្សទោសនៅពួករង់ចាំឱយសត្វនេះវារកកន្លែងពងបានសិនមិនមានទៅជិតវាទេ ។ លុះវាបានកន្លែងហើយ វាកកាយដីខ្សាច់ធ្វើរណ្តៅដោយជើងមុខជម្រៅប្រហែល៣ឬ៤សង់ទីម៉ែត្រ ទើបវាបែរក្បាលចេញក្រៅរួចទយគូថទៅពងដាក់ក្នុងរណ្តៅនោះ ។ លុះវាពងបានប្រហែលពី១៥ទៅ២០ពងហើយ ទើបពួកនោះស្ទុះទៅជួយកេះកកាយបញ្ចេញពងវាឱ្យចេញមកឆាប់ ។ ក្នុងល្មេចមួយ

វាពងម្តងៗពី២០០ទៅ២៥០ យ៉ាងតិច ។ គេក៏លើកសត្វល្អិតនោះដាក់ឱ្យវាផ្ងារជើងឡើងលើក ដែលនាំឱ្យវាទៅណាមិនរួច នៅតែមួយកន្លែងនោះ ។ រួចគេស្រែកហៅគ្នាឱ្យជួយយកស្មៅមក សែងសត្វនោះទៅធ្វើម្ហូបទទួលទានតាមត្រូវការរៀងៗខ្លួន ។ ស៊ុតវានៅក្នុងរណ្តៅចំនួនពី៣៥ទៅ ៤៥ថ្ងៃទើបញាស់ ។ នៅពេលជិតញាស់ពួកអ្នកទោសនាំគ្នារករបោយគ្រប់មុខមានជី សារាឡាដជា ដើមព្រមទាំងទឹកត្រីបាញ់ហាយមួយដប និងស្រាសពីរលីត្រជាមួយនឹងឆ្នាំងចង្ក្រាន ទៅកន្លែងដែល ល្អិតកប់ស៊ុតនោះ ។ គេយកសំណាញ់បង់ត្រីព័ទ្ធធ្វើរបងជុំវិញកន្លែងនោះ ។ ដល់ពេលស៊ុតទាញាស់បាន ២_៣ម៉ោងអស់ហើយវាវារឡើងមកលើក៏ជាប់ទើរនឹងសំណាញ់ រកទៅណាមិនរួច ។ គេដាំទឹកឱ្យពុះចាំជាស្រេច ទើបគេដាក់ទឹកសាបនិងចានដែកឬឆ្នាំងបាយក៏បាន គេចាប់កូនល្អិតមកលាងក្នុងទឹកត្រជាក់នោះឱ្យស្អាតអស់ដីខ្សាច់ចេញ ហើយគេយកចង្កឹះចាប់កូនល្អិតនោះ១ម្តងៗ ជ្រលក់ទៅក្នុងឆ្នាំងទឹកពុះនោះមួយស្របក់រួចក៏យកមកផ្ជាប់នឹងរបោយ ជ្រលក់ទឹកជ្រលក់បាញ់ហាយទទួលទាន ដោយក្លែមស្រាសបន្តិចផង មានឱជារសឆ្ងាញ់ជាងសាច់មាន់ ទា គោ ទៅទៀត ត្បិតស្នូកវានៅទន់នៅឡើយនៅច្រុបៗផ្អែមឆ្ងាញ់ណាស់ សមត្រូវនឹងស្រាសស្រឿងៗថែមទៀតនាំឱ្យទទួល ទានបានច្រើនណាមួយត្រូវខ្យល់អាកាសសមុទ្រត្រជាក់វេលាថ្ងៃរសៀលទៀតផង នាំសប្បាយភ្លេចសេចក្តីលំបាកវេទនានិងភ្លេចនឹកស្រុកទេស១គ្រាទៅដែរ ។ របៀបទទួលទាននោះ មិនខុសគ្នាពីយើងទទួលទានចារហាន ឬបាញ់ហាយប៉ុន្មានទេ ។

# -១១-

# មរណភាពនៃលោកអាចារ្យហែមចៀវ

នៅកន្លែងឌិកយុកនេះខ្លួនខ្ញុំដូចមនុស្សមានឥស្សរភាពពេញទី អាចបំភ្លេចបាននូវសេចក្តីទុក្ខលំបាកទាំងប៉ុន្មាន ។ ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំនៅតែនឹកស្រមៃ ចំពោះជោគវាសនារបស់ខ្ញុំទៅអនាគត និងអនាគតប្រទេសយើងដែរ ម្យ៉ាងទៀតខ្ញុំនឹកគិតទៅដល់លោកគ្រូអាចារ្យហែមចៀវ លោកនួន ឌួង លោកប៉ាចឈឿន ដែលគេប្រកាសនៅព្រៃនគរថាត្រូវប្រហារជីវិតហើយដែលថាចាំផ្ញើសំណុំរឿងទៅលោកឧត្តមសេនីយប៉េតាំងឯក្រុងប៉ារីស៍ ដើម្បីសុំសព្រាព្រទោសនោះ តើបានស្រាលខ្លះដែរ ឬក៏ត្រូវគេប្រហារជីវិតទៅហើយ ? ខ្ញុំគិតថា បើគេបន្ធូរទោសខ្លះនោះប្រហែលអ្នកទាំង៣នេះមិនស្លាប់ទេហើយប្រហែលជាបានត្រូវគេបញ្ជូនមកកាន់កោះត្រឡាចនេះដែរហើយ។



ខ្ញុំនៅកន្លែងឌិកយុកនេះបានជាង៤ខែ ទើបបានដំណឹងថា លោកអាចារ្យហែមចៀវ លោកនួន ឌួងលោកប៉ាច ឈឿន ត្រូវគេបញ្ជូនមកកាន់កោះត្រឡាចនេះមែន ។ បញ្ជូនមកមួយខែហើយគឺក្នុងខែមិថុនា ១៩៤៣ ។ ខ្ញុំស៊ើបទៅដឹងថាគេដាក់អ្នកទាំង៣ ឱ្យនៅគុកលេខ៤ជាកន្លែងទោសឧក្រិដ្ឋទោសអស់អាយុទាំងអស់គ្នា ។ កន្លែងនោះគេឱ្យអ្នកទោសវិញខ្សែព្រួរ ធ្វើរបស់ផ្សេងៗតាមការបង្គាប់របស់បារាំង ។

កន្លែងគុកទី៤នោះគេហាមដាក់ខាតមិនឱ្យមនុស្សទោសផ្សេង ទៅសាកសួរសុខទុក្ខមនុស្សទោសដែលនៅក្នុងនោះសោះឡើយ ។ ជាហេតុនាំឱ្យពិបាកទាក់ទងគ្នាណាស់ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំក៏ចេះតែខំលបលាក់ផ្ញើរបស់របរទៅជូនលោកទាំង៣នោះបានខ្លះៗដែរ ហើយបានដំណឹងសុខទុក្ខពីទីគុកលេខ៤នោះខ្លះៗដែរដោយសារតែពួកមនុស្ស ទោសដែលគេប្រើឱ្យចេញចូលក្នុងទីនោះម្តងម្កាលគេនិយាយឱ្យពត៌មាន ។

លោកអាចារ្យហែម ចៀវ និងលោកនួន ឌួងនៅក្នុងគុកនោះបាន៦ខែក៏មានរោគាពាធបៀតបៀន ។ លោកអាចារ្យហែមចៀវមានរោគមួលជាខ្លាំង ។ ឯលោកអាចារ្យនួន ឌួងកើតរោគស្ពឹកដៃជើង ។ លោកនួន ឌួងត្រូវពេទ្យចាក់ថ្នាំច្រើនម្ជុលពេក ក៏កើតបូសត្រង់ត្រគាកហើមយ៉ាងធំ ហើយពេទ្យក៏វះយកខ្ទុះចេញយ៉ាងសែនវេទនា ។ ដោយអ្នកទោសនេះមានជំងឺកាន់តែដាបណាស់នោះគេក៏បញ្ជូនយកនៅដាក់មន្ទីរពេទ្យទាំង២នាក់ ។

ខ្ញុំប្រញាប់ទៅសាកសួរទៅមន្ទីរពេទ្យ ក៏ស្លុតចិត្តតែម្តងត្បិតឃើញអ្នកទាំងពីរទុរន់ទុរាណាស់ទៅហើយ ហើយឃើញលោកអាចារ្យហែមចៀវ ធ្ងន់ដាបជាងលោកអាចារ្យនួនឌួងទៅទៀត ។ មើលទៅមានធារទេ... រោគមួលនៅស្រុកកោះត្រឡាចនោះពិបាកព្យាបាលណាស់គ្មានថ្នាំសង្កូវសោះពេទ្យនោះយកតែទឹកសមុទ្រឬទឹកកំបោរសឱ្យផឹកប៉ុណ្ណោះ ។ ខ្ញុំដូចជាបានដឹងមុនស្រេចហើយថាលោកអាចារ្យហែមចៀវមិនបានរស់រានមានជីវិតយូរទេ ។ ខ្លោចចិត្តណាស់ខ្ញុំក៏

បានទៅទាក់ទងនឹងមនុស្សទោសជាកម្មករ ដែលរក្សាពេទ្យនោះឱ្យរវាំងជួយមើលលោកអាចារ្យទាំងពីរផង ។ ខ្ញុំបានឱ្យប្រាក់ទៅពួកមនុស្សទាំងនោះឱ្យគេយកចិត្តទុកដាក់ចំពោះអ្នកជំងឺទាំងពីរ ហើយខ្ញុំបានផ្តាំពួកនោះទៀតថា ប្រសិនបើអ្នកទាំងពីរ នោះស្លាប់ ហើយតម្រូវឱ្យយកទៅកប់នោះ សូមមេត្តាលៃលកកប់ឱយស្រួលបួលផងហើយកុំឱ្យកប់លាយឡំជាមួយអ្នកឯទៀតឱ្យសោះ ។ នៅកោះត្រឡាចមានពេលខ្លះមនុស្សទោសស្លាប់ច្រើនខ្មោចនោះគេយកទៅកប់៥-៦នាក់តែមួយរណ្តៅក៏មាន ។ ខ្ញុំសុំឱ្យគេអនុគ្រោះដូច្នេះព្រោះគិតថា បើលោកគ្រូហែម ចៀវ ឬលោកគ្រូអាចារ្យនួន- ខ្លួង ស្លាប់ទៅនោះខ្ញុំក៏អាចបានដឹងបានស្គាល់នូវផ្នូររបស់លោកតទៅទៀតដែរ ។ កាប៉ូរ៉ាល់ពេទ្យនិងកម្មករពេទ្យក៏ទទួលតាមសំណូមពររបស់ខ្ញុំ ។

ខ្ញុំមកកន្លែងវិញដោយទឹកចិត្តបារម្ភ ។

ក្រោយមកខ្ញុំក៏បានដឹងថា លោកគ្រូអាចារ្យហែម ចៀវបានស្លាប់ទៅហើយ ! ដំណឹងនេះមិនបណ្តាលឱ្យខ្ញុំរន្ធត់ចិត្តអ្វីទេ ព្រោះខ្ញុំដូចជាបានដឹងមុនស្រេចទៅហើយ ប៉ុន្តែសេចក្តីខ្លោចផ្សាស្តាយស្រណោះដ៏ធំធេងរបស់ខ្ញុំចំពោះលោកគ្រូអាចារ្យហែម ចៀវធ្វើឱយទឹកភ្នែកខ្ញុំផុសផុលឡើងរលីងរលោងឥតដឹងខ្លួនតែម្តង ។ ខ្ញុំរលះរលាំងទៅពេទ្យសួរលោកនួន ខ្លួង។ លោកនួន- ខ្លួងក៏ខ្សឹកខ្សួលអួលដើមកនិយាយថា លោកអាចារ្យហែម ចៀវ ខូចពីម្សិលមិញទៅហើយ ហើយពួកពេទ្យក៏ជួយយកចិត្តទុកដាក់ណាស់ដែរ គេជួយរុំសពលោកនឹងកន្ទេលមួយ ហើយរុំក្រមាស្អាតបាតមានខ្សែចងត្រឹមត្រូវ ហើយគេនាំយកសពនោះដាក់រទេះរុញមួយយកទៅបញ្ចុះបាត់ទៅហើយ !

ខ្ញុំកិរិយាធេងធោងធ្ងន់ដោយទម្ងន់ទុក្ខ បានដើបចេញទៅជួបកាប៉ូរ៉ាល់ពេទ្យនោះដើម្បីសូមឱ្យគេជូនទៅមើលផ្នូសពលោកគ្រូដ៏កំសត់នេះ ។

លោកកាប៉ូរ៉ាល់នោះ ក៏ប្រញាប់ជូនទៅមើលកន្លែងបញ្ចុះសពនោះ ។ ផ្នូរនោះគឺនៅលើភ្នំខ្សាច់ក្នុងចំណោមផ្នូររាប់ពាន់ឯទៀត ។ នៅមុខផ្នូរទុគតិនោះមានផ្លាកក្តារតូចមួយសរសេរលេខ១១១៣ ។ លោកកាប៉ូរ៉ាល់បញ្ជាក់ប្រាប់ខ្ញុំថា គេគោរពតាមបណ្តាំខ្ញុំទាំងអស់ គេកប់សពនេះដាច់តែឯងមិនលាយឡំនឹងសពឯទៀតទេ ។



ខ្ញុំឈរទ្រឹងសម្លឹងផ្នូរលោក ដោយទង្គឹះខ្សឹកខ្សួល រួចងើបមើលទៅនាយ ដើម្បីឱ្យខ្សែខ្យល់ដែលបក់មកពីសមុទ្រផាត់មកលើមុខខ្ញុំ ជួយលុបលាងទឹកភ្នែកដែលបានរអិលចុះ...

កន្លងពីរបីថ្ងៃក្រោយមក ខ្ញុំក៏បាននាំអ្នកទោសនៅកន្លែងខ្ញុំបានបីនាក់ឱ្យជួយយកដុំថ្មធំៗល្មមដាក់នៅលើផ្នូរនោះបានប្រមាណជា២០ដុំជាគ្រឿងសម្គាល់ចំណាំទីនោះតទៅ ។

អស់លោកអ្នកទាំងឡាយ !មកដល់ទំព័រនេះ ខ្ញុំយល់ថា អស់លោកអ្នកពិតជាមានមនោសញ្ចេតនា ក្តុកក្តួលរំជួលចិត្តអាណិតលោកគ្រូហែម ចៀវមិនខានសោះឡើយ ដែលលោកស្លាប់ចោលឆ្អឹងនៅលើកោះដ៏សែនឆ្ងាយ លន្លង់លន្លោចយ៉ាងនេះ ។ លោកស្លាប់ព្រោះតែរឿងជាតិខ្មែរ សាសនានិងរដ្ឋខ្មែរតែម៉្យាងប៉ុណ្ណោះ លោកស្លាប់ដោយឯកោគ្មានញាតិគ្មានបងប្អូន មានតែលោកនួន ខ្លួងជាមិត្តប៉ុណ្ណោះ ។

គួរឱ្យខ្លោចចិត្តណាស់ ! លោកនួន ខ្លួងថាលោកគ្រូនេះត្រូវស្លាប់នៅលើភ្លៅគាត់ដែលឈឺដូចគ្នា ។

លោកនួន ខ្លួងថាគាត់បានជួយច្របាច់រឹតជូនលោករហូតដល់ទីបំផុត លោកយកក្បាលលោកមកកើយលើភ្លៅគាត់រួចក៏ផុតដង្ហើមទៅ...

លោកអាចារ្យហែមចៀវ កើតនៅថ្ងៃអង្គារ ខែមាឃ ឆ្នាំ ច គ.ស១៨៩៩ ។ លោកទទួលមរណភាពក្នុងជន្មាយុ៤៥ឆ្នាំ នៅចុងឆ្នាំ១៩៤៣ ថ្ងៃខែ ខ្ញុំពុំបានចាំប្រាកដ ។

លោកគ្រូអាចារ្យហែម ចៀវ មានស្មារតីរឹងណាស់ មុននឹងស្លាប់លោកបាននិយាយនឹងលោកនួន ខ្លួងថា :

«ខ្ញុំមិនខ្លាចសេចក្តីស្លាប់ទេ តែខ្ញុំមកនៅទីកស្តាយត្រង់មិនបានឃើញប្រទេសកម្ពុជាបានឯករាជ្យតែម៉្យាងប៉ុណ្ណោះ» ។

នេះជាសម្តីវីរបុរសនេះជាគតិពេចន៍នៃអ្នកតស៊ូដ៏គួរឱ្យគោរពនិងលើកតម្កើង ។

***

# -១២-

# អ្នកប្រដាល់ជើងឯកនៅកោះត្រឡាច

ខ្ញុំនៅកន្លែងដឹកឃុំបានជាងមួយឆ្នាំ ។ លុះដល់ខែកញ្ញា ១៩៤៣ បានឮដំណឹងថា មានមនុស្សទោសជាច្រើនចំនួន៤០០នាក់ ដែលគេបញ្ជូនមកពីព្រៃនគរ ក្នុងរវាង២-៣ថ្ងៃនេះ ។ ក្នុងចំនួននេះមានឈ្មោះយ៉សាវត្រៀងម្នាក់ និងម្នាក់ទៀតឈ្មោះ យ៉បាតុង ដែលជាអ្នកជើងឯងខាងប្រដាល់យ៉ាងនើតល្បីឈ្មោះក្នុងដែនឥណ្ឌូចិន ។ កាលពីដើមខ្ញុំធ្លាប់បានស្គាល់ជើងប្រដាល់ទាំងពីរនាក់នេះ ដែលបានទៅប្រដាល់នៅក្រុងភ្នំពេញ ក្នុងឱកាសពិធីបុណ្យតាំងតុ ចម្រើនព្រះជន្មវស្សាព្រះករុណា ។ កន្លែងដែលប្រកួតនោះ គេធ្វើត្រង់ដើមអំពិលមួយដើម ក្រោយរោងល្ខោនអ្នកអ៊ុកនៅជិតផ្ទះកំណើតខ្ញុំនៅផ្សារស៊ីឡៃក(មុខវត្តឧណ្ណាលោម)ប្រហែល១០០ម៉ែត្រ ។ កន្លែងនោះឥឡូវនេះគេសង់ផ្ទះថ្មអស់ទៅហើយ ។ ហើយកាលពីឆ្នាំ១៩៣៨ខ្ញុំបានទៅមើលការប្រកួតគ្នាឯបាត់ដំបង រវាងអ្នកប្រដាល់ទាំងពីរនេះនិងជាតិសៀមមកពីបឹងកក ។ ខ្ញុំមានការកោតសរសើរស្ញប់អ្នកទាំងពីរនោះថែមទៀត ។ កាលជំនាន់នោះ នៅស្រុកខ្មែរយើងក៏មានអ្នកកីឡាប្រដាល់ជើងឯក១ដែរដូចជាឈ្មោះមៀច ចន ,ដោយឆាយ ឆេងជាដើម ។ ឯដោយឆាយ ឆេងពេលនោះជាសិស្សរបស់ខ្ញុំដែលបានហាត់វិជ្ជានេះនៅវាលមេរុវាល់ល្ងាច រហូតដល់ខ្ញុំមានរឿងទៅនៅកោះត្រឡាចតែម្តង។ដោយឆាយឆេង ក្រោយមកក្លាយខ្លួនទៅជាអ្នកជើងឯកអន្តរជាតិខាងប្រដាល់នៅឥណ្ឌូចិនក្នុងឆ្នាំ១៩៤១-១៩៤២ហើយបានកាត់ទៅដាល់នៅហាណូយនិងព្រៃនគរជាដើម ។

នៅពេលដែលដឹងថា អ្នកកីឡាទាំងពីរមកដល់កោះត្រឡាចហើយ ,ខ្ញុំនឹកបារម្ភក្នុងចិត្តថាម្តងនេះអញពិបាកស៊ីវាហើយពីព្រោះសុទ្ធតែជើងឆើត១របស់ជាតិយួនតែម្តង។ លុះដេកគិតដើរគិតសព្វគ្រប់ទៅ ខ្ញុំក៏ចាត់បងហ ទៅស៊ើបសួរពតិមានពីអ្នកទាំងពីរនេះ តើនៅកន្លែងណា សព្វថ្ងៃនេះ



និងឱ្យសួរដំណើររឿងរ៉ាវរបស់វា តើមានរឿងអ្វី គេកាត់ទោសប៉ុន្មានឆ្នាំ ? ជាប់គុកបានប៉ុន្មានឆ្នាំហើយ ? លុះទៅស៊ើបការឯក្រុងកោះត្រឡាចបានមួយយប់មួយថ្ងៃ ទើបបងហត្រឡប់មកវិញហើយផ្តល់ពតិមានថា : ពួកនេះបារាំងចាប់ដាក់គុកចំនួន៦ខែមកហើយ គេវាយវាខ្លាំងណាស់ដោយចោទថាវាជាពួកកៅដាយប្រឆាំងនឹងបារាំង ។ រូបរាងវានៅសមសួនជាអ្នកមានកម្លាំងពលំបរិបូណ៌នៅឡើយ ។ សព្វថ្ងៃវានៅគុកលេខ៥ធ្វើការនៅរោងម៉ាស៊ីនភ្លើង ។ ឮដូច្នេះខ្ញុំគិតថា នៅថ្ងៃណាមួយខ្ញុំនឹងទៅលបមើលពួកនេះឱ្យឃើញច្បាស់នឹងភ្នែកមិនខាន ។

ស្តាប់ថ្លែងពីពួកយួនវិញ គេនាំគ្នាដើរឃោសនាថាម្តងនេះអាន់បាម៉ុល(១) ពិបាកស៊ីអ្នកកីឡាពីរនាក់នេះហើយ ! ដោយហេតុអ្នកទាំងពីរនេះជាកីឡាជើងឯកនៃប្រទេសឥណ្ឌូចិន ជាតិយួនយើងមុខជានឹងបានជ័យជំនះវិញមិនខាន ។ ពួកជាតិយួនជាមនុស្សទោស និងស៊ីវិលដែលខ្ញុំបានជួបតែងតែសាកសួរខ្ញុំថាម៉េចអាន់បាម៉ុលម្តងណេះមានផ្លូវឈ្នះអ្នកកីឡាថ្មីពីរនាក់នោះទេ ?ព្រោះអ្នកទាំងពីរនេះជាជើងឯកនៅព្រៃនគរនរណាក៏ដឹងស្គាល់ដែរ ។ខ្ញុំឆ្លើយថាចំណែកខ្លួនខ្ញុំវិញមិនហ៊ានអារកាត់ទេ ត្បិតមិនទាន់បានសមដៃគ្នាមើលនៅឡើយប៉ុន្តែឱ្យខ្ញុំសុំចាញ់មុនការប្រយុទ្ធនោះសុំទោសទៅចុះខ្ញុំមិនព្រមចាញ់ទេ។មានមេតម្រួតជាតិយួនជាច្រើននាក់បាននិយាយនឹងខ្ញុំថា គេអាណិតខ្ញុំណាស់ខ្លាចក្រែងស្លាប់អសារឥតការ ឱ្យខ្ញុំសុំញ៉មគូប្រយុទ្ធជាមុនតែម្តងទៅ ។ ខ្ញុំស្ទង់ចិត្តពួកមេតម្រួតជាតិយួនទាំងនេះមិនស្គាល់សោះ ពុំដឹងជាគេអាណិតខ្ញុំដោយស្មោះ បានជាគេឱ្យខ្ញុំសុំញ៉មមុនដូច្នេះ ដោយគេយល់ច្បាស់ថាខ្ញុំពិតប្រាកដជាមិនឈ្នះគូប្រយុទ្ធថ្មីមែន ឬមួយក៏គេមានគំនិតបោកប្រាស់ឱ្យខ្ញុំសុំចុះចាញ់មុនប្រយុទ្ធដើម្បីគេនឹងសប្បាយចិត្តសើចលេងក៏មិនដឹង ។ ប៉ុន្តែតាមខ្ញុំស្គាល់ចិត្តថ្លើមនៃលោកទាំងនេះពីមុនមក ពុំមែនមានគំនិតក្រឡិចក្រឡុចឡើយ ប្រហែលជាគេអាណិតខ្ញុំ ខ្លាចខ្ញុំស្លាប់មែន ពីព្រោះជើងប្រដាល់ថ្មីពីរនាក់នេះនៅទីក្រុងព្រៃនគរនោះ ជាតិយួនទាំងប្រទេសដែលចូលចិត្តខាងកីឡាប្រដាល់សឹងបានស្គាល់ឈ្មោះ ស្គាល់មុខគ្រប់ៗគ្នាថា ជា

១-ភាសាយួនអាន់បា ប្រែមកជាភាសាខ្មែរថាបងទី៣,ភាសាយួនហៅអាន់ហាយគឺបងទី២ គ្មានបងទី១ ទេមានតែបងទី២-៣-៤ ។ល។ បើហៅទី២ គឺបងបង្អស់ក្នុងទីនេះគេហៅខ្ញុំថាបង១ដូចខ្មែរយើងដែរ ។

អ្នកល្បីពូកែទាត់ ធាក់ ដាល់មានល្បិចស្នៀតពូកែណាស់ តែធាក់ដាល់ត្រូវគូប្រយុទ្ធម្ខាងហើយ បើមិនក្ដួតឈាមក៏គង់សន្លប់បាត់ស្មារតីដែរ ។ មានអ្នកខ្លះក្រោយពេលដាល់ ទៅជាមនុស្ស ល្ងីល្ងើវិកលចរិតក៏មានដែរ ដោយសារដៃជើងរបស់អ្នកទាំងពីរនេះធ្ងន់ណាស់ ។ ខ្ញុំនឹកភ័យខ្លាចដែរ ប៉ុន្តែមកនឹកឃើញថា ការអ្វីៗមិនត្រូវខ្លាចមុនពេលដែលបានសាកល្បងមើលនោះទេ ។ មួយទៀត ធម្មតាជាតិយួនចូលចិត្តហ៊ានហួសហេតុ ប៉ុន្តែលោជាខ្លាចវិញក៏ហួសហេតុដែរ ដូចខ្ញុំជម្រាប មកហើយ ។ សូមមិត្តប្រយ័ត្នឱ្យមែនទែនកុំឱ្យចាញ់បោកជាតិនេះ ពួកវាចូលចិត្តនិយាយអួតពេក ។ ឧទាហរណ៍ដូចរឿងរកស៊ីចូលហ៊ុនគ្នា ត្រូវយើងប្រយ័ត្នវាមានប្រាក់តែ១០.០០០វានិយាយថា មាន ដើមទុនដល់ទៅ១៥០.០០០រៀល ។ បើគ្នាវាមានតែ១០នាក់ វាអួតបំភ័យយើងថា មាន១០០ឬ ២០០នាក់ជាប្រាកដ ។ បើយើងស្លឹកត្រចៀកស ច្បាស់ជាចាញ់កលវាហើយ ។ ហេតុនេះសុំមិត្ត ប្រយ័ត្នកុំចាញ់ការឃោសនារបស់វា ត្បិតវាចូលចិត្តនិយាយពន្លើសហួសហេតុ ។ ម្យ៉ាងទៀតដូចជា នៅពេលបច្ចុប្បន្ននេះ ដែលវាចូលមកវាយយើងនៅកន្លែងណាមួយ គ្នាវាមានតែ១០នាក់ឬ២០នាក់ វានិយាយពន្លើសថាមាន១០០ឬ២០០នាក់សុទ្ធតែមានអាវុធគ្រប់ដៃ ។ តែតាមការពិតវិញ គឺពួកវា មានគ្នាតែ៤-១០នាក់ មានអាវុធ៤-៥ដើមប៉ុណ្ណោះសោះ ។ ប៉ុន្តែមានពេលខ្លះដែលវាកុហកលែង កើត លែងបានផល វាក៏ត្រឡប់ជាប្រើពាក្យពិតទៅវិញ ដែលនាំឱ្យយើងលំបាកក្នុងការស្ទង់គំនិត របស់វាណាស់ ។ ហេតុនេះដើម្បីបញ្ជាក់ការពិត ត្រូវយើងចាត់គ្នាទៅលបមើលផ្ទាល់ឱ្យច្បាស់ថា ពួកវាតិចឬច្រើន មានអាវុធតិចឬច្រើន ទើបយើងចាត់ការបានលទ្ធផលល្អ កុំចេះតែ ជឿតៗគ្នា ហើយនាំគ្នាភ័យផ្អើលដូចជាទន្សាយភ្ញាក់នឹងផ្លែត្នោតជ្រុះនោះ ។ សុភាសិតបុរាណបានប្រដៅថា កុំ ទុកចិត្តបរទេស ប្រហែសវាបាត់ ប្រយ័ត្នវាគង់ ដែលត្រូវឱ្យយើងចងចាំឱ្យជាប់ជានិច្ចក្នុងចិត្ត ទើប យើងធ្វើការជាមួយជាតិយួនក្រឡិចក្រឡុចនេះបាន ។

ថ្ងៃខែចេះតែកន្លងទៅមុខជានិច្ច ចូលដល់ខែធ្នូ ១៩៤៣ ខ្ញុំបានទទួលសំបុត្រមួយច្បាប់ពី លោកទូសទូ អនុញ្ញាតឱ្យខ្ញុំទៅហាត់ដាល់សមដៃនៅឯទីក្រុងកោះត្រឡាច រាល់ថ្ងៃសៅរ៍នៅពេល ល្ងាចម៉ោង១៥ ។ មុននឹងសមដៃឯកោះត្រឡាច ខ្ញុំបានហាត់ម្នាក់ឯងនៅកន្លែងដិកបរុក ដើម្បី បម្រុងការទុកតាំងពីខែតុលាប្លែះ ។ ខ្ញុំខំហាត់រហូតដល់ថ្ងៃចូលប្រយុទ្ធតែម្ដង ឥតមានភ្លេចភ្លាំង ស្នៀតអ្វីឡើយ ។ នៅកន្លែងដិកយុកនោះជាកន្លែងល្អគួរឱ្យចាប់ចិត្តក្នុងការហាត់កីឡាណាស់ ដូច



ជាដាល់បាវខ្សាច់នៅលើភ្នំខ្សាច់ ។ ខ្ញុំហាត់ដាល់បាវខ្សាច់ពី៣០ទៅ៤០នាទីទើបខ្ញុំចុះទៅមាត់សមុទ្រ រួចហាត់រត់តាមមាត់សមុទ្របាន១ម៉ោងទៅ១ម៉ោង៣០នាទីរួចហើយខ្ញុំចុះទៅក្នុងទឹកសមុទ្រឱ្យបាន ត្រឹមស្មា ទើបហាត់ដាល់ទឹកសមុទ្រទៀត ដោយយកដៃទាំងពីរដាល់ទឹកសមុទ្រឱ្យឡើងបែក សំពោងបាន២០ឬ៣០នាទី ហើយក៏រត់ឡើងទៅលើភ្នំខ្សាច់ម្ដងទៀត ។ ក្នុងការរត់ឡើង ភ្នំខ្សាច់នេះ ដៃខ្ញុំទាំងពីរ មានកាន់ដុំដែកទម្ងន់ប្រហែល១០គីឡូនៅដៃម្ខាងៗផង ។ លុះរត់ចុះរត់ ឡើងបាន៣-៤បក ទើបឈប់សម្រាក ។ ធ្វើតែយ៉ាងនេះរាល់ពេលព្រឹក ដែលនាំឱ្យមានកម្លាំង ពេញបរិបូណ៌ បើដាល់១០ទឹកក៏ស៊ូបានមិនសូវហត់ដែរ ។ ប៉ុន្តែក្នុងពេលដាល់ គេឱ្យដាល់តែ៣ទឹក ទេ ។ ខ្ញុំខំហាត់ដូច្នេះបានពីរបីខែ ក៏បានឡើងកម្លាំងពេញបរិបូណ៌ណាស់ ។ ចំណែកអ្នកកីឡាទាំង ពីរនាក់ជាគូប្រយុទ្ធនោះ គេឱ្យវាហាត់ដែរ តែនៅកន្លែងវាគ្មានកន្លែងហាត់ស្រួលដូចកន្លែងខ្ញុំទេ គឺ វាហាត់តែក្នុងគុក បានត្រឹមតែលោតខ្សែ ដាល់បាវខ្សាច់តែប៉ុណ្ណោះ ទទួលទានមិនបានបរិបូណ៌ ដេកមិនស្រួល ជាហេតុនាំឱ្យ ខូចកម្លាំងផង ។

លុះដល់ថ្ងៃទី១៥ធ្នូ ១៩៤៣ទើបគេឱ្យយើងសមដៃគ្នា ។ នៅពេលនោះ ខ្ញុំបានឃើញរូប រាងមុខមាត់គូប្រដាល់ទាំងពីរនាក់ច្បាស់ហើយ។ បាសាវត្រៀងចាស់បន្តិចអាយុប្រហែល៤២-៤៣ ឆ្នាំជាអ្នកប្រដាល់របៀបបុរាណជើងទាំងពីរធំៗមានធំខ្ពស់ជាងខ្ញុំ ។ ឯយ៉ៅបាតុងវិញរូបរាងមូលទាប ជាងខ្ញុំបន្តិច តែយ៉ៅបាតុង ដាល់ឈ្នះសាវត្រៀង រាងរហ័សរហួនជាងសាវត្រៀងច្រើន ។ នៅពេល សមដៃសាវត្រៀងចូលមុន ។ លុះសមបានពីរបីទឹកហើយ ក៏ឈប់ ទើបយ៉ៅបាតុងចូលមកសមតទៅ ទៀត ប៉ុន្តែមុននឹងចូល គេបានសួរខ្ញុំជាមុនថា ដាល់ទៀតបានទេ ? ខ្ញុំឆ្លើយថាដាល់បាន ។ ទើប គេឱ្យចូលដាល់ថែមទៀត ។ លុះសមជាមួយយ៉ៅបាតុងគ្រប់បីទឹកហើយទើបឈប់។ក្នុងពេលសម នេះ ខ្ញុំចេះតែសង្កេតបណ្ដើរសមបណ្ដើរដើម្បីមើលស្នៀតគូប្រយុទ្ធឱ្យច្បាស់ ។ ក្រោយនោះ បនុស្សខ្មែរ-យួនដូចគ្នាចេះតែមកសួរខ្ញុំថា ម៉េចបងម៉ុល មានផ្លូវឈ្នះវាទេ ? ខ្ញុំឆ្លើយប្រាប់ទៅ វិញថា នៅមិនទាន់ប្រាកដទេ បើវានៅតែប្រើស្នៀតដដែលៗនេះ ខ្ញុំមានផ្លូវសង្ឃឹមខ្លះ បោជាវា ប្រើស្នៀតអ្វីផ្សេងទៅវិញ ខ្ញុំមិនប្រាកដជាយ៉ាងណាទេ សុំឱ្យរង់ចាំមើលដល់ថ្ងៃប្រយុទ្ធមែនទែន ទៅចុះ ! មាននាយតម្រួតជាតិយួនខ្លះ ខ្មែរខ្លះ និងពួកមនុស្សទោសដូចគ្នាខ្លះ បានសួរបញ្ជាក់ខ្ញុំ

ដោយចង់ដឹងថា ខ្ញុំមានសង្ឃឹមអាចយកជោគជ័យបានលើគូថ្មីនេះ ? ដើម្បីគេនឹងភ្នាល់ដាក់ប្រាក់ស៊ីសងគ្នា ពីព្រោះនាយតម្រួតយួននិងមនុស្សទោសជាតិយួន ភាគច្រើនគេបម្រុងកាន់ខាងយ៉ាបាតុង គេត១០០ស៊ី៥០ ។ ខ្ញុំចេះតែដេក_ដើរ_ឈរគិត តើប្រាកដជាឈ្នះយ៉ាបាតុងបានទេ ? បើវានៅតែប្រើស្នៀតដដែលនេះ ខ្ញុំមុខជាមានផ្លូវឈ្នះ តែប្រសិនបើវាប្រើស្នៀតថ្មីផ្សេងទៅវិញ នៅពេលប្រយុទ្ធផ្ដាច់ព្រ័ត្រនោះ មិនប្រាកដជាយកឈ្នះវាបានឡើយ ។ បើខ្ញុំប្រាប់គេថាប្រាកដជាឈ្នះវាមែននោះ ជាការគាប់ប្រសើរ នាយតម្រួតទាំងអស់នោះរឹងរឹតតែស្រឡាញ់រាប់អាន និងសរសើរខ្ញុំពេញទី ។ ចុះបើលោតែចាញ់គេវិញនាយតម្រួតព្រមទាំងមនុស្សទោសដូចគ្នា ដែលគេបានភ្នាល់ចាញ់ប្រាក់កាស គេមុខតែនឹងខឹងខ្លាំង ដល់ជួបមុខខ្ញុំកាលណា គេមិនជេរប្រទេចស្លាប់ហើយ ? គិតទៅគិតមកឃើញគ្មានចំណេញអ្វីសោះ ទើបខ្ញុំឆ្លើយប្រាប់ទៅវិញថា មិនប្រាកដជាឈ្នះគូប្រយុទ្ធទេ ។ ពាក្យនេះចេះតែឮសុះសាយទៅដល់យ៉ាបាតុង ក៏កើតក្ដីមើលងាយដល់រូបខ្ញុំតែម្ដង ។ យ៉ាបាតុង បាននិយាយថាខ្លួនគេនឹងយកជ័យជំនះលើអាន់បាម៉ុល បានដោយងាយជាហេតុនាំឱ្យតម្រួតជាតិយួនទាំងប៉ុន្មានមានសេចក្ដីពេញចិត្តគ្រប់ៗគ្នា ។ គេដើរកាត់រកនាយតម្រួតជាតិខ្មែរបបួលឱ្យភ្នាល់នឹងគេ តែអស់លោកខ្មែរប្រកែកពុំហ៊ានភ្នាល់ ដោយហេតុមិនបានការធានាពីខ្ញុំ ក៏បណ្ដាលឱ្យការភ្នាល់គ្នានោះស្ងប់ស្ងៀមទៅវិញ ។ មានលោកខ្លះមិនអស់ចិត្តចេះតែមកទទូចសួរខ្ញុំឱ្យឆ្លើយច្បាស់ ។ ខ្ញុំក៏ឆ្លើយដោយសុភាពថា អ្នកប្រដាល់មិនប្លែកអ្វីពីមាន់ប្រជល់ទេ ។ មាន់ម្ខាងដែលកំពុងតែមានជ័យជំនះដោយមានគូប្រយុទ្ធម្ខាងចង់ចាញ់ទៅហើយ ស្រាប់តែមាន់ងនោះលោចាក់មួយខ្ទាយត្រូវចំកន្លែងដំណំណាមួយ មាន់ដែលមានជ័យនោះ ត្រឡប់ជារត់ឬមួយស្លាប់ក៏មានដែរ ។ ចំណែកខ្ញុំជាអ្នកប្រដាលវិញ ប្រៀបបាននឹងមាន់ប្រជល់ដូច្នោះឯង ។ មានពេលខ្លះខ្ញុំដាល់គូប្រយុទ្ធត្រូវយ៉ាងច្រើន គេមើលរាល់គ្នាមកឃើញខ្ញុំថាច្បាស់ជាមានជ័យហើយ ស្រាប់តែភ្លាត់ស្នៀតធ្វើឱ្យគូប្រយុទ្ធដាល់ត្រូវកន្លែងដំណំតែមួយដៃវិញនោះ ខ្ញុំប្រាកដជានឹងដួលសន្លប់បាត់មាត់តែម្ដង ។ នេះហើយជាធម្មតានៃកីឡាប្រដាល់នឹងឱ្យខ្ញុំធានាទុកជាមុនថាប្រាកដជាឈ្នះគូសត្រូវពុំបានទេ សុំទោសទៅចុះ !

ខ្ញុំបានចូលប្រកួតសមដៃជាមួយយ៉ាបាតុង៥ដង ទើបចូលដល់ថ្ងៃ១មករា ១៩៤៤ ជាការប្រកួតផ្ដាច់ព្រ័ត្រ ។ នៅយប់ថ្ងៃទី៣០ ធ្នូ ១៩៤៣ ខ្ញុំបានប្រាប់បងហាមុនថា បើយ៉ាបាតុង ប្រើតែ



ស្នៀតដដែលដូចវាប្រើនៅថ្ងៃហាត់ធម្មតាទៀតមើលទៅខ្ញុំមានផ្លូវឈ្នះ ប៉ុន្តែបើគេផ្លាស់ស្នៀតថ្មីវិញនោះមិនប្រាកដជាយ៉ាងណាទេ ។

មិត្តជាទីស្នេហា ! យប់ថ្ងៃទី១ មករា ឆ្នាំ១៩៤៤ ជាថ្ងៃប្រយុទ្ធផ្ដាច់ព្រ័ត្រ ខ្ញុំនៅអល់ឯកក្នុងចិត្តមិនទាន់ដាច់ស្រេចថាចាញ់ឬឈ្នះនៅឡើយ ។ ខ្ញុំតែងនឹកសម្លឹងសម្រូងដល់គុណបុណ្យព្រះរតនត្រ័យ ព្រមទាំងមាតាបិតាជីដូនជីតានិងកុសលសីលទាន ដែលបានធ្វើមកទាំងប៉ុន្មាន សូមឱ្យលោកជួយជ្រោមជ្រែងឱ្យមានជ័យជំនះលើគូប្រយុទ្ធជាតិយួនដូចបំណង ដើម្បីឱ្យជាតិខ្មែរយើងមានកេរ្តិ៍ឈ្មោះល្បីល្បាញលើទឹកដីកោះត្រឡាច ។ មុនពេលប្រកួតខ្ញុំបានធ្វើទឹកក្រូចឆ្មាលាយស្ករសមួយកូនដបស្ងួដា ឱ្យបងហាគាត់កាន់ទៅតាមខ្ញុំ ។ ចំណែកលោកទូសទូ ក៏បានសួរខ្ញុំថា ម៉េចឯងមានផ្លូវឈ្នះយ៉ាបាតុងទេ ? ខ្ញុំឆ្លើយជម្រាបគាត់ទៅវិញថា : ខ្ញុំមិនទាន់ប្រាកដទេសែហ្វ ! រួចលោកក៏ប្រាប់ខ្ញុំថាយ៉ាបាតុងនេះវាវាយបុក្ស (BOXE) នៅទីក្រុងព្រៃនគរកាលពីឆ្នាំ១៩៤២នោះឃើញថាវាពូកែខ្លាំងណាស់ ឈ្លាសវាងវៃច្រើន ! ហេតុនេះត្រូវឯងប្រុងប្រយ័ត្ន ហើយប្រឹងប្រែងឱ្យមែនទែន ទើបមានផ្លូវឈ្នះវាបាន ! ខ្ញុំទទួលបាទ ! នៅឆ្នាំនេះ លោកមេការក្រុងកោះត្រឡាច បានចាត់ឱ្យរៀបចំកន្លែង ប្រដាល់ក្នុងបរិវេណទាត់បាល់(លានប្រកួតបាល់)ចំណុះមនុស្សប្រហែល៣.០០០នាក់ ។ កន្លែងអង្គុយមានកៅអីធំតូច សម្រាប់ស៊ីវិល និងអ្នករាជការទាំងអស់ ។ ចំណែកមនុស្សទោសគេក៏ធ្វើជារានក្ដារបន្ទះវែងៗឱ្យអង្គុយ ។ មានលក់សំបុត្រចូលមើលការប្រកួត បើស៊ីវិលក្នុងម្នាក់ៗតម្លៃ៤រៀល ឯមនុស្សទោស ក្នុងម្នាក់ៗយក២រៀល ។ ពេលយប់ម៉ោង១៨.៣០គេបើកលក់សំបុត្រ ដល់ម៉ោង២០ ទើបឱ្យបើកឆាកប្រកួត ។

យប់នោះ មានគូប្រកួត១០គូ ហើយខ្ញុំនិងយ៉ាបាតុង ជាគូចុងក្រោយ ។ គូនីមួយៗប្រកួតគ្នាជាលំដាប់ ។ ដល់ម៉ោងជិត២២ទៅហើយ ទើបដល់គូចុងក្រោយគឺខ្ញុំនិងយ៉ាបាតុង ។ ទាំងស៊ីវិលទាំងមនុស្សទោសចូលទៅពេញកន្លែង ដោយហេតុតែចង់ឃើញមួយគូក្រោយនេះឯង ។ ពេលនោះខ្ញុំភ័យផងអរផង ខំសូត្រពុទ្ធគុណជាប់ញាប់មាត់ស្អេក រហូតដល់ពេលចូលប្រកួតតែម្ដង ។ នៅពេលឡើងលើសង្វៀនប្រកួតខ្ញុំបានទារទឹកក្រូចពីបងហា ដែលខ្ញុំឱ្យកាន់នឹងជាអ្នកចាំឱ្យទឹកខ្ញុំផង

ដើម្បីយកមកទទួលទានបន្តិច ។ នៅពេលដែលទទួលដបទឹកក្រូចមកស្រាប់តែពិនិត្យទៅឃើញអស់ពាក់កណ្ដាលដប ។ ខ្ញុំសួរបងហាថា ៖ ម៉េចក៏ទឹកក្រូចពាក់កណ្ដាលដបទៅហើយ ? គាត់ឆ្លើយថា ៖ យ៉ាបាតុង សុំផឹកបន្តិចទៅហើយ ! ខ្ញុំសួរថាម៉េចក៏ទៅគេផឹកយ៉ាងអ៊ីចឹង ? បងហាឆ្លើយថាវាចេះតែទទូចសុំច្រើនដងពេក ទ្រាំមិនបានក៏ឱ្យទៅ ។ ខ្ញុំនឹកក្នុងចិត្តថា យ៉ាបាតុង ប្រហែលជាមានការព្រួយបារម្ភញញើតខ្ញុំខ្លះជាមិនខាន ជឿថាខ្ញុំមានថ្នាំពូកែឬអ្វីៗហើយទើបសុំផឹកដូច្នេះ ។ ជាធម្មតាជាតិយួន ជាតិសៀម វាខ្លាចខ្មែរយើងណាស់ រឿងថ្នាំគង់និងសិល្បសាស្ត្រ មន្តវិជ្ជាផ្សេងៗដូចជាកាប់មិនមុតដុតមិនឆេះជាដើម ។ ដូច្នេះហើយខ្ញុំមានកម្លាំងក្នុងខ្លួនថែមបន្តិចឡើងដោយគិតឃើញថា បើសត្រូវខ្លាចយើងហើយយើងមានផ្លូវឈ្នះវាជាមិនខាន ។ គ្រានោះគេវាយរគាំងម៉ូង! ឱ្យសញ្ញាប្រកួត ។

ខ្ញុំនឹងយ៉ាបាតុងដើរចូលរកគ្នា ឯអាជ្ញាកណ្ដាលក៏ឱ្យសញ្ញាថាប្រយុទ្ធបាន ។ គ្រានោះយ៉ាបាតុងដាល់ខ្ញុំ១ដៃស្ដាំមុន តែខ្ញុំគេចផុតរួចក៏វាថយក្រោយវិញ ។ ទើបវាចូលដោយប្រុងប្រយ័ត្នមកម្ដងទៀត វាក៏ដាល់ខ្ញុំដោយដៃឆ្វេងផង ដៃស្ដាំផង ។ ដៃឆ្វេងវាត្រូវមុខខ្ញុំបន្តិច ខ្ញុំលោតថយក្រោយ រីឯដៃស្ដាំវិញដាល់ខ្ញុំខុសទទេ ។ ពេលដែលខ្ញុំគេចផុតពីដៃស្ដាំវាទាន់ ខ្ញុំបានដាល់សងទៅវិញភ្លាម១ដៃស្ដាំត្រូវក្រោមចង្កាខាងឆ្វេង យ៉ាបាតុងផ្ងារក្រោយបន្តិចហើយថយក្រោយពីរជំហានទើបទប់ជំហរនឹង ។ ខ្ញុំចូលដាល់ថែមមួយដៃស្ដាំទៀតជាការបញ្ឆោតសត្រូវប៉ុណ្ណោះ ។ ពេលដែលសត្រូវគេចពីដៃស្ដាំខ្ញុំ ខ្ញុំក៏បានដាល់ដៃឆ្វេង១ដៃយ៉ាងខ្លាំងត្រូវកំភ្លៀងខាងស្ដាំរបស់សត្រូវ យ៉ាបាតុងផ្ងារម្ដងទៀត ។ ពេលនោះ ពួកអ្នកមើលជាតិបារាំង ,ខែ ,យួនស្រែកហ៊ោគ្រប់គ្នាស្រែកឱ្យខ្ញុំថែម !!! ។ ខ្ញុំដេញគូប្រយុទ្ធជាប់ទាល់តែដល់ទឹកទីមួយ ទើបរគាំងឱ្យសញ្ញាឈប់ ! វេលាឈប់សម្រាកឱ្យទឹកខ្ញុំប្រាប់បងហាថា បើគេប្រើស្នៀតនេះតទៅទៀត ខ្ញុំមានផ្លូវឈ្នះប្រាកដ ។ បងហាឆ្លើយថាខ្ញុំឃើញគូប្រយុទ្ធទន់ដៃហើយ !

រគាំងទឹកទី២ ផ្ដើមឡើងម៉ូងៗ ខ្ញុំក៏ចូលទៅដល់ពាក់កណ្ដាលទី យ៉ាបាតុង ក៏ចូលមកដែរ អាជ្ញាកណ្ដាលឱ្យសញ្ញាថាប្រយុទ្ធបាន ។ ម្ដងណោះ ខ្ញុំបានដាល់សត្រូវមុនត្រូវត្រង់មុខមួយដៃយ៉ាង



ដំណំ ។ យ៉ាបាតុងថយក្រោយ ខ្ញុំចេះតែដេញតាមបញ្ឆោតដៃឆ្វេង វាយដៃស្ដាំ ដេញតាមរហូតដល់ទៅចុងជ្រុងខ្សែព្រ័ត្រ ខ្ញុំដាល់ដោយដៃស្ដាំត្រូវចំថ្គាមមួយដៃ យ៉ាងទម្ងន់ ។ យ៉ាបាតុងទ្រេត ខ្ញុំក៏ថែមដៃឆ្វេងពីរដៃជួនៗគ្នាទៅទៀត យ៉ាបាតុង រងមិនទាន់ក៏ដួលផ្ងារសន្លប់ឈឹង ! ខ្ញុំថយក្រោយវិញ ។ ឯអាជ្ញាកណ្ដាលក៏តាំងរាប់១...២...៣ដល់គ្រប់១០ទើបឈប់ តែនៅតែយ៉ាបាតុងងើបមិនរួច ទើបគេមកលើកដៃខ្ញុំឡើងលើក្នុងនាមមានជ័យជំនះ !

សម្រែកជយោ !ហ៊ោកញ្ជ្រៀវបានផ្ទុះឡើងកក្រើកទាំងលានប្រដាល់ទទួលជ័យជំនះខ្ញុំ !

មិត្តភក្តិជាទីស្នេហា ! នៅពេលដែលបានឃើញយ៉ាបាតុងដួលសន្លប់នោះ ខ្លួនខ្ញុំទៅជាភ័យព្រឺក្បាលសំពោង បន្តិចមកទើបនឹកអរឡើងវិញដោយនឹកឃើញថា ៖ ខ្ញុំមានជ័យជំនះម្ដងនេះទៀតដូចជាមានជ័យជំនះអស់មួយជីវិតហើយ ដោយហេតុថា ឈ្មោះយ៉ាអាតុងជាជើងឯកនៅលើដីឥណ្ឌូចិន ។ ខ្ញុំបានឈ្នះឈ្មោះនេះ ដូចខ្ញុំបានឈរឈ្មោះ នៅលើដីឥណ្ឌូចិនដូច្នោះដែរ ។ នៅពេលនោះ ក្រុមរដ្ឋការនិងពួកអ្នកទោសជាមិត្តបានស្ងើចសរសើរខ្ញុំសឹងគ្រប់គ្នា ព្រោះខ្ញុំជាមនុស្សត្រឹមត្រូវ ស្លូតបូត មិនចេះមើលងាយមនុស្សដូចគ្នាជាមនុស្សចិត្តល្អចំពោះក្រុមមនុស្សទោសដូចគ្នា មិនដែលជេរស្ដីមនុស្សទោសនៅក្រោមបង្គាប់ មិនដែលប្រើពាក្យអាមីង អាឯង ទៅរកមនុស្សគ្នាឯងឡើយ ។ ឃើញតែប្រើពាក្យសុភាពរាបសាថាបង ប្អូន មាដរាប ។ លុះមកមានជ័យជំនះនេះក៏ត្រូវបាន សម្រេចនាំឱ្យមានសេចក្ដីសរសើរពីគ្រប់មជ្ឈដ្ឋានហើយសំខាន់បំផុត ជ័យជំនះនេះបានជួយឱ្យលោកទូសទូ ជាមេតម្រួត រឹតតែស្រឡាញ់ទុកចិត្តខ្ញុំទ្វេឡើងទៀត ។ ឯមនុស្សនៅលើកោះកោះត្រឡាចក៏រឹតតែស្គាល់ខ្ញុំរាប់អានជាងមុនៗទៅទៀត ។

គេចូលចិត្តហៅថា បាន់បាម៉ុល យ៉ាស៊ី(គឺជាអ្នកប្រដាល់ជើងឯក) ។

***

# -១៣-

# ទស្សនាចរនៅកោះត្រឡាច

នៅឆ្នាំ១៩៤៤ ខ្ញុំបានដើរកម្សាន្តពេញទឹកដីកោះត្រឡាច គឺដើរជុំវិញកោះត្រឡាច ។ ខ្ញុំដើរតែម្នាក់ឯងវាងតាមឆ្នេរសមុទ្រដោយមានតែដាវវែងមួយដូចជាដាវជប៉ុនស្ពាយលើស្មា ឆ្ពោះទៅកាន់កន្លែងធ្វើឈើហ៊ុបជាដំបូង នៅនោះខ្ញុំត្រូវបានកាប៉ូរ៉ាល់កន្លែងនោះទទួលរាក់ទាក់ណាស់ ។ ឯមេតម្រួតជាអ្នករាជការម្នាក់នៅទីនោះ ក៏ទទួលរាប់អានខ្ញុំដូចជាមនុស្សមានបុណ្យសក្តិម្នាក់ដូច្នោះដែរ ។ គេបានកាប់មាន់ទាធ្វើម្ហូបជប់លៀងខ្ញុំ រួចនាំទៅពិនិត្យកន្លែងដែលមនុស្សទោសរស់នៅ ព្រមទាំងឱ្យវត្ថុអនុស្សាវរីយ៍ដល់ខ្ញុំដូចជារូបចម្លាក់អ្នកតាយួនជាដើម ព្រមទាំងឱ្យពរខ្ញុំថា ៖ សូមឱ្យអ្នកតានៅទីកោះត្រឡាចនេះ ជួយបីបាច់ថែរក្សាខ្ញុំឱ្យរស់រានមានជីវិតរហូតដល់បានត្រឡប់ទៅស្រុកទេស ជួបមាតាបិតាញាតិកាកុំខានឡើយ ខ្ញុំក៏បានទទួលពរជ័យនេះដោយរីករាយ ។ ក្រោយដែលធ្វើភត្តកិច្ចពេលព្រឹកហើយ ខ្ញុំក៏បានលាគេបន្តដំណើរទៅមុខទៀត ។ ខ្ញុំចេញពីកន្លែងកាប់ឈើនៅម៉ោង១២ លុះដល់ម៉ោង១៦រសៀល ទើបបានដល់កន្លែងមួយឈ្មោះការុង ដែលជាកន្លែងធ្វើស្រែចំការយ៉ាង ធំ ។ នៅទីនោះមានជាតិបារាំងម្នាក់នៅត្រួតត្រា ។

ខ្ញុំបានចូលទៅសួររកកាប៉ូរ៉ាល់ម្នាក់ឈ្មោះខាន់ ដែលធ្វើការនៅទីនោះ ។ មើលខ្ញុំពីចម្ងាយមិនស្គាល់ទេលុះខ្ញុំដើរចូលទៅប្រហែល ១៥០ម៉ែត្រនឹងដល់ ទើបកាប៉ូរ៉ាល់ខាន់ស្គាល់ស្រែកដោយរីករាយថា លោកប្អូនម៉ុល មកដល់កន្លែងយើងហើយវើយ ! នៅពេលនោះ ក្រុមមនុស្សទោសខ្មែរ យួនទាំងប៉ុន្មាន នៅកន្លែងនោះក៏នាំគ្នាចេញពីផ្ទះរៀងៗខ្លួនមកទទួល ខ្ញុំដោយរាក់ទាក់ជាទីបំផុត ។ ត្បិតពួកនោះមិនដែលស្គាល់មុខខ្ញុំទេ ឮតែឈ្មោះល្បីខាងប្រដាល់ ទើបគេចោមរោមមើលខ្ញុំខ្លាំងណាស់ ។ គេសួរសុខទុក្ខហើយគេសួរថា ៖ ដើរមកនេះប៉ុន្មានម៉ោងហើយពីព្រោះផ្លូវ



មកនេះមនុស្សទោសធម្មតាដើររហោតរហូតមិនបានទេ មានតែក្រុមសម្ងាត់ទើបអាចដើរកាត់បាន។ ខ្ញុំក៏ឆ្លើយប្រាប់គេតាម ហួរហែទៅវិញថាមិនអីទេ ខ្ញុំអាចដើរកាត់បាន ! ដោយរាប់អានល្ងាចនេះខ្ញុំសម្រាកនៅផ្ទះកាប៉ូរ៉ាល់ខាន់ ។ ល្ងាចនោះ គេបានចាត់ចែងម្ហូបអាហារច្រើនមុខជប់លៀងដោយសាច់មាន់ ទា ត្រីសមុទ្រយ៉ាងបរិបូណ៌ ។ ក្រោយពេលបាយល្ងាចគេជប់លៀងតែកាហ្វេទៀតហើយគេនាំគ្នាសាកសួរពីរឿងដែលបានជ័យជំនះលើយ៉ាតុង ។ ត្បិតកាលប្រកួតគ្នានោះមានតែកាប៉ូរ៉ាល់ខាន់ម្នាក់ទេ ដែលបានទៅមើលលុះត្រឡប់មកវិញកាប៉ូរ៉ាល់នេះ បានដំណាលរឿងប្រដាល់និង ជ័យជំនះរបស់ខ្ញុំប្រាប់មនុស្សទោសក្រោមបង្គាប់គាត់រួចទៅហើយ ។ លុះគេបានឃើញរូបខ្ញុំទៅដល់គេសុំឱ្យខ្ញុំអធិប្បាយបញ្ជាក់ផ្ទាល់ខ្លួនឱ្យគេស្តាប់ម្តងទៀត ។ ខ្ញុំក៏អធិប្បាយហួរ-ហែតាម ដំណើរការណ៍ ឱ្យ ក្រុមមិត្តមនុស្សទោសទាំងនោះស្តាប់ រហូតដល់ម៉ោង២៣ ។ យប់នោះខ្ញុំទទួលទានដំណេកនៅ នឹងផ្ទះកាប៉ូរ៉ាល់ខាន់ ។

លុះព្រឹកឡើង កាប៉ូរ៉ាល់ខាន់ បានរៀបចំឱ្យខ្ញុំទទួលទានបបរមាន់ទៀត មុននឹងឱ្យខ្ញុំបន្តដំណើរចេញពីកន្លែងគាត់ ។ ចេញពីកន្លែងនេះហើយ ខ្ញុំក៏ធ្វើដំណើរឆ្ពោះទៅកាន់កន្លែងមួយទៀតឈ្មោះចំការថ្មមូល ហៅក្រៅថាថ្មមូល ដែលមានផ្លូវចម្ងាយ១៨គីឡូម៉ែត្រ ។ ទេសភាពនៃចំការនេះប្រហាក់ប្រហែលនឹងកន្លែងដែលខ្ញុំនៅដែរ ឃើញខុសគ្នាតែគ្មានភ្នំខ្សាច់នៅខាងមុខដូចខាងកន្លែងខ្ញុំ ។ ពីខាងមុខមើលទៅឃើញទឹកសមុទ្រខៀវស្រងាត់ គួរឱ្យពិចពិលគយគន់ និងឃើញភ្នំតូចៗដុះលេចចេញពីទឹកកណ្តាលសមុទ្រនៅឆ្ងាយពីច្រាំងកោះត្រឡាច ។ ទេសភាពកន្លែងនោះល្អណាស់ដែរ កន្លែងនោះមានអ្នកត្រួតម្នាក់ មានមនុស្សទោសប្រហែល២០នាក់ ។ ខ្ញុំបានទៅសួររកកាប៉ូរ៉ាល់នៅទីនោះឈ្មោះបាវៀង ។ នៅវេលាដែលបានឃើញខ្ញុំភ្លាម បាវៀងក៏ស្រែកហៅចំឈ្មោះខ្ញុំដោយក្តីរាក់ទាក់ ព្រមទាំងស្រែកប្រាប់ទៅមនុស្សទោសជាមិត្តទាំងអស់ថា ៖ នេះហើយឈ្មោះប៉ិណ្ឌច័ន្ទ ម៉ុល ដែលបានដាក់ឈ្នះយ៉ាតុង សន្លប់នៅនឹងកន្លែង ! មនុស្សទោសទាំងនោះក៏ផ្អើលមកចោមរោមមើលរូបរាងខ្ញុំ ហើយគេសរសើរខ្ញុំថា រូបរាងសមរម្យ រាងរហ័សរហួនល្អណាស់ ។ កាលខ្ញុំទៅដល់កន្លែងនោះនៅវេលាម៉ោង១ហួសពេលបាយទៅហើយ ដោយផ្លូវឆ្ងាយពេក ។ ទើបបងបាវៀងបានចាត់ឱ្យពួកគាត់កាប់មាន់ធ្វើម្ហូបដណ្តាំបាយជាថ្មីឱ្យខ្ញុំទទួលទាន

ដោយក្ដីរាប់រាន ។ លុះទទួលទានបាយហើយ ខ្ញុំក៏លាបងវៀង ព្រមទាំងមិត្តទាំងអស់នៅចំការថ្មមូល បន្តដំណើរទៅមុខទៀត ទៅឯកន្លែងមួយទៀតដែលគេធ្វើអំបិលនៅនឹងជាយក្រុងកោះត្រឡាចតែម្ដង ។ រយៈផ្លូវពីកន្លែងចំការថ្មមូលទៅទីនោះ ចម្ងាយ១៦គីឡូម៉ែត្រ ។

កន្លែងនោះជាភូមិធំមួយ មានមនុស្សទោសជាច្រើន ដែលគេហៅមនុស្សទោសល្ងូ ។ ទោសល្ងូនេះខ្ញុំបានជម្រាបអស់លោកអ្នកនៅទំព័រទី១០៦រួចម្ដងហើយ គឺទោសល្ងូនេះដូចជាទោសអស់មួយជីវិតដែរ ។ នៅកោះត្រឡាចគេខ្លាចមនុស្សទោសល្ងូនេះណាស់ ត្បិតវានៅតែប្រព្រឹត្តលួចឆក់ដោយឥតលះបង់អំពើថោកទាបនេះឡើយ ។ បើពួកល្ងូនៅកន្លែងណា គេត្រូវប្រយ័ត្នកន្លែងនោះគ្រប់គ្នា ។

នៅកន្លែងនោះខ្ញុំស្គាល់កាប៉ូរ៉ាល់ម្នាក់ឈ្មោះបាហាយជាមនុស្សត្រឹមត្រូវ ដែលខ្ញុំបានស្គាល់គាត់ក្នុងពេលដែលខ្ញុំនាំរបស់របរទៅប្រគល់ឱ្យរដ្ឋការ រាល់ពេលព្រឹកថ្ងៃអាទិត្យ នៅទីក្រុងកោះត្រឡាច ។ កំពុងតែត្រួតមើលមនុស្សទោសដាំរម្ងាស់ទឹករំបិលធ្វើអំបិលស អាន់បាហាយគាត់ឃើញខ្ញុំដើរសំដៅទៅរកគាត់ពីចម្ងាយដែរ តែគាត់មិនចាប់ភ្លឹកដោយមិនបានគិតថា ខ្ញុំមានវាសនាបានមកដល់កន្លែងគាត់ឡើយ ។ លុះខ្ញុំដើរចូលទៅកាន់តែជិតទៅៗគាត់ក៏ខំសម្លឹងមិនដាក់ភ្នែក ។ លុះស្គាល់ច្បាស់ថាខ្ញុំហើយ ទើបគាត់បន្លឺវាចាសួរខ្ញុំថា ប្អូនប៊ុណ្ណចន្ទ ម៉ុលទេឬ ? ខ្ញុំក៏ងក់ក្បាលទទួលសម្ដីគាត់សួរនោះ ។ គាត់ស្ទុះមកឱបរឹតខ្ញុំ ហើយគាត់និយាយថា គាត់មិនស្មានថាខ្ញុំបានទៅដល់កន្លែងគាត់ទេ ហើយក៏នាំខ្ញុំទៅទទួលទានទឹកតែនិងស្ករអំពៅឯផ្ទះគាត់ ដោយសេចក្ដីរាក់ទាក់និងនឹករលឹកបែនៗ ។ បន្តិចទៅមនុស្សទោសជាច្រើនក៏នាំគ្នាមកចោមរោមមើលមុខខ្ញុំ ។ គ្នាគេជាង២០នាក់ ចូលពេញផ្ទះបាហាយហើយឈរអើតក្បាលរហង់ប្រជ្រៀតគ្នាមើលខ្ញុំ ។ ពីព្រោះតែខ្ញុំយកជ័យជំនះលើយ៉ុរាតុងបាននោះ ជាជ័យជំនះធំដុំណាស់ ។ ខ្ញុំនៅនោះមួយយប់ព្រឹកឡើងក៏សុំលាមិត្តពោយរ និងមនុស្សទោសឯទៀតឆ្ពោះទៅមុខទៀត ដែលមានចម្ងាយផ្លូវចំនួន១០គីឡូម៉ែត្រទើបមកដល់ទីក្រុងកោះត្រឡាច ។



មិត្តជាទីស្នេហា ! ទីក្រុងកោះត្រឡាចជាកន្លែងមួយដែលមានទេសភាពល្អគួរឱ្យទស្សនា ។ ខ្ញុំដើរបណ្ដើរគយគន់មើលទេសភាពបណ្ដើរ ត្បិតមកដល់ទីក្រុងកោះត្រឡាចមានផ្លូវស្អាតដែលរថយន្តបើកបរបានស្រួលមិនដូចកន្លែងឯទៀតៗមុននោះទេ ។ ក្នុងដំណើរចំនួនពីរម៉ោងទើបទៅដល់កន្លែងមួយមានថ្មធំមួយនៅមាត់ទឹកសមុទ្រ ដែលគេលាបទឹកកំបោរសស្គុះដើម្បីជាសញ្ញាឱ្យកប៉ាល់សមុទ្រអាចចូលមកកាន់ផែកោះត្រឡាចបានស្រួល ។ ដុំថ្មនោះ ទំហំប្រហែល៣ទៅ៤ឱបមនុស្សចាស់ ។

ខ្ញុំសូមធ្វើអត្ថាធិប្បាយជូនបន្តិចថា នៅលើទឹកដីកោះត្រឡាចនោះមានរបស់ខ្លះជាភស្តុតាងដែលនាំឱ្យគេថា ជាទឹកដីរបស់ខ្មែរយើងដោយពិតប្រាកដ ។ មានរឿងដំណាលថាកាលពីដើមកន្លងយូរណាស់មកហើយ នៅលើភ្នំកោះត្រឡាចផ្នែកខាងជើង ចំនួនប្រហែល៧គីឡូម៉ែត្រពីទីក្រុងទៅមានប្រឡាយទឹកមួយដែលមានទឹកហូរចុះពីលើភ្នំទៅដល់ពាក់កណ្ដាលភ្នំ ។ នៅក្បែរប្រឡាយទឹកនោះមានថ្មមួយដុំយ៉ាងធំ ។ ប្រហែលក្នុងឆ្នាំ១៩២៥មានខ្យល់ព្យុះសង្ឃរាមួយបានកើតឡើងនៅលើដីកោះត្រឡាចទាំងមូល បណ្ដាលឱ្យមានការអន្តរាយជាច្រើនកន្លែង ។ ពេលនោះ មានដើមឈើមួយដើមយ៉ាងធំបានរលំទៅប៉ះដុំថ្មធំនោះ ។ ថ្មនោះក៏រមៀលបាំងបិទប្រឡាយមុខទឹក ធ្វើឱ្យមុខទឹកស្ទះហើយទឹកនោះក៏ហូរចាល់ចាក់មកលើកន្លែងថ្មនោះទៅវិញ ។ កន្លងមកបានពីរឬបីឆ្នាំពួកមនុស្សទោសទៅរកអុសរកវល្លិបានទៅផឹកទឹកដាំបាយស៊ីនៅកន្លែងថ្មធំនោះ ក៏រើសបានរូបទេពប្រណម្យធ្វើដោយមាសសុទ្ធនៅកន្លែងនោះ ។ ពេលលេងល្បែងចាញ់មនុស្សទោសដែលរើសបាននោះ យករូបទេពប្រណម្យនោះទៅលក់ឱ្យគ្នាគេ ដែលជាហេតុនាំឱ្យបែកការណ៍ឡើងឮទៅដល់មេតម្រួតបារាំង ។ តម្រួតបារាំងបានឱ្យមនុស្សទោសនោះ ទៅស្រាវជ្រាវរកវត្ថុតម្លៃនៅកន្លែងដែលឃើញមុននោះ ។ គេរកសព្វគ្រប់ក៏ប្រមូលបានរូបទេព្យប្រណម្យមាសប្រហែល២៣-២៤ព្រះអង្គថែមទៀត ។ ខ្ញុំមានវាសនាបានទៅឃើញផ្ទាល់នឹងភ្នែកខ្លួន នូវរូបទេពប្រណម្យមាសដែលនៅលើដៃមេតម្រួតជាតិយួនម្នាក់ ។ តាមខ្ញុំពិនិត្យមើលទៅ ឃើញថា ជាមាសមែន ទំហំប៉ុនចង្អុលដៃតែពណ៌សជាងមាសធម្មតាបន្តិច ដែលគេហៅថាមាសផ្កាកប្បាស ។ តាមទំនងរូបនោះ

ប្រហែលជាក្បាច់ភ្ជាប់សង្វារស្តេចជាន់ដើម ។ គេបានឃើញព្រះពុទ្ធរូបមួយអង្គធ្វើដោយថ្មអង្គរវត្ត ហើយនិងពាងក្រឡរបស់ខ្មែរយើងពីបុរាណកាលផង ជាហេតុនាំឱ្យខ្ញុំសន្និដ្ឋានថាទីនោះ គង់នៅនៃស្តេចខ្មែរយើងជំនាន់ដើមឬ ជាកន្លែងឃុំឃាំងមនុស្សទោសជំនាន់ដើមដែលស្តេចបងប្អូនទាស់ទែងគ្នាពីរឿងដណ្តើមរាជសម្បត្តិគ្នា ហើយម្ខាងឈ្នះក៏យកខាងចាញ់ទៅបំបរបង់ចោលឱ្យរងទុកទោសនៅទីនោះក៏មិនដឹង ?

ខ្ញុំនៅនឹងទីក្រុងកោះត្រឡាចលុះពេលព្រលប់ធំ ខ្ញុំទៅសំណាក់នៅផ្ទះកាប៉ូរ៉ាល់ខាត់ជាមិត្តចាស់របស់ខ្ញុំ ។ ជួនថ្ងៃនោះជាថ្ងៃសៅរ៍ដែលដល់ព្រឹកឡើងជាថ្ងៃអាទិត្យ គឺជាថ្ងៃដែលមនុស្សទោសគ្រប់កន្លែងត្រូវនាំរបស់របរគ្រប់មុខ តាមកន្លែងរៀងក្រុមយកទៅប្រគល់ឱ្យកន្លែងមួយដែលសម្រាប់ទទួលរបស់ផ្សេងៗរាល់តែថ្ងៃអាទិត្យ ។ ខ្ញុំនៅរង់ចាំនៅផ្ទះបងខាត់ចាំទទួលរបស់របរក្រុមខ្ញុំ ដែលពួកខ្ញុំនឹងនាំមកប្រគល់ឱ្យគេនៅថ្ងៃអាទិត្យស្អែកនេះដែរ ។

សូមជម្រាបថា ចំការដំឡូងរបស់កាប៉ូរ៉ាល់ខាត់ជាមិត្តខ្ញុំនេះ នៅជិតជើងភ្នំម្ខាង ចម្ងាយប្រហែលពាគីឡូម៉ែត្រពីជើងភ្នំ ។ ឯចំការចេកខ្ញុំនៅជើងភ្នំម្ខាង គឺថាចំការទាំងពីរនេះនៅជិតជើងភ្នំម្ខាងម្នាក់ ។ រាល់តែថ្ងៃអាទិត្យ ពេលព្រឹកម៉ោង៦កន្លះ ក្រុមមនុស្សនៅគ្រប់ទិសទីលើកោះត្រឡាច ត្រូវនាំរបស់របរគ្រប់យ៉ាង ដែលមាននៅកន្លែងរៀងខ្លួនយកមកប្រគល់ឱ្យក្រុមកណ្តាលមួយនៅទីក្រុងកោះត្រឡាច ដើម្បីវាយចំណែក ចែកចាយយកទៅគ្រប់ក្រុមទាំងអស់ ហើយគេត្រូវចែកមកឱ្យក្រុមខ្លួនវិញនូវអង្ករ សាច់គោ សាច់ជ្រូក មាន់ បន្លែ ជាដើម ។ បើនិយាយឱ្យខ្លីទៅគឺជារបៀបដូរគ្នាតែម្តង ។ ក្រុមកណ្តាលគេបប្រមូលរបស់ទាំងអស់ដែលគ្រប់ក្រុមនាំមកនោះ ចែកជាបីចំណែក ។ ទី១ចំណែក ដែលល្អៗសម្រាប់ឱ្យទៅអ្នករាជការជាតិបារាំង ទី២ចំណែកមធ្យមសម្រាប់អ្នករាជការជាតិយួន ជាតិខ្មែរ ទី៣ ចំណែកយ៉ាងអន់ សម្រាប់ចែកចាយមនុស្សទោសក្រុមឆ្ងាយជិត ។

ខ្ញុំសូមជម្រាបពីក្រុមខ្ញុំវិញ របស់ដែលត្រូវយកទៅឱ្យគេឯទីក្រុងទាំងប៉ុន្មានត្រូវរៀបចំឱ្យស្រេចពីល្ងាចថ្ងៃសៅរ៍ ។ លុះដល់ម៉ោងពារំលងអធ្រាត្រ គេវាយរគាំងដាស់ឱ្យភ្ញាក់នៅពេលម៉ោង



ពារំលងអធ្រាត្រ ដើម្បីនាំរបស់ទៅប្រគល់ឱ្យគេឯទីក្រុងកោះត្រឡាច ក្រោយដែលកាប៉ូរ៉ាល់ បានត្រួតគ្នាប្រមូលគ្នាគ្រប់សព្វហើយ ។ លុះឮសញ្ញាបង្គាប់ឱ្យដើរទៅមុខហើយ ពួកមនុស្សទោស ក៏នាំគ្នាលីបែងវត្ថុទាំងនោះដើរបន្តគ្នាទៅទាំងយប់ងងឹត ប៉ុន្តែគេបំភ្លឺផ្លូវដោយដុតខ្លួបដូង ដែលគេពុះផែកតូចៗប៉ុនចង្កឹះ ហាលឱ្យស្ងួតហើយចងជាបាច់តូចៗប៉ុនកដៃក្មេង របៀបដូចជាចន្លុះដូច្នោះឯង ។ ខ្លួបដូងនេះដុតស្រួលជាងចន្លុះ ដុតមិនសូវមានផ្សែង ហើយភ្លឺជាងចន្លុះទៀតផង ។ នៅពេលម៉ោងជាង៤ ដែលខ្ញុំនៅរង់ចាំក្រុមខ្ញុំនៅផ្ទះកាប៉ូរ៉ាល់ខាត់ ខ្ញុំក្រឡេកមើលទៅលើខ្នងភ្នំឃើញក្បួនភ្លើងគុបដើរ ភ្លើងបន្តគ្នាគួរឱ្យឡូមើលណាស់ ជាហេតុនាំឱ្យខ្ញុំនឹកឃើញកាលពីកុមារភាពនៅឡើយ ដែលបានមើលពិធីហែអ្នកតា និងពិធីហែបុណ្យកាទ័រស្វ៊ិយេត(១៤កក្កដា) របស់បារាំងដូច្នោះឯង ។

មនុស្សទោសគ្រប់ក្រុម ចំនួន១២០ឬ១៥០នាក់ដែលមកពីក្រុមផ្សេងៗមកជួបគ្នាលើខ្នងភ្នំហាក់ដូចជាបានណាត់គ្នាហើយដើរពេនចុះ ពេនឡើង តាមរបត់ផ្លូវ មើលពីក្រោមទៅល្អមើលណាស់ ។

ក្នុងក្រុមនីមួយៗមានមនុស្សទោសនៅធ្វើការ ខ្លះ២០០នាក់ខ្លះ៣០០នាក់ ឃើញតិចតែក្រុមខ្ញុំទេ ដែលមានមនុស្សតែ៤៣ឬ៤៥នាក់ប៉ុណ្ណោះ ។ ក្រុមឯទៀតៗសុទ្ធតែមានអ្នករាជការជានាយក្រុម២ឬ៣នាក់ ជួយត្រួតត្រាលើកាប៉ូរ៉ាល់ទៅទៀត ។ ចំណែកខាងក្រុមខ្ញុំដែលមានគ្នាតិចនោះ មានតែខ្ញុំម្នាក់ឯងជាកាប៉ូរ៉ាល់ឥតមានមេក្រុមជាអ្នករាជការទេ ។ ប៉ុន្តែមនុស្សដែលនាំអីវ៉ាន់ពីគ្រប់កន្លែងទៅមិនមែនទៅទាំងអស់គ្នាទេ គឺទៅតែល្មមនឹងចំនួនរបស់ដែលត្រូវលី សែង កាន់ទៅតែប៉ុណ្ណោះ ប៉ុន្តែលុះទៅជួបគ្នាលើភ្នំទៅ ក៏ទៅជាក្បួនវែងមួយ ។

ប្រហែលម៉ោង៥ភ្លឺ ក្បួនទាំងនោះចុះដល់ទីកន្លែងកាប៉ូរ៉ាល់ខាត់ ហើយឈប់សម្រាកនៅទីនោះប្រហែលកន្លះម៉ោង ។ ចំណែកខ្លួនខ្ញុំនៅរង់ចាំក្រុមខ្ញុំនៅផ្ទះបងខាត់ ក៏ទៅទទួលក្រុមខ្ញុំហើយនាំទាំងអស់គ្នាបន្តដំណើរទៅទីក្រុងកោះត្រឡាច ដើម្បីប្រគល់អីវ៉ាន់ទៅឱ្យមេក្រុមកណ្តាលដែលពានឃ្លាំងគេចាំទទួលវត្ថុផ្សេងៗ ដែលនាំមកពីគ្រប់ក្រុមនៅម៉ោង៦កន្លះ ។

នៅពេលជួបជុំគ្នានោះហើយដែលនាំឱ្យស្គាល់គ្នាសិទ្ធស្នាលរវាងកាប៉ូរ៉ាល់គ្រប់ក្រុមនៅជិត

ឆ្ងាយ ព្រមទាំងមនុស្សទោសគ្រប់ក្រុមផង បានសប្បាយរីករាយ,សួរសុខទុក្ខគ្នាទៅវិញ ទៅមកលុះប្រគល់រីវ៉ាន់ដែលគេត្រូវចែកឱ្យយកទៅវិញ ។ ពេលខ្លះនៅរហូតដល់ម៉ោង១០ឬ១១ ទម្រាំបានត្រឡប់ទៅវិញហើយដល់ម៉ោង២ឬ៣រសៀល ទើបបានទៅដល់ទីកន្លែងរៀងខ្លួន ។

មួយវិញទៀតនៅកន្លែងខ្ញុំ ក្នុងអំឡុងខែកញ្ញា នាយតម្រួតតែងនាំមនុស្សទោសចំនួន១០០ឬ១៥០នាក់ទៅកាប់អុសនៅនោះ ។ ទៅដល់កន្លែងខ្ញុំនៅយប់នៅឡើយប្រហែលជាម៉ោង៣ឬម៉ោង៤ជិតភ្លឺប៉ុណ្ណោះ ។ ពេលគេទៅដល់ម្តងៗគេតែងតែលួចរបស់របរគ្រប់មុខតាំងពីអង្ករបន្លែមាន់ជាដើម បើមិនប្រយ័ត្ន ពួកវាលួចអស់គ្មានសល់ ។

ក្នុងពេលដែលធ្វើដំណើរកាត់ចំការខ្ញុំនោះ ពេលនោះច្រើនតែនៅយប់នៅឡើយ ។ ពួកទាំងនោះពុំអាចមើលឃើញផ្លែចេកនៅត្រង់ណាទេ ម្ល៉ោះហើយគេលើកដៃទាំងពីរដាក់លើក្បាលហើយបម្រះម្រាមដៃបញ្ឈរឡើងទៅលើ ដើរមុខរះស្មានៗទៅតែ ម្តង ។ បើម្រាមដៃប៉ះទៅលើស្ពងចេកគេក៏ប្រញាប់ឈប់ភ្លាមកាច់ភ្លែត ទុំក៏ដោយខ្ចីក៏ដោយគេអាស្រ័យបានទាំងអស់ ។ នេះទម្លាប់របស់អ្នកទោសដែលគ្នាមានការស្រេកឃ្លាន ត្រូវតែប្រព្រឹត្តដូច្នោះ ។ ពួកមនុស្សទោសដែលគ្មានអត់ឃ្លានណាស់ ទៅ ចេកខ្ចី ល្ហុងខ្ចី ល្ពៅខ្ចី ត្រឡាច ប៉េងប៉ោះអ្វីៗ ចេះតែអាស្រ័យបានទាំងអស់ ។

ហេតុដូច្នេះហើយ បានជានៅពេលនោះ ខ្ញុំត្រូវតែប្រយ័ត្នមែនទែន ដោយចាត់គ្នាពី១២ទៅ១៥នាក់ឱ្យរាយគ្នាយាមតាមផ្លូវចំការនោះ ។ បើឃើញមនុស្សទោសបេះបោចផ្លែឈើអ្វី ត្រូវស្ទុះទៅចាប់ភ្លាម វាយនឹងរំពាត់ផ្តៅ២,៣រំពាត់ រួចនាំទៅឱ្យនាយតម្រួតនៃមនុស្សទោសនោះនាយតប្រួតនោះ វាយថែមទៀតមុខគួរឱ្យរាណិតអាសូរគ្នាណាស់ ប៉ុន្តែមិនដឹងធ្វើម៉េច បើយើងមានភារៈត្រូវតែការពាររបស់របរទាំងនេះឱ្យគង់ ។ បើយើងបណ្តែតបណ្តោយទៅប្រាកដជាអស់ទាំងចំការមិនខាន ជាហេតុនាំឱ្យមានទុក្ខទោសដល់ខ្លួនយើង គេនឹងវាយឬធ្វើទោសយើងតាមចិត្តគេ ។

ចំពោះអ្នកទោសនៅក្នុងក្រុមខ្ញុំវិញ ខ្ញុំមានចិត្តសន្តោសណាស់ ក្នុងរយៈ១០ឬ១៥ថ្ងៃខ្ញុំបានឱ្យពួកខ្ញុំនេះបេះផ្លែឈើក្នុងចំការទទួលទានគ្រប់ៗគ្នា ។ ខ្ញុំបានអប់រំមនុស្សទាំងនេះឱ្យមានចរិយា



ស្លូតសុភាព រួចខ្ញុំតែងប្រាប់ពួកនេះថា សូមឱ្យអ្នករាល់គ្នាទុកខ្ញុំដូចជាបងប្អូនទៅចុះ បើខ្ញុំធ្វើកាត់ខុសអ្វីសុំរំលឹកទៅចុះ ខ្ញុំពុំប្រកាន់ឬកថា ជាអ្នកត្រួតអ្វីទេ ។ យ៉ាងនេះហើយទើបពួកក្រុមខ្ញុំពេនការរាប់អាន ហើយស្មោះត្រង់នឹងខ្ញុំជាងក្រុមឯទៀតៗទាំងអស់នៅកោះត្រឡាច ។

កាលេពីកាប៉ូរ៉ាល់យួនមុនៗមនុស្សទោសក្រោមបង្គាប់វាមិនខ្លាចវាសម្លាប់កាប៉ូរ៉ាល់ក៏មាន វាប្រមាថមើលងាយក៏មាន ជាហេតុនាំឱ្យលំបាកធ្វើការណាស់ ។ តែនៅពេលដែលខ្ញុំមកកាន់ការវិញបានស្រួលរហូត ។

***

# -១៤-

# ពន្លឺសេរីភាព

ប្រិយមិត្តទាំងឡាយ តាមការកត់សម្គាល់របស់អស់លោកចំពោះវគ្គខាងក្រោយ នៃរឿងនេះ អស់លោកយល់ថារូបខ្ញុំនេះគឺជាមនុស្សម្នាក់ ដូចជាមនុស្សមានសេរីភាពធម្មតាឬឧបមាដូចជាបុគ្គលិករាជការដែលគេបញ្ជូនឱ្យទៅធ្វើការនៅកោះត្រឡាចដូច្នោះដែរ ។ ចំពោះឋានៈជាកាប៉ូរ៉ាល់អ្នកទោសហើយដែលបានសេចក្តីសុខ មានគេទទួលស្គាល់ដ៏ច្រើននេះកម្រគេធ្វើដូចណាស់នៅកោះត្រឡាច ។ ចំពោះជីវភាពដ៏សុខស្រួលនេះនាំឱ្យអស់លោកអ្នកយល់ថា ខ្លួនខ្ញុំបានសប្បាយចិត្តលែងគិតអ្វីទាំងអស់ហើយ គឺគិតតែខំធ្វើការឱ្យបានល្អ ឱ្យបានរាំងនៅកោះត្រឡាច ស្រឡាញ់តែប៉ុណ្ណោះហើយ ។

ប្រិយមិត្តទាំងឡាយ ពុំមែនយ៉ាងនោះទេ ! ដោយពិតឧត្តមគតិចិត្តគំនិតរបស់ខ្ញុំដែលកើត

មានឡើងយ៉ាងណា វានៅតែមានយ៉ាងនោះដដែល ។ បុព្វហេតុដែលនាំឱ្យខ្ញុំហែលឆ្លងសមុទ្រ ទុក្ខតាំងពីគុកភ្នំពេញ គុកព្រៃនគរ រហូតដល់មករស់នៅលើកោះត្រឡាច ដែលជាកោះមរណៈនេះ គឺមកតែអំពីឧត្តមគតិចិត្តគំនិតខ្ញុំដែលរួមធ្វើការបដិវត្តន៍នោះឯង ពោលគឺមកពីខ្ញុំចង់រំដោះមាតុភូមិយើង ឱ្យផុតពីអនិស្សរភាពរបស់បារាំងនេះឯង ។ បើដូច្នេះតើឱ្យខ្ញុំសប្បាយនឹងជីវភាពសុខស្រួលរបស់ខ្ញុំនេះម្ដេចនឹងកើត ? បើខ្ញុំមិនទាន់បានឃើញស្រុកខ្មែរយើងមានដំណើរទៅដល់ណាផងនោះ ។ ជាការពិតហើយ ជាក់ច្បាស់ យើងមានការតូចចិត្តហើយចងកំហឹងដ៏ក្រៃលែងចំពោះការដែលពួកបារាំង វាយកយើងមកប្រោសចោលកណ្ដាលសមុទ្រ បំបរបង់ឱ្យឆ្ងាយដាច់ស្រយាលពីមិត្តភក្តិបំណងឱ្យយើងភ្លេចឧត្តមគតិរបស់យើង ឬថាចង់ឱ្យយើងរាងចាលស្បថលែងចង់ធ្វើនយោបាយអស់មួយកំណើតតែម្ដងយ៉ាងនេះ ។ ដូច្នេះយើងគ្មានគំនិតឯណាស្មោះចំពោះបេអាណានិគមនោះឡើយ !

នៅក្នុងចិត្តខ្ញុំ ខ្ញុំតែងនឹកទន្ទឹងថា ចាំមើលតែលទ្ធផលនៃសង្គ្រាមលោកលើកទី២ ដែលកំពុងឆេះសន្ធោសន្ធៅស្ទើរពេញអាស៊ីនេះ ។ ខ្ញុំយល់ថា បើជប៉ុនឈ្នះបារាំងនោះប្រហែលជាខ្ញុំមានវាសនាខ្លះបានត្រឡប់ទៅស្រុកវិញមុនកាលកំណត់នៃសាលក្រមព្រៃនគរ ដែលសម្រេចថា «គុក៥ឆ្នាំធ្វើការដោយបង្ខំនិងនិរទេស១៥ឆ្នាំមិនឱ្យចូលស្រុកខ្មែរ»នោះមិនខាន ។ ផ្ទុយទៅវិញបើជប៉ុនចាញ់បារាំង បារាំងនៅតែជាអាណាព្យាបាលលើសមាគតរដ្ឋឥណ្ឌូចិននោះ ខ្ញុំអស់បានត្រឡប់ទៅស្រុកវិញមុនកាលកំណត់របស់សាលក្រមព្រៃនគរហើយ ។ ខ្ញុំនឹងនៅតែជាអ្នកទោសជាងពីរឆ្នាំទៅមុខទៀត ហើយនឹងត្រូវនៅក្រៅស្រុកជាង១២ឆ្នាំតទៅមុខទៀតឯណោះ ដែលជាថិរៈវេលាមួយវែងឆ្ងាយណាស់[(១)] ។ បើសម្លឹងតាមវេលានេះឃើញថា ខ្ញុំដូចជាគ្មានសង្ឃឹមថា បានត្រឡប់ទៅស្រុកវិញ បន្តសកម្មភាពនយោបាយស្រុកទេសជាមួយនិងវរជនខ្មែរឯទៀតបានឡើយ ។

ប៉ុន្តែធម្មជាតិយើងជាអ្នកនយោបាយ យើងមិនត្រូវអស់សង្ឃឹមទេ ! ខ្ញុំចេះតែមានសង្ឃឹមថា ថ្ងៃណាមួយ ឆ្នាំណាមួយគង់តែខ្ញុំបានរួចខ្លួន បានទៅប្រាកដខ្លួនលើទឹកដីខ្មែរវិញពុំខានទេ ហើយខ្ញុំនឹងបានបន្តសកម្មភាពខ្ញុំរួមជាមួយនឹងវរជនឯទៀតៗក្នុងការទាមទារសិទ្ធិសេរីភាព

១_នេះបើគិតពីជាប់ទោសពីឆ្នាំ១៩៤២ ដល់ឆ្នាំ១៩៥៥



ខ្មែរមកអំពីជនបរទេសនោះ ពុះត្រាតែបានសម្រេចពុំខានសោះឡើយ ។

ខ្ញុំបានរស់នៅនឹងតំបន់ដីកយុក នៃកោះត្រឡាចនោះដោយចេះតែទន្ទឹងចាំស្ដាប់ការវិវត្តន៍នៃសង្គ្រាមខ្លះដែរ ។ ស្រាប់តែចូលមកដល់ចុងឆ្នាំ១៩៤៤ ការប្រែប្រួលប្ដូរផ្លាស់ក៏កើតមានឡើងពិតមែន ។ ជប៉ុនបានឈ្នះបារាំងនៅឥណ្ឌូចិន ។ ហើយទីកោះត្រឡាចទាំងមូលជនជាតិបារាំង ត្រូវកងទ័ពជប៉ុនឡើងមកដកអាវុធចេញអស់ ។ បារាំងត្រូវអស់អំណាចត្រឹមណោះ ។ ប៉ុន្តែមិនជាយូរប៉ុន្មាន ដល់បកខែកុម្ភៈ១៩៤៥ កងទ័ពសម្ព័ន្ធមិត្ត(អាមេរិកាំង)បានជួយបារាំងឡើងវិញ ។ នៅថ្ងៃទី៨កុម្ភៈ១៩៤៥ ទីកោះត្រឡាចបានត្រូវរងគ្រាប់បែកពីសំណាក់ទ័ពសម្ព័ន្ធមិត្តយ៉ាងកោលាហល(១)។ ក្រោយការទម្លាក់គ្រាប់បែកនេះ ចំនួនប្រមាណជាមួយអាទិត្យស្រាប់តែមានទាហានជប៉ុនមួយក្រុមបាននាំទូរលេខមួយច្បាប់មកពីភ្នំពេញ ឱ្យនាំអ្នកទោសនយោបាយបួនរូបគឺលោកអាចារ្យហែម ចៀវ ,លោកនួន ឌួង ,លោកប៉ាច ឈឿន និងខ្លួនខ្ញុំប៊ុណ្ណចន្ទ ម៉ុលត្រឡប់ទៅភ្នំពេញវិញ ។

ដោយលោកអាចារ្យហែម ចៀវ បានទទួលមរណភាពបាត់ទៅហើយនោះ ទើបគេប្រមូលបានតែបីនាក់គឺលោកនួន ឌួង លោកប៉ាច ឈឿន និងខ្លួនខ្ញុំប៉ុណ្ណោះ ។

នៅព្រលប់ម៉ោងប្រហែលជាង១៨ គេនាំពួកយើងខ្ញុំចុះទៅក្នុងនាវាមួយ ។ នាវានោះជានាវាពិឃាតប្រដេញយ៉ាងលឿនរបស់ជប៉ុននៅសម័យសង្គ្រាមលោកលើកទី២ ។ អ្នកចុះកប៉ាល់នេះក្រោយខ្ញុំទៀត គឺកងទាហានខ្មែរកម្ពុជាក្រោមយើងចំនួន១០០នាក់ ព្រមទាំងប្រពន្ធកូនរញ៉េចរញ៉ាចផង ដែលត្រូវជប៉ុនជួយនាំជូនត្រឡប់ទៅក្រុងព្រៃនគរវិញ ។ ទាហានទាំងនោះគឺបារាំងយកមកប្រើការនៅលើកោះត្រឡាចនេះ ។

លុះដាក់មនុស្សគ្រប់ហើយ ១០នាទីក្រោយមកនាវានេះក៏ស្រាវយុថ្កាថយចេញពីកោះត្រឡាចមួយរំពេច ។

កោះត្រឡាច ! កោះទារុណកម្ម ! កោះឧក្រិដ្ឋ ! កោះមរណៈតែជាកោះផ្ដល់ឱ្យខ្ញុំនូវ

១_ឯក្រុងភ្នំពេញនោះក៏ត្រូវរងគ្រាប់បែកនៅថ្ងៃជាមួយគ្នានេះដែរ

អនុស្សាវរីយ៍ក្បៀចក្សាន្តជាចុងក្រោយ ! ខ្ញុំបានឃ្លាតឆ្ងាយហើយ ! ខ្ញុំលើកដៃឡើងគ្រវីលាកោះនោះ...ទាំងស្រណោះ...ហើយស្រណោះសោកស្ដាយចំពោះរូបលោកអាចារ្យហែប ចៀវ ដែលលោកចែកឋានទៅហើយ ផ្នូរលោកលេខ១១៣នៅលើកោះនេះ...ស្ដាយណាស់ យើងពុំបានទៅលា លោក ! ស្ដាយណាស់ ! លោកពុំបានមកជាមួយយើង !

កោះត្រឡាច សូមអ្នកជួយថែរក្សាឆ្អឹងវីរជននេះឱ្យយើងផង ថ្ងៃណាយើងសម្រេចជោគ-ជោគជ័យយើងនឹងត្រឡប់មកសុំឆ្អឹងនេះអំពីអ្នកហើយយើងនឹងររគុណអ្នក !

នេះជាមនោវាចារបស់ខ្ញុំ ដែលរសាត់តាមខ្យល់ឆ្ពោះទៅកាន់កោះត្រឡាច ដែលលិចបន្តិចម្ដងៗទៅក្នុងផ្ទៃអន្ធការ ។ ខ្ញុំមើលកោះលែងយល់ព្រោះឆ្ងាយព្រោះយប់ ។

ពេលនោះ គេនាំយើងខ្ញុំចូលទៅក្នុងបន្ទប់មួយ ដែលមានទាហានជប៉ុនពីរបីនាក់នៅនោះផង ។ គេរាប់រកយើងខ្ញុំដោយរាក់ទាក់ណាស់ ។ ក្រោយមកទើបគេមានរៀបអាហារឱ្យយើងខ្ញុំព្រមទាំងលោកសក្តិ៥ជាមេបញ្ជាការនៃនាវានេះ អាស្រ័យរួមនិងទាហានជាន់ខ្ពស់ឯទៀត ។

ក្រោយពេលបាយខ្ញុំបានចេញឡើងមកលើនាវា មើលទេសភាពសមុទ្រ ប៉ុន្តែមើលគ្មានឃើញអ្វីទេ ងងឹតសូន្យសុងតែម្ដងហើយគេហាមមិនឱ្យអុជភ្លើងបំភ្លឺសោះឡើយ ខ្លាចកប៉ាល់ហោះពួកសម្ព័ន្ធមិត្តឃើញ ។

នៅគ្រានោះ រលកសមុទ្រធំៗអស្ចារ្យ លើកគ្រលែងយោលយោកនាវាទៅឆ្វេង ទៅស្ដាំឡើងលើចុះក្រោមមួយៗ រង្វើលៗ ដូចគេគ្រលែងប្រមាត់ថ្លើមអ្នកជិះឱ្យរកើ ! គួរឱ្យអាសូរពួកប្រពន្ធនិងកូនតូចៗរបស់ទាហានកម្ពុជាក្រោមណាស់ ដែលគេឱ្យអង្គុយនៅកន្សែនាវា ។ ពួកនេះត្រូវពុលរលកក្អួតចង្អោរច្របល់ខ្យល់ចាប់រកើ គ្មានដំបូលការពារត្រូវទឹករលក ដែលប៉ះកប៉ាល់នោះសាចបាចចូលបកទៀត...ក្មេងតូចៗក៏យំរងេ៉ករង៉ាកឡើងគួរឱ្យវេទនាក្រៃលែង ។ ម្ដាយចេះតែខំទ្រាំក្រាបត្រកងកូនទៅទ្រាំទម្រាំតែបានដល់ស្រុកទេសវិញ ។ ខ្ញុំឃើញដូច្នេះនឹកអាណិតខ្លោចចិត្តប៉ុន្តែមិនដឹងជានឹងជួយដូចម្ដេច ។



ខ្ញុំបានចុះចូលទៅក្នុងនាវាវិញព្រោះទ្រាំឈរតទៅទៀតពុំបានដែរ ។ ខ្ញុំបានចូលទៅក្នុងបន្ទប់ដែលគេរៀបចំទុកឱ្យស្រេច ។ ខ្ញុំឃើញលោកនួន ឌួង និងលោកប៉ាច ឈឿន កំពុងពុលរលកក្រាបជ្រៅហិតជ្រហម ឃើញក្រុមនាវាឱ្យថ្នាំលេបការពារកុំឱ្យពុលខ្លាំងពេក ។ ឯខ្ញុំទៅដល់កន្លែងកើបមួយម៉ោងក្រោយមកក៏តាំងរង៉ាប់រង្វើលមុខបែកញើសពេញខ្លួនចង់ក្អួតបន្តិច ចង់បត់ជើងបន្តិចលំបាកក្នុងខ្លួនជាខ្លាំង ខំបិទភ្នែកទៅ តែនៅតែវិលដដែល រួចមិនយូរប៉ុន្មានខ្ញុំក៏តាំងក្អួតចង្អោរក់ៗ,បកដែរ ។ អស់កំអួតហើយ ទើបសម្ងំដេកទៅទាំងយោលខ្លួន ។

ប្រហែលជាម៉ោង៥ភ្លឺ ខ្ញុំភ្ញាក់ពីពុលរលក ខ្ញុំខំក្រោកដើរចេញពីបន្ទប់ឡើងទៅលើនាវា ។ ពេលភ្លឺនោះខ្ញុំមើលទៅកន្សែនាវាដែលមានប្រពន្ធទាហាននៅនោះ ឃើញសុទ្ធតែកំអួត និងលាមកក្មេងពាសពេញទាំងរបស់ ដែលកាលពីយប់នោះគ្នាពុលរលកច្រងាប់ច្រងិលនោះឯង ពួកនេះគ្នាលំបាកវេទនាជាងខ្ញុំណាស់ទៅទៀត ។

ក្រោយនោះកប៉ាល់ក៏បានទៅដល់កាប់សាំងហ្សាក់[១] នៅកំពង់ផែនោះ ខ្ញុំឃើញអ្វីនោះដូចជាសសរធំៗ មូលៗ គេយកទៅបោះត្រៀបនៅត្រាំក្នុងទឹក... លុះចូលទៅជិតទើបដឹងថា : ឱជាបំពង់ភ្លើងកប៉ាល់ដែលលិចទៅទេតើ ! កប៉ាល់ទាំងនោះត្រូវលិចដោយសារការទម្លាក់គ្រាប់បែករបស់ពួកសម្ព័ន្ធមិត្ត ។ កប៉ាល់លិចនោះ មានចំនួន២០គ្រឿង ។

យើងហួសពីនេះទៅទៀត ក៏ទៅដល់ព្រែកមួយដែលជាច្រកចូលទៅកាន់ក្រុងព្រៃនគរ ។ កប៉ាល់នេះបានចតស្រួលហើយប្រហែលជិតកន្លះម៉ោង ទើបឃើញទាហានជប៉ុនម្នាក់ចុះមកអញ្ជើញពួកយើងទាំងបីនាក់ ។ គេនាំយើងចុះពីនាវាហើយនាំឡើងទៅជិះរថយន្តតូចមួយឆ្ពោះទៅកាន់កន្លែងមួយនៅក្រុងព្រៃនគរ ។ ទីនោះជាកន្លែងរាជការជប៉ុនរៀបចំឱ្យពួកមេនយោបាយធំៗរបស់យួនមានពួកកៅដាយ ,វ៉ាហាវ ,ប៊ីនស្វៀងជាដើមនៅទីនោះ ។

នៅឱកាសនោះហើយ ដែលនាំឱ្យខ្ញុំបានស្គាល់ក្រុមមេកៅដាយវ៉ាហាវ ប៊ីនស្វៀង ។

១- Cap Saint Jaque ជាកំពង់ផែធំមួយរបស់យួនព្រៃនគរ ។

ចំណែកពួកយើង គេយកទៅផ្ញើឱ្យនៅនឹងក្រុមកៅដាយដែលជាក្រុមធំជាងគេនៅទីនោះ ។ ក្រុមកៅដាយបានរៀបចំទទួលក្រុមខ្ញុំដោយរាក់ទាក់។ តែពួកកៅដាយទទួលទានម្ហូបប្លួស(ម្ហូបគ្មានសាច់ខ្លាញ់)ទាំងអស់គ្នា[១] ។

ខ្ញុំហោកនួន ខួងលោកប៉ាច ឈឺន នៅទីនោះបាន១៤ថ្ងៃ ទើបបានជប៉ុនគេមកអញ្ជើញឱ្យឡើងរថយន្តមួយដែលជារថយន្តដឹកកងទ័ព ។ ពេលម៉ោង៩ព្រឹកយើងទាំងបីនាក់ក៏បានធ្វើដំណើរតាមឡានទាហានចាកចេញពីទីក្រុងព្រៃនគរឆ្ពោះមកប្រទេសកម្ពុជា !

នៅលើឡានខ្ញុំដឹងថា ទឹកមុខខ្ញុំឡើងថ្លាពព្រាយ...ថ្លាព្រោះនឹងបានមកប្រាកដស្រមោលលើមាតុប្រទេសជាទីស្នេហា ដែលខ្ញុំព្រាត់ប្រាស់ទៅជិត៤ឆ្នាំ ហើយដែលញាតិមិត្តគ្រប់គ្នាគ្មាននឹកស្មានថា ខ្ញុំអាចនឹងរស់រួចមកវិញទេ ! ថ្លាព្រោះខ្ញុំមានសង្ឃឹមជាថ្មីថា ខ្ញុំអាចបន្តសកម្មភាពនយោបាយរបស់ខ្ញុំបានតទៅទៀតហើយ !

មកដល់កំពងចម្លងអ្នកលឿង ក៏បានជួបនឹងលោកអាចារ្យប៉ាង ខាត់ ជុំ ម្ទូង ព្រមទាំងមិត្ត-ភក្តិទៀត ។ យើងទាំងអស់គ្នាឱបរឹតគ្នាដោយសេចក្តីត្រេកអរជាភិយោភាព ! តើមានពាក្យអ្វីថ្លែងឱ្យចំបាន រំពឹមនោសញ្ចេតនាសប្បាយរីករាយដោយសារបានជួបគ្នានេះ ? គ្មានឡើយ ! យើងសប្បាយណាស់រកពាក្យថ្លែងពុំបាន !

ក្រោយដែលបានសាសងសំណោះសំណាលគ្នាចប់សព្វគ្រប់ហើយនោះ មិត្តយើងគេឱ្យយើងបន្តដំណើរមកភ្នំពេញចុះ គេទាំងនោះបន្តដំណើរទៅកាន់ខេត្តព្រៃវែង និងស្វាយរៀងតទៅទៀតជួយឃោសនាជាមួយទ័ពជប៉ុនដើម្បីដឹកនាំប្រជាពលរដ្ឋនៅតំបន់នោះ ។

១-ពួកក្រុមកៅដាយ,វ៉ាហោវ,ប៊ីនស្វៀង ជាក្រុមសាសនានាំបំបះបំបោររំដោះពីនឹមបារាំង ។ ពួកនេះគេរៃប្រាក់ពីពួកគ្នាគេដើទិញអាវុធតស៊ូនឹងបារាំង ។ ខ្ញុំបានឃើញក្រុមនេះយួរប្រាក់ទាំង[illegible]ជូនមេក្រុមគេរាល់វេលា ។ គេមានគណៈកម្មការគេអង្គុយរាប់ប្រាក់ច្រើនគ្នា ពួកក្រុមគេប្រមូលបានប្រាក់ច្រើនហោនរៀលបានច្រើនជាងគេគឺពួកកៅដាយនេះតែម្តង ។



យើងខ្ញុំទាំងបីនាក់ ក៏ធ្វើដំណើរឆ្ពោះមកកាន់ក្រុងភ្នំពេញតមកទៀត ដែលបានមកដល់នៅវេលាម៉ោង១២(ថ្ងៃត្រង់)ដោយសុវត្ថិភាព ។

បិតាខ្ញុំ បងប្អូនខ្ញុំ[១] បានចោមរោមព្រោងព្រាត ញញឹមលាយនឹងទឹកភ្នែក ដោយសប្បាយពេកចំពោះវត្តមានរបស់ខ្ញុំដែលគេពិបាកនឹងសង្ឃឹម ។

អស់លោកជាមិត្តមេត្រីទាំងឡាយ ជីវភាពខ្ញុំនៅគុកភ្នំពេញ នៅគុកព្រៃនគរ នៅកោះត្រឡាច បានចប់ហើយ ។ ខ្ញុំមានសេរីភាពវិញហើយ ! ប៉ុន្តែគ្រាន់តែជាពន្លឺតូចប៉ុណ្ណោះទេ ពុំមែនជាសេរីភាពមែនទែនទេ ! ពីព្រោះប្រទេសយើងពេលនោះ ពុំទាន់បានឯករាជ្យនៅឡើយ ។ សេរីភាពនៃប្រជាជន ដែលរស់នៅក្នុងប្រទេសដែលកញ្ជះគេមានគេត្រួតត្រានោះ ពុំមែនជាសេរីភាពពិតប្រាកដទេ ។ យើងត្រូវតែត្រេចរកសេរីភាពប្រជាធិបតេយ្យនេះឱ្យបានពិតប្រាកដជាក់ស្តែង ។

នៅក្នុងឆ្នាំ១៩៤៦ ខ្ញុំក៏បានធ្វើជាក្រុមខ្មែរឥស្សរៈនៅក្នុងតំបន់ខេត្តបាត់ដំបងរហូតមក ។ លុះឆ្នាំ១៩៥១ ខ្ញុំក៏បានស្ម័គ្រធ្វើតំណាងរាស្ត្រនៅរដ្ឋសភា **ប៉ុន្តែអកុសលណាស់ រដ្ឋសភានោះត្រូវស្តេចសីហនុរំលាយទៅនៅថ្ងៃ១៣-០១-៥៣ ហើយខ្លួនខ្ញុំក៏ត្រូវគេចាប់ដាក់គុកអស់ពេល៨ខែ ២០ ថ្ងៃថែមទៀតជាមួយពួកមិត្ត ។**

**គិតទៅឈ្មោះខ្ញុំ(ប៊ុណ្ណចន្ទ ម៉ុល) និងគុកនយោបាយនោះដូចជាមិនចេះចប់សោះ ។**

**ប៉ុន្តែខ្ញុំសូមបញ្ចប់រឿងគុកនយោបាយនេះត្រឹមរឿងខ្ញុំបានចូលមកស្រុកខ្មែរទៅចុះ ដើម្បីកុំឱ្យអស់លោកអ្នកជាមិត្តធុញទ្រាន់ព្រោះវែងពេក ។**

**ហើយបើមិត្តចូលចិត្តរឿងខ្ញុំចាប់ពីខ្ញុំធ្វើឥស្សរៈបដិវត្តន៍ ដេញបាញ់បារាំងយ៉ាងណាៗទៅទៀតនោះ ចាំខ្ញុំឆ្លៀតពេលសរសេរជូននូវសៀវភៅមួយទៀត ។**

**១-សូមជម្រាបថា ម្តាយខ្ញុំទទួលអនិច្ចកម្មតាំងពីថ្ងៃ ១៤ កក្កដា ១៩៥០ ម្ល៉េះ ។**

ទីបញ្ចប់នេះ ខ្ញុំសូមអរគុណអស់លោកប្រិយមិត្តទាំងឡាយ ដែលបានអានរឿងគុកនយោ-បាយនេះ ។

ហើយខ្ញុំសូមឧទ្ទិសជាអវសានថា សូមឱ្យចិត្តគំនិតកូនខ្មែរមានការចម្រើនល្វតហេស់ភ្ញាក់រលើក ស្រឡាញ់ទឹកដីខ្មែរ ពូជពង្សខ្មែរ ប្រពៃណីខ្មែរគ្រប់កាលគ្រប់វេលា !

សូមទឹកដីខ្មែរ នៅតែជាកេរ្តិ៍ដំណែលរបស់ខ្មែរហើយរីកចម្រើនទៅអនាគតជានិច្ច !

# ចប់

---

## អំណរគុណ

*អ្នកនិពន្ធសូមសម្តែងអំណរគុណដ៏ស្មោះចំពោះអ្នកនិពន្ធគុយ ឡុតដែលបានខិតខំយ៉ាងពេញទំហឹងក្នុងការជួយរៀបចំបោះពុម្ពផ្សាយសៀវភៅនេះ លុះត្រាតែបានសម្រេច ។*

*ការខិតខំនេះគឺពិតជាបានជួយសម្រាលបន្ទុករបស់អ្នកនិពន្ធ ដែលកំពុងមានភារកិច្ចរវល់មមាញឹកក្រៃលែង ក្នុងកិច្ចការប្រទេសជាតិសព្វថ្ងៃនេះ ។*

ភ្នំពេញ,ថ្ងៃទី១ មីនា ១៩៧១

**ប៊ុណ្ណចំនួ ម៉ុល**

រូបថតកាលនៅគុកធំភ្នំពេញ
ថតនៅមន្ទីរក្រុមព្រះនគរបាល(ថ្ងៃទី៦ សីហា ១៩៤២)

បោះពុម្ពលើកទី១ ចំនួន៣.០០០ក្បាល

តម្កល់ទុកតាមលេខ១២៥

ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៧១